ឯកសារតាមវិស័យ និង បញ្ហានានា របស់ NGO ស្តីពីការកាត់បន្ថយភាពក្រីក្រ និង កិច្ចអភិវឌ្ឍន៍ ក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៣

ចេញផ្សាយដោយ វេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពី កម្ពុជា ខែ មិនា ឆ្នាំ ២០០៤

ពត៌មាន និង ការសំដែងទស្សនៈនៅក្នុងឯកសារនេះឆ្លុះបញ្ចាំងជំហររបស់អ្នកនិពន្ធនីមួយៗតាមវិស័យ ឬ ជំហររបស់អ្នកនិពន្ធឯកសារស្តីពីបញ្ហានានា។ ខ្លឹមសារនៅក្នុងឯកសារនេះអាចត្រូវបានដកស្រង់ និងបោះពុម្ពផ្សាយជាថ្មីសំរាប់គោលបំណងអភិវឌ្ឍន៍ ប៉ុន្តែយើងស្វាគមចំពោះការសំដែងមតិរបស់អ្នកនិពន្ធចំពោះអត្ថបទតាមវិស័យ ឬ អ្នកនិពន្ធឯកសារស្តីពីបញ្ហានេះ។

មាតិកា

អារម្ភកថា iv
សេចក្តីថ្លែងអំណរគុណ vi
បញ្ជីអ្នកចូលរួមឧបត្ថម្ភ vii
កសិកម្ម និងអភិវឌ្ឍន៍ជនបទ ១
សិទ្ធិកុមារ ៦
វិមជ្ឈការ ១៣
ពិការភាព និងការស្តារពលកម្ម ១៨
ការគ្រប់គ្រងគ្រោះមហន្តរាយ ២៤
វិស័យអប់រំ ៣១
កំណែទំរង់ការបោះឆ្នោត ៤១
វិស័យជលផល ៤៩
វិស័យព្រៃឈើ ៥៩
យែនឌ័រនៅក្នុងការកាត់បន្ថយភាពក្រីក្រ ៦៥
អភិបាលកិច្ច និងតម្លាភាព ៧៣
វិស័យសុខាភិបាល ៨០
ជនជាតិដើមភាគតិច ៨៨
តំបន់ឧស្សាហកម្ម ៩៦
កំណែទំរង់ដីធ្លី ១០០
ការរុះរើតាំងទីលំនៅសារជាថ្មី ១០៤
នីតិរដ្ឋ ១០៨
អាវុធធុនតូច និង អសន្តិសុខ ១១២
វិស័យទេសចរណ៍ ១១៩
នយោបាយពាណិជ្ជកម្ម ១២៦

អារម្ភកថា

ក្នុងការបោះពុម្ពផ្សាយនេះ អង្គការក្រៅរដ្ឋាភិបាល ដែលកំពុងប្រតិបត្តិការនៅកម្ពុជា បានផ្តល់នូវសេចក្តីសង្កេត និងផ្តល់អនុសាសន៍ជាច្រើន ស្តីពីបញ្ហាសំខាន់ៗជុំវិញកិច្ចអភិវឌ្ឍនៅកម្ពុជា ដោយឆ្លុះបញ្ចាំងនូវការរីកចំរើន នៅក្នុងឆ្នាំ ២០០៣។

សហគមន៍អង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជា ស្វាគមន៍ការបញ្ចូលសហគមន៍ខ្លួន ទៅក្នុងដំណើរនៃការរួមចំណែក ចំពោះនយោបាយអភិវឌ្ឍន៍ និងក្នុងការវាយតំលៃការរីកចំរើន។ សហគមន៍នៃអង្គការក្រៅរដ្ឋាភិបាល ប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការចូលរួមក្នុងដំណើរការនេះ ប្រកបដោយលក្ខណៈវិជ្ជមាន ដោយរួមចំណែកផ្តល់នូវវិភាគទានចំពោះពលរដ្ឋក្រីក្រ និងវិភាគទានផ្តោតលើបទពិសោធន៍ ក្នុងការពិភាក្សាដេញដោល ជុំវិញការកាត់បន្ថយភាពក្រីក្រ ព្រមទាំងតាមរយៈសកម្មភាពកាត់បន្ថយភាពក្រីក្ររបស់ខ្លួន។

អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ ដែលជាស្ថាប័នអភិវឌ្ឍន៍ អាចរួមចំណែកយ៉ាងច្រើន ចំពោះផែនការកាត់បន្ថយភាពក្រីក្រ តាមរយៈការចែករំលែកនូវការសង្កេតពិនិត្យ និងចែករំលែកសេចក្តីសន្និដ្ឋាននានា ដែលទទួលបានពីបទពិសោធន៍ក្នុងកិច្ចអភិវឌ្ឍន៍របស់ខ្លួន។ ក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន អង្គការក្រៅរដ្ឋាភិបាល ធ្វើការយ៉ាងជិតស្និទ្ធជាមួយពលរដ្ឋក្រីក្រ និងធ្វើការជាមួយក្រុមជនងាយរងគ្រោះ ហេតុនេះ អង្គការក្រៅរដ្ឋាភិបាល មានតួនាទីដ៏សមស្របបំផុត ក្នុងការលើកយកនូវសេចក្តីត្រូវការរបស់ក្រុមទាំងនេះ មកជំរាបជូនអ្នកធ្វើសេចក្តីសំរេចចិត្ត។

អង្គការក្រៅរដ្ឋាភិបាល បានចាប់ផ្តើមប្រតិបត្តិការនៅកម្ពុជា ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម នៅក្នុងឆ្នាំ ១៩៧៩។ បន្ទាប់ពីមានការបន្តផ្តល់ជំនួយអភិវឌ្ឍន៍ពីលោកខាងលិច នៅឆ្នាំ ១៩៩២ មក អង្គការក្រៅរដ្ឋាភិបាល បានរួមចំណែកយ៉ាងសកម្មដល់កិច្ចប្រជុំរបស់គណៈកម្មាធិការអន្តរជាតិសំរាប់ការកសាងប្រទេសកម្ពុជាឡើងវិញ (ICORC), ដែលត្រូវបានរៀបចំឡើងនៅរៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៥។ ចាប់តាំង ពីឆ្នាំ ១៩៩៦ មក អង្គការមិនមែនរដ្ឋាភិបាល បានចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមពិគ្រោះយោបល់ និងបានបង្ហាញ នូវសេចក្តីថ្លែងការណ៍ពីស្ថានស្តីពីបញ្ហា និងអនុសាសន៍នានារបស់អង្គការក្រៅរដ្ឋាភិបាល សំរាប់កិច្ចអភិវឌ្ឍនៅកម្ពុជា ជារៀងរាល់ឆ្នាំ ផងដែរ។ នៅឆ្នាំ ២០០៣ កន្លងមកនេះ កិច្ចប្រជុំក្រុមពិគ្រោះយោបល់ មិនត្រូវបានរៀបចំឡើយ ដោយសារការជាប់រវល់ជាមួយនឹងការរៀបចំការបោះឆ្នោតសកល។ *ឯកសារតាមវិស័យ និង បញ្ហានានារបស់ NGO ស្តីពីការកាត់បន្ថយភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍* អាចរួមចំណែកដល់កិច្ចប្រជុំក្រុមពិគ្រោះយោបល់នៅលើកក្រោយ ដែលគេរំពឹងថានឹងប្រព្រឹត្តទៅនៅឆ្នាំ ២០០៤ បន្ទាប់ពីការបង្កើតរដ្ឋាភិបាលថ្មី។

អង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជា សង្ឃឹមថាការបោះពុម្ពផ្សាយនេះ អាចនឹងនាំទៅរកការជជែកដេញដោល និង ជាឯកសារយោងមួយដ៏សំខាន់ សំរាប់អង្គការក្រៅរដ្ឋាភិបាល រដ្ឋាភិបាល ម្ចាស់ជំនួយ អ្នកជំនាញការ និងទីភ្នាក់ងារអភិវឌ្ឍន៍នានា ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

សេចក្តីថ្លែងអំណរគុណ

ឯកសារតាមវិស័យ និង ឯកសារស្តីពីបញ្ហានានា របស់អង្គការក្រៅរដ្ឋាភិបាល ត្រូវបានរៀបចំឡើងតាមរយៈកិច្ចខំប្រឹងប្រែងដោយស្ម័គ្រចិត្ត របស់អង្គការក្រៅរដ្ឋាភិបាលជាច្រើន ទាំងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដោយផ្អែកលើបទពិសោធន៍របស់ពួកគេ ក្នុងកិច្ចការអភិវឌ្ឍន៍នៅកម្ពុជា។ អង្គការក្រៅរដ្ឋាភិបាល ឬក្រុមអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ដែលបានដឹកនាំការរៀបចំឯកសារតាមផ្នែកនីមួយៗ ត្រូវបានរៀបរាប់ឈ្មោះក្នុងបញ្ជី " អ្នកផ្តល់វិភាគទាន " នៅក្នុងទំព័របន្ទាប់។ ចំណែកឯវេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា ជាអ្នកសំរបសំរួលក្នុងការកែសំរួល។ វេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលបានរួមវិភាគទានចំពោះការបោះពុម្ពផ្សាយឯកសារនេះ។

តារាងឈ្មោះអ្នកឧបត្ថម្ភ

ឯកសារតាមវិស័យ	អ្នករួមវិភាគទាន
កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ	មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
សិទ្ធិកុមារ	គណៈកម្មការអង្គការក្រៅរដ្ឋាភិបាលស្តីពីសិទ្ធិកុមារ
វិមជ្ឈការ	គំរោងទ្រទ្រង់ក្រុមប្រឹក្សាឃុំ-សង្កាត់ (CCSP)
ពិការភាព និងការស្តារលទ្ធភាពពលកម្ម	ក្រុមប្រឹក្សាសកម្មភាពពិការភាព (DAC)
ការគ្រប់គ្រងគ្រោះមហន្តរាយ	បណ្តាញទទួលខុសត្រូវផ្នែកមនុស្សធម៌នៅកម្ពុជា
វិស័យអប់រំ	ដៃគូអប់រំអង្គការក្រៅរដ្ឋាភិបាល និង EDUCAM
កំណែទំរង់ការបោះឆ្នោត	ក្រុមតាមវិស័យនៃការបោះឆ្នោត/ COMFREL
ជលផល	ក្រុមសម្ព័ន្ធសកម្មភាពជលផល (FACT)
ព្រៃឈើ	គំរោងបណ្តាញព្រៃឈើនៃវេទិកាអង្គការក្រៅរដ្ឋាភិបាល
យ៉េនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ	បណ្តាញយ៉េនឌ័រ និងការអភិវឌ្ឍន៍ និងវេទិកាស្តីពីយែនឌ័រនៃវេទិកាអង្គការក្រៅរដ្ឋាភិបាល
អភិបាលកិច្ច និង តម្លាភាព	មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម
សុខាភិបាល	មេឌីខាំ (MEDICAM)
កិច្ចការជនជាតិភាគតិច	វេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា, គំរោងផលិតផលព្រៃឈើក្រៅពីឈើ (NTFP) , សុខភាពគ្មានព្រំដែនប្រចាំនៅរតនគីរី, CARE ប្រចាំនៅរតនគីរី
តំបន់ឧស្សាហកម្ម	STAR កម្ពុជា
កំណែទំរងដីធ្លី	អុក្សហ្វាមអង់គ្លេស
ការតាំងទីលំនៅសារជាថ្មី	បណ្តាញសកម្មភាពនៃការតាំងទីលំនៅសារជាថ្មី
នីតិរដ្ឋ	គណៈកម្មការសកម្មភាពសិទ្ធិមនុស្សកម្ពុជា (CHRAC)
អាវុធធុនតូច និង អសន្តិសុខ	ក្រុមការងារស្តីពីការកាត់បន្ថយអាវុធ
វិស័យទេសចរណ៍	ទស្សនៈពិភពលោក

គោលនយោបាយពាណិជ្ជកម្ម...អុកស្វហ្វាមអង់គ្លេស, របៀបវារៈ Womyns សំរាប់ធ្វើអោយមានការផ្លាស់ប្តូរ

កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ

(i) សេចក្តីផ្តើម

នៅប្រទេសកម្ពុជា កសិកម្មគ្រួសារមានតួនាទីយ៉ាងសំខាន់ ដោយផ្តល់នូវឱកាសការងារដល់មនុស្សប្រមាណជាពីរភាគបីនៃប្រជាជនសរុប និងរួមចំណែកដល់សន្តិសុខស្បៀង និងសេដ្ឋកិច្ចជាតិ។ លើសពីនេះទៅទៀតកសិកម្មមានតំលៃផ្នែកវប្បធម៌ និងបរិស្ថាន និងមានមុខងារសំខាន់សំរាប់សង្គមកម្ពុជា។ ស្ថិតក្រោមបរិបទនៃការផ្លាស់ប្តូរយ៉ាងលឿនផ្នែកនយោបាយ សេដ្ឋកិច្ច និងបច្ចេកវិទ្យា ការគំរាមកំហែងចំពោះនិរន្តរភាពនិងផលិតភាព នៃកសិកម្ម គ្រួសារកាន់តែមានលក្ខណៈកើនខ្លាំងឡើងៗ។

(ii) បញ្ហាគន្លឹះ

បញ្ហាសំខាន់ៗដែលជាកង្វល់ចំពោះកសិកម្ម និងការអភិវឌ្ឍន៍ជនបទ មានដូចខាងក្រោម :

- កំណើននៃសំពាធលើធនធានដីធ្លី ដែលបណ្តាលមកពីកំណើននៃការធ្វើសម្បទានព្រៃឈើ និងសម្បទាន ដីកសិកម្ម ការរកចំណេញពីការតំលើងថ្លៃដីធ្លី និងកំណើនប្រជាពលរដ្ឋ។ ស្ថានភាពនេះ រារាំងលទ្ធភាពក្នុងការទទួលបាននូវធនធាន ព្រៃឈើ និងដីធ្លី របស់ប្រជាកសិករដែលកំពុងតែកើនឡើង។
- កំណើននៃការហូរចូលនូវផលិតផល ពីបណ្តាប្រទេសផ្សេងៗទៀត។ ជាទូទៅ ទំនិញទាំងអស់ដែលនាំចូលមានលក្ខណៈប្រកួតប្រជែងជាងទំនិញក្នុងស្រុក ដែលជាហេតុបន្ទុចបង្អាក់ដល់កសិករតូចតាច ជាពិសេសកសិករដែលធ្វើស្រែចំការដើម្បីចិញ្ចឹមជីវិត មិនអោយវិនិយោគក្នុងវិស័យកសិកម្ម។ កសិករកម្ពុជាគ្មានលក្ខណៈប្រកួតប្រជែងទេ ព្រោះពួកគេមានលទ្ធភាពតិចតួច ក្នុងការទទួលបានបច្ចេកវិទ្យា គ្រាប់ពូជ ប្រព័ន្ធធារាសាស្ត្រ និងឧបករណ៍ផ្សេងៗទៀត។ លើសពីនេះទៅទៀត ពួកគេមិនទាន់មានការរៀបចំល្អនៅឡើយទេ។ ការចូលរបស់កម្ពុជា ទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) នឹងរឹតតែធ្វើអោយស្ថានភាពនេះកាន់តែអាក្រក់ទៅប្រសិនបើគ្មានយន្តការសមស្របសំរាប់លើកកំពស់សមត្ថភាពកសិកម្មក្នុងស្រុក ដើម្បីដោះស្រាយដោយជោគជ័យជាមួយពាណិជ្ជកម្មសេរីទេនោះ ។
- មានការពឹងផ្អែកយ៉ាងខ្លាំងលើទំនិញនាំចូល មានន័យថាជាការចំណាយខ្ពស់ ជាពិសេសការចំណាយលើជី និងថ្នាំសំលាប់សត្វល្អិត ដែលធ្វើអោយបាត់បង់អស់នូវចំណូលរបស់កសិករតូចតាច។ យ៉ាងហោចណាស់ ទឹកប្រាក់ប្រមាណជា ៥០ លានដុល្លារ ត្រូវបានចំណាយដើម្បីទិញទំនិញទាំងនេះក្នុងមួយឆ្នាំៗ។

- ចំនួនយុវជននៅតាមជនបទកំពុងតែកើនឡើង ប៉ុន្តែជាទូទៅពួកគេគ្មានឱកាសទទួលបាននូវជំនាញ វិជ្ជាជីវៈផ្សេងៗ ក្នុងវិស័យកសិកម្ម សហគ្រាសជនបទ និងការអភិវឌ្ឍន៍មូលដ្ឋានឡើយ។ កត្តានេះនាំអោយប៉ះពាល់ដល់ការអភិវឌ្ឍន៍រយៈពេលវែង នៅសហគមន៍ជនបទ។
- ចំនួនកសិករតូចតាចកាន់តែច្រើនឡើងជំពាក់បំណុលគេ ជាពិសេស ដោយសារការចំណាយលើការថែទាំសុខភាព និងចំណាយលើវត្ថុធាតុដើមផ្នែកកសិកម្ម។ ជាទូទៅ ដោយសារ ពួកគេជាកសិករធ្វើស្រែចំការ ដើម្បីចិញ្ចឹមជីវិត ហើយពួកគេគ្មានលទ្ធភាពក្នុងការធ្វើសកម្មណាផ្សេងក្រៅពីកសិកម្ម ដើម្បីរកចំណូលនោះឡើយ។ ដូចនេះពួកគេត្រូវខ្ចីបុលពីអ្នកចងការប្រាក់ឯកជន និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។ បើទោះបីជា សេវាកម្មនៃស្ថាប័នមីក្រូហិរញ្ញវត្ថុនៃអង្គការក្រៅរដ្ឋាភិបាល កំពុងតែកើនច្រើនឡើងៗក៏ដោយ ក៏អត្រាការប្រាក់សំរាប់កសិករ នៅតែមានកំរិតខ្ពស់នៅឡើយ។ បន្ថែមលើនេះទៀត ពួកគេពុំបានវិនិយោគថវិការបស់ខ្លួនលើផលិតកម្មកសិកម្មឡើយ ដោយសារកង្វះខាតនៃការទទួលបានពត៌មានបច្ចេកទេស។

បើទោះបីជាមានសារៈសំខាន់ និងមានការគំរាមកំហែងចំពោះកសិកម្មដែលមានលក្ខណៈជាគ្រួសារ យ៉ាងណាក៏ដោយ ក៏គេពុំឃើញមានអាទិភាព និងកម្មវិធីច្បាស់លាស់ណាមួយ តំរង់ទិសទៅគាំទ្រការអភិវឌ្ឍន៍កសិកម្មចំពោះកសិករតូចតាចឡើយ តែផ្ទុយទៅវិញ រាជរដ្ឋាភិបាលបានផ្តោតលើកសិពាណិជ្ជកម្ម និងកសិកម្មដែលមានទ្រង់ទ្រាយធំនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ខ្លួនទៅវិញ។

(iii) អនុសាសន៍ :

យើងសូមស្នើអោយរាជរដ្ឋាភិបាល និងសហគមន៍ប្រទេសផ្តល់ជំនួយ សហការជាមួយវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាលនិងកសិករនៅតាមជនបទដើម្បីរៀបចំគោលនយោបាយនិងកម្មវិធីផ្សេងៗ សំរាប់លើកកំពស់កសិករតូចតាច និងការអភិវឌ្ឍន៍កសិកម្មដោយមិនប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី។ យើងមានជំនឿយ៉ាងមុតមាំថា ស្ថេរភាពសេដ្ឋកិច្ច សង្គមកិច្ច និងស្ថេរភាពនយោបាយនៅកម្ពុជា ពឹងផ្អែកជាសំខាន់លើការធ្វើអោយប្រសើរឡើង នូវកំរិតជីវភាពរស់នៅរបស់គ្រួសារកសិករតូចតាចប្រមាណជាង ២.៥ លាននាក់។ ក្នុងន័យនេះ យើងសូមលើកឡើងនូវអនុសាសន៍ជាក់ស្តែងមួយចំនួនដូចខាងក្រោមនេះ :

- យើងសូមស្នើយ៉ាងទទូចថា គប្បីដាក់កំហិតចំពោះសម្បទានដីកសិកម្ម។ ប្រសិនបើមានការផ្តល់សម្បទានបែបនេះ គប្បីមានការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ផង។ គប្បីមានការវិភាគត្រឹមត្រូវអំពី ការខាតបង់

និងផលចំណេញ លើទិដ្ឋភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ លទ្ធភាពសំរាប់កសិករតូចតាច ក្នុងការទទួលផល ពីព្រៃឈើ និងដីធ្លី គប្បីជាអាទិភាពមួយ ។

- ការផ្សព្វផ្សាយកសិកម្មគួរត្រូវពង្រឹង
  តាមរយៈការបង្កើតនូវប្រព័ន្ធនៃការផ្សព្វផ្សាយកសិកម្មមួយដែលមានប្រសិទ្ធភាព មានលក្ខណៈវិមជ្ឈការ នៅថ្នាក់ស្រុក។ ការិយាល័យនេះ គួរមានប្រព័ន្ធ ផ្តល់សេវាចំរុះ បំពេញកិច្ចការទាំងឡាយដូចជា ការផ្សព្វផ្សាយពតិមាន សំរួលការគាំទ្រដល់អង្គការកសិករ និងបណ្តាញការងារកសិករ ព្រមទាំងធានាបរិស្ថានគាំពារមួយសំរាប់ប្រព័ន្ធផ្តល់សេវាចំរុះ។
- លើសពីនេះទៅទៀត ដើម្បីកែលំអការផ្សព្វផ្សាយវិស័យកសិកម្ម ក៏តំរូវអោយមានការគាំទ្រផងដែរចំពោះកសិករតូចតាច ដើម្បីអោយពួកគាត់អាចដោះស្រាយបានដោយជោគជ័យនូវបរិបទ នៃការផ្លាស់ប្តូរយ៉ាងលឿន លើវិស័យសេដ្ឋកិច្ច សង្គម នយោបាយ បច្ចេកវិទ្យា និងបរិស្ថាន។ គប្បីជួយកសិករក្នុងការរៀបចំពួកគេជាសមាគម និង/ឬជាសហករណ៍។ គប្បីមានអង្គការ ជាតំណាងពិតប្រាកដចំពោះផលប្រយោជន៍កសិករ និងអនុញ្ញាតិអោយកសិករធ្វើសកម្មភាពរួម សំរាប់ផលប្រយោជន៍ទៅវិញទៅមក និងសំរាប់សហគមន៍។ អ្នកតំណាងរបស់អង្គការកសិករគួរត្រូវបានអញ្ជើញចូលរួមក្នុងរាល់ដំណើរការនៃការពិគ្រោះយោបល់ ពាក់ព័ន្ធនឹងគោលនយោបាយ និងយុទ្ធសាស្រ្តក្នុងការអភិវឌ្ឍន៍កសិកម្ម។ ការគាំទ្រផ្នែកបច្ចេកទេស ការគ្រប់គ្រងឥណទាន និងរកទីផ្សារលក់ផលិតផល គួរតែត្រូវបានផ្តល់ជូនដល់អង្គការកសិករទាំងនេះ ។
- គប្បីមានការវិនិយោគលើគំរោងសាកល្បងផ្សេងៗ ដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ សំរាប់យុវជននៅជនបទ យុវកសិករ ទាក់ទងនឹងការអភិវឌ្ឍន៍សហគ្រាសជនបទ ការអភិវឌ្ឍន៍មូលដ្ឋាន ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង។ ជោគជ័យនៃគំរោងនេះ នឹងផ្តល់ផលប្រយោជន៍រយៈពេលវែង ដល់សហគមន៍ជនបទតាមរយៈវត្តមាននៃធនធានមនុស្សដែលមានសមត្ថភាពនៅថ្នាក់មូលដ្ឋាន។
- គប្បីពង្រឹងការអនុវត្តន៍នីច្បាប់លើសារធាតុគីមីសំរាប់កសិកម្ម ជាពិសេសថ្នាំសំលាប់សត្វល្អិត តាមរយៈការគ្រប់គ្រងការនាំចូល ការផលិត ការចែកចាយ ការរកទីផ្សារ ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតថ្នាក់លេខ I [១]

[1] តាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល នៅខែ តុលា ឆ្នាំ ១៩៩៨ រាល់ថ្នាំសំលាប់សត្វល្អិតថ្នាក់លេខ ១ ទាំងអស់ ត្រូវបានហាមឃាត់នៅកម្ពុជា។ ប៉ុន្តែ ការអនុវត្តន៍មិនទាន់មានប្រសិទ្ធភាពនៅឡើយ ។

និងថ្នាំផ្សេងទៀត ជាពិសេស DDT និង Endosulfan[២]។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល និងក្រសួងបរិស្ថាន គប្បីសកម្មបន្ថែមទៀតក្នុងការផ្សព្វផ្សាយដល់សាធារណៈជន តាមរយៈសារពត៌មាន វិទ្យុ និងទូរទស្សន៍ អំពីបញ្ហាដែលបណ្តាលមកពីថ្នាំសំលាប់សត្វល្អិត។ គប្បីរៀបចំការបណ្តុះបណ្តាលអំពីថ្នាំសំលាប់សត្វល្អិត និងសុខភាព ចំពោះមន្ត្រីសុខាភិបាល ដើម្បីអោយពួកគេបានយល់ដឹងអំពីជំងឺ ឬបញ្ហាសុខភាពពាក់ព័ន្ធនឹងការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត[៣]។

- យើងសូមលើកទឹកចិត្តអោយរាជរដ្ឋាភិបាល ប្រទេសផ្តល់ជំនួយ ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល ប្រមូលផ្តុំធនធាន និងប្រមូលផ្តុំជំនាញ លើការស្រាវជ្រាវ និងផ្សព្វផ្សាយពត៌មានអំពីនវានុវត្តន៍ថ្មីៗ ពាក់ព័ន្ធទៅនឹងវត្ថុធាតុពីបរទេសដែលមានតំលៃថោក កសិកម្មដែលមិនបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងបរិស្ថាន ព្រោះថាទាំងអស់នេះគឺជាវិធីសាស្ត្រដែលអាចកាត់បន្ថយភាពក្រីក្រ ។ ឧទាហរណ៍ប្រព័ន្ធអេកូឡូស៊ីនៃការធ្វើប្រពលវប្បកម្មដំណាំស្រូវ (SRI) គឺជាវិធីសាស្ត្រមួយដ៏មានជោគជ័យបំផុតក្នុងការសំរេចអោយបាននូវកំណើនផលស្រូវយ៉ាងខ្លាំង ដោយមិនពឹងផ្អែកលើវត្ថុធាតុនាំចូលពីបរទេស ដូចជាជី និងថ្នាំសំលាប់សត្វល្អិត[៤]។ បច្ចុប្បន្ននេះ កសិករកម្ពុជាប្រមាណជា ១០.០០០ នាក់ បានប្រើបាស់ប្រព័ន្ធនេះ ហើយមានប្រព័ន្ធនេះសក្តានុពលពង្រីកយ៉ាងឆាប់រហ័ស។ អង្គការក្រៅរដ្ឋាភិបាល អង្គភាពរដ្ឋ ម្ចាស់ជំនួយ និងអង្គការអន្តរជាតិ (ដូចជា GTZ, Oxfam, JICA និង ADB) បានផ្តល់ធនធានដើម្បីគាំទ្រគំរោងប្រពលវប្បកម្មដំណាំស្រូវនេះ។ ប្រសិនបើមានការគាំទ្រកាន់តែខ្លាំងបន្ថែមទៀតពីម្ចាស់ជំនួយ ពីរាជរដ្ឋាភិបាល និងពីអង្គការក្រៅរដ្ឋាភិបាល កសិករនៅកម្ពុជា នឹងអាចប្រើប្រាស់ប្រព័ន្ធនេះ ក្នុងរយៈពេលពី ៥ ទៅ ១០ ឆ្នាំខាងមុខ ដែលអាចជួយកាត់បន្ថយបញ្ហាបច្ចុប្បន្នពាក់ព័ន្ធទៅនឹងគ្រួសារ និងសន្តិសុខស្បៀង។

---

[2] Endosulfan ត្រូវបានហាមឃាត់នៅខែ មីនា ឆ្នាំ ២០០៣ ដោយក្រសួងកសិកម្ម តាមសំណើរបស់ក្រសួងសុខាភិបាល។ DDT ស្ថិតក្នុងថ្នាំសំលាប់សត្វល្អិតប្រភេទ លេខ២ ហើយស្ថិតក្នុងបញ្ជីនៃអនុសញ្ញាក្រុងស្តុកខុល ស្តីពីថ្នាំធ្វើអោយកខ្វក់សរីរាង្គ POPs (ប្រទេសកម្ពុជា ជាហត្ថលេខីចំពោះអនុសញ្ញានេះ) ។

[3] ឧទាហរណ៍ EJF (២០០២) មរណភាពដោយសារកំរិតបន្តិចបន្តួច : បញ្ហាថ្នាំសំលាប់សត្វល្អិត និងដំណោះស្រាយនៅកម្ពុជា មូលនិធិយុត្តិធម៌បរិស្ថាន ក្រុងឡុងដ៏ ចក្រភពអង់គ្លេស CEDAC (២០០៣) ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតនៅកម្ពុជា ឯកសារចុះតាមមូលដ្ឋានរបស់ CEDAC មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា ភ្នំពេញ ។

[4] យ៉ាំង សាំងកុមា (២០០១) ការពិសោធន៍របស់កសិករនៅក្នុងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ (SRI): លទ្ធផលរដូវវស្សាឆ្នាំ ២០០០ ភ្នំពេញ យ៉ាំង សាំងកុមា (២០០២) ប្រព័ន្ធអេកូឡូស៊ីនៃប្រពលវប្បកម្មដំណាំស្រូវនៅកម្ពុជា លទ្ធផល និងបទពិសោធន៍នៅមូលដ្ឋាន ឆ្នាំ ២០០០-២០០១ ភ្នំពេញ- យ៉ាំង សាំងកុមា (២០០៣), *ប្រព័ន្ធអេកូឡូស៊ីនៃប្រពលវប្បកម្មដំណាំស្រូវនៅកម្ពុជា លទ្ធផល និងបទពិសោធន៍នៅមូលដ្ឋាន ឆ្នាំ ២០០០-២០០១ ភ្នំពេញ- យ៉ាំង សាំងកុមា (២០០២)* ភ្នំពេញ Uphoff, N. (២០០៣) របាយការណ៍ពីទស្សនកិច្ច SRI មកកាន់កម្ពុជា វិទ្យាស្ថានអន្តរជាតិ Cornell ដើម្បីស្បៀងអាហារ កសិកម្ម និង ការអភិវឌ្ឍន៍ ញូវយ៉ក សហរដ្ឋអាមេរិក។

- ពាក់ព័ន្ធនឹងបញ្ហាធារាសាស្ត្រវិញ យើងសូមស្នើអោយម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលគាំទ្រប្រព័ន្ធធារាសាស្ត្រខ្នាតតូច តាមរយៈការជួយសហគមន៍ដើម្បីរៀបចំខ្លួនគេ ក្នុងសហគមន៍អ្នកប្រើប្រាស់ទឹក ជាជាងការផ្តោតលើប្រព័ន្ធធារាសាស្ត្រខ្នាតធំ ។
- រាជរដ្ឋាភិបាលគប្បីអនុម័តគោលនយោបាយ និងកម្មវិធីដើម្បីគាំទ្រការផលិតគ្រាប់ពូជនៅសហគមន៍ និងផ្លាស់ប្តូរគំនិតផ្តួចផ្តើម ដែលអាចធានាសិទ្ធិរបស់សហគមន៍កសិករតូចតាច ក្នុងការទទួលគ្រាប់ពូជ។ ក្នុងន័យនេះ កិច្ចខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍ មិនគួរគប្បីផ្តោតលើការបង្កើតអោយមានការពឹងផ្អែករបស់កសិករតូចតាចលើក្រុមហ៊ុនគ្រាប់ពូជនោះទេ តែផ្តោតលើការពង្រឹងសហគមន៍ក្នុងការបង្កាត់ពូជ និងផ្លាស់ប្តូរគ្រាប់ពូជ។ ក៏ប៉ុន្តែក៏ត្រូវមានបទប្បញ្ញត្តិស្តីពីគុណភាពគ្រាប់ពូជដែលដាក់លក់ផងដែរ ។
- ជាមួយនឹងការកើនឡើងនៃភាពមិនច្បាស់លាស់ និងការព្រួយបារម្ភ អំពីផលប៉ះពាល់ជាអវិជ្ជមានដែលអាចកើតមាន ពីផលិតផលដែលកែប្រែពូជ (Genetically Modified Organism-GMOs)មកលើសុខភាពអេកូឡូស៊ី និងមកលើជីវភាពរស់នៅរបស់កសិករតូចតាច យើងគាំទ្រយ៉ាងពេញទំហឹងចំពោះគំនិតផ្តួចផ្តើមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបញ្ឈប់ផលិតផល GMOs នៅកម្ពុជា។ រាល់ជំនួយជាស្បៀងអាហារទាំងអស់ គប្បីត្រូវបានត្រួតពិនិត្យអោយបានត្រឹមត្រូវ ដើម្បីធានាថា ស្បៀងទាំងនោះ មិនមែនជាផលិតផល GMOs ។

សំរាប់ពត៌មានបន្ថែមពាក់ព័ន្ធបញ្ហាលើកឡើងក្នុងរបាយការណ៍នេះ សូមទំនាក់ទំនងជាមួយៈ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍកសិកម្មនៅកម្ពុជា (CEDAC) (ទូរស័ព្ទលេខ : ០២៣ ៨៨០៩១៦ Email: cedac@camnet.com.kh)

ផ្នែកសិទ្ធិកុមារ

(i) សេចក្តីផ្តើម

គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ធ្វើការរួមគ្នាដើម្បីតស៊ូមតិលើផ្នែកសិទ្ធិកុមារ និងតាមដានការអនុវត្តន៍នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។ គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលដើម្បីសិទ្ធិកុមារត្រូវបានបង្កើតឡើងក្នុង ឆ្នាំ១៩៩៤ ហើយបច្ចុប្បន្នមាន អង្គការ ចំនួន ៣៨ ជាសមាជិក ។ កុមារមានចំនួនប្រហែល ៥២% នៃចំនួនប្រជាជនទាំងអស់នៅក្នុងប្រទេសកម្ពុជា។ តាមការប៉ាន់ប្រមាណមានប្រជាជនកម្ពុជាប្រហែល ៣៦% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីការកាត់បន្ថយភាពក្រីក្រ ចាំបាច់ត្រូវដាក់បញ្ចូលនូវវិធានការណ៍ជាក់លាក់ដើម្បីបំពេញតំរូវការរបស់កុមារ។ អនាគតរបស់ប្រទេសកម្ពុជា និងការរីកចំរើន ផ្នែកសេដ្ឋកិច្ច ត្រូវពឹងផ្អែកយ៉ាងសំខាន់ទៅលើការរស់រានមានជីវិត និងការអភិវឌ្ឍន៍កុមារនៃប្រទេសខ្លួន។ នៅពេលប្រទេសកម្ពុជាអភិវឌ្ឍ ប្រសិន បើគ្មានកម្មវិធីសំរាប់ទ្រទ្រង់កុមារទេនោះ ហើយគ្មានការធ្វើផែនការ និងគ្មានសហប្រតិបត្តិការទេនោះ កុមារក្រីក្រ និងកុមារងាយរងគ្រោះ នឹងមិនបានទទួលនូវការយកចិត្តទុកដាក់ឡើយ។ សិទ្ធិកុមារ គឺជាបញ្ហាអភិបាលកិច្ចមួយដែលការអនុវត្តន៍នូវសិទ្ធិទាំងនោះតំរូវអោយ រាជរដ្ឋាភិបាលកម្ពុជា មានមត្តទេសភាព ការប្តេជ្ញាចិត្ត និងមានប្រភពធនធានផ្សេងៗ។ វិស័យសំខាន់ៗដែលត្រូវ ចាប់អារម្មណ៍ រួមមានការអភិវឌ្ឍន៍គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សនិងសេដ្ឋកិច្ច ព្រមទាំងការបែងចែកធនធាន និងការពង្រឹងការអនុវត្តន៍នីច្បាប់ដើម្បីការពារកុមារ។ សិទ្ធិកុមារគឺជាបញ្ហាមួយដែលមាននៅក្នុងគ្រប់វិស័យទាំងអស់របស់ សង្គម ដូច្នេះឯកសារនេះជាឯកសារដែលបំពេញបន្ថែមលើវិស័យផ្សេងៗទៀត ជាពិសេស វិស័យអប់រំ និងសុខភាព ។

(ii) បញ្ហាសំខាន់ៗ

ការអនុវត្តន៍ និងការតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដែលបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដោយអនុក្រឹត្យជាអង្គភាពសម្របសម្រួលក្នុងកិច្ចឧបត្ថម្ភគាំទ្រ និងតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជា ។ ដើម្បីអនុវត្តការងារអោយមានប្រសិទ្ធភាព ក្នុងគោលបំណងលើកកំពស់សិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្កើតនូវអនុគណៈកម្មការ (អន្តរក្រសួង) ចំនួន៤ : អនុគណៈកម្មការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ច

ផ្លូវភេទលើកុមារ អនុគណៈកម្មការពលកម្មកុមារ អនុគណៈកម្មការរៀបចំតាក់តែងច្បាប់ នឹង អនុគណៈកម្មការអភិវឌ្ឍន៍កុមារពីដើមដំបូង។

ផែនការជាតិ ៥ឆ្នាំ (២០០០-២០០៤)ស្តីពីការប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចលើកុមារត្រូវបានបង្កើតឡើង និង បានផ្សព្វផ្សាយតាមមន្ទីរក្រសួង និងតាមខេត្តនានាមួយចំនួនក្នុងការខិតខំទប់ស្កាត់បញ្ហាជួញដូរកុមារដែលកំពុងរីករាលដាលនៅក្នុងសង្គមកម្ពុជា ។

ទន្ទឹមនឹងការខិតខំប្រឹងប្រែងដ៏ល្អរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គេក៏សង្កេតឃើញផងដែរថាបញ្ហាកុមារនៅតែជាបញ្ហាចំបង និងជាកង្វល់របស់សង្គម និងរបស់រាជរដ្ឋាភិបាល។ កុមារកម្ពុជានៅតែរងនូវការរំលោភសិទ្ធិ អំពើហិង្សា ការរំលោភបំពានផ្លូវភេទ ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ និងការប្រើប្រាស់គ្រឿងញៀន ។

សកម្មភាពឆ្លើយតបរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលទាក់ទងទៅនឹងបញ្ហាកុមារ នៅមានកំរិតដោយពុំទាន់មាន សកម្មភាពបណ្តាញការងារគ្របដណ្តប់លើបញ្ហាកុមារទូទាំងប្រទេសនៅឡើយ។

<u>គ្រឿងញៀន</u>

ក្នុងកំឡុងឆ្នាំ ២០០២-២០០៣ រាជរដ្ឋាភិបាលបានខិតខំយ៉ាងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ការផលិត និង ការប្រើប្រាស់គ្រឿងញៀន។ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាយកដ្ឋានកំចាត់គ្រឿងញៀន និងបណ្តាញកំចាត់គ្រឿងញៀនគ្រប់ខេត្តក្រុងទូទាំងប្រទេស ។

តាមការសិក្សាថ្មីៗមួយ (ក្នុងទីក្រុងភ្នំពេញ ទីប្រជុំជនសំខាន់ៗនៃខេត្តបាត់ដំបង និងក្រុងព្រះសីហនុ) ដែលប្រកាសដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងចំណោមសិស្សសាលាកម្ពុជាដែលរៀននៅថ្នាក់ទី ៩ ដល់ទី ១២ បានបង្ហាញ អោយឃើញថា ក្នុងចំណោមសិស្សសាលា ៥ នាក់មានម្នាក់បានសាកល្បងប្រើប្រាស់គ្រឿងញៀន នៅក្នុងជីវិតរបស់គេ។ បរិមាណដ៏ច្រើននៃថ្នាំញៀនដែលសមត្ថកិច្ចចាប់បាន ក៏បានធ្វើអោយយើងបារម្ភណ៍អំពីការកើនឡើងនៃអ្នកប្រើប្រាស់ថ្នាំញៀនផងដែរ ពិសេសវត្តមាននៃការប្រើប្រាស់គ្រឿងញៀនចាក់តាមសរសៃ។ នាខែតុលាឆ្នាំ ២០០៣ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់វិធានការណ៍បំបាត់កន្លែងផលិតថ្នាំញៀនលួចលាក់ នៅទីក្រុងភ្នំពេញ ហើយថ្នាំញៀន ៣៥ គក្រ ត្រូវបានបំផ្លាញដោយរដ្ឋាភិបាល។

ថ្នាំញៀនបានធ្វើអោយប៉ះពាល់យ៉ាងខ្លាំងទៅលើ សន្តិសុខ និងសុខុមាលភាពសង្គម ក៏ប៉ុន្តែការផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់សារធាតុញៀននៅពុំទាន់បានទូលំទូលាយក្នុងរង្វង់សិស្សសាលា និង កុមារតាមសហគមន៍

នៅឡើយ។ ម្យ៉ាងទៀត កម្ពុជានៅមានកង្វះខាតមជ្ឈមណ្ឌលព្យាបាល-ថែទាំ និងស្តារលទ្ធភាពពលកម្មកុមារ ដែលរងគ្រោះដោយថ្នាំញៀន។

មេរោគអេដស៍/ជំងឺអេដស៍

ដើម្បីទប់ស្កាត់ការរីករាលដាលនៃការឆ្លងនៃ មេរោគអេដស៍/ជំងឺអេដស៍ រដ្ឋាភិបាលបានបង្កើតឡើងនូវអាជ្ញាធរជាតិ ប្រយុទ្ធនឹងជម្ងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ជំងឺសើរស្បែក និងជំងឺកាមរោគ និងមានលេខាធិការដ្ឋាន និងការិយាល័យប្រយុទ្ធនឹងជម្ងឺអេដស៍គ្រប់ខេត្តក្រុងទាំងអស់ទូទាំងប្រទេសកម្ពុជា ។ ការផ្សព្វផ្សាយនិងការអនុវត្តន៍កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% នៅទូទាំងប្រទេសបានទទួលនូវលទ្ធផលល្អប្រសើរ។ តាមការស្រាវជ្រាវរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ជំងឺសើរស្បែក និងជំងឺកាមរោគបានបង្ហាញថា អត្រាឆ្លងរាលដាលនៃមេរោគអេដស៍ បានថយចុះ ពី ៣,៣% នៅឆ្នាំ១៩៩៧ មក២,៦% នៅឆ្នាំ២០០២។ ប៉ុន្តែទន្ទឹមនឹងនេះ អ្នកដែលបាត់បង់ជីវិតដោយសារជម្ងឺអេដស៍បានកើនឡើងពី ១៩.៣០៥ នាក់ នៅឆ្នាំ១៩៩៧ ដល់ ៧៨.៦៥៣ នាក់ នៅឆ្នាំ ២០០២ ដែលបន្សល់ទុកនូវកុមារកំព្រាចំនួនប្រមាណ ៦០.០០០ នាក់ ដែលជាបន្ទុកធ្ងន់ធ្ងររបស់រាជរដ្ឋាភិបាល ។ កុមារកំព្រាជាច្រើនត្រូវបានគេបោះបង់ចោល ឬមិនយកចិត្តទុកដាក់ ពីសហគមន៍ និងពីសាច់ញាតិ។ កុមារត្រូវបង្ខំចិត្តឈប់សិក្សាដើម្បីរកស៊ីចិញ្ចឹមប្អូនរបស់ខ្លួន។ កំព្រាជួបប្រទះនូវកង្វះខាតអាហារូបត្ថម្ភ ខ្វះជម្រក និងខ្វះសម្ភារៈសិក្សា ហើយកុមារទាំងនោះប្រឈមនឹងគ្រោះថ្នាក់ជាជនរងគ្រោះពីការជួញដូរ ពេស្យាចារ្យ និងការប្រើប្រាស់គ្រឿងញៀន ។

ការរំលោភលើផ្លូវភេទ ការកេងប្រវញ្ច័ និងការជួញដូរកុមារ

រាជរដ្ឋាភិបាល បានពង្រឹងកិច្ចការរបស់ខ្លួនដោយឆ្លើយតបទៅនឹងការដោះស្រាយបញ្ហានេះ ដោយបានពង្រីងបណ្តាញការងារតាមបណ្តាខេត្តក្រុងមួយចំនួនជាមួយអង្គការនានាដែលកំពុងធ្វើការប្រយុទ្ធប្រឆាំងលើបញ្ហានេះ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ពត៌មានដែលគណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលដើម្បីសិទ្ធិកុមារបានទទួល បង្ហាញអោយឃើញនូវការកើនឡើងពីសកម្មភាពនៃការរំលោភបំពានផ្លូវភេទមកលើកុមារ ។

នៅក្នុងឆ្នាំ២០០២-២០០៣ គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលដើម្បីសិទ្ធិកុមារបានរាយការណ៍ថា មានការរំលោភបំពានលើកុមារចំនួន ៣១៧ ករណី ក្នុងនោះមាន ១៩៧ ករណី ជាករណីរំលោភសេពសន្ថវៈ។ ក្នុងចំណោម ១៩៧ ករណីនេះ ២២,៨៤%ជាកុមារដែលមានអាយុចាប់ពី១៤ខែ-៩ឆ្នាំ ៤៣,១៥% ជាកុមារដែល មានអាយុចាប់ពី១០-១៤ឆ្នាំ និង ៣៤,០១% ជាកុមារដែលមានអាយុចាប់ពី១៥-១៧ឆ្នាំ។ កំណើនតួលេខនៃការរំលោភលើផ្លូវភេទ បានបង្ហាញ

នូវការស្រុតចុះនៃសីលធមិសង្គម និងភាពទន់ខ្សោយនៃការអនុវត្តន៏នីច្បាប់។ ករណីជាច្រើនត្រូវបានបញ្ចប់ដោយការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ។

ពលកម្មកុមារ : កុមារបំរើការតាមផ្ទះ

កុមារបំរើការតាមផ្ទះគឺជាទំរង់ការងារដែលមានលក្ខណៈប្រពៃណីមួយដែលច្រើនតែធ្វើអោយប៉ះពាល់ដល់ស្ត្រីនិងកុមារីមកពីគ្រួសារក្រីក្រ។ ពលកម្មកុមារជាការប្រព្រឹត្តមួយដែលពាក់ព័ន្ធនឹងការរើសអើង និងជាការងារដែលមានលក្ខណៈដូចគ្នានឹងទាសភាព។ កុមារបំរើការតាមផ្ទះជាទំរង់ការងារអាក្រក់បំផុតមួយ ក្នុងចំណោមទំរង់ការងារផ្សេងៗទៀត ដែលកុមារកំពុងអនុវត្ត។ មានកត្តាជាច្រើន ដែលជំរុញអោយកុមារបំរើការតាមផ្ទះ រួមមានវត្តមាននៃភាពក្រីក្រ ទស្សនៈសង្គមកម្ពុជា ដែលទទួលស្គាល់ការងារនេះថាមិនមែន ជាការងារប្រកបដោយគ្រោះថ្នាក់នោះទេ ហើយដែលការយល់បែបនេះ ធ្វើអោយមានការរំលោភបំពានមកលើកុមារ។ លើសពីនេះទៅទៀតការបោះជំហានរបស់កម្ពុជាទៅរករបបសេដ្ឋកិច្ចទីផ្សារសេរី និងនគរូបនីយកម្ម និងសាកលភាវូបនីយកម្ម នៅក្នុងទសវត្សរ៏ចុងក្រោយនេះ ធ្វើអោយតំរូវការទីផ្សារពលកម្មកុមារកើនឡើង សំរាប់គ្រួសារដែលមានកំរិតជីវភាពមធ្យម។ ការមិនទទួលស្គាល់បញ្ហាកុមារបំរើការតាមផ្ទះ មានន័យថានៅតែគ្មានបទប្បញ្ញត្តិស្តីពីពេលវេលាធ្វើការ គ្មានបទប្បញ្ញត្តិស្តីពីការផ្តល់ប្រាក់ខែ និងគ្មានលក្ខខណ្ឌ ហើយគ្មានវិធីបង្កាកុមារកុំអោយរងនូវការកេងប្រវ័ញ្ច ។

ទោះបីជាពុំមានការសិក្សាស្រាវជ្រាវច្បាស់ដើម្បីបង្ហាញទំហំនៃបញ្ហាក៏ដោយ ក៏គេបានគិតថាមានកុមារបំរើការនៅតាមផ្ទះរាប់ពាន់នាក់កំពុងធ្វើការនៅក្នុងទីក្រុងនានានៃប្រទេសកម្ពុជា។ តាមការសិក្សាក្រៅផ្លូវការមួយដែល ធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយក្នុងឆ្នាំ ១៩៩៩ បានបង្ហាញថា មានកុមារប្រហែល ៤000 នាក់ ដែលកំពុងបំរើការតាមផ្ទះនានានៅក្នុងទីក្រុងភ្នំពេញ ។ ក្នុងនោះ ប្រហែលជា ៩0% ជាកុមារី ហើយ ៨0% មានអាយុពី ១២-១៧ ឆ្នាំ និង ៤0% ត្រូវបានរាយការណ៏ថា មានការរំលោភបំពានទាំងផ្លូវកាយ និងពាក្យសំដី ជារៀងរាល់ថ្ងៃ។ មានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងស្ថាប័នរដ្ឋាភិបាលមួយចំនួនកំពុង ធ្វើការងារលើបញ្ហានេះ ប៉ុន្តែជាញឹកញាប់ ពួកគេពុំសូវបានទទួលការសហការណ៏ពីអាជ្ញាធរមូលដ្ឋានទេ។ មានឧទាហរណ៏ជាក់ស្តែងជាច្រើន ដែលអង្គការក្រៅរដ្ឋាភិបាលបានធ្វើជាសាក្សី និងធ្វើអន្តរាគមន៏ និង/ឬសង្គ្រោះកុមាររងគ្រោះដោយការធ្វើទណ្ឌកម្មលើរាងកាយយ៉ាងធ្ងន់ធ្ងរ ការបំពារបំពានផ្លូវភេទ ការវាយតប់ និងការរំខានផ្សេងៗទៀត។

យុត្តិធម៌សំរាប់កុមារ

រាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមផ្តល់ដំណោះស្រាយផ្សេងៗដើម្បី កែលំអស្ថានភាពទាក់ទងនឹងយុត្តិធមិសំរាប់កុមារ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ប្រព័ន្ធយុត្តិធមិសំរាប់កុមារក្នុងប្រទេសកម្ពុជា នៅតែគ្មានរូបរាង ហើយការការពារកុមារតាមផ្លូវច្បាប់មានចំនួនស្តួចស្តើងណាស់។ កុមារដែលមានកំហុសត្រូវបានគេអនុវត្តន៍ ដោយមធ្យោបាយផ្សេងៗ ខុសពីមនុស្សពេញវ័យ ហើយមានបញ្ញត្តិមួយចំនួននៅក្នុងច្បាប់ព្រហ្មទណ្ឌរបស់ជាតិ បានលើកឡើងអំពីដំណោះស្រាយចំពោះជនល្មើសជាកុមារ។ លើសពីនេះទៅទៀតកម្ពុជាបានអនុម័តច្បាប់ស្តីពីស្ថានទម្ងន់ទោស ដែលក្រោមច្បាប់នេះឧត្តមប្រយោជន៏របស់កុមារបានបាត់បង់។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការខ្វះចន្លោះនូវចំណុចសំខាន់ៗជាច្រើនក្នុងការការពារតាមផ្លូវច្បាប់ចំពោះកុមារដែលមានកំហុសនឹងច្បាប់។ មានការកំនត់ស្តីពីរយៈពេលនៃការឃុំខ្លួនកុមារ អាចត្រូវបានឃុំខ្លួនក្រោមច្បាប់ព្រហ្មទណ្ឌ ។ គ្មានបទប្បញ្ញត្តិ ឬបទបញ្ជាណែនាំណាមួយដែលចែងថាការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួន ឬការដកហូតសេរីភាពកុមារគួរតែជាជំរើសចុងក្រោយនោះទេ។ គ្មានទីកន្លែងថែទាំច្បាស់លាស់ណាមួយសំរាប់ការឃុំឃាំង ឬការដាក់គុកចំពោះកុមារក្រៅតែពីគុក/កន្លែងឃុំឃាំងសំរាប់មនុស្សចាស់។ កុមារបានជាប់ទោសក្នុងពន្ធនាគារជាមួយមនុស្សចាស់ ទោះបីជាមានការបំបែកកុមារចេញពីបន្ទប់ឃុំឃាំងពីក្រុមមនុស្សចាស់ ដែលនៅទីនោះមនុស្សចាស់ចំណាយពេលវេលាដ៏ច្រើនបំផុតសំរាប់ការជាប់ទោសរបស់ពួកគេ។ ចំពោះសិទ្ធិទទួលបាននូវការព្យាបាលអោយជាសះស្បើយផ្នែករាងកាយ និងផ្នែកចិត្តសាស្ត្រ ព្រមទាំងការធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញ ប្រព័ន្ធពន្ធនាគារកម្ពុជាមិនបានផ្តល់នូវសេវាស្តារនីតិសម្បទាណាមួយ ចំពោះមនុស្សដែលជាប់ឃុំឃាំងទេ រួមទាំងកុមារដែលទើបនឹងកាត់ក្តីក្នុងពេលថ្មីៗនេះ ត្រូវបានដាក់ក្នុងគុកជាមួយមនុស្សចាស់។

(iii) អនុសាសន៍

ការអនុវត្តន៍ និងការតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

ដើម្បីឆ្លើយតបនឹងបញ្ហាកុមារដែលជាបញ្ហាអាទិភាពរបស់សង្គម ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារគប្បី :

- ជាស្ថាប័នមួយដែលមិនត្រូវស្ថិតនៅក្រោមក្រសួងសង្គមកិច្ច និងមានឋានៈស្មើអាជ្ញាធរជាតិ
- ទទួលការបង្កើនធនធាន ទាំងធនធានមនុស្ស និងទាំងថវិកា
- បង្កើនការផ្សព្វផ្សាយចំណេះដឹងផ្នែកសិទ្ធិកុមារដល់មហាជន និងសហគមន៍

គ្រឿងញៀន

- រាជរដ្ឋាភិបាលចាំបាច់ត្រូវចាត់វិធានការប្រឆាំងការផលិត ការជួញដូរ និង ការប្រើប្រាស់គ្រឿងញៀន
- រាជរដ្ឋាភិបាលគប្បីបង្កើតយុទ្ធនាការដ៏ទូលំទូលាយ ដែលមានរយៈពេលវែងនៅទូទាំងប្រទេស ប្រឆាំងនឹងការប្រើប្រាស់ ការជួញដូរ និងការផលិតគ្រឿងញៀន

មេរោគអេដស៍/ជំងឺអេដស៍

- រាជរដ្ឋាភិបាលគប្បីបង្កើនចំនួនមជ្ឈមណ្ឌលថែទាំកុមារដែលឆ្លងមេរោគអេដស៍ និងមានជម្ងឺអេដស៍
- រាជរដ្ឋាភិបាលគប្បីទប់ស្កាត់កំណើនកុមារកំព្រាដែលបណ្តាលមកពីការស្លាប់របស់ឪពុកម្តាយដោយសារមេរោគអេដស៍ /ជម្ងឺអេដស៍ ដោយជួយផ្តល់ថ្នាំ ពន្យារអាយុ(អង់ទីរេត្រូវ៉ាយរុស) ដោយឥតគិតថ្លៃ ចំពោះឪពុកម្តាយកុមារ ដែលរងគ្រោះដោយ មេរោគអេដស៍ /ជម្ងឺអេដស៍
- ផ្តល់ចំណីអាហារដល់កុមារកំព្រា ដោយសារឪពុកម្តាយដែលស្លាប់ដោយជម្ងឺអេដស៍
- លើកកំពស់ការជួយឧបត្ថម្ភពីសហគមន៍ដល់កុមារកំព្រា និងលើកំពស់ការលុបបំបាត់ភាពរើងអើង ចំពោះកុមារកំព្រា ដោយសារឪពុកម្តាយស្លាប់ដោយជម្ងឺអេដស៍ និងកុមារដែលផ្ទុកមេរោគអេដស៍និងមានជំងឺអេដស៍ ។

ការរំលោភ ការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទលើកុមារ

- បំបាត់ការផ្សព្វផ្សាយទស្សនាវដ្តី កាសែតវីដេអូអាសអាភាស
- ពង្រឹងការអប់រំសីលធមិសង្គមតាមសហគមន៍ និងបង្កើតវិធានការទប់ស្កាត់នៅតាមសហគមន៍(ភូមិសុវត្ថិភាព)
- ពង្រឹងការអនុវត្តន៍នីច្បាប់

ពលកម្មកុមារ

- ចាំបាច់ត្រូវផ្តល់សច្ចាប័ន និងដាក់ជាអាទិភាពនូវការអនុវត្តន៍នីអនុសញ្ញា ILO ១៨២ ហាមឃាត់ និងធ្វើសកម្មភាពជាបន្ទាន់ ប្រឆាំង នឹងទម្រង់អាក្រក់បំផុតនៃការប្រើប្រាស់ពលកម្មកុមារ ។
- រាជរដ្ឋាភិបាលគប្បីប្រកាសថាការងារកុមារបំរើតាមផ្ទះជាទំរង់អាក្រក់បំផុតនៃការប្រើប្រាស់ពលកម្មកុមារ អាស្រ័យហេតុនេះ ចាត់វិធានការ និងធ្វើការហាមឃាត់ពលកម្មកុមារ ។ បញ្ហានេះគប្បីបញ្ជ្រាបទៅក្នុងរបៀបវារៈសកម្មភាព NPA ស្តីពីទំរង់អាក្រក់បំផុតនៃពលកម្មកុមារ ។
- ចាំបាច់ត្រូវធ្វើអង្កេតគ្រប់ជ្រុងជ្រោយ

- គប្បីផ្តល់ការអប់រំដោយមិនគិតថ្លៃ និងជាកាតព្វកិច្ច ក្នុងការអប់រំប្រកបដោយគុណភាព និងមានខ្លឹមសារ ចំពោះកុមារទាំងអស់ ដោយយកចិត្តទុកដាក់ចំពោះតំរូវការពិសេសរបស់កុមារបំរើការតាមផ្ទះ និងតំរូវការរបស់កុមារី និងកុមារងាយរង គ្រោះនៅក្នុងតំបន់ក្រីក្រ ។
- រាជរដ្ឋាភិបាលចាំបាច់ត្រូវតាក់តែងច្បាប់ស្តីពីកុមារបំរើការតាមផ្ទះ ដោយគិតគូរកំរិតអាយុអប្បបរមា ប្រាក់ឈ្នួល និង លក្ខខ័ណ្ឌការងារ ។
- បើកយុទ្ធនាការថ្នាក់ជាតិមួយដើម្បីអោយមហាជនចាប់អារម្មណ៍លើបញ្ហាកុមារបំរើការងារតាមផ្ទះ។ ជាពិសេស ឪពុកម្តាយ និងនិយោជកគប្បីទទួលការអប់រំអំពីការងារប្រតិបត្តិអំពីការជ្រើសរើសកុមារអោយបំរើការតាមផ្ទះ។
- គប្បីបង្កើតនូវយន្តការនៅកំរិតសហគមន៍ដើម្បីតាមដានការរំលោភបំពានធ្ងន់ធ្ងរ
- អនុវត្តផែនការសកម្មភាពជាតិក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជនបទ

តុលាការសំរាប់កុមារ

- រាជរដ្ឋាភិបាលគប្បីបំបែកកុមារជាបន្ទាន់ដែលត្រូវជាប់ឃុំឃាំងចេញពីមនុស្សពេញវ័យ និងធានាអោយមាន កម្មវិធីអប់រំ និងស្តារនីតិសម្បទាដល់កុមារដែលជាប់ពន្ធនាគារ ។
- បង្កើតច្បាប់ និងគោលនយោបាយណែនាំ ដែលធានាថា ការចាប់ខ្លួនកុមារ ជាវិធានការចុងក្រោយតែមួយគត់ ហើយការដកហូតសេរីភាពមានរយៈពេលខ្លីសមស្រប ។
- បង្កើតប្រព័ន្ធយុត្តិធម៌សំរាប់កុមារ ដោយផ្អែកលើទស្សនៈរួមនៃការស្តារនីតិសម្បទាជនល្មើស និងបង្កើតនូវ កម្មវិធីសមស្របដើម្បីស្តារឡើងវិញ និងធ្វើសមាហរណកម្មចូលមកក្នុងសង្គម ចំពោះកុមារដែលមានល្មើស ច្បាប់។
- រាជរដ្ឋាភិបាល ដោយមានសហប្រតិបត្តិការពីអង្គការក្រៅរដ្ឋាភិបាល ចាំបាច់ត្រូវយល់ព្រមបង្កើត និង សម្របសម្រួលមន្ទីរកែប្រែនៅសហគមន៍ ធ្វើជាជំរើសមួយផ្សេងទៀត ចំពោះការដាក់គុកកុមារដែលល្មើសច្បាប់ ។
- រាជរដ្ឋាភិបាលគួរតែធ្វើសេចក្តីព្រាងច្បាប់ (ស្របជាមួយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ) ដាច់ដោយឡែកមួយសំរាប់កុមារដែលល្មើសច្បាប់ និងបង្កើតឡើងតុលាការសំរាប់កុមារ ។

សំរាប់ពិតមានបន្ថែមទាក់ទងទៅនឹងបញ្ហាទាំងឡាយដែលមាននៅក្នុងរបាយការណ៍នេះ
សូមទំនាក់ទំនង NGO-CRC Tel:023 882 412, E-mail: ch.ngocrc@online.com.kh

វិមជ្ឈការ

(i) សេចក្តីផ្តើម

ដោយមានការជំរុញលើកទឹកចិត្តពីលទ្ធផលឆ្នាំទី ១ នៃការអនុវត្តន៍នីគោលនយោបាយវិមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈគណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងបណ្តាក្រសួង ស្ថាប័ន ព្រមទាំងម្ចាស់ជំនួយផ្សេងៗទៀត បានបន្តពង្រឹងនិងពង្រីកសកម្មភាពនានា នៅក្នុងឆ្នាំទី ២ សំដៅសំរេចអោយបាននូវគោលបំណងនៃគោលនយោបាយវិមជ្ឈការ។ សមិទ្ធផលដែលសំរេចបាន រួមមាន ការចេញលិខិតបទដ្ឋានដើម្បី ជាមគ្គុទេសក៍នៃការអនុវត្តន៍វិមជ្ឈការ ការពង្រឹងប្រព័ន្ធនៃការគាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់ និងកិច្ចសហប្រតិបត្តិការ ជាមួយគំរោងផ្សេងៗដែលគាំទ្រដោយម្ចាស់ជំនួយ ដូចជាកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិដើម្បីគាំទ្រគំរោងវិមជ្ឈការ (UNDP SDP) គំរោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ/សង្កាត់ របស់ធនាគារអភិវឌ្ឍន៍អាស៊ី (CCDP/ADB) GTZ, មូលនិធិ Konrad Adenauer និងគំរោងគាំទ្រឃុំ/សង្កាត់ (CCSP)។

ជាទូទៅ សង្គមស៊ីវិលបានគាំទ្រដល់ការអនុវត្តន៍កម្មវិធីវិមជ្ឈការ។ តាមរយៈ CCSP ការិយាល័យទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាលមួយ ត្រូវបានបង្កើតឡើងនៅក្នុងនាយកដ្ឋានរដ្ឋបាល។ ការិយាល័យទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាលនេះ មានតួនាទីបង្កើនការផ្លាស់ប្តូរ និងជាចរន្តក្នុងការប្រាស្រ័យទាក់ទងគ្នា រវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ពាក់ព័ន្ធនឹងវិមជ្ឈការ និងបញ្ហាកំណែទំរង់អភិបាលកិច្ចនៅមូលដ្ឋាន។ ការិយាល័យនេះ ក៏មានតួនាទីជំរុញភាពជាដៃគូរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល ក្នុងបញ្ហាវិមជ្ឈការផងដែរ។ សម្ព័ន្ធភាពរបស់អង្គការក្រៅរដ្ឋាភិបាលដែលគួរអោយជឿជាក់មួយ កំពុងសកម្មចូលរួមជំរុញភាពជាដៃគូ រវាងក្រុមប្រឹក្សាឃុំ/សង្កាត់ និងសង្គមស៊ីវិល ក្នុងការអនុវត្តន៍គំរោងនានា។ **ក្រុមការងារស្តីពីភាពជាដៃគូវិមជ្ឈការ** បានប្រសូត្រចេញមកពីសិក្ខាសាលាថ្នាក់ជាតិដ៏ធំមួយដែលដឹកនាំដោយអង្គការ CIDSE ដើម្បីតំរង់ទិសភាពជាដៃគូ ក្នុងចំណោមក្រុមប្រឹក្សាឃុំ/សង្កាត់ និងបណ្តាអង្គការបំរើការងារនៅថ្នាក់សហគមន៍ ក្នុងការអនុវត្តន៍គំរោង។ ក្រៅពីនេះ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនទៀត មិនត្រឹមតែកំពុងចូលរួមយ៉ាងសកម្មក្នុងការផ្តល់មូលនិធិដល់គំរោងឃុំ/សង្កាត់ប៉ុណ្ណោះទេ បន្តែក៏ផ្តល់មូលនិធិដល់ការកសាងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់បន្ថែមទៀតផងដែរ។ អង្គការ Concern Worldwide កំពុងតំរង់ទិសកម្មភាពរបស់ខ្លួន ដើម្បី ធ្វើការអោយកាន់តែជិតស្និទ្ធជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងកម្មវិធីកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ/សង្កាត់។ អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍ Buddhism for Development កំពុងផ្តួចផ្តើម

គំនិត ស្តីពីការកសាងសមត្ថភាពអំពីវិមជ្ឈការ សំរាប់គណៈបក្សនយោបាយទាំងអស់។ អង្គការ Star Kampuchea បានធ្វើការស្រាវជ្រាវមួយស្តីពីតម្លាភាពរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។ ជាការពិតណាស់ បច្ចុប្បន្ននេះមានគំនិតផ្តួចផ្តើម សមស្របដ៏សំបូរបែប របស់អង្គការក្រៅរដ្ឋាភិបាលក្នុងវិស័យវិមជ្ឈការ ។

(iii) បញ្ហាសំខាន់ៗ

<u>លៃយ៉ាងណាអោយគំរោងអភិវឌ្ឍន៍ឃុំ/សង្កាត់ នាំទៅរកការកាត់បន្ថយភាពក្រីក្រ</u>

ឃុំ/សង្កាត់ស្ទើរតែទាំងអស់ បានរៀបចំផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និងផែនការវិនិយោគឃុំ/សង្កាត់ តាមរបៀបមួយដែលអាចចាត់ទុកថា ជាដំណើរការមួយដែលមានការចូលរួមយ៉ាងខ្លាំងក្លា។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏គ្មានវិធានការណាមួយត្រូវបានប្រកាន់យក ដើម្បីធានាអោយគំរោងទាំងអស់ដែលត្រូវបានធ្វើ ក្នុងដំណើរការនៃការចូលរួមនេះ គឺជាគំរោងដែលនឹងមានឥទ្ធិពលខ្លាំងបំផុតដល់ការកាត់បន្ថយភាពក្រីក្រឡើយ។ ក្នុងករណីជាច្រើន ការជ្រើសរើសគំរោង និងដំណើរការនៃការផ្តល់អាទិភាពគំរោង តែងតែផ្អែកលើនីតិវិធីនៃការបោះឆ្នោតមួយចំនួន ដែលមានភាពមិនច្បាស់លាស់ ទាំងនៅថ្នាក់ភូមិ និងគណៈកម្មាធិការធ្វើផែនការនិងគ្រោងថវិកា។ ជំនួយដែលផ្តល់ជូនដោយក្រុមគាំទ្រផ្នែកបច្ចេកទេស មានទំហំស្តួចស្តើង ដែលនាំអោយមានបញ្ហាលំបាកដល់លទ្ធភាពអនុវត្តន៍ផ្នែកបច្ចេកទេស ដើម្បីដំណើរការគំរោងដែលបានជ្រើសរើស ហើយទីបញ្ចប់ គឺឥទ្ធិពលនិងផលប៉ះពាល់នៃជំនួយនោះ ឬការកាត់បន្ថយភាពក្រីក្រនៅក្នុងឃុំ/សង្កាត់ ។

តំរូវការពីឃុំ/សង្កាត់ គួរបញ្ចូលទៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីជាពតិមានផ្អែកគោលនយោបាយ និងការបែងចែកធនធាន

គេនៅតែធ្វើផែនការថ្នាក់ខេត្តរបស់បណ្តាក្រសួងដោយគ្មានការពិភាក្សាជាមុន និងគ្មានការសំរបសំរួលជាមួយឃុំ/សង្កាត់ទេ។ ដូច្នេះផែនការរបស់ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ខេត្ត ត្រូវលើកបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក សំរាប់អោយឃុំ/សង្កាត់ពិចារណា។ ប្រការនេះចោទជាបញ្ហាចំពោះសារៈសំខាន់ នៃដំណើរការធ្វើផែនការដោយមានការចូលរួម។ គោលការណ៍ " ទទួលយក ឬ បោះបង់ចោល " នៅតែឃើញមានអនុវត្តជាទូទៅ ហើយគេហាក់ដូចជាមើលឃើញថា តំណាងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ខេត្ត មិនបានបញ្ចូលស្មារតីវិមជ្ឈការ ទៅក្នុងឥរិយាបថរបស់ខ្លួនឡើយ ។

មានការផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការធ្វើផែនការមូលដ្ឋាន តែទិដ្ឋភាពផ្សេងៗទៀតក្នុងវិមជ្ឈការ ដូចជាវិមជ្ឈការសារពើពន្ធ និង ការរកចំណូលនៅមូលដ្ឋាន មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ :

ការធ្វើផែនការមូលដ្ឋាន និងដំណើរការនៃការចូលរួម គឺជាមូលដ្ឋានគ្រឹះនៃវិមជ្ឈការ។ តែទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់មូលនិធិគ្រប់គ្រាន់ដល់មូលដ្ឋាន សំរាប់អនុវត្តគំរោង ក៏ទាមទារអោយមានការធានាផងដែរ ដើម្បីធ្វើអោយមាននិរន្តរភាពផលប្រយោជន៍ និងមានជំនឿជឿជាក់ក្នុងកិច្ចដំណើរការ។ ប្រសិនបើគ្មានមូលនិធិគ្រប់គ្រាន់ទេ វិមជ្ឈការអាចប្រែ ទៅជាក្តីសុបិន្តមួយដែលគ្មានបានការ ហើយប្រជាជននៅក្នុងឃុំ/សង្កាត់ នឹងបាត់បង់ការចាប់អារម្មណ៍ ឬមួយប្រឆាំងនឹងវិមជ្ឈការ ប្រសិនបើគ្មានលទ្ធផលជាក់ស្តែងទេនោះ ។

គួរមានតម្លាភាព ទាំងនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត និងទាំងក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ :

ទន្ទឹមនឹងមានគោលការណែនាំពីការគ្រប់គ្រងហិរញ្ញវត្ថុ នៅក្នុងឃុំ/សង្កាត់ ប្រព័ន្ធ និងការទទួលខុសត្រូវក្នុងការធ្វើសវនកម្ម មិនទាន់ត្រូវបានរៀបចំឡើងនៅឡើយ។ ក្នុងករណីខ្លះ ដែលមានការធ្វើសវនកម្ម ប៉ុន្តែរបាយការណ៍សវនកម្មមិនត្រូវបានផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធទេ ។

មេឃុំ/ចៅសង្កាត់ នៅតែបន្តជាអ្នកសំរេចចិត្តផ្តាច់មុខ។ ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តផ្តាច់ការ តាមបែបប្រពៃណី នៅតែបន្តកើតមាន បើទោះបីជាមានការជំរុញអោយមាន ដំណើរការនៃការចូលរួមក៏ដោយ។ ក្នុងករណីជាច្រើន សេចក្តីសំរេចចិត្តត្រូវបានធ្វើឡើងដោយមេឃុំ/ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយគ្មានការចូលរួមពីអ្នកដែលទទួលរងផលប៉ះពាល់ឡើយ។

(iii) អនុសាសន៍

ចំពោះរាជរដ្ឋាភិបាល :

- គួរផ្តល់ជំនួយបច្ចេកទេសបន្ថែមទៀត ដល់ដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ដើម្បីផ្តល់ជំរើសផ្សេងៗ ដែលអាចមានលទ្ធភាពដំណើរការបានតាមបច្ចេកទេស និងឆ្លើយតបទៅនឹងតំរូវការដែលបានកំណត់ ។
- សហការជាមួយដៃគូដើម្បីកសាងឡើងនូវប្រព័ន្ធទាំងឡាយ សំដៅវាយតំលៃពីផលប៉ះពាល់នៃវិមជ្ឈការ លើការកាត់បន្ថយភាពក្រីក្រ ។
- ធានាអោយមានភាពស៊ីសង្វាក់គ្នា រវាងកំរិតនីមួយៗនៃការធ្វើផែនការ (ឃុំ/សង្កាត់ ស្រុក/ខ័ណ្ឌ ខេត្ត/ក្រុង និងថ្នាក់ជាតិ) ដោយកំណត់ប្រព័ន្ធមួយ ដើម្បីធ្វើអោយផែនការឃុំ/សង្កាត់ មានភាពស៊ីសង្វាក់ជាមួយក្របខ័ណ្ឌនៃផែនការថ្នាក់លើ ។

- បន្តកសាងសមត្ថភាព មិនត្រឹមតែនៅលើការធ្វើផែនការអភិវឌ្ឍន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅលើផ្នែកផ្សេងៗទៀត ដែលប៉ះពាល់ដល់អភិបាលកិច្ច ដូចជាតម្លាភាព និងការទទួលខុសត្រូវសាធារណៈ ។
- ដាក់ចេញបទប្បញ្ញត្តិទាំងឡាយដើម្បីធានាអោយមានតម្លាភាព ក្នុងការបើកផ្តល់ និងប្រើប្រាស់មូលនិធិឃុំ/សង្កាត់។ គួរកំណត់អោយមានយន្តការសំរាប់ធ្វើសវនកម្មចំពោះមូលនិធិ ឃុំ/សង្កាត់។ កម្មវិធីប្រឆាំងអំពើពុករលួយមួយ ដែលរួមមានការអប់រំ ការបង្ការ និង ការកាត់ទោស គួរដាក់ចេញយ៉ាងហោចណាស់នៅថ្នាក់មូលដ្ឋាន ប្រសិនបើ មិនបាននៅគ្រប់កំរិតរបស់រដ្ឋាភិបាល ។
- វិមជ្ឈការមិនត្រឹមតែផ្តោតលើផែនការមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតលើទិដ្ឋភាពផ្សេងៗទៀតនៃ អភិបាលកិច្ច ដូចជាការលើកំពស់ និងការបញ្ជ្រាបទស្សនទានផ្សេងៗ ដូចជាតម្លាភាព ការទទួលខុសត្រូវសាធារណៈ វិមជ្ឈការសារពើពន្ធ និងការកសាងសមត្ថភាពនៅក្នុងវិស័យទាំងនេះ ។

ចំពោះម្ចាស់ជំនួយ :

- ឯកភាពលើក្របខ័ណ្ឌរួមមួយ សំរាប់ទស្សនវិស័យរយៈពេលវែងនៃវិមជ្ឈការនៅកម្ពុជា ។
- បន្តទ្រទ្រង់វិមជ្ឈការ និងការផ្តួចផ្តើមគំនិតអភិបាលកិច្ចថ្នាក់មូលដ្ឋាន ដោយរដ្ឋាភិបាល និង ដោយអង្គការក្រៅ រដ្ឋាភិបាល ។
- តាមដានមើលថាតើមូលនិធិជំនួយទាំងនេះចំណាយលើអ្វីខ្លះ និងបង្កើតយន្តការជាមួយរដ្ឋាភិបាល ដើម្បីធានា អោយមានតម្លាភាពហិរញ្ញវត្ថុ ។
- ផ្តល់ការប្រឹក្សាលើគោលនយោបាយចំពោះរដ្ឋាភិបាល និងរៃយ៉ាងណាអោយរដ្ឋាភិបាលយកគំនិតទាំងនោះ ទៅពិចារណា ។

ចំពោះអង្គការក្រៅរដ្ឋាភិបាល

- បន្តធ្វើអោយប្រសើរឡើងចំពោះការចូលរួមពីប្រជាពលរដ្ឋ នៅក្នុងដំណើរការអភិបាលកិច្ចថ្នាក់មូលដ្ឋាន តាមរយៈ ការលើកំពស់ការយល់ដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវ នៅក្នុងប្រព័ន្ធថ្មីនៃអភិបាលកិច្ចនៅមូលដ្ឋាន ។
- បន្តជំរុញភាពជាដៃគូរវាងសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ/សង្កាត់ មិនត្រឹមតែនៅក្នុងការអនុវត្តន៍គំរោងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ/សង្កាត់ អង្គការបំរើការងារនៅតាមសហគមន៍ និងភាគី ពាក់ព័ន្ធផ្សេងៗទៀត អំពីអភិបាលកិច្ចមូលដ្ឋានផងដែរ។

- អនុវត្តកម្មវិធីនានាដែលនឹងបញ្ជ្រាបទស្សនាទានដល់ប្រជាពលរដ្ឋថា មន្ត្រីឃុំ/សង្កាត់ទទួលខុសត្រូវចំពោះប្រជាពលរដ្ឋផងដែរ។ ដាក់ចេញនូវយុទ្ធវិធី ឬកម្មវិធីដែលមានលក្ខណៈឆ្នៃប្រឌិត ដែលសំរួលដល់ការតាមដានរបស់ប្រជាពលរដ្ឋ លទ្ធផលអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការផ្តល់មតិយោបល់ត្រលប់មកវិញ និងក្នុងការលើកកំពស់ការពិភាក្សារបស់សង្គមស៊ីវិល ជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បី កំណត់ពីតំរូវការនៃការកែទំរង់នៅក្នុងឃុំ/សង្កាត់។
- ចៀសវាងការបង្កើតឡើងរចនាសម្ព័ន្ធជាន់គ្នា នៅក្នុងឃុំ/សង្កាត់ ដែលអាចធ្វើអោយខូចខាតដល់លទ្ធផលអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ។

ចំពោះពត៌មានបន្ថែម និងបញ្ហាដែលលើកឡើងនៅក្នុងរបាយការណ៍នេះ សូមទំនាក់ទំនងជាមួយ : The Commune Council Support Project, Tel: 023 427197, Email: ccsp.pl@online.com.kh ccsp@online.com.kh

ពិការភាព និងការស្តារលទ្ធភាពពលកម្ម

ឯកសារនេះមានគោលបំណងបង្ហាញពីសេចក្តីត្រូវការជាអាទិភាពនាពេលអនាគតរបស់ផ្នែកពិការភាព និងការស្តារលទ្ធភាពពលកម្មដើម្បីទាក់ទាញការផ្តោតអារម្មណ៍របស់អ្នកផ្តល់ជំនួយ និងរាជរដ្ឋាភិបាលក្នុងការបង្កើនប្រសិទ្ធិភាពអនុវត្តយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ។

(i) សេចក្តីផ្តើម:

កម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសនានាដែលនាំមុខក្នុងការចុះហត្ថលេខានិងការទទួលស្គាល់វិធានការអន្តរជាតិនានា ដែលទាក់ទងដល់ការការពារសិទ្ធិ និងការចូលរួមដ៏ពេញលេញរបស់ជនពិការ។ ក្នុងនោះរួមមានកម្មវិធីនៃសកម្មភាពសកលលោកផ្តោតលើជនពិការ វិធានស្តង់ដារបស់អង្គការសហប្រជាជាតិ ស្តីពីឱកាសស្មើភាពសំរាប់ជនពិការនៃទស្សវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ១៩៩៣-២០០២ របស់គណៈកម្មាធិការសេដ្ឋកិច្ចសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក របស់អង្គការសហប្រជាជាតិ (UNESCAP) និងគោលការណ៍សហសវត្សរ៍បីវ៉ាកូសំរាប់សកម្មភាពឆ្ពោះទៅរកការបញ្ចូលជនពិការទៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ២០០៣-២០១២។

ដើម្បីប្រឈមទៅនឹងបញ្ហានៃការអភិវឌ្ឍន៍សង្គម គប្បីផ្តោតអាទិភាពលើការកាត់បន្ថយភាពក្រីក្រ រួមជាមួយគាំទ្រកំណើនសេដ្ឋកិច្ច និងអភិបាលកិច្ចល្អផ្តោតលើពលរដ្ឋក្រីក្រ។ ការកាត់បន្ថយភាពក្រីក្រ និងការធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវិតសំរាប់ប្រជាជនទាំងអស់ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិកបានក្លាយជាគោលដៅចំបងរបស់ធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ី។ជនពិការជាជនក្រីក្របំផុតក្នុងចំណោមជនក្រីក្រក្នុងប្រទេសកម្ពុជា ជាពិសេសស្រ្តីពិការ និងកុមារពិការ។ ពួកគេជាជនងាយរងគ្រោះបំផុត ដែលទាមទារការផ្តោតការយកចិត្តទុកដាក់ជាពិសេស ព្រោះក៏រិតជីវភាពរស់នៅរបស់គេស្ថិតនៅឆ្ងាយក្រោមបន្ទាត់នៃភាពក្រីក្រ ហើយសមត្ថភាពក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចអាចមានកំហិតដោយសារពិការភាព។

ការវិនិយោគនៅក្នុងកម្មវិធីពាក់ព័ន្ធជាមួយក្រុមជនពិការ និងស្តារលទ្ធភាពពលកម្ម ពឹងផ្អែកលើប្រភពធនធានខាងក្រៅ ទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស។ នៅពេលដែលប្រទេសកម្ពុជា បានបោះជំហានចូលក្នុងដំណាក់កាលអភិវឌ្ឍន៍ តំរូវអោយមានសេចក្តីត្រូវការច្រើនបន្ថែមទៀត ក្នុងការសំរបសំរួល ជាពិសេសរវាងរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការសហប្រជាជាតិ និងអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី លៃយ៉ាងណាអោយមានការវិនិយោគបន្ត។

និន្នាការនៃការកាត់បន្ថយជំនួយពីអ្នកផ្តល់ជំនួយក្នុងការជួយធានានិរន្តរភាព និងរក្សាសេវាកម្មជាមូលដ្ឋានដែលមានស្រាប់ អាចជាបន្ទុកដ៏ធ្ងន់ធ្ងរសំរាប់រដ្ឋាភិបាល ដែលមានកង្វះខាតធនធាន។

(ii) បញ្ហាជាគន្លឹះ

ក្នុងឆ្នាំ២០០១ មានមជ្ឈមណ្ឌលស្តារលទ្ធភាពកាយសម្បទាទាំងអស់ចំនួន ១៦។ ប៉ុន្តែ មកដល់ឆ្នាំ២០០៣ មានមជ្ឈមណ្ឌលតែ ១២ ប៉ុណ្ណោះ ដែលដំណើរការ ដោយសារមានកង្វះខាតក្នុងការផ្តល់មូលនិធិ។ អ្នកផ្តល់ជំនួយមួយចំនួនបានផ្លាស់ប្តូរអាទិភាព ហើយអ្នកផ្តល់ជំនួយផ្សេងទៀតចង់ឃើញការរួមវិភាគទាន ការគាំទ្រ និងភាពជាម្ចាស់របស់រដ្ឋាភិបាល។ ការនេះបង្ហាញនូវជំរើសដ៏លំបាក ថាតើនៅពេលដែលរដ្ឋាភិបាល បង្កើនការចូលរួម តើពិតជាអាចទាក់ទាញអ្នកផ្តល់ជំនួយនានាឱ្យបង្កើនជំនួយឬយ៉ាងណា។ក្រុមអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់សេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទាបានខិតខំទាក់ទាញរដ្ឋាភិបាលអោយផ្តោតអារម្មណ៍ទៅលើបញ្ហាធ្ងន់ធ្ងរអំពីអនាគតនៃសេវា តាមរយៈការស្នើសុំអោយរដ្ឋាភិបាលរៀបចំផែនការរយៈពេលវែង ចែករំលែកធនធានហិរញ្ញវត្ថុ និងកែសំរួលគោលនយោបាយក្នុងការមិនយកថ្លៃសេវាកម្ម។ ការបារម្ភណ៍និងការ ប្តេជ្ញារបស់រដ្ឋាភិបាល ត្រូវបានទទួលស្គាល់ ប៉ុន្តែសកម្មភាពជាក់ស្តែងមិនទាន់ធានាបានទាំងស្រុងនៅឡើយទេ។

នាពេលបច្ចុប្បន្ននេះ គេមិនអាចជឿទុកចិត្តចំពោះទិន្នន័យស្តីពីពិការភាពបាននៅឡើយ។ តួលេខផ្លូវការរបស់រដ្ឋាភិបាលបង្ហាញថា ជនពិការមានពី ២ ទៅ ២,៥% នៃចំនួនប្រជាជនសរុប។ តួលេខនេះហាក់បីដូចជាទាបណាស់ បើធៀបទៅនឹងប្រទេសអភិវឌ្ឍន៍មួយចំនួន ដែលមានជនពិការពី ១០ ទៅ ២០% ឬច្រើនជាងនេះ។ គួរអោយសោកស្តាយ ពុំទាន់មាននិយមន័យរួមជាផ្លូវការណាមួយស្តីពីពិការភាពនៅឡើយទេ។ ទោះជាមានភ្នាក់ងារ និងអង្គការនានាជាច្រើនបានធ្វើអង្កេតមួយចំនួនក្តី ក៏មានការទទួលស្គាល់ថា ទិន្នន័យអំពីសេដ្ឋកិច្ចសង្គម និងប្រជាសាស្ត្រទាក់ទងនឹងពិការភាព គ្មានភាពស៊ីសង្វាក់គ្នា និងជាទិន្នន័យមិនត្រឹមត្រូវ ។ លើសពីនេះទៅទៀត ការពែងចែកប្រភេទ និងលក្ខណៈនៃពិការភាពមានលក្ខណៈខុសៗគ្នា ពីស្ថាប័នមួយទៅស្ថាប័នមួយមានការ លំបាកក្នុងការប្រៀបធៀបផ្ទៀងផ្ទាត់ វិភាគ និងការបកស្រាយពតិមាន ដែលជាទូទៅខ្វះលក្ខណៈជាប្រព័ន្ធ ហើយដកស្រង់ពីប្រភពផ្សេងៗគ្នា។ ស្ថានភាពជនពិការមិនទាន់ដោះស្រាយបានទាំងស្រុងនៅឡើយ ដោយសារមានកង្វះប្រភពពតិមានមានលក្ខណៈប្រមូលផ្តុំ កង្វះលក្ខណៈជារចនាសម្ព័ន្ធ និងមិនអាចទទួលពតិមានបាន ទាក់ទងនឹងចំនួនជនពិការ ព្រមទាំងសេវាកម្មដែលបានផ្តល់។

នេះជាឧបសគ្គចំបងចំពោះការសំរេចចិត្តដែលមានប្រសិទ្ធិភាពនិងភាពសនិទានភាព ជាឧបសគ្គចំពោះការសកសាងផែនការយុទ្ធសាស្ត្រ ជាឧបសគ្គចំពោះការតាមដាន និងវាយតម្លៃអំពីអន្តរាគមន៍ ដើម្បីដោះស្រាយស្ថានភាព ក៏ដូចជាការបែងចែកធនធាន និងសេវាកម្ម ។

ជនពិការកម្ពុជាបានទទួលផលតិចតួចពីទស្សនាទានអំពីភាពស្មើៗគ្នានៃដំណោះស្រាយ នៅពេលដែលមានឧបសគ្គផ្នែកបរិស្ថាន ដែលរារាំងមិនអោយជនពិការធ្វើសមាហរណកម្មក្នុងសង្គមបាន ។ ដោយធុញទ្រាន់នឹងបែបបទនៃសុខមាលភាពសង្គម ជនពិការកម្ពុជាបានចាប់ផ្តើមទាមទារសិទ្ធិ ជំនួសអោយអភ័យឯកសិទ្ធិ ក្នុងការចូលរួមដោយស្មើភាពដូចជនទូទៅក្នុងសង្គម ។

បច្ចុប្បន្ននេះកម្ពុជាពុំមានច្បាប់ដោយឡែកស្តីពីពិការភាពទេ ប៉ុន្តែបញ្ហាពិការភាពត្រូវបានលើកឡើងក្នុងច្បាប់ និងបទប្បញ្ញត្តិមួយចំនួន ។ សេចក្តីព្រាងច្បាប់ស្តីពីពិការភាពត្រូវបានរៀបរៀង ។ ច្បាប់នេះមាន ៧០ មាត្រា មានបំណងជំរុញការធ្វើសមាហរណកម្មជនពិការ ទៅក្នុងចរន្តសកម្មភាពអភិវឌ្ឍន៍នានា ដើម្បីធានាការការពារ និងជំរុញសិទ្ធិដល់ជនពិការព្រមទាំងហាមឃាត់ការរំលោភ និងការមិនអើពើ និងការរើសអើងចំពោះជនពិការ ។

សេចក្តីព្រាងច្បាប់ចុងក្រោយ(ជាភាសាខ្មែរ និងភាសាអង់គ្លេស) បានផ្តួចផ្តើមឡើងដោយអង្គការជនពិការកម្ពុជាត្រូវបានពិនិត្យ និងកែសំរួលដោយក្រុមការងារច្បាប់ ដោយមានការផ្តល់មតិពីអ្នកជំនាញការច្បាប់ជាតិ និងមន្ត្រីជាន់ខ្ពស់នៃក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ កាលពីដើមឆ្នាំ២០០២ សិក្ខាសាលាមួយត្រូវបានរៀបចំឡើង ដើម្បី ទទួលយកមតិយោបល់ និងទស្សនៈផ្សេងៗពីភាគីពាក់ព័ន្ធ និងពីជនពិការ ដើម្បីកែលំអខ្លឹមសារ នៃសេចក្តីព្រាងច្បាប់ ។ ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានបង្កើតក្រុមអ្នកជំនាញដើម្បីរៀបចំឯកសារសំរាប់បញ្ជូនសេចក្តីព្រាងច្បាប់ទៅទីស្តីការគណៈរដ្ឋមន្ត្រី ។ ច្បាប់ស្តីពីពិការភាពនឹងជួយកម្ពុជាអោយទទួលបាននូវកិត្តិយស និងកិត្តិនាមលើឆាកអន្តរជាតិ ជួយរដ្ឋាភិបាលក្នុងការអនុវត្តន៏គោលនយោបាយ ក៏ដូចជាផ្តល់ប្រយោជន៏និងផ្តល់ឱកាសចំពោះជនពិការក្នុងការចូលរួមអភិវឌ្ឍន៏ជាតិ ដើម្បីលើកកំពស់សុខុមាលភាពសំរាប់ពួកគេ សំរាប់គ្រួសារ សំរាប់សហគមន៍ និងសង្គម ។

នាយករដ្ឋមន្ត្រី និងអ្នកនយោបាយ ជានិច្ចកាលបានបង្ហាញការគាំទ្រយ៉ាងពេញលេញ ក្នុងការជំរុញការអនុម័ត និងការអនុវត្តន៏ន៏ច្បាប់នេះ ។ ដោយមានការបោះឆ្នោតក្នុងឆ្នាំ២០០៣ សេចក្តីព្រាងច្បាប់នេះរំពឹងថា នឹងដាក់បញ្ជូនសំរាប់ពិភាក្សាក្នុងឆ្នាំ២០០៤ ។ ជនពិការរំពឹង និងចង់ឃើញការអនុម័ត ព្រមទាំងការអនុវត្តន៏ច្បាប់ក្នុងអាណត្តិក្រោយរបស់រាជរដ្ឋាភិបាល ។

(iii) អនុសាសន៍:

ផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម សូមលើកឡើងនូវអនុសាសន៍ដូចខាងក្រោម:

- ចាំបាច់ត្រូវមានកិច្ចសហការពហុវិស័យ និងការប្រឹងប្រែងសហប្រតិបត្តិការគ្នា លៃយ៉ាងណាអោយមានសមាហរណកម្មពេញលេញនៃក្រុមជនពិការ ។ ស្ថាប័នសំរបសំរួលជាតិ គប្បីត្រូវជំរុញជាបន្ត និងគាំទ្រតទៅទៀតពីសំណាក់រដ្ឋាភិបាល និងពីម្ចាស់ជំនួយ ។ ប្រការនេះលើកឡើងពីកង្វះខាតនៃការរប់រំ ការបណ្តុះបណ្តាលជំនាញ ដីធ្លី និងឥណទាន ដែលទំនងជាបញ្ជាក់ថា មានសភាពធ្ងន់ធ្ងរនៅសហគមន៍ ។ ដូចនេះ ការបញ្ជ្រាបក្រុមជនពិការចូលទៅក្នុងកម្មវិធី និងសេវាដែលមានស្រាប់ គឺមានន័យថាមានការទទួលស្គាល់ កន្លែងធ្វើការជាធម្មតារបស់ក្រុមជនពិការ ធ្វើជាផ្នែកមួយដ៏សំខាន់នៅក្នុងសង្គម ។

អនុសាសន៍សំរាប់រាជរដ្ឋាភិបាល:

- បញ្ចូលសេចក្តីត្រូវការរបស់ជនពិការ ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ
- បង្កើតនូវផែនការរយៈពេលវែងស្តីពីផ្នែកពិការភាព ជាពិសេសលើផ្នែកស្តារលទ្ធភាពពលកម្មកាយសម្បទា រៀបចំនូវការផ្ទេរ និងប្រគល់ដើម្បីនិរន្តរភាពនៃសេវាកម្ម ។
- ផ្តល់ធនធានមនុស្ស និងហិរញ្ញវត្ថុ សំរាប់វិស័យពិការភាព និងធានាអោយមានការផ្តល់ថវិកាជាក់ស្តែង ។
- ធ្វើសកម្មភាពឆ្ពោះទៅរកការអនុវត្តន៍សំដៅក្របខ័ណ្ឌគោលដៅសហសវត្សប៊ីវ៉ាកូ ដើម្បីជំរុញការចូលរួមនៃជនពិការក្នុងគ្រប់សកម្មភាពសង្គម និងក្នុងដំណើរការអភិវឌ្ឍន៍ផ្សេងៗ ។
- ធ្វើការយ៉ាងជិតស្និទ្ធិជាមួយស្ថាប័នសំរបសំរួលថ្នាក់ជាតិ (ក្រុមប្រឹក្សាសកម្មភាពជនពិការ) និងក្រសួងផែនការ/វិទ្យាស្ថានជាតិស្ថិតិក្នុងការប្រមូលទិន្នន័យ ស្តីពីពិការភាព ការវិភាគនិងការបែងចែក ដោយមានការពិភាក្សាយ៉ាងជិតស្និទ្ធិជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធអង្គការជនពិការ និងភាគីពាក់ព័ន្ធនានា ។
- ទទួចអោយពិចារណាសេចក្តីត្រូវការរបស់ជនពិការ ធ្វើជាផ្នែកសំខាន់នៃផែនការកម្មវិធី និង គំរោងរួម ដោយមិនគិតថាជាបញ្ហាដាច់ដោយឡែក ។
- ធានាអោយមានការអនុវត្តន៍គោលនយោបាយពាក់ព័ន្ធជនពិការ និងមានការត្រួតពិនិត្យប្រាកដប្រជា ហើយគួរតែបង្កើតគោលនយោបាយថ្មីៗបន្ថែមទៀត ។

- ជំរុញនិងបង្កើនល្បឿនក្នុងការអនុម័តច្បាប់ស្តីពីពិការភាពដែលជាផ្នែកនៃការប្រឹងប្រែងក្នុងការពង្រឹង និងការការពារសិទ្ធិ និងការពារផលប្រយោជន៍របស់ជនពិការ ហើយនិងធានាអោយមានការចូលរួមពេញលេញ និងដោយស្មើភាពក្នុងគ្រប់សកម្មភាពសង្គមដូចពលរដ្ឋទូទៅ ។

អនុសាសន៍សំរាប់អ្នកផ្តល់ជំនួយៈ

- ពិនិត្យគោលនយោបាយស្តីពីពិការភាព លៃយ៉ាងណាអោយគោលនយោបាយនោះត្រូវបានអនុវត្តជាក់ស្តែង ។ ប្រសិនបើពុំទាន់មានគោលនយោបាយស្តីពីពិការភាពទេ គួរពិនិត្យបង្កើតថ្មី ។
- ប្តេជ្ញានិងសន្យាបន្តផ្តល់មូលនិធិបន្ថែមនិងមានរយៈពេលវែងដល់វិស័យពិការភាព ធ្វើយ៉ាងណាបង្កើតអោយមានផែនការពេញលេញសំរាប់ការអភិវឌ្ឍនិងអនុវត្តផ្នែកសេវាកម្មដោយរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលក្នុងកិច្ចសហការ និងសហប្រតិបត្តិការ ។
- ជំរុញអោយពិចារណាសេចក្តីត្រូវការរបស់ជនពិការ ធ្វើជាផ្នែកមួយចាំបាច់ក្នុងគ្រប់កម្មវិធី និងគំរោងផែនការ ដោយមិនគិតថាជាបញ្ហាដាច់ដោយឡែក ។
- ជំរុញអោយមានការបំពេញគោលដៅសហសវត្សប៊ីវ៉ាកូ ក្នុងការប្រមូល និងការប្រើប្រាស់ទិន្នន័យជនពិការ ។
- ជួយជំរុញលើកទឹកចិត្តឱ្យមានការអនុមត័និងផ្សព្វផ្សាយខ្លឹមសារច្បាប់ស្តីពីពិការភាពនៅប្រទេសកម្ពុជា ។

អនុសាសន៍សំរាប់អង្គការក្រៅរដ្ឋាភិបាលៈ

- ជំរុញអោយពិចារណាសេចក្តីត្រូវការរបស់ជនពិការ ធ្វើជាផ្នែកមួយចាំបាច់ក្នុងគ្រប់កម្មវិធី និងគំរោងផែនការ ដោយមិនគិតថាជាបញ្ហាដាច់ដោយឡែក ។
- ធ្វើការជិតស្និទ្ធិជាមួយស្ថាប័នសំរបសំរួលដែលមានស្រាប់ (ក្រុមប្រឹក្សាសកម្មភាពជនពិការ) និង ក្រសួងផែនការ/វិទ្យាស្ថានជាតិស្ថិតិ ជួយនិងចូលរួម ក្នុងការប្រមូលពតិមានរដ្ឋបាល និងទិន្នន័យជនពិការ ។
- ប្តេជ្ញា និងចំណាយពេលវេលា ព្រមទាំងធនធានសំរាប់ប្រាស្រ័យទាក់ទង និងផ្លាស់ប្តូរពតិមានតាមរយៈស្ថាប័នសំរបសំរួលថ្នាក់ជាតិ ក្នុងការបំពេញគោលដៅសហសវត្សប៊ីវ៉ាកូ ដើម្បីជៀសវាងការត្រួតជាន់គ្នា និងការខ្វះខ្វាយធនធាននិងខ្វះខ្វាយពេលវេលា ។
- ជួយផ្សព្វផ្សាយខ្លឹមសារច្បាប់ស្តីពីពិការភាព និងគោលនយោបាយក្នុងការបង្កើនសិទ្ធិ និងការចូលរួមដោយស្មើភាពនិងដោយពេញលេញរបស់ជនពិការក្នុងសកម្មភាពអភិវឌ្ឍន៍ ។

ចំពោះពត៌មានបន្ថែមទាក់ទិននឹងបញ្ហានានាដែលលើកនៅក្នុងអត្ថបទនេះ, សូមមេត្តាទាក់ទងអង្គការ Disability Action Council លេខទូរសព្ទ័ (៨៥៥) ២៣ ២១៨ ៧៩៧ និង អ៊ីម៉ែលៈ dac@dac.org.kh.

ការងារគ្រប់គ្រងគ្រោះមហន្តរាយ

(i) សេចក្តីផ្តើម

ប្រទេសកម្ពុជារងភាពខ្ទេចខ្ទាំដោយសារគ្រោះទឹកជំនន់ និងរាំងស្ងួតក្នុងរយៈពេល ៣ ឆ្នាំកន្លងមក ។ ជាការពិតណាស់ ទឹកជំនន់ដែលមាននៅឆ្នាំ ២000 បានសំលាប់ប្រជាជនអស់ ៣៤៧ នាក់ ហើយជាង ៣,៥ លាន នាក់ទៀតទទួលរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់នេះ[5] ។ គិតត្រឹមឆ្នាំ ២០០២ គណៈកម្មការជាតិគ្រប់គ្រង គ្រោះមហន្តរាយថ្នាក់ (NCDM) បានរាយការណ៍ឱ្យដឹងថា ការខូចខាតសរុបដោយសារគ្រោះធម្មជាតិនានា មានទឹកប្រាក់ ចំនួន ៣៣ លានដុល្លារអាមេរិក[6] ។ ផលប៉ះពាល់នៃគ្រោះធម្មជាតិ (ទឹកជំនន់ និងរាំងស្ងួត)គឺជាផលប៉ះពាល់ដ៏ធ្ងន់ធ្ងរមួយ ទាក់ទងនឹងភាពងាយរងគ្រោះរបស់គ្រួសារក្រីក្រ។ ទឹកជំនន់បណ្តាលឱ្យបាត់បង់ផ្ទះសំបែង និងសមត្ថភាពផលិតទាប ចំពោះផលិតកម្មដំណាំស្រូវ និងការបន្តពូជរបស់មច្ឆជាតិ។ ប្រការនេះធ្វើឱ្យមានវដ្តនៃការជំពាក់បំណុល និងភាពក្រីក្រ។ ស្រូវ និងត្រីគឺជាអាហារប្រចាំថ្ងៃ ដែលមានសារៈសំខាន់ជាងគេរបស់ប្រទេសកម្ពុជា ។ ចំណុចនេះបានបញ្ជាក់ច្បាស់ណាស់ថាក្រុមងាយរងគ្រោះបំផុតដែលទទួលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ និងរងផលប៉ះពាល់ពីភាពរាំងស្ងួត នៅតែមានភាពងាយរងគ្រោះលើបញ្ហាភាពក្រីក្រ និងអសុវត្ថិភាពស្បៀងដដែល។

ទឹកជំនន់ទន្លេមេគង្គគឺជាព្រឹត្តិការណ៍មួយដែលកើតមានជារឿយៗ។ រាជរដ្ឋាភិបាលកម្ពុជា ចាត់ការងារគ្រប់គ្រងគ្រោះមហន្តរាយជាអាទិភាព ដោយតំរូវអោយមានការធ្វើអន្តរាគមន៍ដ៏សំខាន់ៗសំរាប់កាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា។ការធ្វើអន្តរាគមន៍ដែលកាន់តែមានប្រសិទ្ធភាព នឹងបង្កើននិរន្តភាពផ្នែកបរិស្ថាន ព្រមទាំងលើកកំពស់ការគ្រប់គ្រងធនធាន និងនាំមកនូវការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជាដែលកំពុងរស់នៅក្រោមតំបន់ទំនាបលិចទឹក។ ហេតុដូច្នេះ គប្បីធ្វើអន្តរាគមន៍លើការងារគ្រប់គ្រងគ្រោះមហន្តរាយផ្សេងៗ[7] ។ ក្រៅពីគ្រោះមហន្តរាយធម្មជាតិ គ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស ក៏មានឥទ្ធិពលគួរឱ្យកត់សំគាល់ទៅលើសហគមន៍ងាយរងគ្រោះទាំងនោះដែរ។

---

[5] (NRPS, ឆ្នាំ ២០០២)

[6] (ECHO,ឆ្នាំ ២០០៣) ការវាយតំលៃរួមគ្នារវាង CARE, NCDM និង WFP ឆ្នាំ ២០០២ ភ្នំពេញ ECHO និង CARE កម្ពុជា ខែ មេសា ឆ្នាំ ២០០៣

[7] ECHO (២០០៣) ibid

ចំណុចខ្លាំង

សារាចរលេខ ០១ និង០២ ស.រ របស់សម្តេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ត្រួស១ពីការខិតខំប្រឹងប្រែងមួយ ក្នុងការបង្ការគ្រោះមហន្តរាយតាមរយៈអាជ្ញាធរពាក់ព័ន្ធ ដូចជា ក្រសួងស្ថាប័ននានា គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM) គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (DCDM) និងក្រុមគ្រប់គ្រងការងារគ្រោះមហន្តរាយឃុំ ។ រចនាសម្ព័ន្ធនេះជួយគណៈកម្មការនានាដែលមានស្រាប់នៅថ្នាក់ភូមិ និងឃុំ ក្នុងការអនុវត្តន៏សកម្មភាពការងារគ្រប់គ្រងគ្រោះមហន្តរាយ ។

ការផ្តល់មូលនិធិដែលទទួលបានពីអង្គការអន្តរជាតិ (IO) សំរាប់ការបណ្តុះបណ្តាលទៅលើការងារត្រៀមបង្ការនិងកាត់បន្ថយគ្រោះមហន្តរាយ មាននៅគ្រប់ថ្នាក់ទាំងអស់ចាប់ពីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងរហូតដល់ថ្នាក់ឃុំ។ ដោយមានការឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី NCDM បានបង្កើតភាពជាដៃគូមួយជាមួយអង្គការអន្តរជាតិធំ១ ដើម្បីក្លាយទៅជាសមាជិកមួយរបស់មជ្ឈមណ្ឌលកាត់បន្ថយ និងកសាងផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងសហគមន៏អាស៊ាន[8] ។

គំរោងនៃការទទួលខុសត្រូវខ្ពស់ផ្នែកមនុស្សធម៌ (HAP) បានធ្វើការប៉ាន់ប្រមាណនានាផ្នែកមនុស្សធម៌ជាមួយអង្គការនានាដែលធ្វើការផ្នែកការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា។ អនុសាសន៏នានាតាមរយៈការរកឃើញទាំងនេះ បាននាំទៅរកការបង្កើតឡើងនូវបណ្តាញនៃការទទួលខុសត្រូវខ្ពស់ផ្នែកមនុស្សធម៌នៅកម្ពុជា “HANet”។ របកគំហើញទាំងនោះ កំពុងត្រូវបានគេដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាល និង កម្មវិធីផែនការសកម្មភាពមួយ។

NGO កាន់តែមានតួនាទីចូលរួមកាន់តែធំឡើងក្នុងការកាត់បន្ថយភាពក្រីក្រ[9] ។ អង្គការ NGO ជាច្រើនកំពុងដាក់បញ្ចូលនូវគំនិតផ្តួចផ្តើមនេះសំរាប់ការត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយទៅក្នុងគំរោងរបស់ខ្លួន និងក្នុងកម្មវិធីជាយុទ្ធសាស្ត្រ ក៏ដូចជាដាក់បញ្ចូលការងារនេះទៅក្នុងថ្នាក់ភូមិ-ឃុំផងដែរ។

ADB និង WB បានបង្កើតគំរោងគ្រប់គ្រងគ្រោះទឹកជំនន់ជាបន្ទាន់ និងបង្កើតគំរោងស្តារប្រព័ន្ធធារាសាស្ត្រឡើងវិញ ដែលជាការគាំទ្រដល់សហគមន៏ទាំងឡាយដែលងាយរងគ្រោះពីឥទ្ធិពលនៃទឹកជំនន់។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធីសាស្ត្រផ្តួចផ្តើមមួយស្តីពីការអនុវត្តន៏យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះទឹកជំនន់រយៈពេលវែងមួយ បន្ថែមលើការបែងចែកស្បៀងអាហារ និងផ្តល់ទីជំរកស្នាក់នៅពេលមានគ្រោះអាសន្នបន្ទាន់។

---

[8] សេចក្តីប្រកាសរបស់ NCDM ស្តីពីស្ថានភាពគ្រោះមហន្តរាយឆ្នាំ ២០០៣ ត្រីមាសទី៣

[9] (ឯកសារ AusAID អំពី "គោលការណ៏នៃការអនុវត្តន៏ល្អ" របស់ NGO នៅកម្ពុជា ២០០៣)

ឱកាស

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាប្រធាន NCDM ។ ចំណុចនេះនឹងលើកស្ទួយកិច្ចសហប្រតិបត្តិការល្អ រវាងអង្គការ អន្តរជាតិ និងស្ថាប័នជាតិរបស់រដ្ឋាភិបាល ។ ការសហការនេះអាចជួយនៅក្នុងដំណើរការនៃការកែទំរង់ច្បាប់ និងទាក់ទាញ ការផ្តល់មូលនិធិចំពោះ NCDM/ស្ថាប័នរដ្ឋាភិបាល អង្គការអន្តរជាតិ/ជាតិ ។

បណ្តាប្រទេសដែលនៅតាមអាងទន្លេមេគង្គ និងក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) នឹងបង្កើត យុទ្ធសាស្ត្រគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់រយៈពេលវែងដ៏ទូលំទូលាយមួយ ។ MOWRAM នឹងធ្វើការ ប៉ាន់ស្មាន ឥទ្ធិពលដែលអាចកើតមានអំពីការប្រែប្រួលផ្នែកបរិយាកាស ។ MOWRAM នឹងធ្វើការប៉ាន់ប្រមាណមួយ ពីគ្រោះទឹក ជំនន់របស់សហគមន៍នានា ព្រមទាំងវាយតំលៃពីទ្រព្យសម្បត្តិទាំងឡាយដែលអាចខូចខាត និងអាចបាត់បង់ អំពីតំលៃ ខូចខាតជាក់ស្តែង ដែលបង្កដោយគ្រោះទឹកជំនន់ ។

កម្មវិធីកសាងសមត្ថភាពនៅក្នុងក្របខ័ណ្ឌ NCDM និង MOWRAM ព្រមទាំងនៅតាមស្ថាប័នពាក់ព័ន្ធផ្សេងៗ ទៀត នឹងជួយដល់ការធ្វើអន្តរាគមន៍ដ៏ត្រឹមត្រូវនៅកម្ពុជា ។

ធម្មនុញ្ញស្តីពីមនុស្សធម៌ និងកំរិតស្តង់ដាអប្បរមារបស់គំរោងស្វ៊ែរ (sphere) ដាក់បញ្ចូលនូវចំណងទាក់ទងរវាង ច្បាប់ដែលមានស្រាប់ ហើយតើចំណងទាក់ទងទាំងនេះត្រូវបានគេប្រែក្លាយយ៉ាងដូចម្តេចនៅក្នុងកំរិត នៃជំនួយសំភារៈ ជាក់លាក់ចំពោះប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះមហន្តរាយ ។ស្តង់ដារទាំងនេះក៏តំណាងឱ្យការពិនិត្យសារឡើងវិញ ក្នុងទ្រង់ទ្រាយធំនៃការអនុវត្តន៍ល្អ ដើម្បីធានាអោយមានគុណភាពនៃជំនួយមនុស្សធម៌នៅកម្ពុជាមានជាប្រចាំ ។

ក្រុមប្រឹក្សានៃគណៈកម្មការជាតិទន្លេមេគង្គ (MRC) បានអនុម័តនូវកម្មវិធីគ្រប់គ្រងគ្រោះទឹកជំនន់រយៈ ពេល ៥ ឆ្នាំ ដើម្បីបង្ការ និង ធ្វើឱ្យថយចុះជាអប្បរមា និងកាត់បន្ថយនូវការខាតបង់របស់ប្រជាជន ដោយសារគ្រោះទឹកជំនន់ ក្នុងខណៈរក្សាការពារផលប្រយោជន៍ពីការលិចលង់ ។ កម្មវិធីនេះលើកឡើងនូវការជូនដំណឹង ឬផ្តល់ពត៌មានជាមុន ធ្វើជាអាទិភាពមួយក្នុងចំណោមអាទិភាពនានាដែលសំខាន់បំផុត ។

ចំណុចខ្សោយ

នៅថ្នាក់ជាតិ សមត្ថភាពទាបក្នុងចំណោមបុគ្គលិក និងធនធានមានតិចតួចនឹងជះឥទ្ធិពលទៅលើការអនុវត្តន៍ កម្មវិធីនេះនៅថ្នាក់សហគមន៍ ។ ចាំបាច់ត្រូវពិចារណាអំពីសមត្ថភាពនៃគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅ ថ្នាក់ស្រុក និងថ្នាក់ឃុំ ។ គេសង្កេតឃើញថាគ្មានវត្តមាននៃគណៈកម្មការទទួលមតិត្រលប់ ឬគណៈកម្មការនេះច្រើនតែ

អប្រសិទ្ធភាព។ ចាំបាច់ត្រូវអភិវឌ្ឍបន្តទៀតនូវសមត្ថភាពរបស់អ្នកទាំងឡាយណា ក្នុងការកំណត់អត្តសញ្ញាណ ការអនុវត្តន៍ និងតាមដានអំពីទំរង់ សមស្របនៃការបញ្ចៀសគ្រោះមហន្តរាយ និងមានវិធានការត្រៀមបង្ការ។

គេសង្កេតឃើញថាផែនការយុទ្ធសាស្ត្ររយៈពេលវែងដែលមិនច្បាស់លាស់ ចំពោះការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់ NCDM មាននៅគ្រប់ថ្នាក់។ ដោយសារខ្វះធនធាន នាំឱ្យមានអវត្តមានផែនការទប់ទល់សំរាប់ការងារត្រៀមបង្ការ និងបញ្ចៀសគ្រោះមហន្តរាយ។ មុខងារសំរបសំរួលរបស់ NCDM ច្រើនតែអប្រសិទ្ធភាព ហើយតំរូវអោយមានការកែលំអ។

គំរោងច្រើនតែផ្តោតលើការផ្តល់ជំនួយសង្គ្រោះជាជាងការធ្វើសមាហរណកម្មនៃកិច្ចអភិវឌ្ឍន៍ និងជំនួយសង្គ្រោះ។

ចាំបាច់ត្រូវមានការពង្រឹងបណ្តាញមួយដែលមានការទទួលខុសត្រូវ និងមានតម្លាភាពនៅគ្រប់លំដាប់ថ្នាក់ទាំងអស់។ ប៉ុន្តែកិច្ចការនេះមានលក្ខណៈដូចនេះ ជាពិសេសនៅថ្នាក់ស្រុក ព្រោះថារបកគំហើញកាលពីពេលថ្មីៗពីការស្រាវជ្រាវរបស់ HAP បានគូសបញ្ជាក់នូវបញ្ហាមួយចំនួនដែលត្រូវបានលើកឡើងនៅថ្នាក់សហគមន៍ នោះគឺបក្សពួកនិយមតាមបន្ទាត់របស់គណៈបក្ស ហើយគ្មានគណៈកម្មការភូមិសំរាប់ផ្តល់ចំណេះដឹង ស្តីពីការងារត្រៀមបង្ការគ្រោះមហន្តរាយដល់សហគមន៍ ដែលនាំទៅរកការយល់ដឹងដែលមានកំរិតទាប លើបញ្ហាទាំងនេះនៅក្នុងចំណោមប្រជាជនក្នុងភូមិ។

(ii) បញ្ហាសំខាន់ៗ

កង្វះពតិមាន និងកង្វះការផ្សព្វផ្សាយពីគ្រោះធម្មជាតិ។ ប្រព័ន្ធប្រកាសអាសន្ន ឬព្រមានជាមុននៅមានកំរិតនៅឡើយ ដោយសារតួនាទី និងការទទួលខុសត្រូវរបស់រចនាសម្ព័ន្ធដែលមានស្រាប់ ស្តីពីដំណើរការនៃការឆ្លើយតបនឹងគ្រោះមហន្តរាយពុំមានលក្ខណៈច្បាស់លាស់នៅឡើយ។ ជាមួយគ្នានេះដែរ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនៅមានកំរិត ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ។

ឥទ្ធិពលគ្រោះទឹកជំនន់នៅតែជាបញ្ហាធ្ងន់ធ្ងរ។នៅតាមសហគមន៍ងាយរងគ្រោះ គេពុំឃើញមានមូលនិធិបំរុងទុកសំរាប់ផែនការសកម្មភាពពេលមានគ្រោះមហន្តរាយ ដែលគ្រោះទឹកជំនន់នេះបណ្តាលឱ្យមានជំងឺលើរាងកាយ ការបាត់បង់សន្តិធិម្ហូបអាហារ ជំងឺ/របួស (កង្វះអាហារូបត្ថម្ភចំពោះស្ត្រី និងកុមារ) ការផ្លាស់ប្តូរសង្គម អស្ថេរភាពផ្នែកហិរញ្ញវត្ថុ (ការថែរក្សាសុខភាព ទីជំរក ការដឹកជញ្ជូន ការកសាងឡើងវិញ និងតំរូវការសំរាប់ការដាំដុះ)។

ក្នុងពេលដែលមានទីភ្នាក់ងារអន្តរជាតិនានា និងការកើនឡើងនូវចំនួនអង្គការ NGO កម្ពុជាក្នុងស្រុក ដែលកំពុងធ្វើការឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រនោះ មានការយកចិត្តទុកដាក់មិនបានគ្រប់គ្រាន់ទៅលើគុណភាព ការទទួលខុសត្រូវ តំរូវការក្នុងការសរសេររបាយការណ៍/ការតាមដាន ដោយសារពួកគេច្រើនតែផ្តោតទៅលើការបង្កើតសកម្មភាពរបស់កម្មវិធី ។

ស្ត្រីនៅជនបទក្នុងប្រទេសកម្ពុជាដែលជាមេគ្រួសារ ច្រើនតែជាស្ត្រីមេម៉ាយ និងមានការទួលខុសត្រូវចំពោះបន្ទុកការងារផ្ទះសំបែង។ អាស្រ័យហេតុនេះ មានក្តីកង្វល់អំពីការធ្វើឱ្យមានប្រាក់ចំណូល ក្នុងចំណោមក្រុមងាយរងគ្រោះនានានៅក្នុងសហគមន៍[១០] ។

លោកស្រី NP គឺជាស្ត្រីម្នាក់ដែលរស់នៅក្នុងខេត្តព្រៃវែង។ គាត់បាននិយាយថា "ដោយសារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងភូមិរបស់ខ្ញុំៗលែងមានស្រូវ/អង្ករគ្រប់គ្រាន់សំរាប់បំពេញសេចក្តីត្រូវការរបស់គ្រួសារខ្ញុំបានតទៅទៀត ។ខ្ញុំអាចលក់កំលាំងក្របី គោ និងដីរបស់ខ្ញុំដើម្បីយកលុយចាក ចេញ ពីភូមិស្រុក" ឯកសារយោង: DIPECHO, ២០០២

លោកស្រី SP គឺជាស្ត្រីមេម៉ាយម្នាក់ ហើយមានកូនចំនួន ៦ នាក់។ គាត់និយាយថានៅឆ្នាំ ២000 និង ២00១ គ្រួសាររបស់គាត់ពុំអាចដាំស្រូវបានទេដោយសារទឹកជំនន់ ហើយរនាបឫស្សីផ្ទះរបស់គាត់ត្រូវលិចទឹក។ មានការលំបាកណាស់ក្នុងការចិញ្ចឹមសត្វ ឬរកម្ហូបអាហារ ហើយអង្ករក៏ឡើងថ្លៃទៀត។ នៅឆ្នាំ ២000 គាត់បានលក់គោមួយ ដើម្បីទិញអង្ករ និងដោះដូរស្បៀងអាហារ។ គាត់ពុំអាចខ្ចីលុយពីទីផ្សារដូចអ្នកភូមិឯទៀតបានទេ ពីព្រោះគាត់គ្មានលុយសំរាប់សងបំណុលគេ។ គាត់បាននិយាយថា "ខ្ញុំ និង កូនៗរបស់ខ្ញុំបាននិងកំពុងត្រដររស់ ក្នុងស្ថានភាពដ៏លំបាកទាំងនេះ"។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ដោយសារការដាំដុះមានភាពល្អប្រសើរជាងមុន ដូច្នេះគាត់ និងកូនៗរបស់គាត់អាចជួយធ្វើការងារគេបាន។ ឯកសារយោង: DIPECHO, ២០០២

[10] (WFP, 2000:5)

(iii) អនុសាសន៍

រាល់ការអភិវឌ្ឍន៍ និង/ឬគំនិតផ្តួចផ្តើមក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយជោគជ័យណាមួយ ធ្វើឱ្យមានការកើនឡើងនូវទ្រព្យសម្បត្តិរបស់គ្រួសារ និងផលិតភាពផ្នែកកសិកម្មតាមរយៈការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងការសង្កត់ធ្ងន់ទៅលើផ្នែកផ្សេងៗនៃការចិញ្ចឹមជីវិតច្រើនបែបដូចជាការគ្រប់គ្រងធនធានធម្មជាតិ និងលទ្ធភាពទទួលឥណទាន។

ចំពោះរាជរដ្ឋាភិបាលៈ

- ជំរុញលើកទឹកចិត្តដល់ស្ថាប័នរដ្ឋាភិបាលទាំងអស់ឱ្យចូលរួមក្នុងការងារត្រៀមបង្ការ និងការបញ្ជៀសគ្រោះមហន្តរាយនៅថ្នាក់មូលដ្ឋាន។
- NCDM ត្រូវដើរតួនាទីក្នុងការសំរបសំរួលដ៏មានប្រសិទ្ធភាព ក្នុងការពង្រឹងកិច្ចសហការរវាងស្ថាប័នដែលធ្វើការងារគ្រប់គ្រងគ្រោះមហន្តរាយនៅតាមមូលដ្ឋានទាំងអស់ និងជាមួយក្រសួងនានា ដើម្បីអនុវត្តផែនការសកម្មភាព ដែលបានឯកភាព។
- គេទទួលស្គាល់ថា NCDM គួរត្រូវបានបំពាក់បំប៉នជំនាញសំរបសំរួលការងារ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែយកចិត្តទុកដាក់លើការដាក់ឱ្យមានអ្នកជំនាញគ្រប់គ្រងទៅក្នុងស្ថាប័ន NCDM ក្នុងគោលបំណងបង្កើតឱ្យស្ថាប័ននេះមានសមត្ថភាពឆ្លើយតបប្រកបដោយប្រសិទ្ធភាព និង សកម្ម។ ត្រូវបង្កើតអោយមានជំនាញគ្រប់គ្រងក្នុងការចរចារ ការគ្រប់គ្រងកិច្ចប្រជុំដើម្បីបង្កើតផែនការសកម្មភាពឯកភាព សំរបសំរួលក្រុមដែលមានលក្ខណៈខុសៗគ្នា ធ្វើការនៅតំបន់ផ្សេងៗគ្នា។ ចាំបាច់ត្រូវមាន ការយល់អំពីដំណើរការទទួល ខុសត្រូវ ដែលត្រូវធ្វើតាមរយៈទីភ្នាក់ងារឆ្លើយតបនឹងគ្រោះអាសន្នបន្ទាន់។
- ការប្តេជ្ញាចិត្តមួយក្នុងការទទួលខុសត្រូវ និងមានតម្លាភាពក្នុងចំណោមស្ថាប័នរដ្ឋាភិបាលនានា។

ចំពោះម្ចាស់ជំនួយៈ

- ផ្តល់មូលនិធិដើម្បីគាំទ្រកម្មវិធីការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជាតាមរយៈការបណ្តុះបណ្តាល និងពង្រឹងផែនការសកម្មភាពចំពោះការត្រៀមបង្ការគ្រោះមហន្តរាយ នៅថ្នាក់ភូមិនិងឃុំដែលអាចទទួលរងគ្រោះពីផលប៉ះពាល់នៃគ្រោះទឹកជំនន់។

ចំពោះ NGOs:

- គាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង និងអាជ្ញាធរតាមមូលដ្ឋានគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងការបង្កើតយុទ្ធសាស្ត្រច្បាស់លាស់មួយសំរាប់ការងារត្រៀមបង្ការគ្រោះមហន្តរាយ ជំនួយសង្គ្រោះបន្ទាន់ ការបញ្ចៀសគ្រោះមហន្តរាយ និងធ្វើការស្តារឡើងវិញ ក្រោមការសំរបសំរួលពី NCDM ។
- បង្កើតផែនការទប់ទល់សំរាប់ត្រៀមបង្ការ និងឆ្លើយតបចំពោះការបញ្ចៀសគ្រោះមហន្តរាយ និង ធ្វើសមាហរណកម្មកម្មវិធីនេះទៅក្នុងយុទ្ធសាស្ត្រកម្មវិធីរយៈពេលវែង ។

ចំពោះពត៌មានបន្ថែមទាក់ទិននឹងបញ្ហានានាដែលលើកនៅក្នុងអត្ថបទនេះសូមមេត្តាទាក់ទងអង្គការ The Humanitarian Accountability Network in Cambodia:

1. ហួត ខៀវ, CARE, Tel: 023 215 267/8/9, Email: khieu@care-cambodia.org
2. គៀន វឌ្ឍនៈ កាកបាទក្រហមកម្ពុជា, Tel: 023 212 878, Email: vaddanakkien@yahoo.com
3. មុត សាណា, World Vision International, Tel: 023 216 052, Email: sana_mot@wvi.org
4. និប លី, Urban Sector Group, Tel: 023 360 568, Email: admin.usg@forum.org.kh
5. ភឿក សុក, Oxfam GB, Tel: 023 720 036, Email: psok@oxfam.org.kh
6. សារ៉ុន សំអុល, NAS, Tel: 012 579 048, Email: 012897103@mobitel.com.kh
7. តាន់ ប៊ុនឡេង, CONCERN, Tel: 023 214 879, Email: bunleng@concerncambodia.net

វិស័យអប់រំ

ក្នុងបទឧទ្ទេសនាមនៅក្នុងវេទិកាអប់រំកាលពីខែ ឧសភា ឆ្នាំ ២០០៣ ឯកឧត្តម តុល ឡោះ បានលើកឡើងពីចក្ខុវិស័យ យ៉ាងច្បាស់លាស់ដូចខាងក្រោមៈ

នៅឆ្នាំ ១៩៩៤ នៅពេលដែលខ្ញុំគិតទៅដល់អ្វី ដែលខ្ញុំមើលឃើញថាជាអាទិភាពចំបងៗនៃការកែទំរង់ ខ្ញុំយល់ថា បញ្ហាជាមូលដ្ឋានជាច្រើនសំរាប់កំណែទំរង់វិស័យអប់រំអោយមានប្រសិទ្ធភាពនោះ មិនទាន់ចាប់ផ្តើមនៅឡើយទេ ។ ទីមួយ វានៅតែជាកត្តាសំខាន់នៅឡើយក្នុងការបន្តផ្តោតយកចិត្តទុកដាក់ ទៅលើកម្មវិធីនិងគោលនយោបាយជាអាទិភាពជាគន្លឹះមួយចំនួន ដែលជាចលករជំរុញអោយមានដំណើរការកែទំរង់ ។ ទីពីរ យើងត្រូវបន្តកំណត់នូវក្របខ័ណ្ឌច្បាស់លាស់មួយ ក្នុងការសំរបសំរួលធនធាននានាសំរាប់វិស័យអប់រំ ពីរដ្ឋាភិបាល និងពីដៃគូអ្នកផ្តល់ជំនួយទាំងឡាយ ។ ទីបី ដែលជាផ្នែកសំខាន់បំផុតនោះគឺ យើងត្រូវរក្សាអោយបាននូវវប្បធម៌នៃការផ្លាស់ប្តូរក្នុងប្រព័ន្ធអប់រំ តាមរយៈការផ្សព្វផ្សាយគោលដៅទាំងឡាយដល់អ្នកដែលពាក់ព័ន្ធទាំងអស់ ពិសេសគឺគ្រូបង្រៀន និងមាតាបិតាសិស្ស ។

អង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើការក្នុងវិស័យអប់រំ ទទួលស្គាល់នូវការរីកចំរើនដែលសំរេចបាន ក្នុងរយៈពេល ១០ ឆ្នាំកន្លងមក ហើយប្តេជ្ញាជួយគាំទ្រ និងសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា និង រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ។ គេបានកត់សំគាល់និងអះអាងនូវសមិទ្ធិផល ដូចខាងក្រោមៈ

- ការរៀបចំឡើងនូវឯកសារគោលនយោបាយ និង ដំណើរការធ្វើផែនការនានា ដូចជាយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ផែនការយុទ្ធសាស្រ្តអប់រំ (ESP) កម្មវិធីគាំទ្រវិស័យអប់រំ (ESSP) និង ការអប់រំសំរាប់ទាំងអស់គ្នា (EFA) ។
- ដំណើរការផែនការសកម្មភាពជាអាទិភាព (PAP) ក្នុងការកំណត់គោលដៅដែលត្រូវផ្សព្វផ្សាយ សំរាប់បើកមូលនិធិ ។ ទោះជាការអនុវត្តន៍កម្មវិធី PAP មិនទាន់បានល្អឥតខ្ចោះក៏ដោយ ក៏ប្រព័ន្ធនេះបានផ្តល់នូវធនធានកាន់តែច្រើនឡើង ដល់សាលារៀន និងស្ថាប័នទាំងឡាយ ។
- កិច្ចសហប្រតិបត្តិការរវាងក្រសួង ម្ចាស់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាលនានា មានភាពប្រសើរជាងមុន ។
- កិច្ចសហការរវាងក្រសួងអប់រំ យុវជន និង កីឡា និង អង្គការក្រៅរដ្ឋាភិបាលក្នុងការអនុវត្តន៍មូលនិធិរបស់ជប៉ុនសំរាប់កម្មវិធីកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់អាហារូបករណ៍សិស្សស្រី ។

- កំណើននៃការចុះឈ្មោះចូលរៀនក្នុងគ្រប់វិស័យ ។
- មានសាលារៀនមួយចំនួនត្រូវបានសាងសង់ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល និង កំណើនក្នុងការផ្តល់អណ្តូងទឹក បង្គន់អនាម័យ និងមធ្យោបាយសំរាប់កុមារជនពិការ ។
- សេចក្តីព្រាងសំណើសំរាប់ការរៀបចំកម្មវិធីសិក្សា ដែលសង្កត់ធ្ងន់ទៅលើរចនាសម្ព័ន្ធមួយរលូន ការប្រើធនធាន ប្រកបដោយប្រសិទ្ធភាព និង សមស្របទៅតាមស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន ។
- សេចក្តីព្រាងច្បាប់អប់រំដែលធានាបាននូវឋានៈស្ថាប័ន ស្វ័យយ័តភាព អភិបាលកិច្ចល្អ ការធានាគុណភាព និង ភាពជាដៃគូ ។
- ការកែលំអនិតិវិធីសន្តិសុខ ការរៀបចំ និងការដាក់ពិន្ទុការប្រឡងសិស្សថ្នាក់ទី ១២ ។
- កំណើនក្នុងការបញ្ចូលនិស្សិតដែលទើបបញ្ចប់ការសិក្សា និង ការជះឥទ្ធិពលរបស់ពួកគេទៅលើដំណើការនៃការ កែទំរង់នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។

បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និង កីឡា និង អង្គការក្រៅរដ្ឋាភិបាលមើលឃើញថា គ្រូបង្រៀន និង នាយក សាលា មានឆន្ទៈក្នុងការបង្កើតឡើងនូវគំនិតថ្មីៗ ប្រើប្រាស់ និងអភិវឌ្ឍនូវធនធានថ្មីៗ ហើយយកធនធានទាំង នោះទៅប្រើប្រាស់សំរាប់ការសិក្សាតាមបែបប្រាស្រ័យទាក់ទងគ្នា នៅពេលដែលពួកគេបានទទួលថវិកាដែលបានផ្តល់ជូន និងទទួលបានការណែនាំច្បាស់លាស់ និងជាទៀងទាត់ និងចំណាប់អារម្មណ៍នៅថ្នាក់មូលដ្ឋាន ។ កម្មវិធីនានាដូចជា កម្មវិធី កែលំអគុណភាពអប់រំនៅបឋមសិក្សា (EQIP) របស់ក្រសួងអប់រំ យុវជន និង កីឡា និង គំរោងសាលា កុមារមេត្រីនិងយេនឌ័រ (ដែលឧបត្ថម្ភដោយអង្គការ UNICEF/KAPE) បានបង្ហាញពីគំរូល្អសំរាប់ការគ្រប់គ្រងមាន ប្រសិទ្ធភាព និងមានការទទួលខុសត្រូវ ការចូលរួមយ៉ាងខ្លាំងការពីសហគមន៍ សមធមិផ្នែកយេនឌ័រ ការគ្រប់គ្រង ដោយជួយគាំទ្រការបណ្តុះបណ្តាល ការទំនាក់ទំនងកាន់តែប្រសើរ នាំអោយមានការកែលំអគុណភាពសាលារៀន និង បរិយាកាសថ្នាក់រៀនព្រមទាំងការរៀន និងបង្រៀនដែលមានគោលបំណងជាក់លាក់ ។

ការពិនិត្យមើលសារឡើងវិញនូវបញ្ហាសំខាន់ៗ ក្នុងសេចក្តីថ្លែងការណ៍ស្តីពីវិស័យអប់រំ នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ឆ្នាំ ២០០២

ទោះជាមានការទទួលស្គាល់ពីការរីកចំរើនកន្លងមកក៏ដោយ ក៏សហគមន៍អង្គការក្រៅរដ្ឋាភិបាល បានសំដែងនូវការព្រួយបារម្ភអំពីបញ្ហាជាគន្លឹះមួយចំនួនដែលនៅសេសសល់។ ជាទូទៅ បញ្ហាមួយចំនួនដែលបានលើកឡើងក្នុងឆ្នាំ ២០០១ និង ឆ្នាំ២០០២ បានបង្ហាញពីការរីកចំរើនបន្តិចបន្តួច ឬពុំទាន់បានលើកយកមកដោះស្រាយនៅឡើយ។

លទ្ធភាពប្រើប្រាស់សេវាអប់រំ និង ការដាក់បញ្ចូលនៅក្នុងការអប់រំ

តួលេខនៃការចុះឈ្មោះចូលរៀនឆ្នាំ ២០០៣ បង្ហាញអោយឃើញពីភាពប្រសើរឡើង បើប្រៀបធៀបទៅនឹងឆ្នាំ២០០១។ ក្នុងឆ្នាំសិក្សា ២០០២-២០០៣ សិស្សដែលមានអាយុចូលរៀននៅបឋមសិក្សាចំនួន ៨៩% (កើន៣%) និងសិស្សមធ្យមសិក្សា ១៩% (កើន២%) បានចុះឈ្មោះចូលរៀន [១១]។ ទោះជាយ៉ាងណាក៏ដោយ អត្រាត្រួតថ្នាក់ទី១ និង ថ្នាក់ទី២ នៅមានកំរិតខ្ពស់នៅឡើយ ហើយអត្រាបោះបង់ការសិក្សានិង អត្រាត្រួតថ្នាក់ទាំងនៅបឋមសិក្សា និង មធ្យមសិក្សា នៅតែជាការព្រួយបារម្ភនៅឡើយ។ ស្ថិតិនានាដែលពាក់ព័ន្ធ ដូចជាបំរែបំរួលចំនួនប្រជាជន និង តួលេខដែលបង្ហាញពីការសិក្សាបន្តរបស់សិស្ស ទាមទារអោយធ្វើបច្ចុប្បន្នភាព។

កុមារីនៅតែមានចំនួន ៤៧% នៃចំនួនសិស្សដែលចុះឈ្មោះចូលរៀនថ្នាក់ទី១។ តួលេខនេះធ្លាក់មកនៅត្រឹម ៤១% ចំពោះការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ និង ៣៣% សំរាប់វិទ្យាល័យ[១]។ មានការថយចុះយ៉ាងច្រើននៃការចូលរៀនរបស់កុមារី នៅថ្នាក់ទី៦ និង ថ្នាក់ទី៧។ នៅបឋមសិក្សា មានចំនួនពលរដ្ឋក្រីក្រ ៤០% ហើយចំនួននេះថយចុះមកត្រឹម ២២% នៅវិទ្យាល័យ និងតិចជាង ២០% នៅថ្នាក់ក្រោយវិទ្យាល័យ[២]។ ត្រូវមានការយកចិត្តទុកដាក់ទៅលើយុទ្ធសាស្ត្រសំដៅកែប្រែ លើតំរូវការនិងលើការផ្គត់ផ្គង់ ដើម្បីធានាអោយបាននូវការចូលរៀនដែលមានលក្ខណៈសមធម៌ ចំពោះក្រុមអ្នកដែលជួបការលំបាក ដូចជាស្ត្រី ជនពិការ និង ជនជាតិភាគតិច។

---

[11] EMIS- ស្ថិតិ និង សូចនាករវិស័យអប់រំ ឆ្នាំ ២០០២-២០០៣

[2] ការវាយតំលៃអំពីឃែនឌ័រនៃលទ្ធផលអនុវត្តន៍ ESSP ឆ្នាំ ២០០២-២០០៣ ខែ ឧសភា ឆ្នាំ ២០០៣

ហិរញ្ញវត្ថុ

ការសន្យាផ្តល់ថវិកាចរន្តចំនួន ១៨.២% នៅឆ្នាំ ២០០២ និងការសន្យាបង្កើនរហូតដល់ ២០% នៅឆ្នាំ ២០០៥ ត្រូវបានទទួលនូវការកោតសរសើរយ៉ាងក្រៃលែង។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រមូលប្រាក់ចំណូល និង ការផ្តល់ថវិកាយឺតយ៉ាវនិងមិនគ្រប់គ្រាន់ ធ្វើអោយប៉ះពាល់ដល់ការរីកចំរើននៃការកែទំរង់វិស័យអប់រំ។ រហូតមកដល់ពេលនេះ ថវិកា PAP តែ ៨០% ប៉ុណ្ណោះ ត្រូវបានបើកផ្តល់ ចំណែកឯថវិកាឆ្នាំ ២០០៣ វិញ ពុំទាន់បានបើកផ្តល់នៅឡើយមិនតែប៉ុណ្ណោះការផ្តល់ថវិកា PAP នឹងត្រូវបញ្ចប់នៅចុងខែ ធ្នូ ឆ្នាំ ២០០៣[៣]។ ការខកខានមិនបានអនុវត្តថវិកាដែលត្រូវបានអនុម័តដោយសភានោះ ធ្វើអោយកើតមានឡើងនូវចំងល់មួយចំនួនទាក់ទងទៅនឹងបញ្ហាតម្លាភាព និង ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ។ ទោះជាមានការអះអាងផ្ទុយពីនេះក៏ដោយ អង្គការក្រៅរដ្ឋាភិបាលបានទទួល ភស្តុតាងជាក់ស្តែងជាច្រើនពីមូលដ្ឋាន ដែលបញ្ជាក់ថា ការបង់ប្រាក់ក្រៅផ្លូវការទៅអោយសាលារៀន និងគ្រូបង្រៀននៅតែបន្តកើតមានដដែល ដែលជាហេតុធ្វើអោយគ្រួសារក្រីក្រ កាន់តែជួបប្រទះនូវការលំបាកដោយពួកគេពុំមាន ថវិកាសំរាប់បង់ថ្លៃសិក្សា ។

ការអប់រំក្រៅប្រព័ន្ធ និង ការបណ្តុះបណ្តាលជំនាញជីវិត

ការចុះឈ្មោះចូលរៀន និង ការទទួលបានជោគជ័យក្នុងផ្នែកអប់រំរបស់កុមារ ដែលជាកូនចៅពលរដ្ឋក្រីក្រីក្រនៅពេលបច្ចុប្បន្ននេះ មានន័យថាភាពក្រីក្រនឹងត្រូវបានចំឡងពីជំនាន់នេះ ទៅជំនាក់ក្រោយទៀត[៤] ។

បញ្ហាដែលនៅមាននោះគឺ ការសិក្សាតំរូវអោយមានភាគរយកុមារ និងយុវវ័យអោយបានច្រើននោះ ពុំទាន់បានឆ្លើយតបតាមរយៈការអប់រំក្នុងប្រព័ន្ធនៅឡើយ ហើយនេះជាបញ្ហាចោទមួយទាក់ទងទៅនឹងសមត្ថភាព របស់ប្រទេសកម្ពុជាក្នុងការប្រកួតប្រជែង នៅក្នុងទីផ្សារអន្តរជាតិ។

អត្រានៃភាពក្រីក្រមានកំរិតខ្ពស់នៅក្នុងគ្រួសារ ដែលមេគ្រួសារពុំបានទទួលការអប់រំក្នុងប្រព័ន្ធ ឬបានទទួលការអប់រំបន្តិចបន្តួចនៅបឋមសិក្សា។ នៅតាមជនបទ តំបន់ដែលក្រីក្របំផុតមានអត្រាចុះឈ្មោះចូលរៀនពិត នៅបឋមសិក្សាចំនួន ៥០% តួលេខនេះជាចំនួនទាបមែនទែនបើប្រៀបធៀបទៅនឹងតំបន់ ដែលប្រជាជនមានជីវភាព ធូរធារដែលអត្រាស្មើនឹង ៧៥%។ តិចជាង ៥% នៃកុមារអាយុពីអាយុ ១២-១៤ ឆ្នាំ ដែលរស់នៅក្នុងតំបន់ក្រីក្រតាម ទីជនបទបានចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ បើប្រៀបធៀបទៅនិងតំបន់ដែលប្រជាជនមានជីវភាពធូរធារ មានចំនួនស្មើនឹង

---

[3] កិច្ចប្រជុំរវាងក្រសួងអប់រំ យុវជន និង កីឡា ម្ចាស់ជំនួយ និង អង្គការគ្រៅរដ្ឋាភិបាល ឆ្នាំ ២០០៣

២៥%[៤] ។ កុមារដែលមកពីតំបន់ក្រីក្រ មានចំនួនតិចតួចណាស់ដែលបានរៀននៅកំរិតមធ្យមសិក្សាទុតិយភូមិ និងនៅកំរិតឧត្តមសិក្សា។

កង្វះខាតក្នុងការផ្តល់ការអប់រំក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតែបង្ករជាបញ្ហានៅឡើយ។ ការវិភាគទៅលើភាពក្រីក្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ ២០០៣ បង្ហាញថា :

"គោលនយោបាយវិស័យអប់រំបច្ចុប្បន្ន ផ្តោតការយកចិត្តទុកដាក់តិចតួច ទៅលើការអប់រំមូលដ្ឋាន និងថ្នាក់អក្ខរកម្មសំរាប់មនុស្សចាស់ (ABEL)។ ពតិមាន នេះគួរអោយភ្ញាក់ផ្អើលមែនទែន ដោយហេតុថា មនុស្សចាស់ភាគច្រើន (ពិសេសស្ត្រី) ដែលស្ថិតនៅក្នុងវ័យបំរើការងារ ហើយបានទទួលការអប់រំតិចតួច ឬពុំបានទទួលការអប់រំសោះ និងផលប៉ះពាល់សំខាន់ៗ នៃការកាត់បន្ថយភាពក្រីក្រ រយៈពេលខ្លីនិងរយៈពេលមធ្យមតាមរយៈ ABEL។ ការដែលគួរអោយភ្ញាក់ផ្អើលមួយទៀតគឺ មានតំរូវការជាបន្ទាន់ ទាក់ទងទៅនឹងការអប់រំមនុស្សចាស់ ក្នុងវិស័យជាសារវ័ន្តមួយចំនួនដូចជាផ្នែកសុខភាព ការយល់ដឹងពីយេនឌ័រ ការងារកសិកម្ម និងជំនាញផ្នែកសហគ្រិន"។

បញ្ហាជាគន្លឹះ និង អនុសាសន៍ឆ្នាំ ២០០៣

ខាងក្រោមនេះ ជាអាទិភាពមួយចំនួនដែលត្រូវបានកំណត់ដោយអង្គការក្រៅរដ្ឋាភិបាល ដែលកំពុងបំរើការងារក្នុងវិស័យអប់រំ:

១. អង្គការក្រៅរដ្ឋាភិបាលគាំទ្រយ៉ាងពេញទំហឹង ចំពោះយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលបានកំណត់ថាការជាប់គាំងផ្នែកកំណែទំរង់រដ្ឋបាលសាធារណៈ ជាចំណុចមួយសំខាន់ប៉ះពាល់ដល់សមត្ថភាព ក្នុងការសំរេចអោយបានជោគជ័យនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល។ អង្គការក្រៅរដ្ឋាភិបាល លើកឡើងដោយទទូចពីតំរូវការអោយរដ្ឋាភិបាលធ្វើវិភាជន៍ និងបែងចែកថវិកាអោយបានច្រើន ដើម្បីធានាអោយគ្រូបង្រៀន បានទទួលលាភការគ្រប់គ្រាន់សមរម្យទៅតាមការងារដែលគាត់បានបំពេញ និង ស្នើអោយមានការអនុវត្តន៍នូវការកែទំរង់វិស័យអប់រំដែលបានគ្រោងទុក។ អាទិភាពទាំងឡាយមិនបានគ្រោងទុក និង ដែលមានលក្ខណៈប្រជែងគ្នា នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាហេតុបណ្តាលអោយមានការបើកផ្តល់ថវិកាមិនទៀងទាត់ ទៅអោយក្រសួងអប់រំ យុវជន និង កីឡា។ លុះត្រាតែបញ្ហានេះ ត្រូវបានគេលើកយកមកដោះស្រាយ អោយបានត្រឹមត្រូវ ពុំនោះសោតវាមានការលំបាកក្នុងការផ្លាស់ប្តូរ ពីស្ថានភាពបច្ចុប្បន្នទៅរកការជួយឧបត្ថម្ភថវិកាដោយផ្ទាល់។

---

[4] យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥

អនុសាសន៍:

- ធ្វើយ៉ាងណាអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តោតទៅលើតួនាទីរបស់ខ្លួនក្នុងការធ្វើផែនការហិរញ្ញវត្ថុ ហើយក្រសួងអប់រំយុវជន និង កីឡា ទទួលការអនុញ្ញាតអោយទទួលខុសត្រូវ ក្នុងការគ្រប់គ្រងថវិកាផ្នែកអប់រំ ។
- ធ្វើយ៉ាងណាអោយមានតម្លាភាព ភាពអាចប៉ាន់ប្រមាណជាមុនបាន និង ការទទួលខុសត្រូវ ក្នុងការបែងចែក និងបើកផ្តល់ថវិកា ។ ប្រើប្រព័ន្ធ ធនាគារដែលបានរៀបចំឡើង ដើម្បីផ្ទេរប្រាក់ទៅមូលដ្ឋាន ។
- ធ្វើយ៉ាងណាអោយយន្តការ និង នីតិវិធីនៃការផ្តល់ថវិកា មានភាពច្បាស់លាស់ដើម្បីអោយគេអាចធ្វើការវិនិច្ឆ័យពីការអនុវត្តន៍ ធៀបទៅនិងសូចនាករគោល (benchmark) ។
- កែទំរង់ប្រព័ន្ធផ្តល់ថវិកា PAP ដើម្បីអោយមានដំណើរការឿនលឿនទៅមុខ ចៀសវាងការជួបប្រទះនូវការលំបាកដូចពេលកន្លងមក ។
- ព្រមព្រៀងបង្កើតនូវសន្ទានុក្រមសំរាប់វាក្យស័ព្ទគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីបំភ្លឺពីអត្ថន័យនៃពាក្យសំរាប់ប្រតិបត្តិមួយចំនួនដូចជា ថវិកា វិភាជន៍ ការសន្យាផ្តល់ថវិកា អាណត្តិ ការបើកផ្តល់ ការចំណាយ ការកំណត់ឆ្នាំហិរញ្ញកិច្ច ។ល ។
- ក្នុងរយៈពេលមធ្យម ភ្ជាប់ទំនាក់ទំនងប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន ទៅនឹងជីវភាពរស់នៅជាក់ស្តែង និងធ្វើយ៉ាងណាអោយមានផែនការច្បាស់លាស់ ដើម្បីតំលើងប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀន ដើម្បីអោយគេអាចចិញ្ចឹមជីវិតបាន ។ បង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្សប្រកបដោយលក្ខណៈសន្សំសំចៃ និងមានប្រសិទ្ធភាព ដើម្បីអោយបុគ្គលិកអប់រំ អាចទទួលបាននូវរង្វាន់ពីការបំពេញកាតព្វកិច្ចបន្ថែម និង ស្នាដៃណាមួយដែលមានប្រសិទ្ធភាព ។
- ដាក់ចេញនូវគោលការណ៍ច្បាស់លាស់ និង ថវិកាគ្រប់គ្រាន់សំរាប់ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព ការទ្រទ្រង់ក្នុងការតាមដាននិងត្រួតពិនិត្យ ដើម្បីធានាអោយសាលារៀន និងកំរងសាលារៀន អាចធ្វើផែនការកែលំអសាលារៀនប្រកបដោយប្រសិទ្ធភាព (ជាជាងការប្រញាប់ប្រញាល់ចំណាយថវិកា ដែលត្រូវបានទម្លាក់អោយយ៉ាងសន្ធឹកសន្ធាប់ នៅមុនពេលកំណត់ដែលត្រូវសរសេររបាយការណ៍)
- បន្តកែលំអប្រសិទ្ធភាព និងភាពសន្សំសំចៃក្នុងការចែកចាយសៀវភៅសិក្សា ដើម្បីធានាបំពេញគោលដៅដែលបានកំណត់នៅក្នុង ESSP ។

២. មានកង្វះខាតគ្រូបង្រៀនយ៉ាងធ្ងន់ធ្ងរ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល ដែលធ្វើអោយផលធៀប សិស្ស/គ្រូ កើនឡើងខ្ពស់នៅបឋមសិក្សា។ ឧទាហរណ៍: ៨០:១ នៅខេត្តសៀមរាប ៧៧:១ នៅខេត្តកោះកុង ៧៣:១ នៅក្រុងប៉ៃលិន និង ៦៩:១ នៅខេត្តកំពង់ស្ពឺ[5] ។ ថ្នាក់ដែលមានសិស្សច្រើននាក់ ធ្វើអោយប៉ះពាល់ដល់ការខិតខំប្រឹងប្រែងសំដៅកែលំអគុណភាព។ យុទ្ធសាស្ត្រនៃការពង្រាយគ្រូ ពុំបានប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពឡើយ ដោយមូលហេតុពុំមានប្រាក់ឧបត្ថម្ភគ្រប់គ្រាន់ សំរាប់លើកទឹកចិត្ត ខ្វះលំនៅដ្ឋាន ឬប្រាក់ឧបត្ថម្ភសំរាប់ជួលផ្ទះ នៅតំបន់ដែលត្រូវចំណាយច្រើន បញ្ហាវប្បធម៌ដែលទាក់ទងទៅនឹងពលរដ្ឋក្រីក្រ ដែលត្រូវរស់នៅឆ្ងាយពីគ្រួសារ និងដែលមិនអាចទទួលយកបានក្នុងការបើកប្រាក់ បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភ ដែលពន្យារពេលយូរ។

អនុសាសន៍:

- លៃយ៉ាងណាប្រើប្រាស់គ្រូជាប់កិច្ចសន្យាដែលរស់នៅមូលដ្ឋានអោយបានកាន់តែច្រើន ដោយផ្តល់ឱកាសអោយពួកគេ ទទួលបានការបណ្តុះបណ្តាល និងលើកកំពស់សមត្ថភាព ដើម្បីអោយពួកគេមានក្តីសង្ឃឹមក្នុងការចូលបំរើការងារជាគ្រូបង្រៀន និងបើកប្រាក់បៀវត្សរ៍និងប្រាក់ឧបត្ថម្ភអោយបានទាន់ពេលវេលា។
- បន្ទាបពិន្ទុដែលត្រូវអនុញ្ញាតអោយចូលរៀនវគ្គបណ្តុះបណ្តាលគរុកោសល្យ សំរាប់សិស្សនៅមូលដ្ឋាន នៅត្រឹមថ្នាក់ទី ៩ សំរាប់ស្រុកណាដែលគ្មានសាលាមធ្យមសិក្សាទុតិយភូមិ។

៣. អំពើពុករលួយនៅគ្រប់ជាន់ថ្នាក់ជាឧបសគ្គរារាំងដល់ដំណើរការកែទំរង់។ នៅពេលថ្មីៗនេះ មានគំរោងដែលផ្សព្វផ្សាយជាសាធារណៈនៅតំបន់មួយចំនួន តំរូវអោយមានការបង់ប្រាក់ដោយខុសច្បាប់ចំពោះការធ្វើអាជីវកម្មពីការពង្រាយ និង ការតំលើងឋានៈគ្រូបង្រៀន គឺជាកង្វល់ដ៏ធ្ងន់ធ្ងរ។ នៅមានភាពខុសគ្នា រវាងគោលនយោបាយជាតិដែលបានផ្សព្វផ្សាយ និងភាពជាក់ស្តែងដែលកើតមាននៅតាមសាលារៀន និងនៅតាមគ្រឹះស្ថានសិក្សានានា។ ភាពខុសគ្នានេះនាំអោយមានការបង់ប្រាក់ក្រៅផ្លូវការផ្សេងៗ ទៅដល់គ្រូបង្រៀន ការយកកំរៃទៅលើការបង្រៀនបន្ថែម តាមរយៈការគាបសង្កត់អោយសិស្សទៅរៀនក្រៅម៉ោង ការចំណាយប្រាក់ដើម្បីទទួលបានការងារធ្វើ ការបានកន្លែងរៀននៅសាកលវិទ្យាល័យ និងដើម្បីប្រឡងជាប់ជាដើម។ ការបង់ប្រាក់ក្រៅផ្លូវការទាំងនេះ ជះឥទ្ធិពលអាក្រក់ទៅដល់លទ្ធភាពទទួលការអប់រំរបស់សិស្ស ហើយជាពិសេសទៅទៀតនោះ វាជាការរើសអើង

[5] EMIS- ស្ថិតិ និង សូចនាករវិស័យអប់រំ ឆ្នាំ ២០០២-២០០៣

មួយចំពោះពលរដ្ឋក្រីក្រ ។ ការបង់ប្រាក់ក្រៅផ្លូវការនេះ ក៏ធ្វើអោយខូចផងដែរដល់ទំនាក់ទំនង រវាងបុគ្គលិកសិក្សា និងសហគមន៍ ដែលជាហេតុធ្វើអោយបុគ្គលិកសិក្សាដែលមានឆន្ទៈបំរើការងារក្នុងមនៈសិការវិជ្ជាជីវៈ និងជាអ្នកដែលមានសក្តានុពលបំផុតក្នុងការអនុវត្តន៍ការកែទំរង់នេះ គឺជាអ្នកដែលត្រូវលាចាកពីវិស័យអប់រំ ។ ការសំរេចបាននូវការកែលំអគុណភាពអប់រំ និងការលប់បំបាត់នូវការបង់ប្រាក់ក្រៅផ្លូវការ នេះពុំអាចធ្វើទៅបានឡើយ ប្រសិនបើប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនពុំមានលក្ខណៈប្រាកដនិយម ។

អនុសាសន៍:

- រៀបចំគ្រប់គ្រង និងប្រើប្រាស់ប្រាក់ចំណាយក្រៅផ្លូវការ ដើម្បីអោយការពង្រាយគ្រូបង្រៀនមានប្រសិទ្ធភាព និងមានតម្លាភាព ក្នុងការផ្តល់សេវាទៅអោយកុមារ ដែលជួបការលំបាក និងដើម្បីទូទាត់អោយគ្រូបង្រៀន ។
- ក្នុងរយៈពេលមធ្យម ពិនិត្យឡើងវិញពីគំរោងកែលំអប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន ដោយឈរលើទស្សនៈផ្តល់ប្រាក់បៀវត្សរ៍ជូនគ្រូបង្រៀន ក្នុងកំរិតមួយអាចទទួលយកបានសំរាប់រយៈពេលមធ្យម (សូមមើល ១ ខាងលើ) ។

៤. ការបង្កើតឡើងនូវ ESP, ESSP, EFA និង NPRS បានទទួលការលើកសរសើរនៅក្នុងផ្នែកទី១ នៃរបាយការណ៍នេះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅពេលបច្ចុប្បន្ននេះមានមានការបង្កើតឡើងនូវផែនការ គោលដៅ និងឯកសារនានាជាច្រើន ព្រមទាំងមានសកម្មភាពត្រួតពិនិត្យស្មុគស្មាញ សំរាប់តាមដានដំណើរការទាំងនេះ ដែលទំនងដូចជាគ្របដណ្តប់នូវគោលដៅដូចគ្នា ។ សកម្មភាពទាំងនេះ ទាមទារអោយមានការកំណត់អាទិភាពនៅក្នុងផែនការសកម្មភាពច្បាស់លាស់ និងមានភាពប្រាកដនិយម ។

អនុសាសន៍:

- ធ្វើអោយមានភាពចុះសំរុងគ្នា សមាហរណកម្ម និង កំណត់អាទិភាពផែនការផ្សេងៗ ហើយផ្តល់ថវិកាអោយបានគ្រប់គ្រាន់ (គឺសំរាប់ការចំណាយជាក់ស្តែង មិនមែនគ្រាន់តែជាវិភាជន៍ថវិកាប៉ុណ្ណោះទេ) ដើម្បីធានាអោយមានភាពស៊ីសង្វាក់គ្នា ក្នុងការកំណត់គោលដៅ និង ការអនុវត្តន៍យុទ្ធសាស្ត្រនិងអាទិភាពអប់រំ ។
- សំរបសំរួល និង ធ្វើសនិទានកម្មលើដំណើរការតាមដាន ។

៥. យើងបានលើកឡើងពីគំរូផ្សេងៗនៃការអនុវត្តន៍ល្អៗ នៅផ្នែកខាងដើមនៃរបាយការណ៍នេះ។ នៅមានភស្តុតាងមួយចំនួនទៀតដែលបង្ហាញថា អ្នកធ្វើការផ្នែកអប់រំមួយចំនួននៅថ្នាក់មូលដ្ឋាន កំពុងរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសាលារៀនដ៏មានប្រសិទ្ធភាព ហើយការបង្រៀន និងរៀនដែលមានគុណភាពកាន់តែប្រសើរឡើង។ គំនិតផ្តួចផ្តើមទាំងនេះ ពេលខ្លះត្រូវបានធ្វើអោយខូចខាតទៅវិញ ដោយខ្វះការយល់ដឹងបានគ្រប់គ្រាន់ ពីមន្ត្រីមួយចំនួននៅតាមផ្នែក នៅថ្នាក់ខេត្ត និងនៅថ្នាក់ជាតិ ស្តីពីនិតិវិធីទាំងឡាយដើម្បីកែលំអរសាលារៀន អោយទទួលបានជោគជ័យ។ ការជ្រើសរើសអ្នកកាន់តំណែងដែលធ្វើការសំរេចចិត្តនៅគ្រប់លំដាប់ថ្នាក់ គប្បីផ្អែកលើសមត្ថភាពបច្ចេកទេស ជាជាងការផ្អែកទៅលើអតីតភាពការងារ ឬការបន្តរក្សា ទុកនូវការអនុវត្តន៍តាមរបៀបកន្លងមក។

អនុសាសន៍:

- លៃយ៉ាងណាអោយមន្ត្រីនៅគ្រប់ជាន់ថ្នាក់បានយល់ដឹងពីគំនិតផ្តួចផ្តើមថ្មីៗ និង មើលឃើញពីការអនុវត្តន៍ល្អៗ ព្រមទាំងមានឆន្ទៈគាំទ្រប្រកបដោយគំនិតស្ថាបនា នូវយុទ្ធសាស្ត្រកែលំអរ នានាតាមរយៈការជំរុញលើកទឹកចិត្តជាវិជ្ជមាន។
- ជ្រើសរើសអ្នកបំរើការនៅតាមសាលារៀន តាមថ្នាក់រៀនដែលមានសមត្ថភាពល្អ ដើម្បីទទួលមុខតំណែងដែលអាចធ្វើការសំរេចចិត្តនានា នៅតាមសាលារៀន និង នៅក្នុងប្រព័ន្ធអប់រំទាំងមូល។

៦. យុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ បានលើកឡើងសារជាថ្មី នូវតំរូវការគុណភាពខ្ពស់ផ្នែកអប់រំនៅឧត្តមសិក្សា ដើម្បីកែលំអរទាំងផ្នែកសមត្ថភាពបង្រៀនដែលនៅមានភាពទន់ខ្សោយ ព្រមទាំងដើម្បីដឹកនាំដំណើរការអភិវឌ្ឍន៍នៅកម្ពុជា។ ការបង្កើនលទ្ធភាពនិងបង្កើនឱកាសសំរាប់សិស្ស អោយចូលទៅសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលកំពុងរីករាលដាល និងដែលខ្វះការគ្រប់គ្រងនោះ ពុំមែនជាដំណោះស្រាយឡើយ។ និស្សិត ឬមាតាបិតា របស់សិស្សចំណាយប្រាក់ដែលរកបានដោយលំបាក ដើម្បីបង់ថ្លៃសិក្សាដែលគេមិនទាន់ដឹងពីគុណភាព និងតំលៃច្បាស់លាស់នៅឡើយ ហើយវិទ្យាស្ថានអប់រំឧត្តមសិក្សារបស់រដ្ឋទាំងឡាយ នៅតែពុំទាន់បានទទួល នូវការឧបត្ថម្ភអោយបានគ្រប់គ្រាន់ពីរដ្ឋាភិបាលនៅឡើយ ហើយដែលតំរូវអោយវិទ្យាស្ថានទាំងនោះ ទទួលនិស្សិតចូលរៀន ដោយឥតបង់ថ្លៃចំនួន ៥០% ។

អនុសាសន៍ :

- បញ្ជាក់អោយបានច្បាស់លាស់ពីតួនាទីរបស់ក្រសួងអប់រំ យុវជន និង កីឡា ឬនាយកដ្ឋានអប់រំឧត្តមសិក្សា និងគណៈកម្មការវាយតំលៃគុណភាពអប់រំកម្ពុជាដែលទើបបានបង្កើតឡើង ពាក់ព័ន្ធនឹងព្រះរាជក្រឹត្យដែលចុះកាលបរិច្ឆេទ នៅក្នុងខែ មីនា ឆ្នាំ ២០០២ ។
- រាជរដ្ឋាភិបាល/ម្ចាស់ជំនួយ/អង្គការក្រៅរដ្ឋាភិបាល គប្បីធ្វើសហប្រតិបត្តិការដើម្បីដោះស្រាយ បញ្ហាគុណភាពជាគន្លឹះ និងបទប្បញ្ញត្តិនានា ព្រមទាំងបង្កើតឡើងនូវគោលនយោបាយរយៈពេលវែង អំពីកម្មវិធីអាហារូបករណ៍ ស្វយ័តភាពរបស់ស្ថាប័ន ប្រាក់បៀវត្សរ៍តាមកំរិតសមត្ថភាព ការសិក្សាស្រាវជ្រាវ ។ល ។

ក្នុងនាមអង្គក្រៅរដ្ឋាភិបាល ដែលធ្វើការក្នុងវិស័យអប់រំនៅប្រទេសកម្ពុជា យើងកំពុងធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា និង ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកយកអនុសាសន៍ទាំងនេះ មកដោះស្រាយ។ អនុសាសន៍ទាំងនេះត្រូវបានលើកឡើង ក្នុងស្មារតីនៃភាពជាដៃគូ និងដោយឆន្ទៈរបស់យើងទាំងអស់គ្នា សំដៅធ្វើការរួមគ្នាដើម្បីជាប្រយោជន៍ដល់កុមារកម្ពុជាទាំងអស់ ។

ចំពោះពត៌មានបន្ថែមទាក់ទងទៅនឹងបញ្ហាទាំងឡាយ ដែលបានលើកឡើងក្នុងរបាយការណ៍នេះ សូមទំនាក់ទំនងជាមួយ : **ដៃគូអប់រំអង្គការក្រៅរដ្ឋាភិបាល** (NEP)

តាមរយៈអ៊ីម៉ែល: NEP@online.com.kh

ទូរស័ព្ទលេខ : ០២៣ ៩៨៧ ១១៤

ក្រុមប្រឹក្សាភិបាល

Kila Riemer, projdev@icc.org.kh
Kou Boun Kheang, kheang@SCN.online.com.kh
Kurt Bredenberg, kape.cambodia@online.com.kh
Regina Pellicore, mkskhmer@online.com.kh
Richard Geeves, geeves@online.com.kh

EDUCAM
Dr.Luise Ahrens, mkskhmer@online.com.kh

កំណែទំរង់ការបោះឆ្នោត

(i) សេចក្តីផ្តើម

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអណត្តិទីបី ដែលបានប្រព្រឹត្តិទៅកាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៣ កន្លងទៅនេះ បានទទួលការកោតសរសើរពីសំណាក់អង្គការត្រួតពិនិត្យការបោះឆ្នោតជាតិនិងអន្តរជាតិ ចំពោះការការរៀបចំ និងការអនុវត្តន៏ដែលត្រូវបានកែលំអនៃដំណើរការបោះឆ្នោតនៅកម្ពុជា។ ដោយឡែក បញ្ហាអព្យាក្រិតភាព របស់ស្ថាប័ន៍រៀបចំការបោះឆ្នោត នៅតែទទួលការរិះគន់ដដែល។ យោងតាមសេចក្តីថ្លែងការណ៏របស់ក្រុមអង្គការសង្គមស៊ីវិល កាលពីសម័យប្រជុំក្រុមពិគ្រោះយោបល់ស្តីពីកម្ពុជាឆ្នាំ ២០០២ កន្លងទៅ បានលើកឡើងនូវបញ្ហាជាអាទិភាព និងអនុសាសន៏ជាច្រើនជុំវិញការកែទំរង់ការបោះឆ្នោត ដើម្បីជំរុញឱ្យមាន ការអនុវត្តន៏លទ្ធិប្រជាធិបតេយ្យពេញលេញ សំដៅលើកកំពស់អភិបាលកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ដោយឡែកសេចក្តីថ្លែងការណ៏លើកនេះ នឹងធ្វើការពិនិត្យមើលលើលទ្ធផលដែលសំរេចបាន និងបន្តលើកឡើងនូវបញ្ហាអាទិភាពជាច្រើនទៀត ដែលតំរូវឱ្យមានការកែទំរង់ជាបន្ទាន់ នៅមុនការបោះឆ្នោតលើកក្រោយទៀត។ ហើយសេចក្តីថ្លែងការណ៏នេះ ក៏នឹងលើកឡើងនូវបញ្ហាអាទិភាពថ្មីៗទៀត ដូចជា បញ្ហាការបោះឆ្នោតជ្រើសរើសព្រឹទ្ធសភាជាដើម។

ការលើកឡើងនូវបញ្ហាអាទិភាព និងអនុសាសន៏ទាំងអស់ខាងក្រោមនេះ តំណាងឱ្យទស្សនៈដែលបានទទួលពីការពិភាក្សាពិគ្រោះយោបល់ រវាងសម្ព័ន្ធអង្គការសង្កេតការណ៏បោះឆ្នោត ជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលបំរើការផ្នែកសិទ្ធិមនុស្សជាច្រើនទៀត។

(ii) បញ្ហាសំខាន់ៗ

<u>កែលំអរចនាសម្ព័ន្ធរបស់ គ.ជ.ប ដោយមាននីតិវិធីច្បាស់លាស់ក្នុងការជ្រើសរើសបុគ្គលិក ដែលចែងខាលាយលាក់អក្សរនៅក្នុងរដ្ឋធម្មនុញ្ញ:</u>

ទោះបីជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបានកែទំរង់សមាសភាពពីចំនួន ១១ រូប មកនៅត្រឹម ៥ រូប នៅមុនការបោះឆ្នោតឆ្នាំ ២០០៣ ក៏ដោយ ក៏យើងនៅបានធ្វើការកត់សំគាល់ឃើញថា មានការខុសឆ្គងលើនីតិវិធីនៃការជ្រើសរើស ដោយមិនបានគោរពទៅតាមគោលការណ៏បើកចំហនៅឡើយ។ ការជ្រើសរើសបេក្ខជន គ.ជ.ប

ត្រូវបានធ្វើឡើងដោយក្រសួងមហាផ្ទៃ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល និងត្រូវបានចាត់ទុកថា កំពុងដឹកនាំដោយគណបក្សកាន់អំណាច។ បេក្ខជនទាំង ៣ រូបត្រូវបានជ្រើសរើសដោយសហរដ្ឋមន្ត្រីដែលតែងតាំងដោយ ក្រសួងមហាផ្ទៃ ហើយបេក្ខជន ២ រូបទៀតត្រូវបានជ្រើសរើសដោយ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មកពីគណបក្សហ៊្វុនស៊ិនប៉ិច មុនពេលបញ្ជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីស្នើសុំការអនុម័ត និងបញ្ជូនទៅកាន់សភាជាតិ ដើម្បីអនុម័តជាចុងក្រោយ។

បើយើងធ្វើការពិនិត្យទៅលើសមាសភាពនៃគ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់ ភាគច្រើនលើសលប់ចេញមកពីគណបក្សកាន់អំណាច និងមានចំនួនតិចតួចចេញពីគណបក្សហ៊្វុនស៊ិនប៉ិច។ តាមការសិក្សារបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថាខុមហ្វ្រែល បានរកឃើញថា នៅក្នុងសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត-ក្រុង មានចំនួន ៧០% មាននិន្នាការលំអៀងទៅរកគណបក្សប្រជាជនកម្ពុជា ចំនួន ២០% លំអៀងទៅរកគណបក្សហ៊្វុនស៊ិនប៉ិច និងប្រមាណ ១០% ទៀតមាននិន្នាការទៅរកមជ្ឈដ្ឋានផ្សេងៗ។ គណបក្សមួយចំនួនបានសំដែងនូវការមិនពេញចិត្ត ចំពោះតុល្យភាពនេះ ហើយបានលើកឡើងនូវបញ្ហាថា តើ គ.ជ.ប និងភ្នាក់ងារក្រោមបង្គាប់ខ្លួនមានភាពអព្យាក្រិត្យដែរឬយ៉ាងណា?។ កង្វះទំនុកចិត្តទៅលើភ្នាក់ងាររៀបចំការបោះឆ្នោត និងអនុវត្តច្បាប់បោះឆ្នោត បានធ្វើអោយបរាជ័យដល់ដំណើរការទាំងមូល និងបរាជ័យចំពោះលទ្ធផលចុងក្រោយនៃការបោះឆ្នោត។

គួរធ្វើការកែតំរូវប្រព័ន្ធរៀបចំការបោះឆ្នោត ដើម្បីលើកទឹកចិត្តដល់បេក្ខជនឯករាជ្យ :

ដំណើរការបោះឆ្នោតនៅកម្ពុជាពុំបានកែប្រែទេ ពោលគឺការបោះឆ្នោតកន្លងមកនេះ នៅតែបន្តយកតាមប្រព័ន្ធសមាមាត្រ។ មានក្តីបារម្ភមួយចំនួនលើកឡើងថា ប្រពន្ធ័នេះមិនបានជំរុញឱ្យតំណាងរាស្ត្រ ធ្វើការទំនាក់ទំនងជាមួយប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួន ពាក់ព័ន្ធនឹងសកម្មភាពរបស់ពួកគេ ក្នុងនាមជាតំណាងរាស្ត្រ និងជាអ្នកអនុវត្តកិច្ចសន្យាខ្លួនឡើយ។

ម្យ៉ាងទៀត ប្រព័ន្ធនេះផ្តល់អំណាចចំពោះថ្នាក់ដឹកនាំជាអ្នកនយោបាយ អំពីការរាយឈ្មោះបេក្ខជនតំណាងរាស្ត្រ ក្រុមប្រឹក្សាឃុំ /សង្កាត់ ។ តំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែលបានជាប់ឆ្នោត ត្រូវបានគេគំរាមកំហែងដកហូតតំណែង ក្នុងករណីអ្នកតំណាងរាស្ត្រ ឬសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់នោះ មិនបំរើផលប្រយោជន៍ដល់គណបក្សនយោបាយ។ ការកាន់កាប់របស់គណៈបក្សធំៗ ទៅលើដំណើរការនយោបាយ គួបផ្សំជាមួយប្រព័ន្ធបច្ចុប្បន្ន បានរារាំងមិនអោយបេក្ខជនឯករាជ្យឈរឈ្មោះបោះឆ្នោត។

- ចំនួនកូតាគួរត្រូវបង្កើតឡើង ដោយមានសមាជិកស្ត្រីយ៉ាងហោចណាស់ ៣០% នៅក្នុងតំណែង គណបក្សនយោបាយ / តំណែងរដ្ឋាភិបាល
- ជាលទ្ធផល ការបោះឆ្នោតឆ្នាំ ២០០៣ នេះ យើងពិនិត្យឃើញថា មានស្ត្រីចំនួនប្រមាណ ២៥%បានត្រូវចុះឈ្មោះទៅក្នុងបញ្ជីឈ្មោះបេក្ខជនតំណាងរាស្ត្រ។ ក៏ប៉ុន្តែ បើធ្វើការកត់សំគាល់ទៅលើចំនួនបេក្ខនារីដែលបានជាប់ឆ្នោត គឺនៅមាន ក៏រិតទាបប្រហាក់ប្រហែលនឹងរដ្ឋសភាអណត្តិមុន គឺប្រមាណតែ ៩% នៃចំនួនសមាជិកសភាដែលមាន ១២៣ អាសនៈ។ បញ្ហានេះបណ្តាលមកពីគណបក្សនយោបាយទាំងអស់ មិនទាន់មានឆន្ទៈពិតប្រាកដក្នុងការជំរុញ និងផ្តល់លទ្ធភាពដល់ស្ត្រី ឱ្យអាចជាប់ឆ្នោតបានច្រើន (ដាក់បេក្ខនារីនៅក្នុងលំដាប់ទាបក្នុងបញ្ជីគណៈបក្សរបស់ខ្លួន)។ បេក្ខនារីមានចំនួន ៤៩៣ នាក់ (ស្មើនឹង ២៥.៨៨%) បានចុះឈ្មោះបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ក្នុងនោះ មានបេក្ខនារីចំនួន ១២ រូប បានជាប់ឆ្នោតជា សមាជិកាសភា។ នៅក្នុងការបោះឆ្នោតឆ្នាំ ១៩៩៨ បេក្ខនារីចំនួន ៦០៣ នាក់ (ស្មើនឹង ១៦.៩១%) បានចុះឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្នុងនោះមានបេក្ខនារីចំនួន ១៤ រូប បានឈាប់ឆ្នោត ជាសមាជិកសភា។ ដូចនេះ ក្រុមអង្គការសង្គមស៊ីវិលយើង នៅតែសូមជំរុញរាជរដ្ឋាភិបាលនិងគណបក្សនយោបាយ ក្នុងការ លើកស្ទួយតួនាទីស្ត្រី តាមរយៈការលើកទឹកចិត្តស្ត្រីឱ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ (និងផ្តល់អោយស្ត្រីនូវលំដាប់ថ្នាក់ ខ្ពស់ជាងមុន នៅក្នុងបញ្ជីឈ្មោះគណៈបក្សនយោបាយ)។

<u>ការពង្រឹងសមត្ថភាពនិងអំណាចតុលាការឯករាជ្យ ដើម្បីដោះស្រាយការរំលោភច្បាប់បោះឆ្នោត</u>

នៅក្នុងដំណើរការបោះឆ្នោតឆ្នាំ ២០០៣នេះ យើងពិនិត្យឃើញថា គ.ជ.ប ខកខានមិនបានអនុវត្ត នូវប្រព័ន្ធដោះស្រាយបណ្តឹងអោយមានប្រសិទ្ធភាពដដែល។ នីតិវិធីដោះស្រាយបណ្តឹង គ្មានប្រសិទ្ធភាពនៅក្នុងការរៀបចំ និងដំណើរការដាក់ទណ្ឌកម្ម ចំពោះអ្នករំលាភច្បាប់បោះឆ្នោត និងគ្មានប្រសិទ្ធភាពក្នុងការអនុវត្តន៏ច្បាប់ ដើម្បីដាក់ទណ្ឌកម្មចំពោះអំពើធ្ងន់ធ្ងរមួយចំនួន ដូចជាការទិញសន្លឹកឆ្នោត និងករណីបំភិតបំភ័យ។ ករណីជាច្រើន ជាពិសេសនៅថ្នាក់គណៈកម្មាធិការរៀបចំការបោះឆ្នោតឃុំ-សង្កាត់ ត្រូវបានដោះស្រាយតាមនីតិវិធីសំរុះសំរួល ជាជាងសវនាការ។ នីតិវិធីសំរុះសំរួលនេះ ពុំបានធ្វើឱ្យករណីរំលោភទៅលើច្បាប់បោះ ឆ្នោតចុះថមថយឡើយ តែផ្ទុយទៅវិញហាក់ដូចជាបានលើកទឹកចិត្តដល់ជនល្មើសឱ្យបន្តសកម្មភាពរបស់ខ្លួន និងបន្តបង្កើនវប្បធម៌និទណ្ឌភាពទៀតផង។ ទន្ទឹមនឹងនេះ ក៏កើតមានបញ្ហាយុត្តាធិការផងដែរ ពោលគឺពាក់ព័ន្ធ នឹងសមត្ថកិច្ចរបស់ គ.ជ.ប និងសមត្ថកិច្ចរបស់តុលាការ ក្នុងការដោះស្រាយប្រភេទខុសៗគ្នា នៃបទល្មើសបោះឆ្នោត។ ត្រង់ចំណុចនេះ ទាមទារអោយមានការស្រាយបំភ្លឺផ្នែកច្បាប់ និងកំណត់អោយបានច្បាស់លាស់នូវតួនាទីរបស់ភ្នាក់ងារទាំងអស់ ។ ជាចុងក្រោយ ទាមទារអោយមានការបណ្តុះបណ្តាល

មន្ត្រីរៀបចំការបោះឆ្នោត អោយកាន់តែប្រសើរជាងមុន ដើម្បីអោយពួកគេមានការយល់ដឹងពេញលេញ អំពីនីតិវិធីក្នុងការដោះស្រាយបណ្តឹងបោះឆ្នោត។

លទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយៈ

លទ្ធភាពប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយមួយភាគធំ ត្រូវបានត្រួតត្រាដោយគណបក្សកាន់អំណាច ជាពិសេសការផ្សាយតាមវិទ្យុ និងទូរទស្សន៍។ ប៉ុន្តែទោះបីយ៉ាងដូចនេះក្តី ប្រសិនបើយើងធ្វើការប្រៀបធៀបទៅនឹងការបោះឆ្នោតមុនៗ ឃើញថា នៅក្នុងការបោះឆ្នោតឆ្នាំ ២០០៣ នេះ ការប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយសំរាប់ ការឃោសនារបស់គណបក្សនយោបាយ មានភាពរីកចំរើនជឿនលឿន។ កត្តានេះកើតឡើងដោយសារមានការចូលរួមពីសង្គមស៊ីវិល ទាំងក្នុងស្រុក និងអន្តរជាតិ បង្កើតឡើងនូវកម្មវិធីមួយចំនួនដូចជា ការអប់រំអ្នកបោះឆ្នោត ពិភាក្សានយោបាយ និង ពតិមាននយោបាយ (កម្មវិធីពតិមានសមធមិ)។

ពង្រឹងសម្ព័ន្ធអង្គការសង្កេតការណ៍បោះឆ្នោត ដែលគ្មានប្រកាន់គណៈបក្សនយោបាយ (EMO) :

តាមការសង្កេតមើលលើដំណើរការបោះឆ្នោតកន្លងមក ធ្វើឱ្យយើងមានការព្រួយបារម្ភទៅលើទង្វើរបស់រដ្ឋាភិបាល/គណបក្សកាន់អំណាច ដែលបានព្យាយាមបង្កើតយន្តការប្រើប្រាស់នូវឥទ្ធិពលរបស់ខ្លួនយ៉ាងសកម្ម ដើម្បីធ្វើការគ្រប់គ្រងមកលើអព្យាក្រិតភាព និងការងាររបស់សម្ពន្ធ័អង្គការសង្កេតការបោះឆ្នោត។ ជាក់ស្តែង ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៨ រដ្ឋាភិបាល/គណបក្សកាន់អំណាច បានបញ្ចូលសមាសភាពម្នាក់ ទៅក្នុងសមាសភាពនៃសមាជិក គ.ជ.ប ក្នុងតួនាទីតំណាងឱ្យអង្គការសង្គមស៊ីវិល បើទោះបីជាមានការមិន ពេញចិត្តពីក្រុមអង្គការសង្គមស៊ីវិលយ៉ាងណាក៏ដោយ។ មកដល់ឆ្នាំ ២០០២ ដែលជាការបោះឆ្នោតថ្នាក់មូលដ្ឋានក្នុងការជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ រដ្ឋាភិបាល/គណបក្សកាន់អំណាច បានព្យាយាមបង្កើតឱ្យមាននូវ គណៈកម្មាធិការសំរបសំរួលនៃអង្គការក្រៅរដ្ឋាភិបាលដើម្បីសង្កេតការណ៍ការបោះឆ្នោត (គ.ស) មួយទៀត ក្នុងគោលបំណងត្រួតត្រា លើសម្ពន្ធ័អង្គការសង្កេតការណ៍បោះឆ្នោតឱ្យបាត់បង់ឯករាជ្យភាពរបស់ខ្លួន។ ចំពោះការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ ២០០៣ នេះ គណៈបក្សនយោបាយកាន់អំណាច បានរៀបចំបង្កើតឱ្យមាន នូវសម្ព័ន្ធអង្គការមួយក្រុម ដែលមានប្រមាណ ៧៦ អង្គការ ហើយបានប្រកាសថាជាអង្គការក្រៅរដ្ឋាភិបាលដែរ ប៉ុន្តែធាតុពិតសកម្មភាពរបស់ពួកគេបានគាំទ្រទាំងស្រុង ចំពោះទង្វើរបស់គណបក្ស

កាន់អំណាច។ កក្តាទាំងនេះបាន ធ្វើឱ្យសាធារណៈជនមានការភាន់ច្រលំ ដល់អព្យាក្រិតភាពរបស់អង្គការក្រៅរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត។

ការបោះឆ្នោតជ្រើសរើសព្រឹទ្ធសភា

អង្គការក្រៅរដ្ឋាភិបាល សូមសំដែងនូវការគាំទ្រយ៉ាងពេញទំហឹង ឱ្យមានការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាអាណត្តិទីពីរ ដែលស្របតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ កន្លងទៅនេះ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានបដិសេធមិនប្រើប្រាស់ ព្រះរាជបុព្វសិទ្ធិពិសេសរបស់ព្រះអង្គ ក្នុងការតែងតាំងសមាជិកព្រឹទ្ធសភា ដែលមិនបានជ្រើសតាំងតាមរយៈ ការបោះឆ្នោតឡើយ ដោយទ្រង់ព្រះលិខិតថា *"ព្រឹទ្ធសភាត្រូវកើតចេញពីប្រជាជន"*។ ការបោះឆ្នោតនេះមានសារៈសំខាន់ណាស់ ក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងការគោរពរដ្ឋធម្មនុញ្ញនៅកម្ពុជា។ ម្យ៉ាងទៀត ក៏ធ្វើឱ្យមានការចូលរួមពីគ្រប់ភាគី ដែលអាចបំរើផលប្រយោជន៍ដល់សាធារណៈជនគ្រប់ស្រទាប់វណ្ណៈ ។

ការយកមូលហេតុកង្វះថវិកាក្នុងប្រទេស ដែលនាំទៅដល់ការតែងតាំងព្រឹទ្ធសភាពនេះ ជាមូលហេតុមិនសមហេតុផលទេ។ ការខកខានក្នុងការរៀបចំការបោះឆ្នោត នឹងធ្វើអោយបរាជ័យដល់ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដោយសារកង្វះថវិកា ដែលបញ្ហាថវិកានេះគឺរដ្ឋាភិបាលខ្លួនឯង ជាអ្នកទទួលខុសត្រូវក្នុងការស្វែងរកមធ្យោបាយ ក្នុងការបង្កើតធនធាននោះ។

ជាការគួរឱ្យកត់សំគាល់ក្នុងរយៈពេលកន្លងមក មានសមាជិកព្រឹទ្ធសភាមួយចំនួន បានខិតខំប្រឹងប្រែងរៀបចំជាសេចក្តីស្នើ "ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា"។ យើង រួមជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត សន្យានឹងខិតខំជំរុញឱ្យមានកិច្ចពិភាក្សាស្តីពី " សេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា" ដោយមានការចូលរួមពីសមាជិកស្ថាប័ននីតិបញ្ញត្តិ រដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍អ្នកផ្តល់ជំនួយ គណៈបក្សនយោបាយ និងអ្នកច្បាប់មួយចំនួន ដើម្បីរកលទ្ធភាពអោយចេញជាច្បាប់នេះ។

(iii) អនុសាសន៍:

ររចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- កែសំរួលរចនាសម្ព័ន្ធ គ.ជ.ប ឡើងវិញ ដោយមានកំណត់នីតិវិធីច្បាស់លាស់ក្នុងការជ្រើសរើសបុគ្គលិក សរសេរជាលាយល័ក្ខអក្សរនៅក្នុងរដ្ឋធម្មនុញ្ញ។

- អំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ ត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះការរៀបចំច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការរៀបចំការបោះឆ្នោតនេះ ។
- ធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ លើជំពូកទី ៣ ដែលចែងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាពិសេសគឺ :
    - o ពិនិត្យឡើងវិញនូវសមាសភាព គ.ជ.ប ដោយរក្សាចំនួនសមាជិក ០៥ រូប ដដែល ប៉ុន្តែអ្នកទាំងនោះ ពុំមែនជាតំណាងគណៈនយោបាយ និងមិនកាន់តំណែងក្នុងរដ្ឋាភិបាល ឬស្ថាប័នជាតិធំៗ ក្នុងរយៈពេល ៣ ឆ្នាំ នៅពេលតែងតាំងទៅក្នុង គ.ជ.ប ។
    - o សមាជិកទាំងអស់ត្រូវឯករាជ្យ អព្យាក្រិត្យ គ្មាននិន្នាការនយោបាយ មានសមត្ថភាព និងកិត្តិស័ព្ទល្អ ។
    - o សមាជិកទាំងអស់ត្រូវមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅ និង/ឬ ធ្លាប់កាន់មុខតំណែង ដូចជាចៅក្រមយូរឆ្នាំ និង/ឬ មានកិត្តិស័ព្ទល្អ ។ បេក្ខភាពស្ត្រីមានសិទ្ធិជាអាទិភាព ។
- ចំពោះនីតិវិធីជ្រើសតាំង គួរបង្កើតគណៈកម្មាធិការជ្រើសរើសមួយ ដែលមានសមាសភាព : តំណាងគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា តំណាងអង្គការក្រៅរដ្ឋាភិបាល និង តំណាងគណៈមេធាវី ។
- ឈ្មោះរបស់បេក្ខជនដែលត្រូវបានជ្រើសរើសដោយគណៈកម្មាធិការ គួរបិទផ្សាយជាសាធារណៈ ដើម្បីសុំយោបល់ពីមហាជន មុននឹងដាក់ជូនរដ្ឋសភាអនុម័ត ។
- សមាជិកអង្គការរៀបចំការបោះឆ្នោតនេះ គួរមានអភ័យឯកសិទ្ធិ/បុព្វសិទ្ធិពិសេសដូចតំណាងរាស្ត្រ ។
- ដើម្បីពង្រឹងមុខងារ និងសមត្ថកិច្ចរបស់សមាជិក គ.ជ.ប គប្បីបង្កើតឡើងនូវស្ថាប័នឯករាជ្យមួយ ។ ស្ថាប័ននេះត្រូវមានសិទ្ធិដាក់ទណ្ឌកម្មទៅលើសមាជិក គ.ជ.ប ដែលរំលោភច្បាប់បោះឆ្នោត ។

<u>គួរកែប្រែប្រព័ន្ធបោះឆ្នោត ដើម្បីលើកទឹកចិត្តដល់បេក្ខជនឯករាជ្យ</u>

- ប្រព័ន្ធបោះឆ្នោតគួរយកលំនាំតាមប្រព័ន្ធចំរុះ (គឺជាប្រព័ន្ធមួយដែលរួមផ្សំគ្នារវាងប្រព័ន្ធឯកត្តនាម និងប្រព័ន្ធសមាមាត្រ) ដើម្បីផ្តល់ឱកាសអោយបុគ្គល ឬក្រុមឯករាជ្យ ចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ។

- បេក្ខជនគណបក្សនយោបាយ និងបេក្ខជនឯករាជ្យ អាចចូលរួមឈរឈ្មោះប្រកួតប្រជែងបានដូចគ្នា នៅគ្រប់មណ្ឌលទាំងអស់ ។

<u>បង្កើតកូតាសំរាប់បេក្ខនារី</u>

- កំណត់កូតាស្ត្រីយ៉ាងតិច ៣០% នៅក្នុងគ្រប់បញ្ជីបេក្ខជនគណបក្សនយោបាយ ។ បញ្ជីនេះត្រូវ មានចែងនៅក្នុងក្របខ័ណ្ឌគតិយុត្តិស្តីពីការបោះឆ្នោត ឬគោលនយោបាយរបស់គណៈបក្សនយោបាយនីមួយៗ ដើម្បីផ្តល់ដល់ស្ត្រីនូវឱកាសមួយកាន់តែមានប្រសិទ្ធភាព ដើម្បីចូលរួមនៅក្នុងកិច្ចការសង្គម និងនយោបាយ ។
- បេក្ខនារីទាំងនេះ ត្រូវតែឈរឈ្មោះឆ្លាស់គ្នាជាមួយបេក្ខជន ដោយចាប់ពីលំដាប់លេខរៀងលើគេ នៃបញ្ជីបេក្ខជន ។

<u>ពង្រឹងសមត្ថភាពនិងអំណាចតុលាកាឯករាជ្យ ដើម្បីដោះស្រាយការរំលោភច្បាប់បោះឆ្នោត</u>

- បង្កើនការផ្សព្វផ្សាយពតិមាន បណ្តុះបណ្តាលមន្ត្រីតុលាការ ភ្នាក់ងារនគរបាល សាធារណៈជន អំពី នីតិវិធីដោះស្រាយបទល្មើសបោះឆ្នោត ។
- បង្កើតអង្គជំនុំជំរះបទល្មើសបោះឆ្នោត នៅក្នុងស្ថាប័នតុលាការដែលមានស្រាប់ និងឯករាជ្យពី គ.ជ. ប ។
- នគរបាលគ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយភ្នាក់ងារបោះឆ្នោត របស់អនុគណៈកម្មាធិការ ឬ នាយកដ្ឋានអង្កេតរបស់ គ.ជ.ប ។

<u>លទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ</u>

- ដើម្បីលើកកំពស់ផ្នែកពតិមាន និងការជជែកដេញដោយ និងការតាមដានសារពតិមាន អំពីវេទិកានយោបាយទាំងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងរបស់ឯកជន ចាំបាច់ត្រូវមាននីតិវិធី គោលការណ៍និងច្បាប់ស្តីពី លទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយស្មើភាព ។
- មធ្យោបាយសារពតិមានរដ្ឋ គួរផ្តល់ពេលម៉ោងផ្សព្វផ្សាយដោយឥតគិតថ្លៃ ដល់ក្រុមអង្គការ មិនមែនរដ្ឋាភិបាលដែលមានសកម្មភាពក្នុងការងារអប់រំដល់អ្នកបោះឆ្នោត ។
- គួរមានច្បាប់ស្តីពីប្រពន្ធ័ផ្សព្វផ្សាយ ជាពិសេសទូរទស្សន៍ និងវិទ្យុ ។

ចំពោះពត៌មានបន្ថែម និងបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងឯកសារនេះ សូមទំនាក់ទំនង ៖

Election Sectoral Group

ទូរស័ព្ទលេខ ៖ ០២៣-៨៨៤-១៥០/០២៣-៨៨៣-៩៦៧

Email: comfrel@online.com.kh និង comfrel@forum.org.kh

វិស័យជលផល

(i) សេចក្តីផ្តើម

ជលផលគឺជាផ្នែកមួយជាមូលដ្ឋាន និងសំខាន់សំរាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា។ ការអង្កេតលើសេដ្ឋកិច្ចសង្គម នៅឆ្នាំ ១៩៩៥-៩៦ ក្នុងខេត្តនេសាទត្រីចំនួន ៨ ដែលមានប្រជាពលរដ្ឋសរុបចំនួន ២,៤លាននាក់ បានបង្ហាញអោយឃើញថា គ្រួសារចំនួន ១០,៥% យកការនេសាទជាមុខរបរសំខាន់ ចំណែកឯ ៣៤.១% ធ្វើរបរនេសាទនៅពេលទំនេរ (Ahmed et al, 1998)។ ក្នុងខេត្តទាំងនេះ ប្រជាពលរដ្ឋជាង ១លាននាក់ ពឹងផ្អែកទាំងស្រុង ឬពឹងផ្អែកមួយផ្នែក ទៅលើជលផលក្នុងការរកប្រាក់ចំណូល។ នៅទូទាំងប្រទេស ប្រជាពលរដ្ឋចំនួនជាង ១ភាគ៦ ទាញយកការងារពីវិស័យជលផល និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត (ការលក់ត្រី ការកែច្នៃត្រី និងផលិត ឧបករណ៍នេសាទ ។ល។)។ ប្រជាពលរដ្ឋនៅជនបទ បរិភោគត្រីជារៀងរាល់ថ្ងៃ ហើយក៏ពឹងផ្អែកលើធនធានក្នុងទឹក ដទៃទៀតផងដែរ។ ត្រីផ្តល់នូវប្រូតេអ៊ីនពី ៤០-៦០% សំរាប់ប្រជាពលរដ្ឋនៅជនបទ ហើយប្រសិនបើគ្មានត្រីទេ ប្រជាពលរដ្ឋជនបទជាច្រើននឹងត្រូវខ្វះម្ហូបអាហារ។ ដូច្នេះ ដើម្បីកាត់បន្ថយភាពក្រីក្រ គួរតែប្រឹងប្រែងលើកកំពស់ ការទទួលបានធនធានត្រីជានិរន្តរ៍ និងធានានូវការបែងចែកធនធានទាំងនេះប្រកបដោយសមធម៌ សំរាប់ ប្រជាពលរដ្ឋក្រីក្រ។

វិស័យជលផលក៏ជាផ្នែកសំខាន់មួយនៃសេដ្ឋកិច្ចជាតិផងដែរ ដែលរួមចំណែកផ្តល់ពី ៥-១០% នៃ ផលិតផលក្នុងស្រុកសរុប (GDP) ។ ចំពោះផលនេសាទសំរាប់ធ្វើពាណិជ្ជកម្មវិញ ផលត្រីនេសាទសរុបពីបឹងទន្លេសាប ដែលមានលក្ខណៈពាណិជ្ជកម្ម មានបរិមាណប្រហែល ៦០% នៃផលនេសាទទូទាំងប្រទេស (Van Zalinge and Leng 2000)។ គេបានប៉ាន់ស្មានថា ការនេសាទត្រីទឹកសាបប្រចាំឆ្នាំ មានប្រមាណជាង ៤០០.០០០តោន ក្នុងមួយឆ្នាំ ដែលធ្វើអោយការនេសាទត្រីទឹកសាបរបស់ប្រទេសកម្ពុជា ជាប់លំដាប់ថ្នាក់ទី ៤ នៃប្រទេសដែលសំបូរត្រីជាងគេនៅក្នុងពិភពលោក ហើយជលផល ត្រូវបានជំរុញអោយទៅជាវិស័យមួយដែលប្រទេសកម្ពុជាមាន " ប្រៀបក្នុងការប្រកួតប្រជែង "។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធកំណត់ថ្លៃត្រី ចំពោះការលក់ និង ការនាំចេញ បានធ្វើអោយថ្លៃត្រីធ្លាក់ចុះ ធ្វើអោយ ប្រាក់ចំណូលរបស់អ្នកនេសាទខ្នាតតូច ខ្នាតមធ្យម និងអ្នកផ្សេងទៀតដែលរកទទួលទានក្នុងវិស័យជលផលធ្លាក់ចុះ។ លើសពីនេះទៅទៀត ការសិក្សាថ្មីៗមួយបានបង្ហាញថា ៨០%នៃការយកកំរៃលើការនាំត្រីចេញ ត្រូវបានប្រមូលដោយ ស្ថាប័ននានា

ដែលគ្មានទំនាក់ទងផ្ទាល់ទាល់តែសោះ ទៅនឹងការគ្រប់គ្រងជលផល ហើយមន្ត្រីផលផលដែលទទួលបន្ទុក ក្នុងការគ្រប់គ្រង កន្លែងលើកដាក់ត្រីនៅមូលដ្ឋាន និងតំបន់នេសាទ ប្រមូលតែ ៣% នៃកំរៃទាំងអស់តែប៉ុណ្ណោះ ។[១]

ថ្លៃត្រីថោក និងការប្រកួតប្រជែងគ្នាលើធនធានដែលកាន់តែចុះថយនេះ បានធ្វើអោយសហគមន៍នេសាទ ជាច្រើន ក្រីក្រ ។ បើទោះបីជាសំបូរទៅដោយធានធានធម្មជាតិជុំវិញបឹងទន្លេសាបក៏ដោយ ក៏ប្រជាពលរដ្ឋ ប្រមាណ ៣៩% នៅតំបន់នោះ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ដោយប្រៀបធៀបទៅនឹងចំនួនពលរដ្ឋរស់នៅក្រោមបន្ទាត់ក្រីក្រ ៣៦% នៅទូទាំងប្រទេស (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ១៩៩៨) ។ ការលក់ដែននេសាទដែលមានយូរយារពីមុនមក របស់ប្រជាពលរដ្ឋ ក្នុងទំរង់ជាឡូត៍នេសាទពាណិជ្ជកម្ម ធ្វើអោយសហគមន៍បាត់បង់នូវធានធានមួយ ក្នុងចំណោម ធនធានចំបងៗ សំរាប់ជីវភាពរស់នៅរបស់ពួកគាត់ ។ ការកែទំរង់វិស័យជលផលនៅចុងឆ្នាំ ២000 បានដោះស្រាយ បញ្ហានេសាទមួយផ្នែក ដោយបានកាត់បន្ថយឡូត៍នេសាទ ៥៦% ដែលមានលក្ខណៈពាណិជ្ជកម្ម ប្រគល់អោយ សហគមន៍មូលដ្ឋាន ដើម្បីបង្កើតជាសហគមន៍នេសាទវិញ ។ ជាអកុសល ជាទូទៅឡូត៍ទាំងនោះគឺជាឡូត៍នេសាទ ដែលមានតំលៃថោកបំផុត (ឡូត៍ដែលមាន តំលៃតិចជាង ៣០ លាន រៀល ឬ ៧.៥០០ ដុល្លារអាមេរិក) ហើយ ឡូត៍នេសាទខ្លះមិនអំណោយផលសំរាប់នេសាទ សោះឡើយ (រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ២000) ។

ការកែទំរង់នេះ ក៏បរាជ័យផងដែរក្នុងការបញ្ចប់ជំលោះតំបន់នេសាទទាំងនោះ ។ បើទោះជាពេលនេះ គ្មានជំលោះ ធំៗរវាងសហគមន៍ និងម្ចាស់ឡូត៍នេសាទក៏ដោយ តែក៏មានការកើនឡើងនូវជំលោះ ពាក់ព័ន្ធនឹងការរំលោភ បំពាន ការនេសាទខុសច្បាប់ និងការនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ ។ ការនេសាទច្រើនលើសលប់ ក៏នៅតែជាបញ្ហា ធ្ងន់ធ្ងរដែរ ។ ទោះបីជាការផលនេសាទត្រីសរុប ហាក់នៅមានចំនួនស្ថេរក្នុងពេលកន្លងមកក៏ដោយ ក៏តួលេខទាំងនោះគឺជា តួលេខមិនត្រឹមត្រូវ ក្នុងសភាពជាសន្ទស្សន៍នៃភាពសំបូរ និងតំលៃត្រី ។ នៅរយៈប៉ុន្មានឆ្នាំ ថ្មីៗនេះ ការនេសាទបាន កើនឡើងយ៉ាងសំបើម ត្រីធំៗបានថយចុះ ហើយសមាសភាពពូជត្រីបានផ្លាស់ប្តូរទៅជាត្រី ដែលមានដងខ្លួនតូច ជាពូជត្រី មានតំលៃទាប ។ ទាំងនេះ ជានិម្មិត្តហេតុនៃការនេសាទជ្រុលហួស (ADB, 2003) ។ លើសពីនេះទៅទៀត មានភស្តុតាង ដែលបង្ហាញអំពីការថយចុះនៃផលត្រីនេសាទក្នុងលក្ខណៈគ្រួសារ (Tana and Bruce, 2001) ។[២]

ដោយសារៈសំខាន់នៃវិស័យជលផលចំពោះសេដ្ឋកិច្ចជាតិ និងតួនាទីសំខាន់របស់វិស័យជលផលក្នុងយុទ្ធសាស្ត្រ នៃជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់ នោះការគ្រប់គ្រងធនធានដ៏ចាំបាច់នេះ ប្រកបដោយ គតិបណ្ឌិត

---

[1] Yim Chea and Bruce McKenney “ ការនាំត្រីចេញពីបឹងទន្លេសាបៈ ការវិភាគប្រព័ន្ធយកកំរៃ ” ក្នុង *ទស្សនាវដ្តីស្តីពីការអភិវឌ្ឍនៅកម្ពុជា របស់*CDRI ខែ កក្កដា-កញ្ញា ២០០៣

[2] Tana, S. and Bruce, T. 2001. ពាណិជ្ជកម្មត្រីទន្លេ និងត្រីសមុទ្រ នៅកម្ពុជា ទំព័រ ២០-២១

គឺជាធាតុសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។ ចាំបាច់ត្រូវតែកែតំរូវឡើងវិញ នូវបទប្បញ្ញត្តិពាណិជ្ជកម្ម និងការនាំត្រីចេញ ជាពិសេសបទប្បញ្ញត្តិពាក់ព័ន្ធនឹងអជ្ញាប័ណ្ណ ការអនុញ្ញាត និងប្រព័ន្ធបង់ប្រាក់។ ប៉ុន្តែត្រឹមតែ បទប្បញ្ញត្តិ នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ត្រូវប្រែក្លាយសហគមន៍នានាអោយទៅជាដៃគូសកម្ម ក្នុងដំណើរការ ការពារ គ្រប់គ្រង និងការប្រើប្រាស់ធានធានជលផលប្រកបដោយនិរន្តរភាព។

អង្គការក្រៅរដ្ឋាភិបាល (NGOs) នានា បានចូលរួមក្នុងការគាំទ្រសហគមន៍ជលផល ដោយប្រើថវិកាដែលបានមកពីម្ចាស់ជំនួយអន្តរជាតិ ហើយក៏បានមើលឃើញជាលើកដំបូងដែរថា ប្រសិនបើផ្តល់ឱកាស និងផ្តល់ជំនួយបច្ចេក-ទេសអោយសហគមន៍នានា នោះពួកគាត់ពិតជាមានចិត្តចង់ការពារនូវធនធានដែលពួកគាត់ពឹងផ្អែកសំរាប់ជីវភាព ប្រចាំថ្ងៃ។ មកដល់បច្ចុប្បន្ននេះ ក្រុមសហគមន៍នេសាទប្រមាណជា ២៦៤ ត្រូវបានបង្កើតឡើង (DoF, 2003) សហគមន៍ជាច្រើនបានទទួលជោគជ័យយ៉ាងច្រើន ហើយអាចផ្តល់នូវមេរៀនសំខាន់ៗ អំពីវិធីដែលរដ្ឋាភិបាល និង សហគមន៍នានាអាចធ្វើការរួមគ្នាអោយមានប្រសិទ្ធិភាព។ ផ្តើមចេញពីទស្សនៈរបស់អង្គការក្រៅរដ្ឋាភិបាល រដ្ឋាភិបាលត្រូវខិតខំប្រឹងប្រែងតាមគ្រប់លទ្ធភាពដែលខ្លួនមាន ដើម្បីសំរបសំរួលការគ្រប់គ្រងធនធានជលផល នៅសហគមន៍ ដើម្បីជាគុណប្រយោជន៍សំរាប់ពលរដ្ឋជំនាន់នេះ និងសំរាប់អនាគត។

(ii) បញ្ហាគន្លឹះ

១. វិធីនេសាទដែលមានលក្ខណៈបំផ្លិចផ្លាញ និង ខុសច្បាប់

វិធីនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ និងខុសច្បាប់កើតមាននៅពាសពេញប្រទេសកម្ពុជា។ អ្នកនេសាទខ្នាតតូច និងមធ្យម ឈានទៅប្រើវិធីនេសាទខុសច្បាប់ ដោយសារតែ សំពាធក្នុងការចិញ្ចឹមគ្រួសារ ការសងបំណុល និងការបង្កើនប្រាក់ចំណូលរបស់ពួកគេ អោយបានគ្រប់គ្រាន់។ ការនេសាទទ្រង់ទ្រាយធំ ប្រើប្រាស់វិធី ខុសច្បាប់ ដើម្បីទូទាត់ទៅនឹងថ្លៃដើមខ្ពស់ ដោយបានចំណាយទិញឧបករណ៍ខ្នាតធំសំរាប់ធ្វើពាណិជ្ជកម្ម អាជ្ញាប័ណ្ណ ការលក់ដេញថ្លៃឡូត៍នេសាទ និងការចំណាយទៅលើការដឹកជញ្ជូនផ្លូវការ និងមិនផ្លូវការ ព្រមទាំងសោហ៊ុយរកទីផ្សារ។ ការប្រកួតប្រជែងក្នុងពេលដែលបរិមាណត្រីដែលកំពុងតែថយចុះ កាន់តែមានលក្ខណៈតឹងតែងឡើងៗ ហើយអ្នកនេសាទនៅគ្រប់ជាន់ថ្នាក់បានបង្ហាញថា ពួកគេនឹងឆ្លៀតយកប្រយោជន៍ ពីការបរិយាកាសនៃភាពកំសោយ ក្នុងការអនុវត្តន៍ច្បាប់ និងកង្វះខាតប្រព័ន្ធគ្រប់គ្រង ដើម្បីព្យាយាមនេសាទត្រីអោយបានច្រើន និងឆាប់បំផុត តាមដែលអាចធ្វើបាន ដោយគ្មាន គិតខ្វល់ខ្វាយពីពេលអនាគតឡើយ។

វិធីនេសាទត្រីដែលមានលក្ខណៈបំផ្លិចបំផ្លាញ រួមមានៈ

- ការប្រើអួនវែងៗ (១-២គីឡូម៉ែត្រ) ក្រលាល្អិត ដើម្បីនេសាទត្រីតូចៗ និងត្រីដែលគ្មានតំលៃ សំរាប់ធ្វើជាចំណីត្រី ឬជាចំណីសត្វ។ រួមទាំងការប្រើប្រួលនៅតាមផ្លូវទឹកហូរ ដើម្បីនេសាទត្រីដែលហែលឡើងបញ្ច្រាសទឹក រកកន្លែងពង និងលបផំៗដែល មានលក្ខណៈអាជីវកម្មក្នុងបឹងទន្លេសាប។
- ការជួសកូនត្រី (ត្រីដែលទើបញាស់) ពីតំបន់បង្កាត់ពូជធម្មជាតិសំរាប់នាំចេញខុសច្បាប់ និងលក់[៣]។
- វិធីធ្វើអាជីវកម្មដោយការបូមបឹង ឬបូមផ្ទៃទឹក ដើម្បីនេសាទត្រីទាំងអស់តែម្តង។ ការបូមទឹក ធ្វើអោយបាត់បង់តុល្យភាពប្រព័ន្ធអេកូឡូស៊ី ដោយស្ទើរតែបាត់បង់អស់រាល់ជីវិតសត្វក្នុងទឹក រួមទាំងត្រីដែលនៅមិនទាន់ធំផងដែរ។ វាក៏បណ្តាលអោយមានបញ្ហាសំរាប់សហគមន៍ផងដែរ ព្រោះពួកគាត់បាត់បង់ទឹកសំរាប់ស្រោចស្រពដំណាំផងដែរ។
- ការឆក់ត្រី ការបោកគ្រាប់បែក ឬការប្រើថ្នាំពុល ដែលប្រើដោយអ្នកនេសាទខ្នាតតូច និងក្នុងលក្ខណៈពាណិជ្ជកម្ម។ ការឆក់ត្រី គឺជាជំរើសដែលពេញនិយមសំរាប់អ្នកនេសាទខុសច្បាប់ តាមដងទន្លេសាប ដោយសារវាជាវិធីដែលចំណាយដើមទុនតិច ដែលអាចនេសាទតាមច្រាំងទន្លេ ហើយក៏ជាវិធីមួយលឿន និងមានប្រសិទ្ធិភាពក្នុងការនេសាទត្រី។
- ការអូស ឬប្រើទូកអូសនៅក្នុងទឹករាក់ៗ។ ទូកនេសាទជាលក្ខណៈពាណិជ្ជកម្មដែលត្រូវបានធ្វើឡើងសំរាប់នេសាទសមុទ្រ កាន់តែរំលោភបំពានជាបន្តបន្ទាប់តាមរយៈការនេសាទនៅតាមឆ្នេររាក់ៗ ដែល ធ្វើអោយខូចខាត បាតសមុទ្រ និងប៉ះពាល់ដល់ជំរកបង្កាត់ពូជត្រី និងប៉ះពាល់ដល់ជីវភាពរស់នៅរបស់អ្នកនេសាទសាមញ្ញ នៅតាមឆ្នេរ។
- ជួនកាលគេយកកងកំលាំងប្រដាប់អាវុធធ្វើជាខ្នងបង្អែក ក្នុងការរំលោភបំពាន មកលើតំបន់សហគមន៍ ដែលជាតំបន់អភិរក្ស ឬឡូតិ៍នេសាទជិតខាងដែលជាកន្លែងសំបូរត្រី។

កង្វះភាពច្បាស់លាស់លើព្រំប្រទល់ឡូតិ៍នេសាទ ធ្វើអោយមានជំលោះរវាងក្រុមអ្នកប្រើប្រាស់នៅមូលដ្ឋាន និងប្រតិបត្តិករនេសាទដែលមានលក្ខណៈពាណិជ្ជកម្ម។ ក្នុងករណីខ្លះ ម្ចាស់ឡូតិ៍នេសាទបានចោទប្រកាន់អ្នកស្រុក ដែលធ្វើដំណើរឆ្លងកាត់ឡូតិ៍នេសាទថាមានបំណងលួចនេសាទខុសច្បាប់ ឬរុកគួនប្រជាពលរដ្ឋដែលជាសមាជិកសហគមន៍នៅក្បែរដែននេសាទរបស់ឡូតិ៍នេសាទ។ សហគមន៍នេសាទ ក៏តែងជួបប្រទះការរំលោភ និងមានបញ្ហាលំបាកក្នុងការការពារខ្លួន ទប់ទល់នឹងគូបដិបក្សដែលមានអំណាច និងមានទ្រព្យសម្បត្តិ។ ក្រុមសហគមន៍នេសាទ រងការគំរាមកំហែងពីសំណាក់អ្នកនេសាទខុសច្បាប់ ព្រោះថាសហគមន៍បានរាយការណ៍ អំពីការនេសាទខុសច្បាប់ទៅប្រាប់រដ្ឋាភិបាល។

[3] Scrogging, ពាណិជ្ជកម្មត្រូវបានធ្វើចំពោះកូនត្រី ជាអាជីវកម្មគ្រោះថ្នាក់ដល់អាយុជីវិត កាសែត Phnom Penh Post ចុះថ្ងៃទី ៤-១៧ កញ្ញា ឆ្នាំ ១៩៩៨

យ៉ាងហោចណាស់ក៏មានមួយករណីដែរ ដែលអ្នកនេសាទខុសច្បាប់នៅខេត្តបាត់ដំបងបានប្តឹងសហគមន៍នេសាទ ហើយឈ្នះក្តីនេះ ដែលនាំទៅដល់ការដាក់គុកចំពោះអ្នកដែលបានព្យាយាមការពារធនធានជលផល ។ នៅតែជាបញ្ហាផងដែរ ដែលការនេសាទខុសច្បាប់ក្នុងទ្រង់ទ្រាយធំ និងការរំលោភបំពាន ពឹងផ្អែកលើកំលាំងប្រដាប់អាវុធ[4] និងអាជ្ញាធរមូលដ្ឋាន ។

២. គោលនយោបាយទាក់ទងទៅនឹងសហគមន៍នេសាទ

ច្បាប់នេសាទ និងអនុក្រឹត្យស្តីពីសហគមន៍នេសាទ បង្កើតនូវមូលដ្ឋានការពារច្បាប់រឹងមាំដែលអាចជួយការពារសិទ្ធិរបស់សហគមន៍ និងការប្រកបរបរចិញ្ចឹមជីវិត ។ មានការវិវត្តន៍ទៅមុខយ៉ាងច្រើន ចំពោះសេចក្តី ព្រាងច្បាប់នេសាទ និងអនុក្រឹត្យស្តីពីសហគមន៍នេសាទ ។ រាជរដ្ឋាភិបាលបានអនុញ្ញាតិអោយមានការចូលរួមក្នុងកំរិតខ្ពស់ពីសហគមន៍ដែលពឹងពាក់លើការនេសាទ និងភាគីពាក់ព័ន្ធផ្សេងទៀតនៅទូទាំងប្រទេស ក្នុងការធ្វើសេចក្តីព្រាង និងកិច្ចប្រជុំទល់មុខគ្នារវាងតំណាងសហគមន៍ និងនាយកដ្ឋានផលផល ។

អង្គការក្រៅរដ្ឋាភិបាលនានា សហគមន៍នេសាទនៅមូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀត ពេញចិត្តនឹងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបញ្ចូលសង្គមស៊ីវិល និងអ្នកនេសាទនៅមូលដ្ឋាន ទៅក្នុងការពិភាក្សាស្តីពីច្បាប់ ជលផល និងគោលនយោបាយថ្មីៗនេះ ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីខ្លះ បន្ទាប់ពីការពិគ្រោះយោបល់ សង្គមស៊ីវិល និងសហគមន៍នានាយល់ឃើញថា បញ្ហាក្តីកង្វល់ និងយោបល់នានាដែលបានស្នើដោយសហគមន៍មូលដ្ឋាន មិនត្រូវបានគេពិចារណាអោយបានដិតដល់ ឬដាក់បញ្ចូលទៅជាគោលនយោបាយនោះទេ ។ យោបល់ ក្តីកង្វល់ និងសំណើនានារបស់ប្រជាពលរដ្ឋមូលដ្ឋាន ត្រូវបានគេចាត់ទុកថាគ្មានមូលដ្ឋានជាក់ស្តែង និងខ្វះមូលដ្ឋានវិទ្យាសាស្ត្រ បើទោះជាបញ្ហាទាំងនេះ មានទំនាក់ទំនងទៅនឹងជីវភាពប្រចាំថ្ងៃរបស់ពួកគេក៏ដោយ ។ បញ្ហាគន្លឹះ ៣ សំរាប់ពិចារណា និងកំណែទំរង់លើគោលនយោបាយពាក់ព័ន្ធនឹងសហគមន៍នេសាទ មានដូចខាងក្រោម៖

[4] ជាធម្មតាគឺជាប៉ូលីសមូលដ្ឋាន ឬមន្ត្រីយោធា

នីតិវិធីដើម្បីរៀបចំសហគមន៍នេសាទ

រដ្ឋាភិបាលមានតួនាទីយ៉ាងសំខាន់ក្នុងការដាក់ការណែនាំ និងក៏រិតបទដ្ឋានសំរាប់សហគមន៍នេសាទ ព្រមទាំងត្រួតពិនិត្យការអនុវត្តន៏នី។ ទោះជាយ៉ាងនេះក្តី សហគមន៍នានា និងមន្ត្រីរដ្ឋាភិបាលហាក់ដូចជាមានគំនិតផ្សេងគ្នា ថាតើនរណាជាអ្នករៀបចំសហគមន៍។ ជារឿយៗ មន្ត្រីរដ្ឋាភិបាលហាក់ដូចជាមានជំហរថា រដ្ឋាភិបាលត្រូវតែក្តោបក្តាប់លើដំណើរការទាំងមូល ពោលគឺការរៀបចំសហគមន៍ ការធ្វើគំរោងផែនការគ្រប់គ្រង និងការទទួលខុសត្រូវខាងការអនុវត្តន៏នីច្បាប់តែម្នាក់ឯង។ នៅពេលនេះ នីតិវិធីក្នុងការបង្កើតសហគមន៍នេសាទ ត្រូវការប្រើពេលវេលាយ៉ាងច្រើន ហើយស្មុគ្រស្មាញ ដែលតំរូវអោយមានការឯកភាពដាច់ៗពីគ្នាតាមដំណាក់កាលនីមួយៗ ចាប់ពីថ្នាក់ស្រុក រហូតដល់ថ្នាក់ខេត្ត ដល់នាយកដ្ឋានជលផល និងទៅដល់ក្រសួង។ ជាពិសេស សហគមន៍នេសាទដែលនៅឆ្ងាយៗ ការរៀបចំកិច្ច ប្រជុំ និងការចចារការទទួលស្គាល់ នៅដំណាក់កាលបួនខុសៗគ្នា គឺជាកិច្ចការដែលស្ទើរតែមិនអាចធ្វើទៅកើត។

សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលនានាបានជំទាស់ថា នីតិវិធីសំរាប់រៀបចំ និងការចុះបញ្ជីជាសហគមន៍នេសាទ គួរតែមានលក្ខណៈសាមញ្ញ។ ពួកគេក៏ជឿជាក់ផងដែរថា សហគមន៍គួរតែមានលទ្ធភាព ក្នុងការផ្តួចផ្តើមគំនិតដោយខ្លួនគេផ្ទាល់ក្នុងការរៀបចំចាត់តាំង ហើយស្របតាមការណែនាំមួយចំនួនរបស់រដ្ឋាភិបាល គប្បីអនុញ្ញាតអោយពួកគេចុះបញ្ជី និងគ្រប់គ្រងធនធានផ្ទាល់របស់ខ្លួន។ ប្រការនេះនឹងដាក់ការផ្តួចផ្តើមគំនិត ព្រមទាំងការទទួលខុសត្រូវទៅក្នុងដៃរបស់សហគមន៍ នៅពេលដែលរដ្ឋាភិបាលកំណត់បទដ្ឋានច្បាស់លាស់ ផ្តល់គាំទ្រផ្នែក បច្ចេកទេស និងធ្វើការត្រួតពិនិត្យ។

ការនេសាទសំរាប់ចិញ្ចឹមជីវិត និងការនេសាទទ្រង់ទ្រាយមធ្យម

គេបានអោយនិយមន័យការនេសាទខ្នាតតូច ឬការនេសាទសំរាប់ចញ្ចឹមជីវិត ថាជាការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទ។ និយមន័យបច្ចុប្បន្នអំពីការនេសាទសំរាប់ចិញ្ចឹមជីវិត ត្រូវបានបង្កើតឡើងក្នុងអំឡុងពេលអាណានិគមបារាំង ដែលអនុញ្ញាតិអោយប្រើប្រាស់វិធីនេសាទតាមបែបបុរាណដោយសេរី ប៉ុន្តែសំរាប់បំរើតែការបរិភោគប៉ុណ្ណោះ មិនមែនសំរាប់លក់នោះទេ។ និយមន័យនេះមិនទទួលស្គាល់ប្រភេទសហគមន៍ រស់នៅលើផ្ទះបណ្តែតទឹក ដែលនេសាទសំរាប់ចិញ្ចឹមជីវិត ដោយយកទៅលក់សំរាប់ទិញអង្ករ សំលៀកបំពាក់ និង សំភារៈចាំបាច់ផ្សេងៗទៀត ឬសហគមន៍ដែលធ្វើស្រែកន្លះឆ្នាំ ហើយនេសាទសំរាប់ចិញ្ចឹមជីវិត និងរកប្រាក់ចំណូលផង នៅក្នុងរដូវប្រាំងនោះទេ។ គ្មានក្រុមណាមួយក្នុងចំណោមក្រុមទាំងនេះ អាចនេសាទត្រីបានគ្រប់គ្រាន់សំរាប់បរិភោគ ដោយប្រើតែវិធីបុរាណក្នុងការនេសាទត្រី ដើម្បីចិញ្ចឹមជីវិតនោះទេ។

ទោះបីជាការកែទំរង់វិស័យជលផល បានផ្តល់ឡូត៍នេសាទ ៥៦% ទៅអោយសហគមន៍មូលដ្ឋាន ដើម្បីបង្កើតសហគមន៍នេសាទក៏ដោយ ក៏សហគមន៍ដែលរៀបចំ បានត្រឹមតែទទួលការបានអនុញ្ញាតិអោយនេសាទសំរាប់ ចិញ្ចឹមជីវិតតែប៉ុណ្ណោះ។ ក្នុងសេចក្តីសំរេចគោលនយោបាយថ្មីៗនេះ លោកនាយករដ្ឋមន្ត្រីបានលុបចោលការយកពន្ធលើការនេសាទធុនមធ្យម។ ប្រការនេះបានធ្វើអោយបាត់បង់យ៉ាងធ្ងន់ធ្ងរនូវការលើកទឹកចិត្តចំពោះអ្នកនេសាទ ក្នុងការសំរេចចិត្តថាតើត្រូវសហការគ្នាដើម្បីការពារធនធានទាំងនេះដែរឬយ៉ាងណា មានន័យថា ប្រសិនបើពួកគេចូលរួមក្នុងសហគមន៍នេសាទ ពួកគេអាចត្រឹមតែប្រើប្រាស់ឧបករណ៍នេសាទបុរាណដើម្បីចិញ្ចឹមជីវិតប៉ុណ្ណោះ ប៉ុន្តែបើពួកគេ មិនចូលរួមវិញនោះ ពួកគេអាចប្រើឧបករណ៍ធុនមធ្យម នេសាទត្រីបានច្រើន និងរួចពន្ធលើការនេសាទទៀតផង។

ក្រោមលក្ខខ័ណ្ឌទាំងនេះ បុគ្គលម្នាក់ៗ និងសហគមន៍នានាដែលប្រកបរបរនេសាទដើម្បីរកប្រាក់ចំណូល មិនសូវមានទឹកចិត្តក្នុងការរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រង ការពារ និងប្រើធនធានរបស់ពួកគេប្រកបដោយ និរន្តរភាព។ សមាជិកសហគមន៍បានតវ៉ាថា គេគួរកែប្រែនិយមន័យនៃការនេសាទសំរាប់តែចិញ្ចឹមជីវិត បើមិនដូច្នោះទេ សហគមន៍នេសាទគួរតែត្រូវបានអនុញ្ញាតិអោយនេសាទ ដោយយោងទៅលើលក្ខនិកៈរបស់ពួកគេ ដើម្បីអោយពួកគេអាចរស់នៅបន្តទៀតបាន ប៉ុន្តែត្រូវធានាអោយមាននិរន្តភាព។ សហគមន៍នានា គួរតែមានសិទ្ធិ និងការទទួលខុសត្រូវ ដើម្បីកសាងគំរោងការពារធនធានសំរាប់ពលរដ្ឋជំនាន់នេះ និងជំនាន់ក្រោយ។ ដោយហេតុថា រដ្ឋាភិបាលបាន អះអាងថា សហគមន៍នានាមានត្រឹមតែសិទ្ធិអភិរក្ស និងគ្រប់គ្រងធនធាននោះ សហគមន៍នានាបានតវ៉ាថា ពួកខ្លួនគួរតែត្រូវបានអនុញ្ញាតអោយអភិរក្ស គ្រប់គ្រង *និងប្រើប្រាស់* ធនធានទាំងឡាយរបស់ខ្លួន។

ការអនុវត្តន៏នីនៃសហគមន៍នេសាទ

ផ្នែកទីបីដែលសហគមន៍បានស្នើអោយរដ្ឋាភិបាលកែសំរួលគោលនយោបាយរបស់ខ្លួនសារឡើងវិញនៅក្នុងផ្នែកនេះគឺការអនុវត្តន៍។ សេចក្តីព្រាងអនុក្រឹត្យ និងច្បាប់ជលផល មិនអនុញ្ញាតអោយអង្គការសហគមន៍នេសាទមានសិទ្ធិក្នុងការឃាត់ខ្លួនអ្នករំលោភបំពានមកលើតំបន់របស់សហគមន៍ឡើយ។ ប្រការនេះធ្វើអោយសហគមន៍ស្ទើរតែមិនអាចធ្វើសកម្មភាពរួមគ្នាដើម្បីការពារតំបន់របស់ខ្លួនបាន។ សេចក្តីព្រាងនោះក៏ដាក់បន្ទុកដ៏ធ្ងន់ធ្ងរមកលើមន្ត្រីអនុវត្តច្បាប់របស់រដ្ឋាភិបាល ដែលមិនអាចឃ្លាំមើល និងអនុវត្តគ្រប់កន្លែងដោយខ្លួនឯង។ សហគមន៍នៅទូទាំងប្រទេសបានបង្ហាញថាគណៈកម្មការនេសាទសហគមន៍អាចធ្វើបាន ក្នុងការឃ្លាំមើលដោយសន្តិភាព និងឃាត់ខ្លួនជនល្មើស និងធ្វើការជិតស្និទ្ធក្នុងកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីមូលដ្ឋានក្នុងការអនុវត្តន៍នីច្បាប់ និងអនុវត្តបទប្បញ្ញត្តិនានា។ សហគមន៍បានទទួច

ម្តងហើយម្តងទៀតថាអោយរដ្ឋាភិបាលផ្តល់សិទ្ធដល់ពួកខ្លួនក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងការការពារធនធាន ដើម្បីជាគុណប្រយោជន៍សំរាប់សហគមន៍ និងសំរាប់រដ្ឋាភិបាល ។

៣. កំណែទំរង់ការនេសាទដែលមានលក្ខណៈពាណិជ្ជកម្ម

ទោះបីជាការនេសាទដែលមានលក្ខណៈពាណិជ្ជកម្មក៏មានសារៈសំខាន់ផងដែរចំពោះសេដ្ឋកិច្ច ចាំបាច់គេត្រូវគ្រប់គ្រង លុបបំបាត់របៀបនេសាទដែលមានចរិតបំផ្លិចបំផ្លាញ និងការនេសាតខុសច្បាប់ និងចៀសវាងនូវការនេសាទហួសហេតុ ។ ប៉ុន្តែគេមានការលើកទឹកចិត្តតិចតួចប៉ុណ្ណោះក្នុងការធ្វើបែបនេះនៅក្នុងខណៈដែលផលកំរៃដែល បានមកពីការលក់ត្រីនៅមានកំរិតទាប ។ មានការទាមទារអោយបង់ថ្លៃតាមផ្លូវការជាច្រើនកន្លែង និងត្រូវចំណាយ ទឹកប្រាក់ខ្ពស់ណាស់ ប្រសិនបើការតំរូវអោយបង់ថ្លៃទាំងនោះត្រូវបានអនុវត្ត នោះអ្នកប្រកបរបរនាំត្រីចេញទាំងអស់ ឬមួយចំនួនធំ នឹងមិនអាចរកស៊ីលើរបរនេះបានឡើយ ។ ប្រការនេះធ្វើអោយមានការរាយការណ៍បន្ថយចំនួន និងមាន ការចរចារជាទូទៅក្នុងការទូទាត់ប្រាក់ក្រៅផ្លូវការ រួមមានកន្លែងត្រួតពិនិត្យចល័ត "ដើម្បីរកលិខិតអនុញ្ញាតិ " ហើយ តំរូវ អោយបង់ប្រាក់ពីស្ថាប័នដែលគ្មានមូលដ្ឋានជាក់លាក់សំរាប់ប្រមូលប្រាក់បន្ទុកបែបនេះ ។ ប្រាក់បន្ទុកដែលប្រមូល បាន មិនទ្រទ្រង់ការងារនៃការគ្រប់គ្រងធនធានផលផលឡើយ ដែលប្រការនេះក៏ធ្វើអោយអ្នកប្រកបរបរនាំត្រីចេញ បន្ថោកថ្លៃត្រីនៅក្នុងលើកដាក់កាន់តែទាបតាមដែលពួកគេអាចធ្វើបាន ។[១៣]

កំណែទំរង់ជលផលមិនបានបញ្ចប់ជំលោះនេសាទ ក្នុងចំណោមក្រុមអ្នកប្រើប្រាស់ផ្សេងៗគ្នានោះទេ ហើយជំលោះនេះ នៅតែបន្តកើតមានតាមរូបភាពខុសៗគ្នា ។ ទន្ទឹមនឹងនេះ កំណែទំរង់ក៏មិនបានផ្លាស់ប្តូរឡូត៍នេសាទស្រាវជ្រាវទាំងអស់អោយទៅជាឡូត៍លក់ដេញថ្លៃឡើយ ។ ផ្ទុយទៅវិញ ឡូត៍នេសាទត្រូវបានផ្តល់អោយទៅម្ចាស់ឡូត៍ទៅវិញ មុនពេលកំណែទំរង់ ក្នុងរូបភាពជាឡូត៍នេសាទស្រាវជ្រាវ ក្នុងកំឡុងពេល ៦ ឆ្នាំ ចាប់ពីឆ្នាំ ២០០៣-២០០៩ ដែលពន្យារពេលពី ៤ ទៅ ៦ ឆ្នាំ។ សង្គមស៊ីវិលអបអរសាទរ ចំពោះនយោបាយមិនយកពន្ធលើការនេសាទធុនមធ្យម ប៉ុន្តែកត់សំគាល់ឃើញថាអ្នកនេសាទនៅតែបន្តបង់ប្រាក់ ដើម្បីប្រើប្រាស់ឧបករណ៍នេសាទ ដែលមានខ្នាតធំជាងឧបករណ៍នេសាទលក្ខណៈគ្រួសារ ។

កំណែទំរង់ជលផលបានកើតឡើងភ្លាម ហើយសេចក្តីសំរេចចិត្តអំពីការបញ្ចេញតំបន់នេសាទ ត្រូវបានធ្វើឡើងភ្លាមបន្ទាប់ពីកំណែទំរង់ ដោយគ្មានផែនការ នយោបាយ និងទិសដៅណាមួយឡើយ ។ តំបន់នេសាទ ដែលត្រូវបានបញ្ចេញ

---

[13] Yim និង McKenney ទំព័រ ៥

សំរាប់សហគមន៍មូលដ្ឋាន គ្របដណ្តប់លើឡូត៍នេសាទថោកៗ និងជាតំបន់ដែលស្ទើរតែមិនអាចរករបរនេសាទបាន។ ការប្រកួតប្រជែងគ្នា រវាងអ្នកនេសាទធុនតូច និងធុនធំ បណ្តាលអោយមានជំលោះ។

(iii) - អនុសាសន៍

- យើងជំរុញអោយរាជរដ្ឋាភិបាល ចាត់វិធានការតឹងតែង និងជានិរន្តរ៍ ប្រឆាំងនឹងការនេសាទខុសច្បាប់ និងការបំផ្លាញជំរកត្រីពង តាមរយៈការអប់រំ និងការអនុវត្តន៍ច្បាប់។
- យើងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបញ្ចូលអ្នកតំណាងសហគមន៍ ទៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខ្ពស់ ស្តីពីគោលនយោយនេសាទ។ យើងបន្តជំរុញអោយរាជរដ្ឋាភិបាល ធ្វើអោយកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានអំពីគោលនយោបាយនេសាទ កាន់តែមានផលិតភាពខ្ពស់ និងលៃយ៉ាងណាអោយសំណើរបស់ប្រជាពលរដ្ឋមូលដ្ឋានត្រូវបានធ្វើសមាហរណកម្ម បើមិនដូច្នោះទេការពិគ្រោះយោបល់នឹងមិនសូវមានសារៈសំខាន់ឡើយ។
- យើងស្នើអោយរាជរដ្ឋាភិបាលធ្វើអោយដំណើរការនៃការចុះបញ្ជីជាសហគមន៍នេសាទមានលក្ខណៈសាមញ្ញ និងធ្វើអោយកាន់តែមានប្រសិទ្ធភាព ដោយទុកអោយសហគមន៍ជាអ្នកផ្តួចផ្តើមគំនិត និងទទួលខុសត្រូវ ព្រមជាមួយនឹងការណែនាំច្បាស់លាស់ មានតំលាភាព មានជំនួយបច្ចេកទេស និងមានការត្រួតពិនិត្យពីរដ្ឋាភិបាល។
- យើងស្នើថា និយមន័យនៃការនេសាទសំរាប់ចិញ្ចឹមជីវិតនៅបច្ចុប្បន្ននេះ គួរតែត្រូវបានជំនួសដោយការយល់ឃើញ ថ្មីចំពោះការនេសាទសំរាប់ចិញ្ចឹមជីវិត ឬគួរអនុញ្ញាតអោយសហគមន៍ អោយរៀបចំ និងកំណត់វិធីនេសាទដោយសហគមន៍ខ្លួនឯងផ្ទាល់ ប៉ុន្តែធានាអោយបាននូវនិរន្តរភាពជលផល និងជីវភាពរបស់ពួកគេ។ ការកែប្រែគោលនយោបាយ ចាំបាច់ត្រូវតែលើកទឹកចិត្តអោយសហគមន៍ដែលពឹងអាស្រ័យលើការនេសាទ រៀបចំ និង ការពារជីវភាពរស់នៅរបស់ពួកគេ សំរាប់ការប្រើប្រាស់ របស់ពួកគេផ្ទាល់ និងសំរាប់ពលរដ្ឋជំនាន់ក្រោយ។ ការកែប្រែ ទាំងនេះគួរតែធ្វើឡើងដោយមានការពិគ្រោះយោបល់គ្នាយ៉ាងជិតស្និទ្ធ ជាមួយនឹងសហគមន៍នេសាទមូលដ្ឋាន។
- យើងជំរុញអោយមានគោលនយោបាយ ដែលគោលនយោបាយនោះនឹងអនុញ្ញាតិអោយសហគមន៍មានតួនាទីយ៉ាងសកម្មក្នុងការអនុវត្តន៍ច្បាប់ និងការពារតំបន់ធនធានរបស់ខ្លួន ហើយផ្តល់នូវយន្តការច្បាស់លាស់សំរាប់កិច្ចសហ-ប្រតិបត្តិការជាមួយអាជ្ញាធរ។ លុះត្រាតែសហគមន៍មូលដ្ឋានមានសិទ្ធិក្នុងការការពារតំបន់របស់ពួកគេ ពុំនោះទេការនេសាទខុសច្បាប់ និងការធ្វើអាជីវកម្មហួសហេតុ នឹងនៅតែបន្ត។

- យើងស្នើអោយរដ្ឋាភិបាលសើរើលិខិតអនុញ្ញាតិ អាជ្ញាប័ណ្ណ និងប្រព័ន្ធបង់ប្រាក់សំរាប់ពាណិជ្ជកម្ម និងសំរាប់ការនាំត្រីចេញ ដោយសើរើពន្ធនាំចេញ ការបង្កើតសេវាបង់ប្រាក់តែ "មួយដំណាក់" និងជំរុញអោយមាន ទំនាក់ទំនងគ្នា រវាងការបង់ប្រាក់ និងសេវាកម្មគ្រប់គ្រងការនេសាទជាក់ស្តែង ។
- យើងជឿជាក់ថា ក្រុមប្រឹក្សាឃុំសង្កាត់ គួរទទួលបាននូវតួនាទីកាន់តែធំ ដើម្បីចូលរួមនៅក្នុងការគ្រប់គ្រង និង ថែរក្សាធនធានជលផល ។

សំរាប់ពតិមានបន្ថែម និងបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងឯកសារនេះ សូមទំនាក់ទំនង : Fisheries Action Coalition Team ទូរស័ព្ទលេខ : ០២៣ ៩៩០ ៣៨២ E-mail : fact@everyday.com.kh

វិស័យព្រៃឈើ

(i) សេចក្តីផ្តើម:

ធនធានព្រៃឈើជាមូលដ្ឋាននៅប្រទេសកម្ពុជា ត្រូវបានគេប៉ាន់ស្មានថាគ្របដណ្តប់លើផ្ទៃដីប្រទេសជាងពាក់កណ្តាល ភាគច្រើននៃធនធានព្រៃឈើ ត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរ ក្នុងរយៈពេលជាងដប់ទៅដប់ប្រាំឆ្នាំចុងក្រោយនេះ ។ ដូចដែលយើងបានដឹងជាទូទៅមកហើយថា តំបន់សំខាន់ៗ ត្រូវបានគេដាក់អោយស្ថិតនៅក្នុងដែនព្រៃសម្បទាន ហើយតំបន់ផ្សេងៗទៀតត្រូវបានកាប់ដោយអ្នកដែលមិនមែនជាសម្បទាននិក ហើយ នៅតំបន់ទាំងនោះមានកំណើនប្រជាជន និងមានកំណើននៃការប្រើប្រាស់ធានធានព្រៃឈើ ជាផលឈើ ជាអុស រឺងអនុផលព្រៃឈើជាច្រើនប្រភេទទៀតកំពុងតែធ្វើអោយធនធានដែលនៅសេសសល់ទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងក្លា។ ជាងនេះទៅទៀត វិសាលភាពព្រៃកំពុងតែថយចុះជាបន្តបន្ទាប់ដោយសារតែការបង្វែរផ្ទៃដីព្រៃ អោយទៅជាដីកសិកម្ម និងដំណាំចំការធំៗរបស់អ្នកជំនួញ និងក្រុមអ្នក មានទ្រព្យសម្បត្តិ មួយចំនួនតូច ។

ការគំរាមកំហែងមួយទៀតនោះគឺគំរោងសាងសង់ផ្លូវនានារបស់ក្រុមហ៊ុនព្រៃសម្បទានរួមជាមួយជំនួយហិរញ្ញវត្ថុទ្វេភាគីនិងពហុភាគីបានធ្វើអោយគេងាយចូលទៅកាន់តំបន់មានព្រៃឈើ។ ផ្លូវទាំងនេះកំពុងជួយសំរួលយ៉ាងច្រើនដល់ការតាំងទីលំនៅថ្មីនៅក្នុងតំបន់ព្រៃ ហើយជនទាំងនោះស្វែងការកាប់ឆ្ការដីព្រៃដើម្បីនឹងទទួលបានកម្មសិទ្ធិនៅលើផ្ទៃដីដែលកាប់ឆ្ការថ្មីនោះជាបន្តបន្ទាប់។ មានផលប៉ះពាល់យ៉ាងច្រើនជាមួយព្រៃឈើកម្ពុជានិងការអភិវឌ្ឍន៍ទាំងនេះ ពោលគឺសក្តានុពលពាណិជ្ជកម្មនៃព្រៃឈើនាពេលអនាគត និងប្រជាជនដែលតាំងទីលំនៅតាមលក្ខណៈ ប្រពៃណីនៅក្នុងនិងជុំវិញតំបន់ព្រៃ។

នៅពេលដែលធនធានព្រៃឈើជាមូលដ្ឋានស្ថិតនៅក្រោមការគំរាមកំហែងបែបនេះ មានសក្តានុពលដ៏សំខាន់សំរាប់បង្ការភាពក្រីក្រតាមរយៈការអភិវឌ្ឍន៍ព្រៃឈើសង្គម និងប្រពន្ធ័គ្រប់គ្រងព្រៃឈើរួមគ្នា ដែលស្ថាបនាផ្អែកលើសមាហរណកម្មព្រៃឈើដែលមានលក្ខណៈប្រពៃណីជាមួយជលផល ទៅក្នុងប្រព័ន្ធកសិកម្មរបស់ប្រជាជនខ្មែរ និងក្រុមជនជាតិភាគតិច។ លើសពីនេះទៅទៀតការប្រឹងប្រែងដោយសហគមន៍មូលដ្ឋានរ ដើម្បីបញ្ឈប់ការកាប់ឈើខុសច្បាប់នាពេលថ្មីៗនេះកំពុងទទួលបានការគាំទ្រ ដ៏ខ្លាំងក្លាពីសំណាក់អាជ្ញាធរមូលដ្ឋាន នៅក្នុងតំបន់នានាជាច្រើន។

(ii) បញ្ហាគន្លឹះ

<u>ការកាប់ឈើខុសច្បាប់និងការត្រួតពិនិត្យដោយឯករាជ្យ:</u> នៅក្នុងប្រទេសកម្ពុជាការកាប់ឈើមានការកើនឡើង ដល់កំរិតខ្ពស់។ ទោះបីជាការកាប់ឈើ ជាញឹកញាប់ត្រូវបានបង្ហាញថា ជាសកម្មភាពការងាររបស់អ្នកភូមិក៏ដោយ ក៏ជាទូទៅសកម្មភាពនេះត្រូវបានរៀបចំដោយទាហ៊ាន ឬ ប៉ូលីសព្រមទាំងមានការឃុបឃិតពីមន្ត្រីរដ្ឋាភិបាលថែមទៀត ។ ការប្រមូលផលឈើ កែច្នៃឈើ ការដឹកជញ្ជូន និង លក់ត្រូវឆ្លងកាត់បណ្តាញឈ្មួញកណ្តាល ជាមួយនឹងការទប់ស្កាត់យូរៗម្តង ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។ ការកាប់ឈើក្នុងទ្រង់ទ្រាយធំក៏កំពុងកើតឡើងក្រោមរូបភាពជាដីសម្បទានរបស់ក្រុមហ៊ុននិងចំការកៅស៊ូ។ ជាទូទៅតំបន់ គោលដៅសំរាប់ការអភិវឌ្ឍន៍ដំណាំចំការធំៗត្រូវបានកំណត់នៅក្នុងតំបន់ព្រៃដែលមានតំលៃបំផុត ជាជាងតំបន់ដែលគ្មានព្រៃ ឬ ដីវាលដែលវាមានលក្ខណៈសក្តិសមនឹងបង្វែរទៅជាតំបន់ធ្វើកសិកម្ម ។

ការអនុវត្តន៍ការត្រួតពិនិត្យប្រកបដោយភាពឯករាជ្យ លើបញ្ហាស្មុគស្មាញនៃការកាប់ឈើខុសច្បាប់ ត្រូវបានបញ្ឈប់ក្នុងខណៈពេលដែលអង្គការ GlobleWitness ត្រូវបានដកចេញមិនអោយធ្វើសកម្មភាពជាបន្ត នាដើមឆ្នាំនេះ។ ម្ចាស់ជំនួយបានស្វែងរកផងដែរ ក្នុងការភ្ជាប់អ្នកជំនួយបរទេសរបស់ពួកគេ ជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងធនធានព្រៃឈើ ដើម្បីទទួលបានជាអតិបរមានូវផលប្រយោជន៍សាធារណៈ ។ នេះជាហេតុផលចំបងសំរាប់ការត្រួតពិនិត្យប្រកបដោយភាពឯករាជ្យ ដូចជាឯកសារស្តីពី "គំរោងត្រួតពិនិត្យឧក្រិដ្ឋកម្មព្រៃឈើ" ក្នុងឆ្នាំ១៩៩៩ [១៤] ។

<u>ការអភិវឌ្ឍន៍ខ្នាតធំឬតូចលើវិស័យព្រៃឈើ កសិកម្ម និង ដំណាំចំការ:</u> ការផ្តោតជាគន្លឹះនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលគឺការជំរុញវិស័យកសិឧស្សាហកម្ម តាមរយៈការអភិវឌ្ឍន៍ដំណាំចំការ ហើយ ផ្សារភ្ជាប់នឹងការកែច្នៃដំណាំផ្តល់ប្រាក់ (ដូចជាស្វាយចន្ទី ដូងប្រេង កៅស៊ូ និងសណ្តែកសៀង) បន្ទាប់ពីបានទទួលផល។ ការអនុវត្តន៍នាពេលបច្ចុប្បន្នរបស់ រដ្ឋាភិបាលបង្ហាញថា រដ្ឋាភិបាលបានសំរេចចិត្តជំរុញការអភិវឌ្ឍន៍ដំណាំចំការ ដែលមាន

---

[14] ឯកសារស្តីពី*គំរោងឧក្រិដ្ឋកម្មព្រៃឈើ និងការរាយការណ៍* បញ្ជាក់ថា "ដើម្បីបន្តលើទឹកចិត្តរាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់អោយអនុវត្តច្បាប់ព្រៃឈើអោយមានប្រសិទ្ធភាព IMF បានបញ្ជាក់អំពីការបង្កើតនូវប្រព័ន្ធតាមដានព្រៃឈើជាអចិន្ត្រៃយ៏ [sic] ធ្វើជាការចាប់ផ្តើមកម្មវិធីទ្រទ្រង់ផ្នែកម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួន" ហើយ "ក្នុងលទ្ធភាពទី៣ រដ្ឋាភិបាលស្នើអោយមានក្រុមផ្តល់យោបល់ឯករាជ្យ ដែលនឹងផ្សព្វផ្សាយជាសាធារណនូវការវាយតំលៃរបស់ខ្លួនអំពី កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលអំពីបញ្ហាព្រៃឈើ ។ ការវាយតំលៃដែលមានលក្ខណៈឯករាជ្យនេះមានបំណងផ្តល់នូវការធានាដល់សហគមន៏ម្ចាស់ជំនួយអន្តរជាតិស្តីអំពីខ្លឹមសារនៃការប៉ាន់ស្មានក្នុងការរាយការណ៏ផ្ទាល់របស់រដ្ឋាភិបាល និងលើការប្តេជ្ញាជាមូលដ្ឋានរបស់រដ្ឋាភិបាលចំពោះការធ្វើអោយព្រៃឈើមាននិរន្តរភាព" រាជរដ្ឋាភិបាលកម្ពុជា ឧក្រិដ្ឋកម្មព្រៃឈើ និងការរាយការណ៏ ឯកសារគំរោង ខែ កក្កដា ឆ្នាំ ១៩៩៩ ទំព័រ ៤

ទ្រង់ទ្រាយធំ ។ ការសំរេចចិត្តនេះកំពុងតែមានផលប៉ះពាល់យ៉ាងខ្លាំងទៅ លើសហគមន៍ជនបទ ព្រោះវាទាក់ទងទៅនឹងការផ្លាស់ប្តូរ តំបន់ព្រៃឈើជាច្រើនសំរាប់អភិវឌ្ឍផ្នែកកសិកម្ម ។ ប្រសិនបើការសំរេចចិត្តទាំងនេះត្រូវបានអនុវត្តន៍ នោះបំលែងតំបន់ដីព្រៃនឹងបង្កើនល្បឿន ហើយគ្រួសារ និង ក្រុមហ៊ុនមួយចំនួនតូចនឹងក្លាយទៅជាម្ចាស់នៃដីព្រៃដ៏ធំធេងយ៉ាងពិតប្រាកដហើយ វិសមភាពក្នុងការបែងចែកប្រាក់ចំណូលទំនងជាបន្តមានសភាពអាក្រក់ឡើងៗ ។

<u>ការកាប់ឈើច្បោះជ័រ:</u> ការកាប់ឈើច្បោះជ័រនៅតែបន្ត ថ្វីបើមានការហាមឃាត់នៅក្នុងច្បាប់ព្រៃឈើក្តី[១៥] ហើយទោះជាមានការយល់ ដឹងកាន់តែច្រើននៃអ្នកភូមិដែលមានប្រាក់ចំនូលខ្ពស់បានមកពីការជងជ័រទឹកក៏ដោយ[១៦] ។ នាពេលថ្មីៗនេះការកាប់ដើមច្បោះ ភាគច្រើន កំពុងកើតឡើងក្រោមរូបភាពក្លែងភេទនៃដីសម្បទាន និងការអភិវឌ្ឍន៍ដំណាំចំការធំៗ ហើយនេះបញ្ជាក់ថា ការឯកភាពលើព្រៃសម្បទាន គឺមានបំណងកាត់ដើមច្បោះរបស់អ្នកភូមិនៅក្នុងតំបន់សម្បទាន។ ទិន្នន័យសារពើភ័ណ្ឌដែលបានប្រើប្រាស់សំរាប់យុត្តិកម្មលើការអនុម័តផែនការគ្រប់គ្រងព្រៃសម្បទាន មិនបានទទួលស្គាល់ថាភាគច្រើននៃការកាប់ឈើដែលបានអនុញ្ញាតអោយកាប់ប្រចាំឆ្នាំគឺជាឈើច្បោះជ័រឡើយ ។ ជំនាញការ ដែលធ្វើការក្នុងគំរោងសិក្សាអំពីឥណទាននវិកម្មរបស់ធនាគារពិភពលោក លើការគ្រប់គ្រងសម្បទានព្រៃឈើ បានលើកឡើងថា បញ្ហាឈើច្បោះជ័រមិនត្រូវបានគេលើកយកមកធ្វើការ ត្រេះរិះពិចារណា ថាតើសម្បទានព្រៃឈើអាចធ្វើពាណិជ្ជកម្មបានដែរឬយ៉ាងណា និងបានលើកឡើងថា ក្រុមហ៊ុននានាអាចចរចារ ជាមួយអ្នកភូមិអំពីការលក់ឈើច្បោះជ័រ ដែលអាចអោយពួកគេកាប់ឈើទាំងនោះបាន ។

---

[15] មាត្រា ២៩ កពា.នៃច្បាប់ព្រៃឈើ: "ត្រូវបានហាមឃាត់ក្នុងការប្រមូលផលដូចរៀបរាប់ខាងក្រោម ទោះនៅទីណាក្តីនៅក្នុងព្រៃបំរុង ទុកអចិន្ត្រៃយ៍... ឈើច្រើនប្រភេទដែលសហគមន៍បានចោះជាច្បោះ ដើម្បីយកជ័រ សំរាប់ការប្រើប្រាស់តាមទម្លាប់" ។

[16] Tom D. Evans, et al: *ការសិក្សាពីជ័រទឹក និងការចិញ្ចឹមជីវិតរបស់ប្រជាជន ដែលទាក់ទងនឹងការអភិរក្ស និងការគ្រប់គ្រងព្រៃឈើ នៅខេត្តមណ្ឌលគិរី នៃប្រទេសកម្ពុជា.* សមាគមអភិរក្សសត្វព្រៃ. ភ្នំពេញ ខែមករា ឆ្នាំ២០០៣ ។ Ian G. Baird, " ឈើផ្តល់ជ័រទឹកប្រភេទ *Dipterocarpus*, ការគ្រប់គ្រង និងការធ្វើ អាជីវកម្ម: ការអនុវត្តន៍នៃ របស់ Brao ក្នុងភាគឦសាន្តនៃប្រទេសកម្ពុជា" និក្ខេបបទអក្សរសាស្ត្រថ្នាក់អនុបណ្ឌិត ដេប៉ាតឺម៉ង់ភូមិវិទ្យា នៃសាកលវិទ្យាល័យវីកតូរៀ ឆ្នាំ២០០៣ ។ McAndrew, John P., ម៉ម សម្បត្តិ ហុង គីមលី និង លី ប៊ុនថៃ"ការសំរបខ្លួនរបស់ប្រជាជនជនជាតិភាគតិច លើការថយចុះនៃធនធានធម្មជាតិ: បទពិសោធន៍របស់ឃុំភ្នងទាំងពីរ នៅភាគឦសាន្តនៃប្រទេសកម្ពុជា" ភ្នំពេញ CIDSE ពង្រាងនៅឆ្នាំ ២០០៣ ។

<u>កៅស៊ូឬជ័រទឹក:</u> រដ្ឋាភិបាលកម្ពុជានិងសមាជិកសហគមន៍ម្ចាស់ជំនួយមួយចំនួនកំពុងឃោសនាពីសក្តានុពល នៃតំបន់ជន បទរបស់កម្ពុជាសំរាប់កសិឧស្សាហកម្មនិងជាពិសេសសំរាប់ផលិតកម្មកៅស៊ូ[១៧]។ ការវាយតំលៃបែបសុទិដ្ឋិនិយម នៃសក្តានុពលភាពកម្ពុជាសំរាប់ផលិតកម្មកៅស៊ូនេះហាក់បីដូចធ្វើមិនដឹងមិនឮអំពីនិន្នាការនៃការធ្លាក់ចុះជាយូរមកហើយ នូវ តំលៃកៅស៊ូនៅទីផ្សារអន្តរជាតិ សព្វថ្ងៃនេះកៅស៊ូសំយោគបានជំនួសកៅស៊ូធម្មជាតិទៅហើយ[១៨]។ ផ្ទុយមកវិញ តំលៃអន្តរជាតិសំរាប់តំលៃជ័រឈើបានកើនឡើងតាំងពីឆ្នាំ១៩៧០មេ្លះ ព្រោះតែការបាត់បង់ព្រៃឈើទ្រង់ទ្រាយធំ ដែលបានកើតឡើងក្នុងរយៈប៉ុន្មានទសវត្សរ៍កន្លងមកនៅតំបន់អាស៊ីអាគ្នេយ៍[១៩]។ ម្យ៉ាងវិញទៀត ការចោះដើមឈ្មោះយកជ័រទឹក នាំមកនូវការអភិរក្សព្រៃឈើ *dipterocarp* របស់ប្រទេសកម្ពុជា និងផលប្រយោជន៍សំខាន់ផ្នែកបរិស្ថាន ។

<u>ការកាត់បន្ថយភាពក្រីក្រ ឬការបង្កើតភាពក្រីក្រ:</u> គោលជំហរទប់ស្កាត់របស់រដ្ឋាភិបាល និងម្ចាស់ជំនួយ គឺថាកំណែទំរង់គោលនយោបាយដែលបានគ្រោង និង អនុវត្ត សំដៅកាត់បន្ថយភាពក្រីក្រ។ ហើយនៅបច្ចុប្បន្ននេះ ស្ទើរតែគ្រប់សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពរបស់ម្ចាស់ជំនួយ គឺសុទ្ធត្រូវបានធ្វើឡើងដោយផ្អែកលើផលប៉ះពាល់នៃការកាត់បន្ថយភាពក្រីក្រ។ ទោះបីជាយ៉ាងនេះក៏ដោយ ការអនុវត្តន៏ជាក់ស្តែងរបស់រាជរដ្ឋាភិបាល ដែលតែងតែត្រូវបានផ្តល់ហិរញ្ញវត្ថុ និងផ្តល់ភាពស្របច្បាប់ពីសហគមន៍ម្ចាស់ជំនួយ កំពុងជំរុញកម្ពុជាអោយស្ថិតនៅលើគន្លង នៃកំណើនវិសមភាព ហើយអាចជំរុញអោយប្រជាជនមួយភាគធំនៅជនបទ មានភាពក្រីក្រកាន់តែធ្ងន់ធ្ងរឡើងៗ។ ជាពិសេស

---

១៧ ឧទាហរណ៍ ឯកសារទស្សនាទានថ្មីរបស់ធនាគារពិភពលោកស្តីពីកំណើនធនធាន បានកត់សំគាល់ថា: "កៅស៊ូ គឺជាសក្តានុពលភាពនៃធនធានធម្មជាតិ ដែលមានតំលៃបំផុតបន្ទាប់ពីផលឈើរបស់ប្រទេសកម្ពុជា។ កៅស៊ូធ្លាប់ជាផ្នែកមួយប្រសើបំផុតសំរាប់ប្រទេសកម្ពុជាក្នុងការស្វែងរករូបិយប័ណ្ណបរទេស ប៉ុន្តែបច្ចុប្បន្នដំណាំកៅស៊ូបានថយ ចុះហើយដើមកៅស៊ូ ទាំងនោះមានអាយុច្រើន សំភារៈចាស់ទ្រុឌទ្រោម និងមានស្ថានភាពអាក្រក់ ហើយគុណភាពរបស់ កៅស៊ូកាន់តែអន់ទៅៗ" ។ សូមអានឯកសារធនាគារពិភពលោក " កម្ពុជា: ការសិក្សាពីប្រភពកំណើន និងការកាត់បន្ថយភាពក្រីក្រ" ធនាគារពិភពលោក ភ្នំពេញ ខែកញ្ញា ឆ្នាំ២០០៣ ត្រង់ទំព័រទី៥" ។

18 សូមអាន"អភិជនកៅស៊ូ?" របស់ទស្សនាវដ្តី Economist ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៣ និង"ដែលបង្កសំលេងរំពង" របស់ទស្សនាវដ្តី Economist ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៩ ។

១៩ Renee Ankarfjard & Miran Kegl," Tapping oleoresin from Dipterocarpus alatus (Dipterocarpaceae) in a Lao Village", Economic Botany, Vol52, No.1,1998,pp. 7-14; Rosemary Gianno, " ការធ្វើអាជីវកម្មឈើ ផលិតផលជ័រទឹកក្នុងតំបន់ព្រៃទំនាប Malayan", Wallaceana, Vol. 43, 1986, pp. 3-6.

ភាពក្រីក្រកើតមានចំពោះសហគមន៍ដែលពឹងផ្អែកលើព្រៃឈើ ដែលសហគមន៍កាន់តែមានលទ្ធភាពតិចតួច ក្នុងការទទួលបានធនធានព្រៃឈើ ពោលគឺផលិតផលដែលគេពឹងផ្អែកយ៉ាងខ្លាំងសំរាប់រកប្រាក់ចំណូលនោះ ត្រូវបានអ្នកដទៃដណ្តើមយកដោយមិនស្របច្បាប់ ឬ ការយកពន្ធដារស្មើរតែស្មើនឹងតំលៃពេញនៃតំលៃទីផ្សារទៅហើយ[២០] ហើយបច្ចុប្បន្នព្រៃរបស់ពួកគេត្រូវបានដកហូត តាមរយៈការជំរុញគំរោងអភិវឌ្ឍន៍ដែលយល់ដឹងមិនល្អ ដូចជាចំការកៅស៊ូទ្រីងជាដើម។ ចំពោះប្រជាជនជាច្រើននៅតាមទីជនបទ អនាគតនៅតែមានភាពអាប់អួរ។

(iii) អនុសាសន៍:

កម្ពុជាស្ថិតនៅលើផ្លូវបំបែក និងប្រឈមមុខនឹងមហន្តរាយដ៏ធំ ដូចជាប្រទេសហៃទីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ជាមួយនឹងការធ្លាក់ចុះជាបន្តទៅក្នុងភាពក្រីក្រភាគច្រើន ដោយបាត់បង់ស្ទើរតែទាំងស្រុងនូវវិសាលភាពព្រៃឈើ និងកំពុងរងនូវការគំរាមកំហែងនៃអស្ថេរភាពសង្គម។ ផ្អែកលើការគ្រប់គ្រងព្រៃឈើដោយព្រៃសម្បទាន ការកាប់ឈើប្រចាំឆ្នាំ និង ដីសម្បទានមានទ្រង់ទ្រាយធំ នឹងនាំអោយកម្ពុជាឆ្ពោះទៅស្ថានភាពបែបនេះ ។

ជំរើសដ៏ល្អនោះ គឺអ្នកតាក់តែងគោលនយោបាយរបស់ប្រទេសកម្ពុជា អាចជ្រើសរើសយកការចំលងគំរូអភិវឌ្ឍន៍ដែលមានលក្ខណៈសមធម៌នៃប្រទេសដែលមានការគ្រប់គ្រងការពារធនធានព្រៃឈើ តាមរបៀប ដែលផ្តល់សេចក្តីត្រូវការសំរាប់ ការចិញ្ចឹមជីវិតរបស់សហគមន៍ជនបទ ហើយលៃយ៉ាងណាថែរក្សាគន្លឹះនៃប្រព័ន្ធអេកូឡូស៊ីនិងប្រពន្ធ័ផ្លូវទឹក។ ប្រការតំរូវអោយអនុវត្តន៍លើជំរើសយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើមួយ ដែលទទួលស្គាល់ថាកម្ពុជានឹងអាចរក្សាព្រៃរបស់ខ្លួនបាន ប្រសិនបើសហគមន៍ក្លាយជាស្នូលនៃការគ្រប់គ្រង និងត្រូវបានផ្តល់សិទ្ធិដើម្បីការពារ គ្រប់គ្រង និងទទួលផលប្រយោជន៍ពីតំបន់ព្រៃឈើ ។

ដើម្បីតំរង់ឆ្ពោះទៅរកនិរន្តភាព និងការគ្រប់គ្រងប្រកបដោយសមធម៌នៃព្រៃឈើកម្ពុជា ត្រូវមានអនុសាសន៍ជាជំហាន៧ដែលមានលក្ខណៈបន្ទាន់។ ជាការចាំបាច់គឺថារាល់ជំហានទាំងនេះត្រូវអនុវត្តមុនពេលមានការឯកភាពរបស់រដ្ឋាភិបាល អំពីពាណិជ្ជកម្មផ្សេងព្រេងថ្មីៗ ឬ ធ្វើការចរចាឡើងវិញលើកិច្ចសន្យាសម្បទានសព្វថ្ងៃ (ដូចជាព្រៃសម្បទាន ដីសម្បទាន និងការអភិវឌ្ឍន៍ដំណាំចំការ)។ ជំហានទាំងនេះរួមមាន:

---

[២០] ព្រុំ តុលា និង Bruce Mckenney : ការធ្វើអាជីវកម្មផលិតផលព្រៃឈើក្នុងប្រទេសកម្ពុជា: ករណី សិក្សាពីជ័រទឹក" ការត្រួតពិនិត្យការអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ, Vol.7, No. 2, មេសា-មិថុនា ២០០៣។

- ធ្វើការវាយតំលៃវិសាលភាពព្រៃ ដោយឯករាជ្យ និងគ្រប់ជ្រុងជ្រោយ ធ្វើជាមូលដ្ឋានសំរាប់រៀបរាប់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍។
- រៀបរាប់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍។
- រៀបចំ និងអនុម័តច្បាប់ទ្រព្យសម្បត្តិរដ្ឋ (ដែលរួមបញ្ចូលទាំងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍)ដែលធានាតម្លាភាពទាក់ទងទៅនឹងការកំណត់ព្រំដែន ការប្រើប្រាស់ និង ការគ្រប់គ្រង ។
- ធ្វើការប្តេជ្ញាចិត្តច្បាស់លាស់មួយដោយមានការឯកភាពគ្នា ជាមួយនឹងការសិក្សារបស់ធានាគារពិភពលោក និងប្រាក់កម្ចីនវានុវត្តន៏ស្តីពីការគ្រប់គ្រងព្រៃសម្បទាន ដែលច្បាប់បានហាមឃាត់ការកាប់នូវរាល់ដើមឈើច្បោះជ័រ ដែលនឹងដាក់បញ្ចូលទៅក្នុងការវាយតំលៃ ថាតើសម្បទានទាំងនោះអាចធានាភាពស្ថិតស្ថេរដែរឬទេ។
- ដកហូតការទទួលខុសត្រូវក្នុងការត្រួតពិនិត្យឧក្រិដ្ឋកម្មព្រៃឈើ ពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដោយផ្តល់ការទទួលខុសត្រូវនេះទៅស្ថាប័នផ្សេងៗដែលមិនពាក់ព័ន្ធការអនុម័ត និង ការគ្រប់គ្រងព្រៃសម្បទាន ។
- បង្កើតយន្តការត្រួតពិនិត្យដោយឯករាជ្យក្នុងការស៊ើបអង្កេតបទឧក្រិដ្ឋកម្មព្រៃឈើ និង ភាពស្រប ច្បាប់ របស់រដ្ឋាភិបាលក្នុងការធ្វើសេចក្តីសំរេចចិត្តដែលទាក់ទងទៅនឹងការប្រើប្រាស់ និងការគ្រប់ គ្រងធនធានព្រៃឈើ ។
- បង្កើតយន្តការតាមដានឯករាជ្យមួយ ដែលនឹងធ្វើការតាមដានឧក្រិដ្ឋកម្មព្រៃឈើ និងភាពស្របច្បាប់នៃការសំរេចចិត្តរបស់រដ្ឋាភិបាលទាក់ទងនឹងការប្រើប្រាស់ និងការគ្រប់គ្រងនៃធនធានព្រៃឈើ។

ចំពោះពត៌មានបន្ថែមទាក់ទិននឹងបញ្ហានានាដែលលើកនៅក្នុងអត្ថបទនេះ, សូមមេត្តាទាក់ទង The NGO Forum Forestry Project, លេខទូរសព្ទ័ (៨៥៥) ២៣ ៩៩៤ ០៦៣ និង អ៊ីម៉េល: andrewcock@bigpond.com; sokhom@ngoforum.org.kh

យេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ

(i) សេចក្តីផ្តើម

ជាទំលាប់នៅប្រទេសកម្ពុជា គេចាត់ទុកស្ត្រីថាជាអ្នកដែលនៅក្រោមបង្គាប់បុរស។ ស្ត្រីក៏មាននិន្នាការទទួលរងគ្រោះកាន់តែធ្ងន់ធ្ងរថែមទៀតពីផលវិបាកនៃភាពក្រីក្រ។ ជាទូទៅ ស្ត្រីរស់នៅក្នុងស្ថានភាពមួយ ដ៏លំបាកនៅក្នុងប្រទេស ពោលគឺពួកគេមានឱកាសទទួលបានការសិក្សា ធ្វើការមានប្រាក់ខែ មានកម្មសិទ្ធិដីធ្លី និង សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិផ្សេងៗទៀត មានធនធាន និងមានអំណាច តិចជាងបុរស។

អំពើហិង្សាលើរាងកាយ និងលើផ្លូវភេទ នៅតែបន្តកើនឡើង ដែលបង្កជាកង្វល់ដ៏ធ្ងន់ធ្ងរមួយ។ ជាប្រការមួយគួរអោយព្រួយបារម្ភ នៅពេលដែលរកឃើញថា ស្ត្រីខ្មែរប្រមាណ ២៥% បានទទួលរងអំពើហិង្សាក្នុងគ្រួសារ។ ក៏ប៉ុន្តែអំពើនេះកម្រនឹងឈានដល់ការដាក់ទោសណាស់ បើទោះបីជានៅពេលដែលស្ត្រីទាំងនោះ ទទួលរងរបួសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ គប្បីយល់ថាអំពើហិង្សាចំពោះស្ត្រីនិងកុមារ បណ្តាលមកពីភាពក្រីក្រដែលធ្វើអោយពួកគេធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រកាន់តែធ្ងន់ធ្ងរ។

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) បានលើកឡើងយ៉ាងច្រើនពីសមភាពយេនឌ័រ និងចំណុចជាច្រើនដែលទាមទារអោយអនុវត្ត ដើម្បីសំរេចបាននូវការកាត់បន្ថយភាពក្រីក្រ។ នៅមានភាពមិនទាន់ច្បាស់លាស់នៅឡើយថា តើរដ្ឋាភិបាលមានបំណងនឹងអនុវត្តផែនការសកម្មភាពរបស់ខ្លួន ដើម្បីសំរេចអោយបាននូវការអភិវឌ្ឍន៍ប្រកបដោយចិរភាពនៅកម្ពុជាយ៉ាងដូចម្តេចនោះ។

(ii) បញ្ហាគន្លឹះ

សុខាភិបាលៈ

ប្រជាជនខ្មែរជាង ៨០% រស់នៅជនបទ ដែលនៅទីនោះពួកគាត់មានឱកាសតិចតួចក្នុងការទទួលនូវការសិក្សា ទទួលសេវាសុខភាពមូលដ្ឋាន និងទទួលពត៌មានដែលផ្សព្វផ្សាយតាមបណ្តាញសារពត៌មាន។ គ្រូពេទ្យបំរើការងារនៅទីក្រុងមានចំនួនច្រើនជាងនៅជនបទ ហើយវេជ្ជបណ្ឌិតភាគច្រើនគឺជាបុរស។ ដោយសារមានភាពក្រីក្រ ទើបបណ្តាលអោយប្រជាជននៅទីជនបទកាន់តែមានការលំបាកក្នុងការរកចំណូល ហេតុនេះហើយបានមនុស្សជាច្រើនបានធ្វើដំណើរមកទីក្រុងដើម្បីស្វែងរកការងារធ្វើ។ គឺក្នុងពេលនោះហើយដែលកម្មករចំណាកស្រុកជួបប្រទះនូវគ្រោះថ្នាក់កាន់តែខ្លាំង

ដូចជាស្ថានភាពរស់នៅមិនសមរម្យ ម្ហូបអាហារមិនគ្រប់គ្រាន់ មេរោគអេដស៍និងជំងឺអេដស៍ មានផ្ទៃពោះដោយសាម៉ីខ្លួនមិនចង់បាន ពេស្យាចារ ការជួញដូរផ្លូវភេទ និងអំពើហិង្សាផ្ទែកយេនឌ័រ ។

នៅឆ្នាំ ១៩៩៥ ដោយមានការណែនាំអំពីគោលនយោបាយពន្យារកំណើត ថ្នាំគ្រាប់ពន្យារកំណើតត្រូវបានផ្តល់ជូនយ៉ាងទូលំទូលាយ ដល់ស្ត្រីនិងបុរស។ បច្ចុប្បន្ននេះ ស្ត្រី ២៤ % កំពុងប្រើប្រាស់ថ្នាំគ្រាប់ពន្យារកំណើត ហើយប្រទេសកម្ពុជាបានឆ្លងកាត់នូវរយៈពេលមួយ ដែលមានការធ្លាក់ចុះនូវលទ្ធភាពផ្តល់កំណើតកូន ពី ៥.៤ មក ៤.0 នាក់ក្នុងស្ត្រីម្នាក់ដែលដល់អាយុផ្តល់កំណើត។ ការផ្តល់សេវាសុខភាពគាំពារមាតានៅមានកំរិតទាប ហើយនៅ តែមិនទាន់បានឆ្លើយតបទៅនឹងតំរូវការក្នុងការពន្យារកំណើតឡើយ។ ទន្ទឹមនឹងនេះ ស្ត្រីជាច្រើនមិនបានទទួលសេវាពន្លូតកូន ប្រកបដោយសុវត្ថិភាពឡើយ។

ជារៀងរាល់ឆ្នាំនៅប្រទេសកម្ពុជា ស្ត្រី ២000 នាក់ បានស្លាប់ក្នុងកំឡុងពេលឆ្លងទន្លេ ហើយស្ត្រីជាង ២00.000 នាក់ ទទួលរងបញ្ហាលំបាកផ្សេងៗក្នុងពេលមានគភ៌ ដោយសារតែការទទួលបាននូវសេវាសុខភាព គាំពារមាតានៅមានកំរិតទាប ហើយជារឿយៗគឺជាផលវិបាកនៃពីភាពក្រីក្រ។ អត្រាមរណៈមាតាក្នុងរយៈពេលពីឆ្នាំ ១៩៩៤-២000 មានចំនួន ៤៧៣ នាក់ ក្នុងអត្រាកំណើតរស់ចំនួន ១០0.000 នាក់ ដែលជាតួលេខមួយ គួរអោយព្រួយបារម្ភ។ មូលហេតុវេជ្ជសាស្ត្រសំខាន់ៗសំរាប់ស្ត្រី ដែលបានស្លាប់ក្នុងពេលឆ្លងទន្លេ (អត្រាមរណៈមាតា) មាន :

- ការធ្លាក់ឈាមក្រោយពេលសំរាល
- ព្រាយក្រលាភ្លើង
- ការសំរាលកូនមិនរួច
- ការពន្លូតកូនដែលគ្មានសុវត្ថិភាព
- កាពលដាលមេរោគក្នុងខ្លួន
- ខ្វះអាហារូបត្ថម្ភ (ជំងឺខ្វះឈាមក្រហម)
- មេរោគអេដស៍-ជំងឺអេដស៍

អប់រំ :

អនក្ខរកម្មគឺជារនាំងសំរាប់ពលរដ្ឋក្រីក្រ ក្នុងការលើកកំពស់ជីវភាពរស់នៅរបស់គេ។ បញ្ហានេះបានជះឥទ្ធិពលយ៉ាងខ្លាំង រហូតដល់ផាត់ស្ត្រីចេញពីដំណើរការអភិវឌ្ឍន៍។ អត្រាអនក្ខរកម្មមានកំរិតខ្ពស់ ពោលគឺស្ត្រីពេញវ័យ ប្រមាណ

៤៥% មិនចេះអក្សរទាំងស្រុង (ធៀបទៅនឹងបុរស ២៤.៧%) ហើយយុវជនប្រមាណជា ២៥% ក៏មិនចេះអក្សរដែរ។ ស្ត្រីចំនួន ៧០.៨% និងបុរស ៥០.៤% មិនចេះអាន មិនចេះសរសេរសំរាប់បំរើតំរូវការចាំបាច់ប្រចាំថ្ងៃឡើយ[២១]។ ឱកាសក្នុងការបណ្តុះបណ្តាលសំរាប់ស្ត្រី មានការកំណត់ចំពោះតែ "ជំនាញសំរាប់ស្ត្រី" មួយចំនួន ដូចជារៀនអ៊ុតសក់ជាដើម។

អត្រាភាពក្រីក្រកាន់តែមានកំរិតខ្ពស់ ចំពោះគ្រួសារទាំងឡាយណា ដែលមេគ្រួសារមិនដែលបានចូលសាលារដ្ឋសោះតែម្តង ឬមួយក៏បានរៀននៅសាលាបឋមសិក្សាតិចតួច។ មួយភាគនៃចំណាយសំរាប់ការសិក្សា នៅក្នុងចំណាយសំរាប់ទិញរបស់របរប្រើប្រាស់នៅក្នុងគ្រួសាររបស់ពលរដ្ឋក្រីក្រ មានចំនួនតិចជាង ១.១%។

ការទទួលបានការសិក្សាសំរាប់ក្មេងស្រី មានភាពល្អប្រសើរឡើង និងការកំណត់ផ្តល់អាហារូបករណ៍ សំរាប់ក្មេងស្រីដែលមកពីគ្រួសារពលរដ្ឋក្រីក្រីក្រ នៅក្នុងផែនការសកម្មភាព NPRS ត្រូវបានទទួលស្វាគមន៍យ៉ាងខ្លាំង។ ការប្តេជ្ញាចិត្តនេះ ទាមទារអោយមានការគាំទ្រ តាមរយៈការបែងចែកធនធានពិតប្រាកដ ដែលមានលក្ខណៈបន្ត និងជានិរន្តន៍ដើម្បីធានាអោយផែនការនេះផ្តល់ផលប្រយោជន៍ដល់អ្នកដែលត្រូវការបំផុត។ ទន្ទឹមនឹងនេះ ត្រូវចាត់វិធានការដើម្បីធានាដោះស្រាយនូវអត្រាបោះបង់ចោលការសិក្សាដែលមានកំរិតខ្ពស់របស់ក្មេងស្រី។

កង្វះខាតក្នុងការទទួលបានពតិមាន និងការអប់រំអំពីច្បាប់ និងសិទ្ធិ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ។ ការមិនយល់ដឹងអំពីការការពារតាមផ្លូវច្បាប់ បានធ្វើអោយពលរដ្ឋក្រីក្រងាយនឹងទទួលរងនូវការកេងប្រវ័ញ្ច។ នេះក៏ជាករណីមួយពាក់ព័ន្ធទៅនឹងការទទួលបានពតិមាន និងការធ្វើសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលផងដែរ។ បើគ្មានលទ្ធភាពទទួលបានពតិមានដូច្នេះទេ ពលរដ្ឋក្រីក្រ ជាពិសេសស្ត្រីក្រីក្រ ត្រូវបានផាត់ចេញពីការចូលរួមនៅក្នុងសកម្មភាពសហគមន៍ និងមិនអាចជួយផ្តល់ពតិមាន ដែលអាចបំពេញបាននូវគំលាត រវាងនយោបាយរបស់រដ្ឋាភិបាល និងការអនុវត្តន៍នយោបាយទាំងនេះឡើយ។

<u>អំពើហិង្សាយេនឌ័រ :</u>

ច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារនៅមិនទាន់អនុម័តនៅឡើយ ដោយសារការអូសបន្លាយដោយការបោះឆ្នោតសភាជាតិ។ សភាជាតិថ្មីគប្បីចាត់វិធានការជាបន្ទាន់ក្នុងការធ្វើនីតិកម្មផ្នែកនេះ និងលៃយ៉ាងណាអោយច្បាប់នេះ ត្រូវបានអនុវត្តអោយបានត្រឹមត្រូវ ដូចជា ការរំលោភសេពសន្ថវៈ អំពើហឹង្សាប្រឆាំងនឹងអ្នករកស៊ីផ្លូវភេទ ការជួញដូរស្ត្រី និងកុមារទៅកាន់ប្រទេសជិតខាងដែលកំពុងកើនឡើង។

---

21 របាយការណ៍ឆ្នាំ ២០០៣ ស្តីពីការវិភាគយេនឌ័រនៅកម្ពុជា។ រាជរដ្ឋាភិបាលសហការជាមួយ UNDP Unifem និង World Bank

ការកើនឡើងនូវអំពើរំលោភសេពសន្ថវៈ ដែលបានលើកឡើងនៅក្នុងរបាយការណ៍ បង្ហាញអោយឃើញតំរូវការ ក្នុងការកសាងយុទ្ធសាស្ត្រនានាដែលមានប្រសិទ្ធភាព។ ការអប់រំអំពីយ៉េនឌ័រសំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីលុបបំបាត់ទស្សនៈចាស់គំរឹលនានា អំពីតួនាទីរបស់ស្ត្រីនៅក្នុងសង្គមកម្ពុជា គឺជាដំណើរការយូរអង្វែង។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងរយៈពេលខ្លី ប្រព័ន្ធច្បាប់និងតុលាការ គួរចាត់វិធានការតឹងតែង ដើម្បីធានាអោយជនជាប់ចោទ ពីបទរំលោភសេពសន្ថវៈត្រូវបានចាប់ខ្លួន និងកាត់ក្តី ហើយនៅពេលណាដែលរកឃើញថា មានពិរុទ្ធភាព ត្រូវដាក់ទោសអោយបានសមស្របតាមទំងន់ទោស។ ការដាក់ទោសស្រាលចំពោះអំពើរំលោពសេពសន្ថវៈ ជំរុញអោយមានឥរិយាបថមួយយល់ថាអំពើនេះមិនមែនជាបទល្មើសធ្ងន់ធ្ងរ ឬក៏ជាបទល្មើសមួយដែលប្រហែលជា មិននាំអោយមានការដាក់ទោសឡើយ។

ច្បាប់ប្រឆាំងនឹងការជួញដូរ ដែលបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី ចាំបាច់ត្រូវបញ្ចូលនូវប្រភេទទាំងអស់នៃការជួញដូរ ដូចជាការជួញដូចសរីរាង្គមនុស្ស ការកេងប្រវ័ញ្ចការងារ ការជួញដូរផ្លូវភេទ និងការជួញដូរទារក។ រដ្ឋាភិបាលគួរអនុវត្តអោយបានសកម្ម នូវអនុស្សរណៈស្តីពីការជួញដូររវាងប្រទេសកម្ពុជានិងប្រទេសថៃ ដែលបានចុះហត្ថលេខានៅឆ្នាំ ១៩៩២ ហើយក៏ជំរុញអោយអាជ្ញាធរថៃអនុវត្តដូចគ្នាដែរ។

ស្ត្រីក្នុងភាពជាអ្នកដឹកនាំ :

តួនាទីរបស់ស្ត្រីនៅក្នុងជីវិតនយោបាយនៅកម្ពុជា កំពុងតែមានការវិវត្តន៏ឈានឡើង ប៉ុន្តែវានៅតែជាការវិវត្តន៏មួយដ៏យឺត ដោយហេតុថា ស្ត្រីមួយចំនួនតូចប៉ុណ្ណោះ បានឈានដល់កំរិតនៃអំណាចពិតប្រាកដ។ ជាលទ្ធផល ការបោះឆ្នោតឆ្នាំ ២០០៣ មានស្ត្រី ១២ រូប បានជាប់ឆ្នោតនៅក្នុងសភាជាតិ ដែលមានការកើនឡើង ៥ នាក់ លើសការបោះឆ្នោតឆ្នាំ ១៩៩៨។

បន្ទាប់ពីការបោះឆ្នោតឆ្នាំ ១៩៩៨ មានរដ្ឋមន្ត្រីជាស្ត្រីតែ ២ នាក់ប៉ុណ្ណោះ ក្នុងចំណោមក្រសួងចំនួន ២៥ ហើយមានរដ្ឋលេខាធិការជាស្ត្រី ៤ នាក់ ក្នុងចំណោមរដ្ឋលេខាធិការសរុបចំនួន ៥០ នាក់។ យ៉ាងណាក៏ដោយ នេះគឺជាការរីកចំរើនជាងមុន បើទោះបីជាគ្មានអភិបាលខេត្ត-ក្រុង ជាស្ត្រីក៏ដោយ។ កាលពីមុន មានស្ត្រីតែ ៤ នាក់ប៉ុណ្ណោះ ដែលត្រូវបានតែងតាំងនៅក្នុងមុខតំណែងនយោបាយ ហើយក៏គ្មានស្ត្រីជារដ្ឋមន្ត្រី ជារដ្ឋលេខាធិការ ឬជាអភិបាលខេត្ត-ក្រុងដែរ។ មានស្ត្រីតែ ៩% ប៉ុណ្ណោះ ក្នុងចំណោមមន្ត្រីរាជការសរុបចំនួន ១៦៩.០០០ នាក់ ហើយមានចៅក្រមជាស្ត្រី ៨ នាក់ប៉ុណ្ណោះ ក្នុងចំណោមចៅក្រម ១១០ នាក់ ហើយក៏គ្មានព្រះរាជអាជ្ញាជាស្ត្រីដែរ។

នៅមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ ២០០២ មានការពិភាក្សាគ្នាជុំវិញការផ្តល់កូតា កៅអី ៣០% សំរាប់ស្ត្រី។ ប៉ុន្តែ សំណើនេះត្រូវបានបដិសេធទៅវិញ ហើយស្ត្រីចំនួន ៨.៥% បានជាប់ឆ្នោត ជាក្រុមប្រឹក្សាឃុំ-សង្កាត់។ ការចូលរួមរបស់ស្ត្រីកាន់តែច្រើននៅក្នុងនយោបាយថ្នាក់មូលដ្ឋាន គឺជាជំហានមួយ ដ៏សំខាន់ក្នុងដំណើរឆ្ពោះទៅបង្កើតវប្បធម៌នៃការទទួលយកស្ត្រីចូលកាន់អំណាច ព្រមទាំងជំរុញការផ្តល់អំណាចដល់ស្ត្រីដែលជាអ្នករួមវិភាគទានដ៏មានតំលៃ ចំពោះជោគវាសនាអនាគតរបស់ប្រទេសផងដែរ។

សេដ្ឋកិច្ច និង កសិកម្ម

នៅប្រទេសកម្ពុជា ៦៥% នៃពលកម្មកសិកម្ម និង ៧៥% នៃផលិតផលជលផល ស្ថិតនៅក្នុងដៃស្ត្រី។ ភាពក្រីក្រមិនអាចកាត់បន្ថយបានឡើយ ល្ពឹកណាគោលនយោបាយ កម្មវិធី និងថវិកានានា មិនបានដោះស្រាយដោយសមធម៌នូវស្ថានភាពនៃតំរូវការរបស់ស្ត្រីកម្ពុជានោះទេ។

ស្ត្រីនៅជនបទទទួលខុសត្រូវចំពោះការផលិតស្បៀងអាហារចំនួន ៨០% ហើយស្ត្រីជាង ៦៥% គឺជាកសិករ។ ពាក់កណ្តាលនៃស្ត្រីទាំងនោះ គឺជាអ្នកមិនចេះអក្សរ ឬមិនបានបញ្ចប់ថ្នាក់បឋមសិក្សាផង។ ស្ត្រី ៧៨% ជាអ្នកប្រកបកសិកម្មដើម្បីចិញ្ចឹមជីវិត ធៀបទៅនឹងបុរសចំនួន ២៩%។ នៅជនបទ ស្ត្រីប្រមាណតែ ៤% និង បុរសតែ ១០% ប៉ុណ្ណោះដែលជាអ្នកធ្វើការទទួលប្រាក់បៀវត្សរ៍។

គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ច្រើនតែធ្វើការក្នុងវិស័យកសិកម្ម ជាងគ្រួសារដែលមានបុរសជាមេគ្រួសារ ក៏ប៉ុន្តែពួកគេក៏ហាក់ដូចជាគ្មានដីធ្វើស្រែ ឬមួយក៏មានដីដ៏តិចតួចបំផុត។ ស្ទើរតែ ៨០% នៃកសិករទាំងនេះ ប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត ដែលមានស្ត្រីចំនួន ៥៦% ជាកំលាំងពលកម្មចាំបាច់ក្នុងកសិកម្មដើម្បីចិញ្ចឹមជីវិត និង ៥៤% នៃកំលាំងពលកម្មធ្វើការក្នុងវិស័យកសិកម្មសំរាប់ទីផ្សារ។ ស្ត្រីភាគច្រើន ក៏ជាអ្នកបំរើនៅក្នុងផ្ទះដែលមិនបានទទួលប្រាក់បៀវត្សរ៍នោះទេ។

ការទទួលបាននូវសេវាផ្សព្វផ្សាយដែលមានគុណភាពគឺជាបញ្ហាដ៏ធ្ងន់ធ្ងរសំរាប់កសិករបុរសនិងកសិករស្ត្រី ហើយស្ត្រីទទួលបានកាន់តែតិច នូវសេវាផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដែលមានតិចតួចស្រាប់។ ការស្រាវជ្រាវកសិកម្ម និងការផ្សព្វផ្សាយកសិកម្ម មិនបានផ្តោតទៅលើសកម្មភាពរបស់កសិករស្ត្រីឡើយ បើទោះបីជាបុរសនិងស្ត្រី ហាក់ដូចជាមានកិច្ចការដាច់ដោយឡែកពីគ្នាក្តី។

បើទោះបីជាប្រជាជនកម្ពុជាជាង ៧០% បំរើការនៅក្នុងការបង្កបង្កើនផលកសិកម្មក៏ដោយ កសិករវវាង ១២% ទៅ ១៥% គ្មានដីកសិកម្មសំរាប់បង្កបង្កើនផលឡើយ។ ការទទួលបានធនធានធម្មជាតិផ្សេងៗទៀត របស់ពលរដ្ឋក្រីក្រ ដូចជាព្រៃឈើ ជលផល និងធនធានពាក់ព័ន្ធនានា នៅមានកំរិតទាបនៅឡើយ។

ស្ត្រីពិការ

ជនពិការត្រូវបានរើសអើងនៅគ្រប់ស្រទាប់ និងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងសង្គម។ ប្រការនេះ បណ្តាលអោយជនពិការរស់ក្នុងភាពឯកោ ដោយត្រូវបានផាត់ចេញពីចរន្តសំខាន់ៗនៃសង្គម និងមិនទទួលបាននូវសិទ្ធិ និងឱកាសស្មើភាពដូចជនដទៃឡើយ។ រីឯស្ត្រីពិការវិញ ជួបប្រទះនូវការរើសអើងទ្វេដង គឺជាស្ត្រីផង និងជាជនពិការផង។

បញ្ហាពិការភាពហាក់ដូចជាមិនត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ឡើយ។ នៅពេលទិវាជនពិការថ្មីៗនេះ (ថ្ងៃទី៣ ខែ ធ្នូ ឆ្នាំ ២០០៣) គេបាននិយាយថា ប្រជាជនកម្ពុជាតិចជាង ២% គឺជាជនពិការ។ ក៏ប៉ុន្តែ ធនាគារពិភពលោក ប៉ាន់ស្មានថា ចំនួនជនពិការរស់នៅប្រទេសកម្ពុជា មានចំនួន ២០%។

ចំពោះបញ្ហាទឹក និងអនាម័យវិញ ស្ត្រីពិការគឺជាអ្នកដែលងាយរងគ្រោះបំផុត។ គ្មានបង្គន់អនាម័យ ឬបន្ទប់ទឹកត្រឹមត្រូវសំរាប់ស្ត្រីពិការឡើយ។ ក្នុងករណីជាច្រើនទៀត ស្ត្រីទាំងនេះរស់នៅក្នុងបរិយាកាសមួយ ដែលមិនអំណោយផលដល់សុខភាព។

ជនពិការភ្នែក ពិការត្រចៀក និងនិយាយមិនកើត មិនបានទទួលការអប់រំឡើយ។ ពួកគេភាគច្រើន មិនចេះអាន ឬសរសេរឡើយ។ លើសពីនេះទៅទៀត ក្មេងពិការមិនអាចទៅសាលារៀន ឬឈប់រៀន ដោយសារតែអគារសិក្សាគ្មានផ្លូវជំរាលសំរាប់ជនពិការ។

ស្ត្រីពិការកាន់តែទទួលរងគ្រោះថែមទៀត ពីអំពើហិង្សាក្នុងគ្រួសារ។ ភាគច្រើន ប្តីបានបោះបង់នាងចោលបន្ទាប់នាងធ្លាក់ខ្លួនពិការ។ មានករណីជាច្រើនទៀតផងដែរ ដែលស្ត្រីពិការកំពុងត្រូវបានទទួលរងនូវការកេងប្រវ័ញ្ច។

ភាពក្រីក្រអាចនឹងកាត់បន្ថយបាន តែនៅពេលណាដែលតំរូវការរបស់ក្រុមដែលងាយរងគ្រោះបំផុត ត្រូវបានដោះស្រាយ ជាពិសេសស្ត្រីពិការ។

(iii) អនុសាសន៍

- សេចក្តីព្រាងច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ គួរត្រូវបានអនុម័តដោយសភាជាតិ និងអនុវត្ត ប្រកបដោយប្រសិទ្ធភាព និងចាត់ទុកបញ្ហាជាអាទិភាព ។
- រដ្ឋាភិបាលគួរធានាអោយមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នូវច្បាប់ការងារ ច្បាប់ប្រឆាំងការជួញដូរ ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ និងច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ។ ការបង្កើនតម្លាភាពនៅក្នុងប្រព័ន្ធប៉ូលីស និងតុលាការ តំរូវអោយមានការគាំទ្រ និងការតាមដានជាប្រចាំ ។
- គួរមានគ្លីនិកព្យាលកម្មកររោងចក្រ មានមណ្ឌលសុខភាពពេលថ្ងៃ និងការការពារសុខភាពអោយបានល្អប្រសើរ ជាពិសេសពាក់ព័ន្ធនឹងលក្ខខណ្ឌអនាម័យ បន្ទប់ធ្វើការ និងការងាររបស់កម្មករ ។
- ត្រូវបំពេញអោយបានតាមលក្ខខណ្ឌក្នុងការធ្វើរបាយការណ៍ តាមអនុសញ្ញា **CEDAW** ដើម្បីបង្ហាញថា រដ្ឋាភិបាលមានបំណងនឹងលុបបំបាត់ការរើសអើងចំពោះស្ត្រី ។ **CEDAW** ជំរុញអោយមានការអនុវត្តន៍ពេញលេញនូវវិធានការទាំងឡាយ ដើម្បីធានាអោយសិទ្ធិចំពោះការងារ សិទ្ធិចំពោះជីវិតនយោបាយ និងជីវិតសាធារណៈ សិទ្ធិសមភាព សិទ្ធិសង្គម និងសេដ្ឋកិច្ច ពិតជាត្រូវបានទទួលការការពារ ។ រដ្ឋាភិបាលគួរធានាអោយមានប្រព័ន្ធពេញលេញ ក្នុងការអនុវត្តន៍សិទ្ធ និងបន្តធ្វើអោយប្រសើរឡើង នូវការអប់រំនៅសហគមន៍ និងការទទួលបានពត៌មានអំពីសិទ្ធិស្ត្រី ។
- ធានាអោយមានកំណើនថវិកាជាតិ សំរាប់វិស័យអប់រំ សំដៅផ្តល់វឌ្ឍនភាពជានិរន្តន៍ ចំពោះបញ្ហា យ៉េនឌ័រ ឧទាហរណ៍ តាមរយៈការផ្តល់អាហារូបករណ៍ និងអន្តេវាសិកដ្ឋានសំរាប់សិស្សស្រី ។ លើសពីនេះទៅទៀត ថវិកាសំរាប់វិស័យសុខាភិបាល និងកសិកម្ម គួរត្រូវបានបង្កើន ដើម្បីផ្តល់សេវាសុខភាព និងលើកកំពស់កិរិតជីវភាពអោយកាន់តែប្រសើរសំរាប់ស្ត្រី ។ យុទ្ធសាស្ត្រ និង ការបែងចែកថវិកា ត្រូវធ្វើឡើងសំដៅដោះស្រាយតំរូវការរបស់កុមារ និងស្ត្រីពិការ ។
- មូលដ្ឋានទិន្នន័យស្តីពីយ៉េនឌ័រ គួរត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយអោយកាន់តែទូលាយ ដើម្បី ផ្តល់នូវសូចនាករដ៏មានសារៈប្រយោជន៍ផ្សេងៗ ស្តីពីកំណើនក្នុងវិស័យនេះ និងបង្ហាញវិភាគទាន របស់ស្ត្រី ចំពោះការអភិវឌ្ឍន៍សង្គម ។
- គួរមានកូតាមួយសំរាប់ចំនួនស្ត្រី នៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ សភាជាតិ និងមុខតំណែងរដ្ឋាភិបាល ពីថ្នាក់លើដល់មូលដ្ឋាន ។
- រដ្ឋាភិបាលគួរផ្តល់ឱកាសបន្ថែមទៀតសំរាប់ស្ត្រី អោយទទួលបានការជ្រើសរើស ដើម្បីធានាអោយ ពួកគេមានឱកាសស្មើគ្នា ក្នុងការទទួលបានមុខតំណែងធ្វើសេចក្តីសំរេច ។

- រាល់ផែនការអភិវឌ្ឍន៍ទាំងអស់ គួរមានសូចនាករ និងការវិភាគយ៉េនឌ័រ និង យុទ្ធសាស្ត្រយ៉េនឌ័រ ដើម្បីជួយដល់ពលរដ្ឋក្រីក្រ។

ចំពោះពត៌មានបន្ថែមស្តីពីបញ្ហាដែលបានលើកឡើងក្នុងឯកសារនេះ សូមទំនាក់ទំនង :
បណ្តាញយ៉េនឌ័រ និងការអភិវឌ្ឍន៍ តាមទូរស័ព្ទលេខ : ០២៣ ២១៥-១៣៧ Email: gad@online.com.kh

វេទិកាស្តីពីយ៉េនឌ័រ នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
ទូរស័ព្ទលេខ : ០២៣ ៩៨៦-២៦៩ Email: ngoforum@ngoforum.org.kh

អភិបាលកិច្ច និង តម្លាភាព

(i) សេចក្តីផ្តើម

ទស្សនាទានអំពីអភិបាលកិច្ចល្អ ត្រូវបានកត់សំគាល់ ដោយតម្លាភាព ការទទួលខុសត្រូវ ការចូលរួមជាសាធារណៈ ការព្យាករណ៍ទុកជាមុន ការប្រកាន់ខ្ជាប់ចំពោះការគ្រប់គ្រងដោយច្បាប់ និង កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល។ អំពើពុករលួយ គឺជារោគសញ្ញានៃអភិបាលកិច្ចទន់ខ្សោយ ការសិក្សាស្រាវជ្រាវនានា[២២] បានបង្ហាញថា អំពើនេះបានរីករាលដាលយ៉ាងទូលំទូលាយក្នុងសង្គមកម្ពុជា។ ស្ថាប័នតុលាការ ផ្នែករដ្ឋាករ អាជ្ញាធរពន្ធដារ ផ្នែកសុខាភិបាល អប់រំ សាធារណការ និងនគរបាល ជាមជ្ឈដ្ឋានដែលទទួលផលប៉ះពាល់អាក្រក់ជាងគេបំផុត។ អំពើពុករលួយ និងភាពក្រីក្រ គឺជារូបពីរនៃប្រាក់កាក់មួយ គោលបំណង គឺការផ្លាស់ប្តូរប្រាក់កាក់នេះ ដោយប្រាក់កាក់មួយទៀត ដែលមានរូបអភិបាលកិច្ចល្អនៅផ្នែកម្ខាងនៃប្រាក់កាក់ និង រូបតម្លាភាពនៅផ្នែកម្ខាងទៀត នៅលើមុខទាំងពីរខាងនៃកាក់នោះ។

រាជរដ្ឋាភិបាលកម្ពុជាបានព្រាង "ផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ៥ ឆ្នាំលើកទី២ ឆ្នាំ ២០០១-២០០៥" ហើយឯកសារយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ចែងថា ការកែលំអបរិស្ថានអភិបាលកិច្ចអាចនឹងធ្វើឱ្យសម្រេចបាន តាមរយៈការផ្លាស់ប្តូរឱ្យទាន់សម័យ និង ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នូវផែនការសកម្មភាពអភិបាលកិច្ច ឆ្នាំ ២០០១។

រាជរដ្ឋាភិបាល និងរដ្ឋសភា បានអនុម័តច្បាប់ស្តីអំពីអាជ្ញាធរសវនកម្មជាតិ នៅឆ្នាំ ២០០០ ដើម្បីធានាឱ្យមានតម្លាភាពក្នុងការគ្រប់គ្រងថវិកាជាតិ។ វិភាគទាននៃអង្គការក្រៅរដ្ឋាភិបាល ចំពោះការពង្រឹងអភិបាលកិច្ចល្អ និង តម្លាភាព បានរួមបញ្ចូលទាំងការជួយកសាងសម្ព័ន្ធតម្លាភាពជាតិ ដោយរួមជាមួយក្រសួងអប់រំយុវជននិងកីឡា រៀបចំកម្មវិធីសិក្សាមួយស្តីពីតម្លាភាព ការទទួលខុសត្រូវអភិបាលកិច្ចល្អនិងអំពើពុករលួយ។ ក្នុងឆ្នាំ ២០០២ នៅឯកិច្ចប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់ អង្គការក្រៅរដ្ឋាភិបាលនានាបានសម្តែងសេចក្តីព្រួយបារម្ភអំពីដំណើរការច្បាប់គ្មានភាពត្រឹមត្រូវនិងជានិច្ចកាលគ្មានតម្លាភាពលើដំណើរផ្លូវច្បាប់។ នៅខែមិថុនាឆ្នាំ២០០៣ សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយមួយត្រូវ បានបញ្ជូនទៅរដ្ឋសភា បន្ទាប់ពីកិច្ចប្រឹងប្រែងអស់រយៈពេលជាច្រើនឆ្នាំនៃអង្គការក្រៅរដ្ឋាភិបាលនានា និងមានការគាំទ្រពីគណបក្សនយោបាយមួយចំនួន ប៉ុន្តែនិយមន័យនៃពាក្យថា "អំពើពុករលួយ" នៅក្នុងសេចក្តីព្រាងច្បាប់នោះ មានលក្ខណៈស្រពេចស្រពិលមិនទាន់ច្បាស់លាស់។ សេចក្តីព្រាងច្បាប់នោះត្រូវតែទទួលពិនិត្យនិងពិភាក្សាឡើងវិញដោយសមាជិកសភា ដែលជាប់ឆ្នោតថ្មីៗ មុននឹងបានទទួលការអនុម័ត ដោយពង្រឹងនិយមន័យនៃអំពើពុករលួយ និងដាក់ទណ្ឌកម្ម ឱ្យរឹតតែធ្ងន់ធ្ងរទ្វេឡើងចំពោះអ្នកប្រព្រឹត្តល្មើស។

[22] សូមអាន CSD (១៩៩៨) *អង្កេតជាតិស្តីពីឥរិយាបថសាធារណៈចំពោះអំពើពុករលួយ ភ្នំពេញ*

(ii) បញ្ហាគន្លឹះសំខាន់ៗ

បន្ទាប់ពីពិធីសម្ពោធប្រគល់មុខតំណែងថ្មីនៃរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបាន ខិតខំប្រឹងប្រែងកែតម្រូវ និងធ្វើកំណែទម្រង់រចនាសម្ព័ន្ធអភិបាលកិច្ច ដោយមានគោលបំណងនឹងបង្កើតឱ្យមានលទ្ធិប្រជាធិបតេយ្យសេរី និងសេដ្ឋកិច្ចទីផ្សារ។ ច្បាប់ថ្មីៗមួយចំនួនត្រូវបានអនុម័ត ហើយបទបញ្ញារដ្ឋបាលមួយចំនួនធំត្រូវបានដាក់ចេញ ដើម្បីអនុវត្តច្បាប់ទាំងនោះ ស្ថាប័ននិងអង្គការថ្មីៗ ក៏ត្រូវបានបង្កើតឡើង ដើម្បីរ៉ាប់រងការទទួលខុសត្រូវសំខាន់ៗក្នុងផ្នែកសាធារណៈ។ ទោះបីមានកិច្ចប្រឹងប្រែងទាំងនេះក៏ដោយ ក៏នៅមានឧបសគ្គជាច្រើន ចំពោះការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នៃគោលការណ៍អភិបាលកិច្ចល្អ និងតម្លាភាព។

<u>តម្លាភាព និង អំពើពុករលួយៈ</u> ប្រសិនបើរដ្ឋាភិបាលចង់ឱ្យមានតម្លាភាព គ្រប់ស្ថាប័នទាំងអស់ត្រូវតែបង្កើតយន្តការផ្តល់ពត៌មានជូនសាធារណជន អំពីដំណើរការតម្លាភាពរបស់ខ្លួន។ តម្លាភាព គឺជាធាតុគន្លឹះនៃអភិបាលកិច្ចល្អ ដែលគ្របដណ្តប់លើស្ថាប័ននានានៃរដ្ឋាភិបាល ផ្នែកឯកជន សង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ។ អំពើពុករលួយធ្វើឱ្យខូចទឹកចិត្តដល់បំណងប្រាថ្នាលទ្ធិប្រជាធិបតេយ្យ ធ្វើឱ្យខូចជំនឿ និងទំនុកចិត្តនៃប្រជាពលរដ្ឋ ចំពោះអ្នកដឹកនាំរបស់ខ្លួន ធ្វើឱ្យរាំងស្ទះដល់ការលូតលាស់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច គំរាមកំហែងដល់ស្ថាប័ននានា ហើយនិងសិទ្ធិសេរីភាពជាមូលដ្ឋាន។ អំពើនេះក៏គំរាមកំហែងផងដែរដល់ការឧបត្ថម្ភគាំទ្រ ពីអន្តរជាតិចំពោះកម្ពុជា ដែលតាមការប៉ាន់ប្រមាណមួយថា ទឹកប្រាក់ឧបត្ថម្ភគាំទ្រនេះមានចំនួន ៥០០ លានដុល្លារក្នុងមួយឆ្នាំ[២៣]។ ក្នុងការស្ទង់មតិមួយនៃធនាគារពិភពលោក អំពើពុករលួយ ត្រូវបានគេ កំណត់ឃើញថាជាបញ្ហាធំជាងគេនៅពីមុខបញ្ហាធំៗឯទៀត ដែលរួមមាន សុវត្ថិភាព និងឧក្រិដ្ឋកម្ម តម្លៃជីវភាពរស់នៅ ភាពគ្មានការងារធ្វើ ការចំណាយខ្ពស់លើសុខាភិបាល និងចំណាយអប់រំខ្ពស់ អស្ថេរភាពនយោបាយ ការសេពគ្រឿងញៀន និងការជួញដូរមនុស្ស[២៤]។ ការស្ទង់មតិដដែលនេះបានបង្ហាញឱ្យឃើញថា ទម្ងន់នៃអំពើពុករលួយភាគច្រើន បានក្លាយទៅជាបន្ទុកគ្រួសារក្រីក្រ ដែលមានប្រាក់ចំណូលទាប ដោយហេតុគេត្រូវសូកប៉ាន់ លើសេវាសាធារណៈជាមូលដ្ឋាន ដូចជាសេវា សុខាភិបាល និងអប់រំជាដើម។

---

[23] សូមអាន CSD (១៩៩៨) *អង្កេតជាតិស្តីពីឥរិយាបថសាធារណៈចំពោះអំពើពុករលួយ ភ្នំពេញ*

[24] ធនាគារពិភពលោក (ឆ្នាំ ២០០០) កម្ពុជាៈ រោគសញ្ញានៃអភិបាលកិច្ច និង អំពើពុករលួយៈ អង្កេតភស្តុតាងពីប្រជាពលរដ្ឋ ពីសហគ្រាស និងពីមន្ត្រីសាធារណៈ

<u>ការគ្រប់គ្រងដោយច្បាប់:</u> រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងធ្វើសេចក្តីព្រាង និងអនុម័តច្បាប់ និង បទបញ្ជាផ្សេងៗ ដើម្បីប្រយុទ្ធនឹងអំពើពុករលួយ និងធានាឱ្យមានអភិបាលកិច្ចល្អ ប៉ុន្តែការគ្រប់គ្រងដោយច្បាប់ពិតប្រាកដនៅតែពិបាកយល់។ មានការខុសគ្នាយ៉ាងខ្លាំងរវាងការអនុមត័ច្បាប់ និងការដាក់ឱ្យអនុវត្តច្បាប់ ។ ហេតុនេះកិច្ចប្រឹងប្រែងទាំងឡាយត្រូវតែធ្វើឡើង ដើម្បីគាំទ្រយន្តការ និងរចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព ចំពោះការអនុវត្តន៍ និង ការប្រតិបត្តិច្បាប់ និងបទបញ្ជាផ្សេងៗ។ ទោះបីនីតិកម្មប្រឆាំងនឹងអំពើពុករលួយមានសារៈសំខាន់យ៉ាងណាក៏ដោយ ក៏គេគួរតែចាំទុកថា នៅក្រោមច្បាប់កម្ពុជាដែលមានស្រាប់ ដូចជាបទប្បញ្ញត្តិទាក់ទិននឹងតុលាការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីដែលអាចអនុវត្តក្នុងប្រទេសកម្ពុជានាសម័យអន្តរកាល គេអាចវិនិច្ឆ័យទោសពិរុទ្ធជនជាស្រេចទៅហើយ អំពីបទឧក្រិដ្ឋដែលរួមមាន 'ការលួចបន្លំដោយមន្ត្រីសាធារណៈ ' 'អំពើពុករលួយ ' និង 'សំណូកសូកប៉ាន់ '។ បទប្បញ្ញត្តិទាំងនេះ ពុំបានដាក់ឱ្យអនុវត្តជាទូទៅទេ ហើយជាការមិនជាការពិតសោះឡើយ ដែលគេគិតទៅដល់ច្បាប់ប្រឆាំងនឹងអំពើពុករលួយថ្មីណាមួយ ថាអាចនឹងអនុវត្តផ្សេងពីនេះ ដរាបណារដ្ឋាភិបាលមិនដោះស្រាយបញ្ហាទាក់ទងនឹងវប្បធម៌និរទណ្ឌភាព ដែលមានជាអចិន្ត្រៃយ៍ និងមិនចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីកំចាត់អំពើពុករលួយចេញពីតុលាការទេនោះ។ ការលើកយកបទប្បញ្ញត្តិប្រឆាំងនឹងអំពើពុករលួយដែលមានស្រាប់មកអនុម័ត និង ដាក់ឱ្យអនុវត្ត គឺមានសារៈសំខាន់ណាស់ ក្នុងពេលដែលមិនទាន់មានច្បាប់ថ្មី ដើម្បីអនុវត្ត។

> នៅឯមន្ទីរពេទ្យមួយដែលផ្តល់ថវិកាដោយអង្គការក្រៅរដ្ឋាភិបាល គិលានុប្បដ្ឋាយិកាម្នាក់ បានទារប្រាក់ពីអតិថិជន មុននឹងចាក់ថ្នាំអង់ទីប៊ីយូទិកឱ្យទារកម្នាក់ដែលជិតផុតដង្ហើម។ ឪពុកទារកនោះយកផ្ទះខ្លួនទៅដាក់បញ្ចាំ ដើម្បីយកប្រាក់មកបង់ថ្លៃព្យាបាលជំងឺឱ្យកូន[២៥]

[25] សូមអានរបាយការណ៍របស់ CSD ដែលបោះផ្សាយដោយ Ibid

(iii) អនុសាសន៍

អនុសាសន៍ចំពោះរដ្ឋាភិបាលៈ

- ការពង្រឹងឆន្ទៈនយោបាយដើម្បីប្រយុទ្ធនឹងអំពើពុករលួយៈ សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងអំពើពុករលួយ និងការដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តខុសឡើយ ដោយសារនិយមន័យមិនច្បាស់លាស់អំពីពាក្យថា "អំពើពុករលួយ" នៃច្បាប់នោះឯង។ ច្បាប់នេះ ត្រូវតែមានការត្រួតពិនិត្យឡើងវិញ។ រាជរដ្ឋាភិបាល គួរតែប្រើប្រាស់អាណត្តិថ្មី ៥ ឆ្នាំ និងឆន្ទៈនយោបាយរបស់ខ្លួន ដើម្បីអនុវត្តច្បាប់ទាំងឡាយ និងបញ្ចប់អំពើពុករលួយ។ សកម្មភាពនេះគេបានអនុវត្តហើយក្នុងប្រទេសដទៃទៀតនៅទ្វីបអាស៊ី ដូចជាប្រទេសសិង្ហបូរីជាដើម។ បញ្ហាទប់ស្កាត់អំពើពុករលួយ ក្នុងពេលបោះឆ្នោត ឆ្នាំ ២០០៣ កម្មវិធីនយោបាយនៃគណបក្សធំៗទាំងអស់ ត្រូវបានគេលើកធ្វើជាអាទិភាពយ៉ាងខ្ពស់ អ្នកដឹកនាំទាំងឡាយបានយល់ស្របគ្នាថា អំពើពុករលួយកំពុងតែធ្វើឱ្យប្រទេសទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែ ប្រទេសកម្ពុជាត្រូវការឆន្ទៈនយោបាយដ៏មោះមុត ពីការរួមចំណែកនៃអ្នកដឹកនាំ ព្រមទាំងទាមទារឱ្យអ្នកដឹកនាំនយោបាយទាំងអស់ ធ្វើសហប្រតិបត្តិការជាមួយគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ពុំមែនគ្រាន់តែ សំដៅទាញយកផលប្រយោជន៍គណបក្សខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែដើម្បីធ្វើយ៉ាងណាប្រទេសជាតិទាំងមូលបានល្អប្រសើរឡើងផងដែរ ។
- គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយៈ ការអនុវត្តន៍ច្បាប់ប្រឆាំងនឹងអំពើពុករលួយ មានសារៈសំខាន់ជាងការអនុម័តច្បាប់នេះទៅទៀត ។ គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយត្រូវតែជាគណៈកម្មការមួយដែលមានអំណាចពេញលេញសំរាប់អនុវត្តច្បាប់ ។ សមាជិកគណៈកម្មការនេះ គួរតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រីឯរបៀបជ្រើសរើសគួរតែមានតម្លាភាព ហើយគប្បីបង្កើតនីតិវិធីធ្វើការប្រកបដោយប្រសិទ្ធិភាព។
- ច្បាប់ស្តីអំពីសិទ្ធិលើទ្រព្យសម្បត្តិៈ ដើម្បីកាត់បន្ថយភាពក្រីក្រ បង្កើនការវិនិយោគបរទេស និង បង្កើតឱកាសឱ្យមានការងារធ្វើ កិច្ចការពារសិទ្ធិលើទ្រព្យសម្បត្តិ គឺមានសារៈសំខាន់ជាចាំបាច់។ ច្បាប់នេះនឹងរារាំងអ្នកមាន មិនឱ្យរំលោភយកដីធ្លីពីពលរដ្ឋក្រីក្រដោយខុសច្បាប់ និងលើកទឹកចិត្តឱ្យមានការវិនិយោគ។ សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ត្រូវតែលើកការផ្តួចផ្តើមគំនិតក្នុងការព្រាងច្បាប់នេះ ។ សមត្ថកិច្ច ក្នុងការទិញ ការលក់ ឬការផ្ទេរដីធ្លី និងទ្រព្យសម្បត្តិ គឺជាតម្រូវការចាំបាច់មុនអ្វីទាំងអស់ សម្រាប់នីតិរដ្ឋប្រកបដោយប្រសិទ្ធភាព។
- សេចក្តីប្រកាសទ្រព្យសម្បត្តិ និងបំណុល : រាជរដ្ឋាភិបាល គួរតែអនុវត្ត និងទទួលស្គាល់យ៉ាងទូលំទូលាយ នូវតួនាទីបទដ្ឋានសាធារណៈ ដូចមានចែងនៅក្នុងជំពូកទី ៥ នៃសេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ ទុកជាភ័ស្តុតាង

នៃការប្តេជ្ញាចិត្តរបស់ខ្លួន។ ចំពោះរដ្ឋាភិបាលប្រកបដោយតម្លាភាព រដ្ឋមន្ត្រីទាំងឡាយ រួមទាំងនាយករដ្ឋមន្ត្រីផង គួរតែធ្វើសេចក្តីប្រកាសជាសាធារណៈ នូវទ្រព្យសម្បត្តិ និងបំណុលផ្ទាល់ខ្លួន និងសមាជិកគ្រួសារផ្ទាល់របស់ខ្លួន។

- តម្លាភាពនៅក្នុងគណបក្សនយោបាយ ៖ គណបក្សនយោបាយទាំងឡាយ គួរតែធ្វើកំណែទម្រង់សំខាន់ៗ ដើម្បីឱ្យកាន់តែមានតម្លាភាព។ ដូចជាក្នុងប្រទេសក្រីក្រឯទៀតដែរ ការជ្រើសរើសឱ្យបេក្ខជនគណបក្ស ឈរឈ្មោះសម្រាប់បោះឆ្នោតក្នុងប្រទេសកម្ពុជា ច្រើនតែសម្រេចដោយចំនួនទឹកប្រាក់ ដែលគេផ្តល់អោយគណបក្ស។ ប្រសិនបើគ្មានគណបក្សនយោបាយរឹងមាំ ដែលមានការទទួលខុសត្រូវ មានតម្លាភាព និងប្រកបដោយប្រសិទ្ធភាពទេនោះ ស្ថាប័នទាំងឡាយនៃរដ្ឋាភិបាល នឹងធ្វើការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ជាជាងផលប្រយោជន៍ប្រទេសជាតិ ។ កត្តានេះនាំឱ្យមានការរាំងស្ទះនៃការពិភាក្សានយោបាយ បាត់បង់នូវការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ និងធ្វើឱ្យនីតិរដ្ឋចុះខ្សោយបន្តិចម្តងៗ។
- ការគ្រប់គ្រងផ្នែកសារពើពន្ធ ៖ ប្រជាជនកម្ពុជាម្នាក់ៗបានទទួលពីរដ្ឋាភិបាល នូវចំនួនប្រាក់ប្រហែល ៧ ដុល្លារ ក្នុងមួយឆ្នាំ សម្រាប់សេវាសុខាភិបាល និង អប់រំ (បើប្រៀបទៅនឹងប្រទេសថៃ គេទទួលបាន ម្នាក់ៗ ១៥០ ដុល្លារ ក្នុងមួយឆ្នាំ)[២៦]។ ដើម្បីកែលំអសេវារដ្ឋាភិបាលចំពោះប្រជាពលរដ្ឋ ការកែទម្រង់ និងការគ្រប់គ្រង សារពើពន្ធគឺជាការចាំបាច់។ ក្នុងឆ្នាំ២០០២ គណៈរដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ និង ក្រសួងការពារជាតិ បានចំណាយលើសគំរោងថវិការហូតដល់ ៤០ ភាគរយ។ រីឯវិស័យជាអតិភាពនានាដូចជា អភិវឌ្ឍន៍ជនបទ អប់រំ សុខាភិបាល បានទទួលថវិកាតែ ៨០ ភាគរយ តិចជាងចំនួនថវិកាសរុប។ ស្ថានការណ៍នេះកាន់តែយ៉ាប់យ៉ឺនឡើង ដោយហេតុថាក្នុងឆ្នាំ ២០០៣ នេះក្នុងរយះពេល ៨ ខែដំបូងក្រសួងសុខាភិបាលបានទទួលថវិកាតែ ២១ ភាគរយ ប៉ុណ្ណោះ។
- **ការកែទម្រង់ច្បាប់ និង តុលាការ** ៖ រាជរដ្ឋាភិបាល គួរតែធ្វើការប្តេជ្ញាចិត្តឱ្យខ្លាំងក្លា ដើម្បីធ្វើការកែទម្រង់ច្បាប់ និង តុលាការ ដែលមានកំណត់នៅក្នុងផែនការសកម្មភាពនៃរដ្ឋាភិបាល (Government Action Plan – GAP) ។ រដ្ឋាភិបាលគួររៀបចំធ្វើសេចក្តីព្រាងក្រមសីលធម៌មួយ សម្រាប់ចៅក្រមទាំងឡាយ។ ច្បាប់គួរតែអនុវត្តឱ្យមានប្រសិទ្ធភាព និងមិនលំអៀង ដើម្បីដាក់ទោសដល់អ្នកប្រព្រឹត្តកំហុស ទោះបីអ្នកទាំងនោះមានប្រាក់ចំណូលច្រើន និងនៅក្នុងសម្ព័ន្ធភាព ជាមួយគណបក្សនយោបាយណាមួយក៏ដោយ។

[26] សូមអានទស្សនាវដ្តីសេដ្ឋកិច្ចប្រចាំឆ្នាំរបស់កម្ពុជា ឆ្នាំ ២០០២ ដែលបោះផ្សាយដោយ CDRI

- ការលើកស្ទួយកម្រិតជីវភាព : រាជរដ្ឋាភិបាល ចាំបាច់ត្រូវតែកំណត់អាទិភាពចំពោះវិស័យណា ដែលត្រូវការកែទំរង់។ បើប្រៀបធៀបទៅនឹងតម្លៃជីវភាពសព្វថ្ងៃ បៀវត្សរ៍មន្ត្រីរាជការមិនទាន់គ្រប់គ្រាន់ល្មមរស់នៅបានទេ រដ្ឋាភិបាលគួរតែបង្កើនប្រាក់បៀវត្សរ៍ ដើម្បីកុំឱ្យមន្ត្រីរាជការចាំបាច់ ត្រូវតែទទួលសំណូក សំរាប់រក្សាកម្រិតជីវភាពរបស់ខ្លួន។ ការជ្រើសរើសបុគ្គលិកថ្មី ត្រូវតែមានតម្លាភាព មានភាពស្ទាត់ជំនាញ និងមានបទពិសោធន៍ គួរតែចាត់ទុកជាលក្ខណៈវិនិច្ឆ័យដំបូង គេក្នុងការជ្រើសរើសបុគ្គលិក មិនមែនផ្អែកលើទំនាក់ទំនងផ្អែកនយោបាយផ្ទាល់ខ្លួនឡើយ។
- វិមជ្ឈការនិងការពង្រឹងអភិបាលកិច្ចមូលដ្ឋាន : ក្រុមប្រឹក្សាឃុំ-សង្កាត់ ហាក់ដូចជាគ្មានអំណាចអ្វីទាល់តែសោះ។ ដើម្បីធានាឱ្យមានវិមជ្ឈការ និងការពង្រឹងអភិបាលកិច្ចមូលដ្ឋាន ប្រជាពលរដ្ឋក្រីក្រតាមជនបទ គួរតែមានសមត្ថកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ ព្រមទាំងមានអំណាច ជំនាញនិងទេពកោសល្យ ដើម្បីធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនគេផ្ទាល់។ គួរផ្ទេរការទទួលខុសត្រូវ ពីថ្នាក់មជ្ឈិមទៅថ្នាក់ឃុំ សង្កាត់ រដ្ឋាភិបាលគួរតែផ្តល់ការធានាដល់ការអនុវត្តន៍ផែនការដែលមានការចូលរួម និងផែនការពីក្រោមមកលើ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការអន្តរជាតិ គួរតែធ្វើការជាមួយរដ្ឋាភិបាលដោយផ្ទាល់ និងរក្សាសំពាធ ជំរុញឱ្យផ្តួចផ្តើម គំនិតធ្វើវិមជ្ឈការ។
- លទ្ធភាពទទួលពត៌មាន : គេមិនអាចប្រយុទ្ធនឹងអំពើពុករលួយ និងធានាឱ្យមានអភិបាលកិច្ចល្អបានទេ ប្រសិនបើគ្មានប្រព័ន្ធផ្សព្វផ្សាយពត៌មានដោយសេរី និង មិនលំអៀងនោះ។ លទ្ធភាពទទួលបាននូវពត៌មាន និងសេរីភាពក្នុងការសម្តែងមតិ ទាំងក្នុងប្រព័ន្ធផ្សព្វផ្សាយពត៌មានសាធារណៈ និងក្នុងប្រព័ន្ធឯកជន គួរតែត្រូវបានធានា។ ប៉ុន្តែគេគួរចងចាំថា ដោយសារកម្ពុជាជាប្រទេសក្រីក្រ ការប្រើប្រាស់ដោយសេរីនូវពិតមានទូទៅទាំងឡាយ នៅតែមិនទាន់អាចធ្វើបាននៅឡើយ។ ពត៌មានមួយចំនួន ដូចជាពត៌មានអំពីច្បាប់ជាដើម គួរតែផ្តល់ឱ្យប្រជាពលរដ្ឋដោយឥតគិតថ្លៃ រីឯពត៌មានខ្លះទៀត ដូចជាប្រវត្តិនៃសារទំនាក់ទំនងរបស់រដ្ឋាភិបាល គួរតែផ្តល់អោយតាមតំលៃមួយដែលពិចារណា យកថ្លៃត្រឹមតែមួយចំណែកនៃថ្លៃចំណាយក្នុងការប្រមូលចងក្រងពត៌មាន។
- ការអប់រំសាធារណៈ : ប្រជាពលរដ្ឋមានការអប់រំ និងចេះអក្សរ គឺជាឧបករណ៍ដ៏ល្អបំផុតមួយ សម្រាប់ប្រយុទ្ធនឹងអំពើពុករលួយ។ ដើម្បីកំចាត់ប្រព័ន្ធពុករលួយក្នុងប្រទេសកម្ពុជា សាធារណជនគួរតែដឹងថាករណីយកិច្ច នៅក្នុងតំណែងនៃអំណាចនយោបាយ និងអំណាចរដ្ឋាភិបាល គឺត្រូវតែបម្រើប្រជាពលរដ្ឋ។ ទស្សនៈនេះ គួរតែពង្រីកឱ្យទូលំទូលាយដោយរួមបញ្ចូលទាំងការអប់រំ និងការហ្វឹកហ្វឺនមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ផង។ គួរតែបង្កើន ថវិកាជាតិសម្រាប់ការអប់រំ ដោយប្រមូលផ្តុំទៅលើការហ្វឹកហ្វឺន និងលើប្រាក់ខែគ្រូបង្រៀន ពុំមែនគ្រាន់តែកសាងសាលារៀនថ្មីៗប៉ុណ្ណោះឡើយ ។ លើសពីនេះទៀត ថវិកាគួរតែបង្កើនឡើងដោយ បន្ថយការចំណាយលើវិស័យការពារជាតិ។

អនុសាសន៍ចំពោះប្រទេសអ្នកផ្តល់ជំនួយ :

- <u>កង្វល់របស់អ្នកផ្តល់ជំនួយ</u> : តាមសេចក្តីថ្លែងការណ៍នៃអង្គការក្រៅរដ្ឋាភិបាល នៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់ស្តីពីកម្ពុជា នាឆ្នាំ២០០២ ប្រទេសផ្តល់ជំនួយត្រូវធានាថា មូលនិធិរបស់ខ្លួន កំពុងមានផលជាវិជ្ជមានទៅលើពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះ ហើយប្រទេសទាំងនោះមិនត្រូវលទ្ធភាពក្នុងការជំរុញអោយមានអំពើពុករលួយ ហើយមិនរំលោភសិទ្ធិនៃសហគមន៍រងផលប៉ះពាល់ដោយសារគំរោង។ ប្រទេសផ្តល់ជំនួយ ក៏មានតួនាទីជាគន្លឹះផងដែរក្នុងការផ្តល់ការលើកទឹកចិត្ត និង ជំរុញឱ្យស៊ីជម្រៅនូវកិច្ចសន្ទនារវាងរដ្ឋាភិបាល និងសង្គមស៊ីវិល[២៧]។

អនុសាសន៍ចំពោះអង្គការក្រៅរដ្ឋាភិបាល :

- <u>ការផ្តល់មតិណែនាំដោយផ្អែកលើដំណោះស្រាយ</u> : អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ មិនគួរបំពេញមុខនាទីជាអ្នកសារពត៌មាន ឬជាគណបក្សនយោបាយជំទាស់ឡើយ។ អ្នកទាំងនោះ គួរតែផ្តល់យោបល់ ផ្អែកលើដំណោះស្រាយសំរាប់គ្រប់វិស័យ ដើម្បីជួយសម្រួលដល់ដំណើរការកែទម្រង់។ យើងត្រូវការច្បាប់ប្រឆាំងនឹងអំពើពុករលួយផ្សេងៗគ្នាសម្រាប់វិស័យផ្សេងៗគ្នាដែរ ឧទាហរណ៏ អំពើពុករលួយក្នុងការកាប់ឈើខុសច្បាប់ និងអំពើពុករលួយក្នុងវិស័យសុខាភិបាល មិនដូចគ្នាទេ ហើយមធ្យោបាយដោះស្រាយបញ្ហា ក៏ខុសគ្នាដែរ។ ដើម្បីធានាឱ្យការត្រួតពិនិត្យ និងការតាមដានមានជាបន្តតទៅទៀតសំរាប់អភិបាលកិច្ចនិង តម្លាភាពកាន់តែល្អប្រសើរឡើង គេចាំបាច់ត្រូវកសាងសម្ព័ន្ធភាពជាមួយនឹងស្ថាប័នអភិបាលកិច្ចជាតិ និងអន្តរជាតិប្រឆាំងនឹងអំពើពុករលួយ ដូចជា សម្ព័ន្ធភាពដើម្បីតម្លាភាពកម្ពុជា (សតក) សម្ព័ន្ធភាពរវាង វិស័យឯកជន និងសង្គមស៊ីវិល ក៏ជាកម្លាំងចលករមួយជំរុញការកែទំរង់អោយចាប់ផ្តើមផងដែរ។

ចំពោះពត៌មានបន្ថែមស្តីពីបញ្ហានានាដែលបានលើកឡើងក្នុងអត្ថបទនេះ សូមមេត្តាទាក់ទងជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ទូរស័ព្ទលេខ (៨៥៥) ២៣ ៣៦៤ ៧៣៥ ទូរសារលេខ (៨៥៥)២៣ ៣៦៤ ៧៣៦ អ៊ីម៉េល: csd@online.com.kh

[27] សេចក្តីថ្លែងការណ៍របស់អង្គការក្រៅរដ្ឋាភិបាលឆ្នាំ ២០០២ ចំពោះកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីកម្ពុជា

សុខាភិបាល

(i) សេចក្តីផ្តើម

មានសុខភាពល្អតែងតែត្រូវបានគេយល់ថាជាសមិទ្ធិផលនៃការអភិវឌ្ឍន៍ក៏ប៉ុន្តែវាក៏ជាលក្ខ័ណសំខាន់មួយក្នុងការលើកកំពស់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រផងដែរ[២៨]។ ជាការពិតការថែទាំសុខភាពនៅតែជាកត្តាដ៏សំខាន់មួយ ដែលធ្វើអោយប្រជាជនកម្ពុជាកាន់តែធ្លាក់ក្នុងភាពត្រីក្រ នៅពេលដែលពួកគេម្នាក់ៗចាំបាច់ត្រូវចំណាយប្រាក់ជាមធ្យម ២៩ ដុល្លារអាមេរិកក្នុងមួយឆ្នាំ សំរាប់ការថែទាំសុខភាព[២៩](GDPកម្ពុជានៅមានកំរិតទាបគឺ ២៧៥ ដុល្លារអាមេរិកសំរាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ)។ ហេតុដូចនេះមេឪខាំយល់ឃើញនូវតួនាទីដ៏សំខាន់នៃវិស័យសុខភាពសាធារណៈរបស់រដ្ឋាភិបាលនិងបណ្តាញសុវត្ថិភាពសង្គមដើម្បីទប់ស្កាត់ការកើនឡើងនូវចំនួនប្រជាជនរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។

បណ្តាញអង្គការមេឪខាំ រួមមាន អង្គការ ក្រៅរដ្ឋាភិបាល ចំនួន ១១៣ ហើយសមាជិកនានាសហការគ្នាដោយក្តីសោមនស្សរីករាយ ដោយសារពីមួយឆ្នាំ ទៅមួយឆ្នាំបានចូលរួមក្នុងការធ្វើអោយជឿនលឿននូវវិស័យសុខាភិបាល។ ខាងក្រោមនេះគឺជាសមិទ្ធិផលគួរអោយកត់សំគាល់ក្នុងចំណោមសមិទ្ធិផលនានាជាច្រើននាឆ្នាំ ២០០២ - ២០០៣ ដូចជា:

១). កំណើន ចរិកា និង ជោគជ័យ របស់ កម្ពុជា នៅក្នុងជុំទីមួយ និង ជុំទី ២ នៃមូនិធិសកល។

២).ការសាងសង់ និ ងជួសជុលអាគារ សុខាភិបាល សំរេចបានជាង ៨០ ភាគរយ នៃផែនការគ្របដណ្តប់សុខាភិបាល។

៣).បង្កើតគោលការណែនាំ ស្តីអំពីការថែទាំសុខភាពបឋម។

៤). ការពង្រីក នូវកម្មវិធីដតស៏ (DOTS) សំរាប់ព្យាបាលជំងឺ របេង និង យុទ្ធសាស្ត្រ សមាហរណកម្ម គ្រប់គ្រងជំងឺកុមារ

៥). ការបង្កើតផែនការ យុទ្ធសាស្ត្រសុខាភិបាល និង ក្របខ័ណ្ឌការអនុវត្តន៍ផែនការនេះ។

៦). ការបង្កើត និង ការចាប់ផ្តើម អនុវត្តគំរោងទ្រទ្រង់ វិស័យសុខាភិបាល។

៧).ការបូកសរុបប្រចាំឆ្នាំនូវវិស័យសុខាភិបាលជារួម ក្នុងគោលបំណងធ្វើអោយប្រសើរឡើងការសំរបសំរួលរវាងដៃគូសុខាភិបាលទាំងនៅថ្នាក់ជាតិ និងអន្តរជាតិនិង

---

[28] OECD Commission on Macroeconomics and Health (CMH), October 2001
[29] CDHS 2000

៨). ការបង្កើតឡើងនូវដំណើរការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំ ថ្នាក់ខេត្ត ដោយមាន ការចូលរួម យ៉ាងសកម្មពីមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែក។ ទាំងអស់នេះ ជាសមិទ្ធផលមានសារសំខាន់។

ក្នុងភាព ជាដៃគូជាមួយក្រសួងសុខាភិបាល អង្គការក្រៅរដ្ឋាភិបាលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការអនុវត្តន៍គំរោង កែទំរង់វិស័យសុខាភិបាល ដែលបានរួមចំណែក យ៉ាងសំខាន់ចំពោះសមិទ្ធផលខាងលើនេះ។ អង្គការក្រៅរដ្ឋាភិបាលបាននិងកំពុងផ្តល់ជំនួយបច្ចេកទេស ជំនួយសំភារៈ និងជំនួយហិរញ្ញវត្ថុ ផ្តល់ព្រមទាំងធនធានមនុស្សជាច្រើនសំរាប់ទ្រទ្រង់ការអភិវឌ្ឍន៍វិស័យសុខាភិបាល។ អង្គការក្រៅរដ្ឋាភិបាលជាអ្នកអនុវត្ត ហើយបទពិសោធន៍របស់ពួកគេគឺជាធនធានបន្ថែមដ៏សំខាន់មួយក្នុងការជួយគាំទ្ររាជរដ្ឋាភិបាល។ មេឌីខាំជាទីកន្លែងសំរាប់ប្រមូលផ្តុំបទពិសោធន៍នៅតាមមូលដ្ឋាន ធ្វើការស្រាវជ្រាវ ដោយផ្អែកលើបទពិសោធន៍ទាំងនោះហើយធ្វើការវិភាគ។ ហេតុដូចនេះមេឌីខាំសូមធ្វើការសង្ខេបនូវបញ្ហាសំខាន់ៗដែលសហគមន៍អង្គការក្រៅរដ្ឋាភិបាលបានចូលរួមក្នុងវិស័យសុខាភិបាល យល់ឃើញថាជាបញ្ហាលំបាកមួយចំនួនក្នុងចំណោមបញ្ហាលំបាកជាច្រើន នាពេលបច្ចុប្បន្នដែលប្រឈមមុខ ចំពោះការអភិវឌ្ឍន៍វិស័យសុខាភិបាលរបស់កម្ពុជា។

(ii) បញ្ហាគន្លឹះ និង អនុសាសន៍

<u>**ផ្តោតទៅលើក្រុមក្រីក្របំផុត:**</u> ឯកសារពិភាក្សាថ្មីៗមួយ របស់ធនាគារពិភពលោក[៣០] បានលើសំណួរអំពីលទ្ធភាពនៃការរីកចំរើនជាក់ស្តែង ឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍ដែលកំណត់ភាពរីកចំរើនលើផ្នែកសុខាភិបាល

> *" ដោយសារគោលដៅផ្នែកសុខាភិបាលរបស់ MDGs មានបញ្ជាក់អំពីការកែលំអជាមធ្យមនៅក្នុងសង្គមជាជាងបញ្ជាក់អំពីផលប្រយោជន៍នៅក្នុងក្រុមពលរដ្ឋក្រីក្រនៅក្នុងសង្គម មិនដូចគ្នានឹងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដទៃ។ ព្រោះថាការលើកកំពស់នៅក្នុងក្រុមនានា រួមមានក្រុមអ្នកមានជីវភាពធូរធារ នឹងធ្វើអោយមានការលើកកំពស់សង្គមជាមធ្យម វឌ្ឍនភាពឆ្ពោះទៅរកគោលដៅនៅក្នុងលក្ខខ័ណ្ឌទាំងនោះ មិនប្រាកដជាលើកកំពស់ស្ថានភាពរស់នៅរបស់ពលរដ្ឋក្រីក្រនោះទេ "។*

គួររំលឹកថា ប្រជាជនកម្ពុជា៣៦ភាគរយរស់នៅក្រោមបន្ទាត់ភាពក្រីក្រ អង្គការមេឌីខាំសូមផ្តល់អនុសាសន៍:

---

[30] "នរណានឹងទទួលផលពីកិច្ចប្រឹងប្រែងក្នុងការសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ចំពោះវិស័យសុខាភិបាល? ជាសំណួរមួយចំពោះលទ្ធភាពនៃវឌ្ឍនភាព ដែល មិនផ្តល់អត្ថប្រយោជន៍ចំពោះពលរដ្ឋក្រីក្រ" ដោយ Davidson Gwatkin ប្រធានសុខាភិបាល និងអ្នកជំនាញលើភាពក្រីក្រ

- រាជរដ្ឋាភិបាល និងជាពិសេសក្រសួងសុខាភិបាលសូមប្រើប្រាស់សុចនាករបំបែកជា៥ក្រុម ដើម្បីអោយងាយស្រួលក្នុងការតាមដាននូវផលប៉ះពាល់ របស់កម្មវិធី អភិវឌ្ឍន៍ទៅលើក្រុមពលរដ្ឋក្រីក្រីក្របំផុត។

វេជ្ជខ្វះខាតថវិកា: មេឌីខាំសូមអបអរសារទចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនថវិកាប្រចាំឆ្នាំសំរាប់វិស័យសុខាភិបាល ប៉ុន្តែឆ្ងល់ថាតើមានឥទ្ធិពលអ្វីមកលើសុខភាពរបស់ប្រជាពលរដ្ឋ ប្រសិនបើអ្នកអនុវត្តយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងមន្ត្រីសុខាភិបាលនៅតាមមូលដ្ឋាន ដែលជាអ្នកផ្តល់សេវាសុខាភិបាល ជាអ្នកអនុវត្តសកម្មភាពនៅមូលដ្ឋាន និងជាអ្នកបណ្តុះបណ្តាលប្រជាពលរដ្ឋអំពីតវិយាបថ " ស្វែងរកសេវាសុខាភិបាល " គ្មានលទ្ធភាពទទួលថវិការបស់ខ្លួន អោយបានកាន់តែទៀងទាត់នោះ ។ អាស្រ័យហេតុនេះមេឌីខាំសូមស្នើ:

- រាជរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់ជំនួយ អោយធ្វើផែនការសកម្មភាព និងកសាងយុទ្ធសាស្ត្រអំពី

"គណៈកម្មាធិការគ្រប់គ្រងថវិកា "ដែលមានស្រាប់ និង "ក្រុមការងារគ្រប់គ្រងសាច់ប្រាក់ " និងក្រុមបច្ចេកទេសផ្សេងៗទៀតដែលត្រូវបានគេបង្កើតឡើង ដើម្បីដោះស្រាយការពន្យារពេលកាន់តែយូរទៅៗ ក្នុងការបញ្ចេញថវិកាជាពិសេសកើតមាននៅក្នុងអំឡុងប្រាំមួយខែដើមឆ្នាំ ។

ការបើកប្រាក់ឧបត្ថម្ភនិងប្រាក់លើកទឹកចិត្ត

ទោះបីជាមានការបង្កើនប្រាក់បៀវត្សរ៍តាមភាគរយបានគ្រោងនៅក្នុងកំណែទំរង់រដ្ឋបាលសារធារណៈ ជាប្រការគួរអោយចាប់អារម្មណ៍យ៉ាងណាក៏ដោយ ក៏ការតំឡើងប្រាក់បៀវត្សរ៍នេះ និងមិនអនុញ្ញាតិអោយមន្ត្រីរាជការសាធារណៈជាពិសេស បុគ្គលិកសុខាភិបាលទទួលបាននូវប្រាក់ឧបត្ថមគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិត ពីការធ្វើការងារនេះតែមួយមុខបានទេ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ កំណែទំរង់រដ្ឋបាលសារធារណៈមិនបានគិតអំពីការធ្វើការក្រៅម៉ោងរបស់មន្ត្រីរាជការស៊ីវិល និងមិនបានដាក់កំរិតលើការប្រើប្រាស់ពេលវេលាធ្វើការរបស់មន្ត្រីរាជការ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែម ដើម្បីបានប្រាក់ចិញ្ចឹមជីវិតនោះទេ។ ជាងនេះទៅទៀត ការអនុវត្តន៍បទបញ្ជានេះនឹងរារាំងមិនអោយមានទំនាស់អំពីផលប្រយោជន៍ និងធ្វើអោយរចនាសម្ព័ន្ធនៃការផ្តល់សេវាកាន់តែប្រសើរឡើង។ សព្វថ្ងៃនេះ បន្ថែមលើប្រាក់ឧបត្ថម្ភលើប្រាក់ខែដែលប្រមូលបានពីថ្លៃប្រើប្រាស់សេវា នៅតែមិនអនុញ្ញាតិអោយបុគ្គលិកមូលដ្ឋាន ឈានទៅមានថវិកាគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិតបានទេ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើននិងអ្នកផ្តល់ ជំនួយទ្វេភាគីកំពុងផ្តល់ ឬកំពុងមានផែនការផ្តល់ប្រាក់ឧបត្ថម្ភ/ប្រាក់លើកទឹកចិត្ត ដើម្បីកែលំអការលើកទឹកចិត្តដល់បុគ្គលិក កែលំអសេវាដែលអាចរកបាន

កែលំអគុណភាព និងបរិមាណនៃសេវា។ អង្គការក្រៅរដ្ឋាភិបាលមានការព្រួយបារម្ភណ៍ អំពីនិរន្តរភាពនៃផែនការលើកទឹកចិត្តទាំងអស់នេះ ហើយសូមដាក់ខ្លួនរៀនសូត្រពីរដ្ឋាភិបាល ថាតើថវិការបស់ផែនការសកម្មភាពជាអាទិភាព ឬយន្តការផ្សេងៗអាចចាត់ចែងចំពោះពួកគេបានយ៉ាងដូចម្តេច? អង្គការមេឌីខាំបានសំណូមពរដូចតទៅៈ

- ស្នើអោយរាជរដ្ឋាភិបាលធ្វើសំណើទៅគ្រប់អ្នកផ្តល់ជំនួយ សូមអោយពួកគេមានផែនការផ្តល់គ្រឿងលើកទឹកចិត្តនៅក្នុង ផែនការថវិការបស់ពួកគេសំរាប់កម្មវិធីផ្សេងៗ។
- ស្នើអោយក្រសួងសុខាភិបាល សហគមន៍ផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដាក់ចេញនូវស្តង់ដារអនុសាសន៍ អំពីកំរិតនៃការផ្តល់ប្រាក់លើកទឹកចិត្ត ដោយផ្សារភ្ជាប់ទៅនឹងលទ្ធផលអនុវត្តន៍ការងារ និងភ្ជាប់ជាមួយគុណភាពនៃសេវា ដើម្បីរារាំងកុំអោយមានការប្រកួតប្រជែងរវាងកម្មវិធីផ្សេងៗ។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគួរបញ្ជាក់អោយច្បាស់ថាតើថវិកាសំរាប់ផែនការសកម្មភាពជាយុទ្ធសាស្ត្រត្រូវគេចាយវាយប្រាក់នេះសំរាប់ឧបត្ថម្ភបន្ថែមនិងប្រាក់លើកទឹកចិត្តយ៉ាងដូចម្តេច ក្នុងតំបន់ដែលគ្មានការឧបត្ថម្ភគាំទ្រពីអ្នកផ្តល់ជំនួយ ឬពីអង្គការក្រៅរដ្ឋាភិបាល ដើម្បីអោយក្រសួងពាក់ព័ន្ធអាចមានការលើកទឹកចិត្តក្នុងកំរិតអប្បបរមាចំពោះក្រុមរបស់ខ្លួន ដើម្បីលៃយ៉ាងណាអោយមានសេវា និងមានលទ្ធផល។

<u>**ការចំណាយថវិកាបន្ថែមទៀតលើសេវាផ្សេងៗនៅថ្នាក់មូលដ្ឋានៈ**</u> ចំងាយផ្លូវហើយនឹងការចំណាយទៅលើមធ្យោបាយធ្វើដំណើរគឺជាឧបសគ្គពីរដ៏ចំបងសំរាប់ប្រជាជនដែលត្រូវការប្រើប្រាស់មូលដ្ឋានសុខភាពសាធារណៈ ។ប៉ុស្តិ៍សុខភាពនានា នៅតំបន់ជនបទដាច់ស្រយាល ព្រមទាំងបន្ទប់សុខភាព[៣១] នៅតាមទីប្រជុំជន បានបង្ហាញនូវសមាមាត្រនៃការចំណាយធៀបនឹងប្រសិទ្ធភាពឥតខ្ចោះ។ អង្គការក្រៅរដ្ឋាភិបាលជំរុញអោយក្រសួងសុខាភិបាល ចំណាយថវិកាបន្ថែមទៀតនៅសេវាថ្នាក់មូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋក្រីក្រ ។នៅមូលដ្ឋាន ភ្នាក់ងារសុខភាពសហគមន៍និងក្រុមទ្រទ្រង់សុខភាពភូមិ ចាំបាច់ត្រូវតែបានទទួលធនធានបន្ថែមទៀត ព្រោះពួកគេជាក្រុមសំខាន់ ដែលជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថ ។

---

[៣១] គំរោងសុខភាពទីក្រុងភ្នំពេញ និង ការវាយតំលៃផ្នែកសេដ្ឋកិច្ចសំរាប់សេវាសុខាភិបាល សំរាប់អ្នកក្រីក្រនៅក្នុងទីក្រុងភ្នំពេញ ដោយ James C.Knowles, OPTION /DFID/London School of Hygience and Tropical Medicine, September 2001.

បង្កើនការផ្តោតយកចិត្តទុកដាក់និងការខិតខំប្រឹងប្រែងលើគុណភាពសេវា: មេឌីខាំ សូមអបអរសាទរចំពោះក្រសួងសុខាភិបាលដែលបានផ្តល់អាទិភាពទៅលើគុណភាពនៃសេវានៅក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ការធ្វើអោយប្រសើរឡើងនូវគុណភាពសេវាសុខាភិបាល ចាំបាច់ត្រូវកែលំអគុណភាពសេវាសុខភាពសាធារណៈ ដើម្បីការពារការធ្លាក់ចុះនៃការប្រើប្រាស់មន្ទីរសុខាភិបាលសាធារណៈ ។ ក៏ជាការចាំបាច់ផងដែរប្រសិនបើផែនការធានារ៉ាប់រងលើសុខភាព ត្រូវបានគេបង្កើតឡើងនាពេលអនាគត។ មេឌីខាំសូមជំរុញអោយក្រសួងសុខាភិបាលអនុវត្តន៍ផ្នែកគុណភាពនៃក្របខណ្ឌ័ការអនុវត្តន៍ផែនការ យុទ្ធសាស្ត្រវិស័យសុខាភិបាល។

ការសហការណ៍រវាងផ្នែកសាធារណៈនិងផ្នែកឯកជនៈ ទោះបីអ្នកផ្តល់សេវាសុខាភិបាលឯកជន គួរតែរួមចំណែកចំពោះគុណភាពនៃសេវាសុខាភិបាលយ៉ាងណាក៏ដោយ ក៏ ៤៩% នៃការពិគ្រោះវេជ្ជសាស្ត្រឯកជននៅភ្នំពេញ ធ្វើអោយមានការព្យាបាលប្រកបដោយគ្រោះថ្នាក់[៣២] ។ វិស័យសុខាភិបាលឯកជន មិនត្រឹមតែកំពុងប្រជែងជាមួយនឹងប្រព័ន្ធសុខាភិបាលដែលផ្តល់ថវិកាសាធារណៈតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបញ្ហាប្រឈមដ៏ពិតប្រាកដចំពោះសុខភាពសាធារណៈផងដែរ។ ប្រការនេះមិនចាំបាច់មើល ក្នុងន័យអវិជ្ជមាននោះទេ។ អង្គការក្រៅរដ្ឋាភិបាលជឿជាក់ថាចាំបាច់ត្រូវបង្កើតយុទ្ធសាស្ត្រ អនុវត្តន៍ជាក់ស្តែងដើម្បីដោះស្រាយបញ្ហាទាំងអស់នោះ។ អង្គការមេឌីកាំសូមលើកទឹកចិត្តៈ

- ក្រសួងសុខាភិបាលនិងក្រុមប្រឹក្សាវេជ្ជសាស្ត្រ ធ្វើការជាចំហបន្ថែមទៀតជាមួយនិងអ្នកផ្តល់សេវាសុខាភិបាលឯកជន ហើយលើកទឹកចិត្តអោយពួកគេអនុវត្តតាមបទប្បញ្ញិត្តផ្សេងៗដែលមានស្រាប់ ដូចជាផ្តល់ការអនុញ្ញាតិ និងការទទួលស្គាល់។

មេឌីខាំក៏សូមស្នើដែរថាគេគួរតែស្វែងរកដោយច្នៃប្រឌិតឱ្យកាន់តែប្រសើរឡើងនូវតួនាទីផ្សេងគ្នា និង (បំពេញគ្នា) រវាងផ្នែកឯកជននិងសារធារណៈ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើសេចក្តីត្រូវការរបស់អតិថិជន ដែលចង់បានសេវាដែលមានគុណភាព អាចមានលទ្ធភាពបង់ថ្លៃសេវានោះបាន។ គេគួរតែស្វែងរកធ្យោបាយផ្សេងៗ ដើម្បីធ្វើអោយអ្នកផ្តល់សេវាឯកជននិងសេវាសាធារណៈធ្វើការជាមួយគ្នា ឬក៏បំពេញបន្ថែមអោយគ្នាទៅវិញទៅមកជាមួយនិង ទិសដៅចុងក្រោយគឺគុណភាពនៃសេវាដែលអតិថិជនមានលទ្ធភាពបង់ថ្លៃបាន។ ឧទាហរណ៍ៈ

- គេគួរតែបណ្តុះបណ្តាលទៅដល់អ្នកផ្តល់សេវាសាធារណៈ និងអ្នកផ្តល់សេវាឯកជនដោយគ្មានការរើសអើង។

[32] *ប្រតិបត្តិករឯកជននៅក្រុងភ្នំពេញៈអង្កេតអតិថិជនអាថិកំបាំង* ដោយ C. Vickrey, et al. WHO/WHO/Option ខែវិច្ឆិកា ឆ្នាំ ២០០១

- ការលើកកំពស់ និងការបែងចែកផលិតផល ដែលទាក់ទងទៅនឹងសុខភាពមួយចំនួន តាមរយៈអ្នកផ្គត់ផ្គង់ ឯកជន ដែលអាចត្រូវបានពង្រីក និង
- ចាំបាច់ត្រូវតែសំរេចអោយបាននូវការបញ្ជាក់ឱ្យបានច្បាស់ពីអ្នកផ្តល់សេវាសាធារណៈ ដែលធ្វើការឯកជន។ មេឌីខាំ ជឿថាមានឱកាសសំរាប់ភាពជាដៃគូនៃការអនុវត្តន៍ជាក់ស្តែង រវាងផ្នែកឯកជននិង សាធារណៈដែលនឹងនាំទៅ ដល់គុណភាពនៃសេវាដែលធ្វើអោយប្រសើរឡើងទាំងវិស័យសាធារណៈ និងវិស័យឯកជន។

ផ្តល់ធនធានហិរញ្ញវត្ថុបន្ថែមទៀតនៅលើផ្នែកបង្កា អាហារូបត្ថម្ភ ក៏ដូចជានៅថ្នាក់ប្រតិបត្តិៈ

ការផ្តល់ជំនួយបរទេសលើវិស័យសុខាភិបាលនៅកម្ពុជា មាននិន្នាការផ្តោតទៅលើតែជំងឺមួយចំនួនដែលកំពុងពេញ និយម ដូច្នេះហើយធ្វើអោយមានការបែងចែកគ្មានសមាមាត្រគ្នា នៃចំណាយលើធនធានហិរញ្ញវត្ថុ ហើយមិនបានយកចិត្ត ទុកដាក់លើផ្នែកអន្តរាគមន៍សុខាភិបាលសំខាន់ៗមួយចំនួន ដូចជា ការបង្កាជំងឺ អាហារូបត្ថម្ភ និង សុខភាពមាតា និង ទារកជាដើម។ បន្ថែមលើបញ្ហានេះទៀត មានការផ្លាស់ប្តូរភ្លាមៗនូវគោលនយោបាយ/យុទ្ធសាស្ត្រនានារបស់ស្ថាប័ន ផ្តល់ជំនួយ ដូច្នេះធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់លើការងារអភិវឌ្ឍន៍ និងការអនុវត្តន៍គំរោងនៅមូលដ្ឋាន ជាពិសេសទៅលើ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលជំរុញអោយអង្គការទាំងនោះងាកមកអនុវត្តទៅតាមគំរោងដែលបង្កើតឡើង ដោយអ្នកផ្តល់ជំនួយ ដែលមិនឆ្លើយតបទៅនឹងតំរូវការរបស់សហគមន៍ ។ មេឌីខាំសូមអំពាវនាវអោយ

- អ្នកផ្តល់ជំនួយផ្តល់ការគាំទ្រ ដោយផ្តោតលើសេចក្តីត្រូវការរបស់អតិថិជនអ្នកប្រើប្រាស់សេវាថ្នាក់មូលដ្ឋាន។ ហើយ សូមអោយឆ្លើយតបបន្ថែមទៀតចំពោះដៃគូនៅជនបទដែលកំពុងធ្វើការនៅមូលដ្ឋាន ហើយជួនកាលម្ចាស់ជំនួយអាច ធ្វើជាភាគីទីបី ដ៏មាន ប្រសិទ្ធភាព ។
- ម្យ៉ាងទៀតនៅប៉ុន្មានឆ្នាំចុងក្រោយនេះ អង្គការក្រៅរដ្ឋាភិបាលវិតាគឃើញថា មានការប្រើប្រាស់កំលាំងកាយ និង ថវិកាជាច្រើនដើម្បីស្រាវជ្រាវ និងបង្កើតយុទ្ធសាស្ត្រនានា។ បណ្តាញអង្គការ មេឌីខាំ ជឿជាក់ថាដល់ពេលវេលា ផ្តោតការយកចិត្តទុកដាក់លើការអនុវត្តន៍ជាក់ស្តែងម្តង ហើយសូមបន្ថយការយក ចិត្តទុកដាក់លើការស្រាវជ្រាវ និង ការបង្កើតយុទ្ធសាស្ត្រផ្សេងៗ ។

មូលនិធិសមធម៌: អង្គការមេឌីខាំ បានស្វាគមន៍ ចំពោះការរីកចំរើននៃក្របខណ្ឌការងារចំពោះមូលនិធិសមធម៌ ដែលបានបង្កើតឡើង ដោយក្រសួងសុខាភិបាល ។ អង្គការមេឌីខាំ អបអរសាទរចំពោះឆន្ទៈរបស់រដ្ឋាភិបាលក្នុងការប្រែក្លាយមូលនិធិសមធម៌ អោយទៅជាគោលនយោបាយជាតិដែលអាចមាននិរន្តភាព ។ អង្គការក្រៅរដ្ឋាភិបាល មានជំនឿយ៉ាងមាំថា ជំនួយផ្នែកសង្គមសំរាប់ការថែទាំសុខភាពដល់ពលរដ្ឋក្រីក្រ ពិតជាផ្នែកមួយសំខាន់នៃយុទ្ធសាស្រ្តជាសកលសំរាប់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជានាថ្ងៃអនាគត ។ អង្គការក្រៅរដ្ឋាភិបាលបានប្រមូលនូវចំណេះដឹងរួមអំពីការចិញ្ចឹមជីវិតរបស់ពលរដ្ឋក្រីក្រ។ អង្គការជាតិ និងអន្តរជាតិជាច្រើន បានបញ្ចេញថាមពលក្នុងការបង្កើតនូវដំណោះស្រាយថ្មីៗមួយចំនួនដើម្បីលើកកំពស់ជីវភាពពលរដ្ឋក្រីក្រ ។ មូលនិធិសមធម៌គឺគ្រាន់តែជាការផ្តួចផ្តើមមួយក្នុងចំណោមការផ្តួចផ្តើមទាំងនោះ ។ ទស្សនៈវិស័យរបស់អង្គការមេឌីខាំសំរាប់កម្ពុជា គឺឈរលើសង្គមមួយ ដែលរដ្ឋាភិបាល និងសង្គមស៊ីវិលអនុវត្តការងាររួមគ្នាដោយស៊ីសង្វាក់ ។ កម្មវិធីមូលនិធិសមធម៌ គឺជាឱកាសតែមួយគត់ សំរាប់បង្កើតគំរូសង្គមនេះ ។ យោលទៅតាមទស្សនៈវិស័យនេះ មេឌីខាំ

- ពេញចិត្តចង់បាននូវគំរូមួយ ដែលនឹងបង្កើតជាស្ថាប័នមួយដែលមានតំណាងសមស្រប ពីអង្គការក្រៅរដ្ឋាភិបាលនៅក្នុងអង្គភាពផ្សេងៗ ដែលទទួលបន្ទុកយុទ្ធសាស្រ្ត រួមទាំងរួមចំណែកដឹកនាំគោលនយោបាយ សំរេចក្នុងការផ្តល់កិច្ចសន្យាផ្សេងៗ ការរៀបរៀងយុទ្ធសាស្រ្ត ព្រមទាំងការត្រួតពិនិត្យ និងវាយតំលៃសហគ្រិនម៉ៅការបន្តនានា។

តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល: ទូលំទូលាយជាងនេះទៅទៀត ខណៈដែលអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិករដ្ឋាភិបាល មានគោលដៅរួមគ្នា ដើម្បីអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រ និងបំពេញអោយគ្នាទៅវិញទៅមកយ៉ាងដូច្នេះច្រើនតែមានកង្វះខាតក្នុងការកំណត់និយមន័យ លើតួនាទីរបស់ដៃគូ និងតួនាទីចំបងរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការអនុវត្តន៍យុទ្ធសាស្រ្តជាតិដើម្បីកាត់បន្ថយភាពក្រីក្រ ។ ករណីនេះ ជួនកាលអាចបង្កើតអោយមានការមិនយល់គ្នាដោយយល់ថាជាការប្រកួតប្រជែង ហើយក្នុងករណីខ្លះអាចធ្វើអោយមានការមិនទុកចិត្តគ្នា ។ អង្គការ មេឌីខាំ

- សូមផ្តល់អនុសាសន៍ ចំពោះក្រសួងសុខាភិបាល និង អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើចិស័យសុខាភិបាលអោយព្រមព្រៀងគ្នាលើក្របខ័ណ្ឌការងារមួយ ដែលនៅក្នុងក្របខណ្ឌនោះ អង្គការក្រៅរដ្ឋាភិបាល អាចធ្វើការងារនៅមូលដ្ឋានបាន ។

បរិយាកាសវិស័យសុខាភិបាលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។ ទោះជាយ៉ាងណាក្តី គ្រប់ដៃគូទាំងអស់ រួមទាំងអង្គការក្រៅរដ្ឋាភិបាលផងដែរ យល់ព្រមលើតួនាទីជាគន្លឹះរបស់ក្រសួងសុខាភិបាល ក្នុងការសំរបសំរួល ធ្វើនិយតកម្ម លើកកំពស់តវិយាបថ ក្នុងការស្វែងរកសេវាសុខាភិបាល ព្រមទាំងផ្តល់នូវគុណភាពអប្បបរមាមួយចំពោះសេវាសុខាភិបាលសាធារណៈ ។ អង្គការក្រៅរដ្ឋាភិបាលមានចំណាប់អារម្មណ៍ ដោយឃើញការខិតខំយ៉ាងធំធេងរបស់ក្រសួងសុខាភិបាល ក្នុងការកែទំរង់សុខាភិបាលសាធារណៈ ។ រាល់បញ្ហាសំខាន់ៗដែលបានលើកឡើងខាងលើនេះ បង្ហាញអោយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការជាមួយក្រសួងសុខាភិបាល អាចរួមចំណែកបន្ថែមទៀត ដើម្បីធ្វើអោយសុខាភិបាលសាធារណៈបានរីកចំរើនប្រសើរឡើង ។

ចំពោះពិតមានបន្ថែមទាក់ទងនឹងបញ្ហាទាំងឡាយដែលមាននៅក្នុងរបាយការណ៍នេះ សូមទំនាក់ទំនង
MEDiCam, Tel : 023 211-486 E-mail: medicam@online.com.kh

កិច្ចការជនជាតិដើមភាគតិច

(i) សេចក្តីផ្តើម

សហគមន៍ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា រស់នៅតាមប្រពៃណី នៅក្នុងខេត្តរតនគីរី មណ្ឌលគីរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ កោះកុង ពោធិសាត់ កំពង់ស្ពឺ, ព្រះវិហារ(កួយ) និងក្រុងព្រះសីហនុ ហើយភាគច្រើន ពួកគេទាំងអស់នោះរស់នៅក្នុងព្រៃដ៏ធំល្វឹងល្វើយនៅភូមិភាគឦសាន្ត ។

មានអង្គការអន្តរជាតិមួយចំនួនបានបង្កើតឡើងក្នុងគោលបំណងជាក់លាក់សំដៅការពារសិទ្ធិជនជាតិដើមភាគតិចទាំងនោះ ។ នៅក្នុងឆ្នាំ ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្កើតគណៈកម្មការអន្តរក្រសួងមួយសំរាប់អភិវឌ្ឍន៍ជនជាតិដើមភាគតិចដែលរស់នៅតំបន់ខ្ពង់រាប ហើយនៅក្នុងឆ្នាំ១៩៩៧ ស្ថាប័ននេះ បានបង្កើតគោលនយោបាយទូទៅសំរាប់ការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ក៏ប៉ុន្តែឯកសារនេះ ស្ថិតជាសេចក្តីព្រាងនៅឡើយ ។ នៅក្នុងឯកសារនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ មានចំណុចសង្ខេបមួយចំនួនទាក់ទងទៅនឹងជនជាតិដើមភាគតិច ដូចជា:

- ជនជាតិដើមភាគតិចបានទទួលរងគ្រោះដោយសារកង្វះ ឬគ្មានតំណាងរបស់ពួកគេនៅក្នុងជួរអ្នកគ្រប់គ្រង ស្ថាប័នរដ្ឋដោយសារឧបសគ្គផ្នែកភាសា ។
- កង្វះលទ្ធភាពផ្នែកផ្លូវច្បាប់និងសិទ្ធិជាមូលដ្ឋានរបស់ពួកគេ គឺជាបញ្ហាធ្ងន់ធ្ងរ ដោយសារតែពួកគេមិនអាចយល់ច្បាប់ ហើយមិនដឹងអំពីសិទ្ធិជាមូលដ្ឋាន ហើយពួកគេងាយទទួលរងគ្រោះពីអំពើជិះជាន់កេងប្រវ័ញ្ច ។
- តាមប្រវត្តិសាស្ត្រ ជនជាតិដើមភាគតិច មិនត្រូវបានគេរាប់បញ្ចូលនៅក្នុង គោលនយោបាយ ការសំរេចចិត្ត និងដំណើរការអភិវឌ្ឍន៍ណាមួយនោះទេ ។ ហេតុដូច្នេះហើយបានជាជនជាតិដើមភាគតិចត្រូវរស់នៅ ក្នុងស្ថានភាពអន់ថយល័ក្ខខ័ណ្ឌឋានៈតួនាទីតូចទាប និងជីវភាពក្រីក្រ (ទំព័រ ១២៣) ។
- ទោះជាយ៉ាងណាក៏ភាគច្រើននៃអ្នកសំរេចចិត្តថ្នាក់ជាតិ មានការយល់ដឹងតិចតួចអំពីសាវតារជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា (ទំព័រ ១២៣) ។

(II) បញ្ហាសំខាន់ៗ

<u>សិទ្ធិកាន់កាប់ដីធ្លី</u>: ការសិក្សាអំពីដីធ្លីមួយចំនួនបានបង្ហាញអោយឃើញថា ជនជាតិដើមភាគតិចបានអនុវត្តប្រព័ន្ធគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិបានយ៉ាងល្អ តាមលក្ខណៈប្រពៃណីរបស់ពួកគេ ដែលផ្អែកលើការសំរេចចិត្តតាមលក្ខណៈសមូហភាព ការកាន់កាប់ដីធ្លីជាឯកជន ឬការលក់ដូរដីធ្លីដែលផ្ទុយពីប្រពន្ធ័គ្រប់គ្រងតាមលក្ខណៈប្រពៃណីនេះ បាននឹង

កំពុងគំរាមកំហែងដល់សិទ្ធិសមូហភាពតាមបែបប្រពៃណីរបស់ជនជាតិដើមម្ចាស់ស្រុក ហើយវាក៏អាចបង្កើតភាពក្រីក្រកាន់តែខ្លាំងទៅៗ ។

អាជ្ញាធរខេត្ត និងដៃគូអង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តរតនគិរី និងខេត្តផ្សេងទៀតបាននិងកំពុងបង្កើតកម្មវិធីដែលធ្វើឱ្យប្រសើរឡើងអំពីសុវត្ថិភាពដីធ្លី តាមរយៈការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ។ នៅខេត្តរតនគិរីការងារនេះបានទទួលស្គាល់ពីសំណាក់អាជ្ញាធរខេត្តនៃតំបន់គ្រប់គ្រងធនធានធម្មជាតិជាច្រើន ដែលធ្វើឡើងដោយសហគមន៍ ។ នេះគឺជាជំហានវិជ្ជមានសំរាប់ផ្តួចផ្តើមកម្មវិធីសន្តិសុខដីធ្លី ។ នៅឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ភូមិបាលថ្មី ដែលបានផ្តល់អោយសហគមន៍ជនជាតិដើមម្ចាស់ស្រុកនូវសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីរបស់ពួកគេទាំងសិទ្ធិស្របច្បាប់ជាសិទ្ធិបុគ្គល ឬជាសិទ្ធិសមូហភាព ។ នៅក្នុងច្បាប់ភូមិបាល ដីសហគមន៍ជនជាតិដើមភាគតិចមានដូចជា ដីលំនៅដ្ឋាន ឬដីភូមិ ដីជាក់ស្តែង និងដីបំរុងទុកសំរាប់កសិកម្មពនេចរតាមប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ។

អនុក្រិត្យដែលកំណត់អោយមានការទទួលស្គាល់នូវសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លី ក្នុងលក្ខណៈជាសហគមន៍នៅមិនទាន់បានតាក់តែងនៅឡើយទេ ។ ដូច្នេះ គប្បីលើកទឹកចិត្តអាយកសាងសេចក្តីព្រាងអនុក្រឹត្យស្តីពីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច ។នៅក្នុងដំណើរការនៃការបង្កើតអនុក្រិត្យនេះចាំបាច់ត្រូវវិភាគអោយបានគ្រប់ជ្រុងជ្រោយ និងផ្តល់ប្រយោជន៍ពេញលេញសំរាប់សហគមន៍ជនជាតិដើមភាគតិចក្នុងការប្រើប្រាស់ និងគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិរបស់ពួកគេប្រកបដោយ និរន្តរភាព ។ មានការបង្កើតឡើងនូវក្រុមការងារមួយ ដែលបន្តធ្វើការនៅក្នុងគំរោងសាកល្បង ។ ក្រុមការងារនេះបានទទួលការទ្រទ្រង់ដោយវេទិកាពិគ្រោះយោបល់ ដែលសមាជិកវេទិកាអាចផ្តល់មតិយោបល់ ក៏ដូចជាអនុសាសន៍វិជ្ជមាន ដើម្បីសំរួលដំណើរការផ្លូវច្បាប់នៅក្នុងការចុះបញ្ជីដីធ្លី ។

ដើម្បីផ្តល់ដំណឹងអំពីការអភិវឌ្ឍន៍នៃឧបករណ៍ផ្លូវច្បាប់ទាំងនេះ គំរោងចុះបញ្ជីដីធ្លីសាកល្បងនៅឃុំចំនួនបីត្រូវបានអនុវត្ត (ឃុំពីរនៅខេត្តរតនគិរី និងឃុំមួយនៅខេត្តមណ្ឌលគិរី) ។ ត្រូវពិនិត្យគំរោងទាំងនេះ អោយបានដិតដល់ដើម្បីធានាថាដំណើរការនេះមិនត្រូវបរាជ័យដោយសារតែឧបសគ្គផ្នែកការិយាល័យធិបតេយ្យ និងដោយសារការឆ្លៀតយកប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ ។

ទោះបីជាមានគំនិតផ្តួចផ្តើមទាំងនេះក៏ដោយ ក៏ការផ្ទេរកម្មសិទ្ធិដីធ្លីនៅតែជាគ្រោះថ្នាក់និងជាបញ្ហាធ្ងន់ធ្ងរនៅឡើយ ។ បញ្ហាមួយក្នុងចំណោមបញ្ហាទាំងនោះ គឺការរីករាលដាលនៃ "ដីសម្បទាន" ដែលប្រគល់ដោយរដ្ឋាភិបាលនៅតាមបណ្តាខេត្តនានា ដូចជា កំពង់ធំ ស្ទឹងត្រែង និងក្រចេះ ។ គោលបំណងក្នុងការបង្កើតឱ្យមានដីសម្បទានទាំងនេះ

គឺបង្កើតជាតំបន់កសិឧស្សាហកម្ម (ចំការកៅស៊ូ និងចំការស្វាយចន្ទី)។ គំរោងដីសម្បទាន ធ្វើអោយបាត់បង់ព្រៃធម្មជាតិ និងធ្វើអោយជនជាតិដើមភាគតិចរស់នៅក្នុងស្ថានភាពមួយទៅជាអ្នកបំរើជាច់ថ្លៃនិងទីទល់ក្រ ពីព្រោះតែការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិរបស់ពួកគេត្រូវបានដកហូត។

ក៏មានការព្រួយបារម្ភអំពីការកើនឡើងនៃការលក់ដី ដែលពាក់ព័ន្ធនឹងការក្លែងពតិមាន ការបង្ខិតបង្ខំ ការគំរាមកំហែង សំណូកសូកប៉ាន់ដល់មន្ត្រីរដ្ឋាភិបាល និងយន្តការខុសច្បាប់ផ្សេងៗទៀត។

- ទាមទារអោយមានជាបន្ទាន់នូវការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីសិទ្ធិមនុស្សជាមូលដ្ឋាន និងសិទ្ធិអំពីដីធ្លី និងនីតិវិធីផ្នែកកិច្ចសន្យា។
- ការផ្សព្វផ្សាយពតិមាននេះគួរធ្វើឡើងជាភាសាជនជាតិដើមម្ចាស់ស្រុកផងដែរ ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ជនជាតិដើមភាគតិច និងអង្គការរបស់ជនជាតិដើមភាគតិច។
- កិច្ចការនេះទាមទារអោយមានការគាំទ្រ ពី អ្នកតំណាងឯករាជ្យស្របច្បាប់ នៅក្នុងគណៈកម្មការសុរិយោដី និងនៅក្នុងដំណើរការតាមផ្លូវតុលាការ។

<u>បញ្ហាព្រៃឈើ</u>: ដូចសហគមន៍ដទៃទៀតផ្សេងៗ ទៀត ដែលប្រើប្រាស់ព្រៃឈើសំរាប់គាំទ្រដល់ការប្រកបរបរចិញ្ចឹមជីវិតដែរ ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ជាក់ស្តែងគ្មានការធានាសិទ្ធិណាមួយសំរាប់ការគ្រប់គ្រងព្រៃឈើ ដែលពួកគេបានប្រើប្រាស់ និងគ្រប់គ្រងតាមលក្ខណៈប្រពៃណីជាយូរលុងណាស់មកហើយទេ។ ដោយមានការផ្ទេរកម្មសិទ្ធិដីធ្លី ដោយខុសច្បាប់លើដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ធ្វើអោយពួកគេបាត់បង់សិទ្ធិលើដីកសិកម្មប្រពៃណីរបស់គេ ហើយពួកគេត្រូវបង្ខំចិត្តកាប់ព្រៃបន្ថែមសំរាប់ធ្វើចំការបន្តទៀត។បន្ទាប់មកពួកគេក៏ទទួលការស្តីបន្ទោស ថាជាអ្នកបំផ្លាញព្រៃឈើ។ រីឯក្រុមហ៊ុនសម្បទានព្រៃឈើបានបំភិតបំភ័យដល់សហគមន៍ជនជាតិដើមភាគតិចហើយបានទាញយកពីសហគមន៍ទាំងនេះនូវធនធានធម្មជាតិដែលពួកគេប្រើប្រាស់តាមប្រពៃណី សំរាប់ការទ្រទ្រង់ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពរបស់ពួកគេ។

ជនជាតិដីមភាគតិច មិនត្រូវបានអនុញ្ញាតអោយកាប់ឈើហ៊ុប ទោះបីជាអារឈើដែក៏ដោយ " ពីព្រោះគេនិយាយថា នេះមិនមែនជាការប្រើប្រាស់តាមបែបប្រពៃណីទេ"។ ឥលូវនេះជនជាតិដើមម្ចាស់ស្រុកកំពុងបង្កើតបទបញ្ជាសហគមន៍ ដើម្បីការពារព្រៃឈើ និងមានអារម្មណ៍ថា មានការរើសអើងតទល់នឹង "ការប្រើប្រាស់តាមបែបប្រពៃណី" ដែលមានចែងនៅក្នុងបញ្ញត្តិនៃច្បាប់ព្រៃឈើ និងការបកស្រាយតាមផ្លូវច្បាប់។

អនុក្រិត្យស្តីពីការបង្កើតព្រៃសហគមន៍ ត្រូវបានគេពន្យារអស់រយៈពេលជាច្រើនឆ្នាំ ហើយការពន្យារពេល អាចនឹងផ្តល់នូវបញ្ហាបន្ថែមទៀត ដល់ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច។ ចាំបាច់ត្រូវតែតាមដានអោយបានជិតដល់ ដើម្បីលៃយ៉ាងណាអោយអនុក្រិត្យ នេះពិតជាបំរើសេចក្តីត្រូវការនៃសហគមន៍ក្រីក្រយ៉ាងពិតប្រាកដ។

- ជាការចាំបាច់ណាស់ដែលថា ការអនុវត្តន៍អនុក្រិតស្តីពីសហគមន៍ព្រៃឈើ ត្រូវតែបញ្ចូលសិទ្ធិគ្រប់គ្រងតាមបែបប្រពៃណីរបស់សហគមន៍ទាំងនៅក្នុងព្រៃដែលអាចប្រមូលផល និងព្រៃសម្បាទាន ពុំមែនត្រឹមតែព្រៃ រិចរិលនោះទេ។

- ដីព្រៃជាច្រើនកន្លែង ជាពិសេសព្រៃអារក្ស ព្រៃកប់ខ្មោច និងតំបន់ព្រៃតូច១ នៅក្នុងចំណោមដីកសិកម្ម ចាំបាច់ត្រូវដាក់បញ្ចូលជាដីកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ប្រសិនបើការគ្រប់គ្រងដីធ្លី និងវប្បធម៌ជនជាតិដើមភាគតិច ត្រូវបានគេការពារមែននោះ។ ការមិនរាប់បញ្ចូលតំបន់ព្រៃទាំងនេះ នឹងមានឥទ្ធិពលមិនល្អនៃការធ្លាក់ចុះជាបណ្តើរ១នូវដំណើរការរៀបចំផែនទី ដែលជាតំរូវការសំរាប់ដីសហគមន៍ ដោយកាត់បន្ថយសុវត្ថិភាពដីធ្លីសំរាប់ជនជាតិភាគតិចភាគច្រើន។

<u>វិស័យអប់រំ:</u> ការកែទំរង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ជាទូទៅមានដំណើរការរីកចំរើនយឺត១។ នៅក្នុងវិស័យអប់រំសំរាប់ជនជាតិដើមម្ចាស់ស្រុក ទទួលបានលទ្ធផលវិជ្ជមានមួយចំនួន ប៉ុន្តែក៏មានផលអវិជ្ជមានខ្លះ១ ដែលរំខានដល់ការរីកចំរើនផងដែរ។ ចំណុចវិជ្ជមានមួយបានគាំទ្រអោយមានការសិក្សាពីរភាសា គឺការរៀនភាសាជនជាតិដើមភាគតិចដើម្បីធ្វើជាស្ពានដល់ការរៀនភាសាខ្មែរ។ គំរូអប់រំពីរភាសានៅក្នុងប្រព័ន្ធអប់រំជាផ្លូវការ កំពុងបានសហការណ៍គ្នាយ៉ាងជិតស្និទ្ធ ជាមួយក្រសួងអប់រំ យុវជន និងកីឡា ហើយនឹងយកគំរូនេះទៅអនុវត្តនៅកន្លែងផ្សេងទៀត។

ការអប់រំក្រៅប្រព័ន្ធពីរភាសានិងមួយភាសា បន្តទទួលបានផលវិជ្ជមានជាច្រើន តែទំនងជាត្រូវតែបំពេញបន្ថែមចំណុចខ្វះខាតខ្លះ១តាមលទ្ធភាព នៅពេលដែលដាក់ទៅក្នុងប្រព័ន្ធអប់រំជាផ្លូវការ។ ទំរង់ការអប់រំដែលផ្អែកលើការរៀនអក្សរសាស្ត្រជាមូលដ្ឋានបានទទួលជោគជ័យជាច្រើន ហើយសហគមន៍ជនជាតិដើមភាគតិចត្រូវបានគេផ្តល់ការជួយសំរួល ដើម្បីទទួលបានការសិក្សាតាមពេលវេលាសមស្របបំផុត ដែលស្របតាមរដូវកាល និងស្របតាមការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ចំណុចវិជ្ជមានមួយទៀតនៃការអប់រំក្រៅប្រព័ន្ធ គឺជនជាតិដើមភាគតិចមួយចំនួនបានធ្វើជាគ្រូបង្រៀននៅក្នុងសាលារដ្ឋ ហើយបានប្រើភាសាជនជាតិដើមម្ចាស់ស្រុកជាជំនួយក្នុងការរៀនភាសាខ្មែរ។

ចំណុចដែលមិនសូវល្អនោះ គឺមានកង្វះខាតសំភារៈ និងកង្វះខាតថ្នាក់រៀនយ៉ាងច្រើន។ ប្រសិនបើមានថ្នាក់រៀនគ្រប់គ្រាន់ នោះនឹងអាចជួយកូនសិស្សអោយរៀនអក្សរខ្មែរជាមូលដ្ឋានបានយ៉ាងច្រើន។

នៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ សាលារៀនជាច្រើន ខ្វះបុគ្គលិក ឬមួយបុគ្គលិកគ្មានវិជ្ជាជីវៈ។ នៅក្នុងករណីជាច្រើនគេបានបញ្ជូនបុគ្គលិកមិនមែនជនជាតិដើមភាគតិចទៅបង្រៀននៅសាលាដែលមានជនជាតិដើមភាគតិចដោយពិចារណាមិនបានគ្រប់គ្រាន់អំពីលក្ខណៈអនុវត្តន៍ជាក់ស្តែងរបស់វិធីនេះ។ ដោយឃ្លាតឆ្ងាយពីគ្រួសារ និងវប្បធម៌ បញ្ហាភាសា និងឧបសគ្គឆ្លងវប្បធម៌ក្រុមគ្រូទាំងនោះច្រើនតែគ្មានវត្តមាននៅសាលាតែម្តង។ ប្រសិនបើគ្មានការអប់រំក្រៅប្រព័ន្ធទេនោះ សហគមន៍ជនជាតិដើមភាគតិចប្រហែលមិនអាចទទួលបានសេវាអប់រំឡើយ។ បញ្ហានេះលេចមានឡើងនៅក្នុងបរិស្ថានមួយនៃការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គមយ៉ាងឆាប់រហ័ស ហើយមហាគ្រោះថ្នាក់នោះគឺថាសហគមន៍ជនជាតិដើមភាគតិចនឹងកាន់តែឃ្លាតឆ្ងាយទៅពីសង្គម។

<u>វិស័យសុខាភិបាលៈ</u> សូចករសុខភាព ក្នុងចំណោមជនជាតិដើមម្ចាស់ស្រុក នៅក្នុងប្រទេសកម្ពុជា មានសភាពធ្ងន់ធ្ងរបំផុត។ ជនជាតិដើមភាគតិចបានរាយការណ៍ជាញឹកញាប់ ជាបន្តបន្ទាប់នូវឧប្បហេតុនៃអំពើពុករលួយ និងការរំលោភពីសំណាក់ស្នាដៃបុគ្គលិកសុខាភិបាល មិនមែនជាជនជាតិដើមភាគតិច។ បញ្ហានេះធ្វើអោយជនជាតិដើមម្ចាស់ស្រុកគ្មានជំនឿទុកចិត្តទៅលើប្រព័ន្ធសុខាភិបាល ហើយពួកគេភាគច្រើន មិនបានធ្វើតាមការណែនាំ និងការផ្តល់សេវារបស់ក្រុមគ្រូពេទ្យទាំងនោះឡើយ។ មានការខិតខំជាច្រើន ចង់ដោះស្រាយស្ថានការណ៍នេះ ប៉ុន្តែបានជួបឧបសគ្គ ដោយសារតែប្រព័ន្ធសុខាភិបាលសាធារណៈគ្មានប្រសិទ្ធភាព។ ពេលថ្មីៗ នេះជំនួយសុខភាពពីអ្នកក្រៅហាក់អាចផ្តល់ដំណោះស្រាយរយៈពេលខ្លីតែប៉ុណ្ណោះ។ ដូចនេះការកែទំរង់នៃប្រព័ន្ធសុខាភិបាលជាតិ ត្រូវតែមានរយៈពេលវែង ដើម្បីរៀបចំជំនួយសុខាភិបាលដែលឆ្លើយតបសេចក្តីត្រូវការពិតប្រាកដនៃជនជាតិដើមភាគតិច។

<u>ទំនប់វារីអគ្គិសនីៈ</u> ជាច្រើនឆ្នាំកន្លងមក មានបញ្ហាយ៉ាងធ្ងន់ធ្ងរដែលបណ្តាលមកពីលទ្ធផលនៃទំនប់វារីអគ្គិសនី សាងសង់នៅទន្លេសេសានក្នុងប្រទេសវៀតណាម ដែលហូរឆ្លងកាត់ខេត្តរតនគីរី និងខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា ហើយទំនប់វារីអគ្គិសនីនេះបានធ្វើអោយបាត់បង់ជីវិត មនុស្សសត្វ និងមានរបបទឹកទន្លេហូរមិនទៀងទាត់។

ខណៈពេលបញ្ហានេះកំពុងតែបន្តកើតឡើងដោយ ពួកគេទំនងជាសាងសង់ទំនប់វារីអគ្គិសនីថ្មីៗបន្ថែមទៀតនៅក្នុងប្រទេសវៀតណាម។ ទំនប់វារីអគ្គិសនីដែលសាងសង់ទាំងនេះពុំបានវាយតំលៃគ្រប់គ្រាន់អំពីហេតុផលប៉ះពាល់កន្លងមកដែលត្រូវតែកែតំរូវ ឬក៏ធ្វើការងារវាយតំលៃផលប៉ះពាល់ផ្នែកបរិស្ថាន និងផលប៉ះពាល់ផ្នែកសង្គមធ្ងន់ធ្ងរនាពេលអនាគត។

ទីភ្នាក់ងារជំនួយអន្តរជាតិ និងធនាគារពហុភាគីបន្តគាំទ្រ និងបំពេញសុពលភាពដល់ការសាងសង់ ដោយគាំទ្រអនុគំរោង ដូចជាតបណ្តាញអគ្គិសនីជាដើម។ ដូចនេះមានន័យថាគ្រឹះស្ថានហិរញ្ញវត្ថុធំៗ មួយចំនួនដូចជាទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងរដ្ឋាភិបាលវៀតណាមនាំមកនូវមហន្តរាយដល់ជីវិតរស់នៃជនជាតិដើមភាគតិចនៅភូមិភាគឦសាន្តនៃប្រទេសកម្ពុជា។ សហគមន៍មានការព្រួយបារម្ភជាខ្លាំង អំពីឧស្សាហកម្មវារីអគ្គិសនីទ្រង់ទ្រាយធំៗ និងគំរូនៃអភិវឌ្ឍន៍ឧស្សាហកម្មបែបនេះ ព្រោះថាវានឹងនាំមកនូវផលប៉ះពាល់អវិជ្ជមាន ដែលមានរយៈពេលយូរអង្វែង ដល់ការរស់នៅរបស់ជនជាតិដើមភាគតិច។

<u>វិស័យទេសចរណ៍</u>: រដ្ឋាភិបាលប្រទេសកម្ពុជា ឡាវ និងវៀតណាមបានចុះហត្ថលេខាព្រមព្រៀងគ្នាលើ" ផែនការអភិវឌ្ឍន៍តំបន់ត្រីកោណ" ដែលរួមបញ្ចូលការបើកច្រកព្រំដែនខេត្តនៃប្រទេសកម្ពុជា សំរាប់ពង្រីកផ្លូវថ្នល់ធំៗ អោយបានឆាប់រហ័ស និងពង្រីកការអភិវឌ្ឍន៍វិស័យទេសចរណ៍។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់មូលនិធិ តាមរយៈប្រាក់កំចី ដល់ការអភិវឌ្ឍន៍ព្រលានយន្តហោះអន្តរជាតិនៅក្នុងខេត្តរតនៈគីរី ក្នុងទំរង់ក្លែងភេទដែលថា ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងទេសចរណ៍បានរហ័ស នឹងកាត់បន្ថយភាពក្រីក្រ។

គំរូអភិវឌ្ឍន៍នេះបានផ្អែកលើទស្សនៈថាជនជាតិដើមភាគតិច នឹងទទួលផលចំណេញបានមកពីការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។ ក៏ប៉ុន្តែ បើគ្មានការអប់រំ និងការបណ្តុះបណ្តាលសេវាទេនោះ វាមិនប្រាកដថាជនជាតិដើមភាគតិចនឹងអាចមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងទេសចរណ៍ ឬក៏ថាបានទទួលប្រាក់ចំណូលពីវិស័យទេសចរណ៍នោះឡើយ។ ក្នុងបរិបទនេះ វិស័យទេសចរណ៍អាចធ្វើអោយសហគមន៍ជនជាតិដើមភាគតិចកាន់តែឃ្លាតឆ្ងាយពីការយកចិត្តទុកដាក់បន្ថែមទៀត។

- ចាំបាច់ត្រូវតែត្រួតពិនិត្យការអភិវឌ្ឍន៍វិស័យទេសចរណ៍ និងគ្រប់គ្រង រហូតទាល់តែឧបសគ្គដែលរារាំងដល់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយសមធម៌និងចីរភាពត្រូវបានលុបបំបាត់។ គោលនយោបាយបច្ចុប្បន្ន នៃការពង្រីកវិស័យទេសចរណ៍ឆាប់រហ័ស ទំនងជាមិនបានធ្វើការវិភាគគ្រប់ជ្រុងជ្រោយនោះទេ ដែលអាចនាំមកនូវគ្រោះថ្នាក់យ៉ាងធំដល់សហគមន៍ជនជាតិដើមភាគតិច ។

<u>ដំណើរការវិមជ្ឈការៈ ភាពពឹងផ្អែក និងស្វ័យគ្រប់គ្រង:</u> សព្វថ្ងៃមានកិច្ចដំណើរការវិមជ្ឈការជាច្រើនកំពុងមានជាបន្តនៅក្នុងរដ្ឋាភិបាលកម្ពុជា ដែលមានបំណង ផ្តល់កាលានុវត្តភាពពិតប្រាកដ ដើម្បីជំរុញជនជាតិដើមភាគតិច អោយធ្វើស្វ័យគ្រប់គ្រង។ ក៏ប៉ុន្តែ ទឹកប្រាក់ដ៏សន្ធឹកសន្ធាប់ដែលកំពុងត្រូវបានប្រើប្រាស់សំរាប់ "ការអភិវឌ្ឍន៍" នៅក្នុងតំបន់

ជនជាតិដើមភាគតិចជាច្រើន ពុំមានការគាំទ្រគ្រប់គ្រាន់សំរាប់ការអភិវឌ្ឍន៍សហគមន៍ពិតប្រាកដ និងសំរាប់គាំទ្រធនធានមនុស្សឡើយ។ នៅក្នុងតំបន់នានាដែលភាគច្រើនលើសលុបពុំមែនជនជាតិភាគតិច ជួនកាលគរោងរបស់រដ្ឋាភិបាល និងគំរោងរបស់អង្គការក្រៅរដ្ឋាភិបាលរៀបចំគំរោងជាតិ ឬគំរោងប្រចាំតំបន់ជាភាសាមិនមែនរបស់ជនជាតិដើមភាគតិច។ នៅក្នុងទិដ្ឋភាពនេះ ប្រាក់បេសកម្ម និងការគាំទ្រផ្នែកហិរញ្ញវត្ថុប្រហាក់ប្រហែលគ្នានេះ កំពុងត្រូវបានប្រើប្រាស់ សំរាប់តែទាក់ទាញការចូលរួមនៅក្នុងសកម្មភាពរបស់ទីភ្នាក់ងារអភិវឌ្ឍន៍តែប៉ុណ្ណោះ។

លទ្ធផលនៃបញ្ហានេះ កំពុងចាប់ផ្តើមបង្ហាញឱ្យឃើញ នូវការបង្កើតឡើងនូវទំរង់នៃភាពពឹងផ្អែក បាត់បង់ការគ្រប់គ្រងសហគមន៍ដោយខ្លួនឯង ហើយគ្មានការប្រគល់អំណាចអោយទៅសហគមន៍ឡើយ។ ប្រសិនបើគ្មានជនជាតិដើមភាគតិចចូលរួមសកម្មនៅក្នុងដំណើរការអភិវឌ្ឍន៍ផ្ទាល់របស់គេទេ ហើយគ្មានជំរើសផ្សេងក្នុងស្រុកចំពោះគំរូអភិវឌ្ឍន៍វិស័យឧស្សាហកម្មណាមួយដែលត្រូវបានផ្តល់សច្ចាប័នទេនោះ គេរំពឹងថា បញ្ហាសេដ្ឋកិច្ច សង្គមកិច្ចដ៏ធ្ងន់ធ្ងរ នឹងកើតឡើងចំពោះសហគមន៍ជនជាតិដើមភាគតិច ដូចការកើតមាននៅក្នុងសហគមន៍ជនជាតិដើមភាគតិច នៅកន្លែងនានាក្នុងពិភពលោកដែលមានលក្ខខណ្ឌស្រដៀងៗគ្នានេះ។

- ហេតុដូចនេះ តំរូវអោយពិនិត្យសារជាថ្មីនូវផលប៉ះពាល់ចំបង មកលើជនជាតិដើមភាគតិច នូវវិធីសាស្ត្រអភិវឌ្ឍន៍ផ្សេង ដោយឡែកៗពីគ្នា។

(iii) អនុសាសន៍

- រាជរដ្ឋាភិបាលកម្ពុជាគួរតែសំរេចទទួលយកគោលនយោបាយទូទៅមួយសំរាប់ជនជាតិដើមភាគតិចដែល បានព្រាងដោយគណៈកម្មការអន្តរក្រសួងតាំងពីឆ្នាំ១៩៩៧។ គោលនយោបាយជាតិនេះ មានសារៈសំខាន់ខ្លាំងណាស់ ហើយកម្ពុជាចាំបាច់ត្រូវតែអនុញ្ញាតអោយជនជាតិដើមភាគតិចដឹកនាំការអភិវឌ្ឍន៍ផ្ទាល់ខ្លួនគេតែម្តង។ ឧបសគ្គរាំងដល់ការអនុម័តគោលនយោបាយនេះ ចាំបាច់ត្រូវតែកំណត់អត្តសញ្ញាណ និងពិគ្រោះពិភាក្សាដោយចំហ។
- ចក្ខុវិស័យអភិវឌ្ឍន៍ជាច្រើនដែលកំពុងត្រូវបានអនុវត្តនៅក្នុងតំបន់ជនជាតិដើមភាគតិច គឺផ្អែកតែលើការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ដោយមិនអនុវត្តតាមនូវគោលនយោបាយមួយស្តីពីការដឹកនាំខ្លួនឯង នៃសហគមន៍ជនជាតិដើមភាគតិចដែលបានចែងនៅក្នុង សេចក្តីព្រាងរបស់គណៈកម្មការអន្តរក្រសួងនាឆ្នាំ ១៩៩៧ នេះទេ ហើយក៏មិនបានធ្វើតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចនោះដែរ។ ដូច្នេះគួរពិនិត្យសារឡើងវិញនូវទស្សនៈ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាការចាំបាច់ ដើម្បីធានាកែកុនស្ថានការណ៍នេះ។

- ម្ចាស់ជំនួយបានបង្កើតគោលការណ៍ទាក់ទងទៅនឹងដំណោះស្រាយសមស្របសំរាប់ជនជាតិដើមភាគតិច និងដំណោះ-ស្រាយផលប៉ះពាល់នៃគំរោងនានាមកលើសហគមន៏ជនជាតិដើមភាគតិច។ ជាការសំខាន់ណាស់ដែលថា ម្ចាស់ជំនួយទាំងនោះត្រូវរំលឹកដល់អ្នកអនុវត្តគំរោងទាំងឡាយ និងសាធារណៈជនទូទៅ អោយយល់ពីគោលការណ៍ និងសេចក្តីណែនាំអនុវត្តទាំងនេះ ហើយលៃយ៉ាងណាអោយពួកគេគោរពតាម។
- យោងទៅតាមសេចក្តីណែនាំអនុវត្តន៏ លេខ ៤.២០ របស់ធនាគារពិភពលោក ដែលសាកល្បងសិក្សាស្វែងរកកិច្ចការពារជនជាតិដើមម្ចាស់ស្រុកភាគតិចនៅប្រទេសកម្ពុជា នាឆ្នាំ ២០០២ នៅពេលដែលធនាគារពិភពលោកកំពុងរៀបចំឥណទានមួយ សំរាប់គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដើម្បីគាំទ្រការពង្រីកកម្មវិធីសិលារបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាការសំខាន់ណាស់ដែលថា លទ្ធផលនៃការសិក្សាបែបនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅទូទាំងប្រទេស ហើយលទ្ធផលទាំងនោះគួរតែត្រូវបានលើកយកមកពិចារណា នៅពេលធ្វើសេចក្តីសំរេចអភិវឌ្ឍន៏នៅតំបន់នានានៅក្នុងតំបន់ជនជាតិដើមភាគតិច។
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានចាប់ផ្តើមអនុវត្តគំរោងកម្មវិធីសាកល្បងរបស់ខ្លួន ដើម្បីការពារសិទ្ធិកាន់កាប់ដីធ្លីជាសមូសហភាព ចំពោះសហគមន៏ជនជាតិដើមភាគតិចនៅក្នុងឃុំចំនួនបីក្នុងខេត្តរតនគីរីនិងមណ្ឌលគីរី នៅក្នុងឆ្នាំ ២០០៣។ ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលនានា គួរតែមានតួនាទីយ៉ាងសំខាន់ ក្នុងការធានាអោយប្រាកដថា សិទ្ធិកាន់កាប់ដីធ្លីដែលជាមរតកដូនតារបស់ជនជាតិដើមភាគតិច មិនត្រូវគេមើលរំលងនោះទេ។

ចំពោះពតិមានបន្ថែមស្តីពីបញ្ហានានាដែលបានលើកឡើងក្នុងអត្ថបទនេះ សូមមេត្តាទាក់ទងជាមួយ

NGO Forum ទូរស័ព្ទលេខ (៨៥៥) ២៣ ៩៩៤ ០៦៣ អ៊ីម៉េល: ngoforum@ngoforum.org.kh និង

គំរោងផលិតផលព្រៃឈើមិនមែនដើមឈើ (NTFP) ទូរស័ព្ទលេខ (៨៥៥) ៧៥ ៩៧៤ ០៣៩

អ៊ីម៉េល: ntfp@camintel.com

សុខភាពគ្មានព្រំដែនប្រចាំនៅរតនគីរី ទូរស័ព្ទលេខ (៨៥៥) ១២ ៧៣១ ៣៩៦ អ៊ីម៉េល: hurtk@camintel.com and RAMA@camintel.com

CARE ប្រចាំនៅរតនគីរី ទូរស័ព្ទលេខ (៨៥៥) ៧៥ ៩៧៤ ០៥៦ អ៊ីមេល: care_trtk@camintel.com

តំបន់ឧស្សាហកម្ម

(i) សេចក្តីផ្តើម

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យមានស្ថេរភាពសេដ្ឋកិច្ច និងបង្កើតឱ្យមានកន្លែងឈរជើងដ៏រឹងមាំមួយនៅក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិ ប្រទេសកម្ពុជាបានបើកចំហចំពោះការវិនិយោគទុនបរទេស និងការប្រកួតប្រជែងចំហជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។ ចលនានេះធ្វើឱ្យមានការប្រឈមមុខថ្មីមួយចំពោះជាតិទាំងមូលសំរាប់កម្មករ និយោជិត និងសហជីពរបស់ពួកគេ ពិសេសចំពោះសហជីពនានានៅក្នុងឧស្សាហកម្មកាត់ដេរ ។ ការលេចឡើងនូវទីផ្សារពលកម្មពិភពលោក ធ្វើអោយមានកិច្ចសន្យាដេញថ្លៃយ៉ាងទាប រវាងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។នៅពេលដែលថ្លៃផលិតកម្មត្រូវបានគេរក្សាឱ្យទាបនោះ សំពាធត្រូវធ្លាក់ទៅលើប្រាក់ឈ្នួលរបស់កម្មករនិយោជិត និងលក្ខខណ្ឌការងារ។ កង្វះខាតកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមសហជីព/កម្មករអន្តរជាតិនានា និងការគំរាមកំហែងពីបណ្តាប្រទេសជឿនលឿនដែលដាក់ផលិតកម្មទៅរកទីផ្សារថោកៗ កំពុងតែបន្តធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរឡើងៗ។ ទោះជាយ៉ាងណាក៏ដោយឧស្សាហកម្មកាត់ដេរកម្ពុជា ដែលបច្ចុប្បន្នមានមនុស្សបំរើការងារជាង ២០០.០០០ នាក់ មានការជឿជាក់ថា ចំនួននៃកិច្ចសន្យា មុខជានឹងកើនឡើងបន្តទៀត រហូតដល់មានការរីកចំរើនគួរឱ្យកត់សំគាល់ជាងកាលពី ៨ ឆ្នាំមុន។[៣៣]

នៅឆ្នាំ ២០០១ ដោយសហការជាមួយសមាគមរោងចក្រកាត់ដេរ អង្គការពលកម្មអន្តរជាតិ បានចាប់ផ្តើមធ្វើអធិការកិច្ចលើលក្ខខណ្ឌការងារតាមរោងចក្រនានា។ តាមរបាយការណ៍ដែលពួកគេបានធ្វើដោយឡែក គេរកឃើញថាបញ្ហាដ៏ចំបង នៅក្នុងរោងចក្រនានាគឺការបង្ខំឱ្យធ្វើការងារលើសម៉ោង។បណ្តឹងនានា ប្រឆាំងចំពោះការរើសអើងនិងការផ្តល់ប្រាក់បៀវត្សរ៍មិនត្រឹមត្រូវ ។

បញ្ហាគន្លឹះ និងនិន្នាការទូទៅ

ឧស្សាហកម្មកាត់ដេរកម្ពុជា ទំនងជានឹងបណ្តោយទៅតាមស្ថានការណ៍នៃទីផ្សារពលកម្មពិភពលោក នៅពេលដែលប្រពន្ធ័កូតាបច្ចុប្បន្នផុតកំណត់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ។ ការបាត់បង់ស្ថានភាពដ៏ល្អលើទីផ្សារនានានៅសហរដ្ឋអាមេរិក និងអឺរ៉ុប ប្រទេសកម្ពុជានឹងត្រូវបានបង្ខំឱ្យក្លាយខ្លួនជាផ្នែកមួយនៃបណ្តាប្រទេស ដែលចំណាយទាប

[33] កាសែតខេមបូឌាដៃលី ចេញថ្ងៃសៅរ៍ ទី ៦-៧ ខែកញ្ញា ឆ្នាំ២០០៣

និងមានផលិតភាពខ្ពស់។ មន្ត្រីរដ្ឋាភិបាលនិងមន្ត្រីឧស្សាហកម្មកាត់ដេរកំពុងសង្ឃឹមថា កេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជា ដែលមានស្តង់ដារការងារខ្ពស់ នឹងជួយសង្គ្រោះឧស្សាហកម្មកាត់ដេរ និងសេដ្ឋកិច្ចដ៏ទន់ខ្សោយរបស់ប្រទេសជាតិពីការដួលរលំ ។ ផ្ទុយទៅវិញ សេដ្ឋវិទូបារម្ភថា ថ្លៃដើមផលិតកម្មរបស់ប្រទេសកម្ពុជាមានកំរិតខ្ពស់ណាស់ ហើយបារម្ភថា ដោយសារគ្មានប្រពន្ធ័កូតា រោងចក្រនានា នឹងរើទីតាំងដោយងាយស្រួលទៅរកប្រទេសមួយចំនួនទៀត ដែលមានចំណាយផលិតកម្មទាប ។

ដោយឡែកទិដ្ឋភាពដែលគួរឱ្យរំជើបរំជួលមួយនៃតំបន់ឧស្សាហកម្មខ្លះគឺការដាក់អោយសហជីពកម្មករក្រៅច្បាប់ ។ភាពសមហេតុសមផលនៃគោលនយោបាយបែបនេះត្រូវបានបង្កើតឡើងដើម្បីគាំទ្រថ្នាក់គ្រប់គ្រង។ គោលនយោបាយនេះសំរាប់ទប់ស្កាត់កម្មករ/និយោជិតមិនឱ្យត្រៀមខ្លួន ក្នុងការទាមទារសុំតំលើងប្រាក់បៀវត្សរ៍ និងកែប្រែស្ថានភាពការងារដ៏លំបាកលំបិននេះ។ ផ្ទុយទៅវិញការគ្រប់គ្រងនេះបែរជាចូលចិត្តពឹងផ្អែកទៅលើគណៈកម្មាធិការរបស់កម្មករ/និយោជិត និងក្រុមសីលធម៌ ដែលគ្មានប្រសិទ្ធភាព និងដែលបង្កើតដោយខ្លួនឯងទៅវិញ។ ដោយសារតែកំលាំងពលកម្មភាគច្រើន ជាយុវនារីក្មេងៗ មិនបានរៀនសូត្រ និងមានបទពិសោធន៍តិចតួចផ្នែកសហជីពកម្មករ ទើបមានលក្ខណៈងាយស្រួលក្នុងការបង្កើតនូវកិច្ចអនុវត្តន៍បែបនេះនៅក្នុងតំបន់ឧស្សាហកម្ម។ នេះជាកង្វល់ដ៏ធំរបស់ចលនាការងារ នៅប្រទេសកម្ពុជា។ រដ្ឋាភិបាល និងក្រុមហ៊ុននានា ត្រូវយល់ឱ្យច្បាស់ថា ការហាមឃាត់ លើការធានាចំពោះតំបន់ឧស្សាហកម្មនឹងគ្មានការធានាចំពោះភាពសុខសាន្តនៃឧស្សាហកម្មទេ។ ភាពចលាចលនៅក្នុងតំបន់ឧស្សាហកម្ម ដែលមានការគ្រប់គ្រងមិនល្អ និងរូបភាពមិនអំណោយផលដែលតំបន់ឧស្សាហកម្មនានាមាននៅលើពិភពលោក គឺជាភស្តុតាងនៃរឿងនេះ។

ដើម្បីឆ្លើយតបនឹងកង្វល់ខាងលើ រដ្ឋាភិបាលកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីតំបន់ឧស្សាហកម្ម ដើម្បីធ្វើនិយតកម្មលើការបង្កើតរបស់ដែលគេហៅថាតំបន់ឧស្សាហកម្មនៅលើទឹកដីកម្ពុជា ។

(iii) អនុសាសន៍

- កម្មករ/និយោជិត មានសិទ្ធិក្នុងការរៀបចំសមាគមបណ្តុះបណ្តាលវិជ្ជាជីវៈ ឬសហជីពនានារបស់ពួកគេ នៅក្នុងតំបន់ឧស្សាហកម្ម ស្របទៅតាមច្បាប់ការងារ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

- កម្មករ/និយោជិតជាស្ត្រីដែលបំរើការងារនៅក្នុងតំបន់ឧស្សាហកម្មត្រូវបានការពារយ៉ាងពេញលេញពីការបៀតបៀនផ្លូវភេទ ការឃុំខ្លួនខុសច្បាប់ ការងារគ្រោះថ្នាក់នានា ការងារលើសម៉ោងដោយបង្ខំ ប្រាក់ខែទាប ជាដើម ។
- និយោជកត្រូវអនុវត្តអោយបានត្រឹមត្រូវទៅតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តន៍លក្ខខណ្ឌនៃការជួលកម្មករ/និយោជិតមកបំរើការងារ ។ ជៀសវាងការដាក់កម្មករ/និយោជិត ឱ្យស្ថិតនៅក្នុងស្ថានភាពសាកល្បងការងារក្នុងរយៈពេលយូរ ក្នុងគោលបំណងមិនឱ្យពួកគេបានទទួលប្រាក់ឈ្នួលពេញលេញ មិនបានទទួលប្រាក់កំរៃផ្សេងៗ រឺផ្លាស់ប្តូរកម្មករ/និយោជិតដែលស្ថិតនៅក្នុងស្ថានភាពសាកល្បងការងារ ដោយគ្មានហេតុផលច្បាស់លាស់ ។
- កម្មករ/និយោជិតមានតំណាងនានាដែលបានបោះឆ្នោតជ្រើសរើសដោយខ្លួនឯងនៅក្នុងតំបន់ឧស្សាហកម្ម ។ កម្មករ/និយោជិតគួរតែត្រូវបានអនុញ្ញាតិផងដែរដើម្បីបង្កើតសហជីព និងសមាគមនានា ស្របទៅតាមសិទ្ធិ និងតំរូវការរបស់ពួកគេ ។
- តំបន់ឧស្សាហកម្ម គួរតែត្រូវបានគ្រប់គ្រងនៅក្រោមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា និងដោយអនុសញ្ញាអន្តរជាតិនានាស្តីពីការងារ ហើយក្រឹត្យនិងអនុក្រឹត្យនានា គួរតែអនុវត្តស្របតាមច្បាប់នេះ ។
- នៅក្រោមច្បាប់នេះ អង្គការជាតិនិងអន្តរជាតិ និងអ្នកដឹកនាំសហជីពនានា នឹងត្រូវទទួលបាននូវសិទ្ធិ ដើម្បីត្រួតពិនិត្យដោយសេរី និងធ្វើអធិការកិច្ចទៅលើស្ថានភាពការងាររបស់រោងចក្រដោយគ្មានការជ្រៀតជ្រែក ។
- បញ្ហានានាដូចជាបរិស្ថាន ទំនាស់ដីធ្លី និងការតាំងទីលំនៅជាថ្មីនៃអ្នកកាន់កាប់ពីមុន នឹងត្រូវធ្វើការពិចារណា នៅពេលមានការបង្កើតតំបន់ឧស្សាហកម្ម ។
- មិនគួរយកដីធ្លីដោយបង្ខំ ឬដោយអំពើឃោរឃៅចំពោះប្រជាពលរដ្ឋក្រីក្រ ដើម្បីសាងសង់តំបន់ឧស្សាហកម្មឡើយ ឧទាហរណ៏ ការទាមទារថាម្ចាស់ដីគ្មានបណ្ណ័កម្មសិទ្ធិកាន់កាប់ ឬថាពួកគេកំពុងកាន់កាប់ដីជាកម្មសិទ្ធិសាធារណៈ ។
- តំបន់ឧស្សាហកម្មទាំងអស់ដែលបានបង្កើតឡើង ត្រូវតែគោរពតាមប្លង់មេនៃតំបន់ឧស្សាហកម្ម និងច្បាប់ស៊ីវិល ព្រមទាំងច្បាប់បរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។
- កម្មករ/និយោជិត ត្រូវបានទទួលបាននូវវគ្គបណ្តុះបណ្តាលសមរម្យ ដែលនឹងត្រូវបានគាំទ្រដោយម្ចាស់ឧស្សាហកម្ម អង្គការជាតិ និងអន្តរជាតិ និងគាំទ្រដោយក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវៈនីតិសម្បទា ។
- តំបន់ឧស្សាហកម្មទាំងអស់ ត្រូវតែស្ថិតនៅជិតអាកាសយានដ្ឋាន/កំពង់ផែ តាមតែអាចធ្វើបាន បើពុំដូច្នោះទេ មិនគួអនុញ្ញាតិឱ្យសាងសង់ឡើយ ។

- ស្តង់ដារការងារ និងច្បាប់ស្តីពីទំនាក់ទំនងទាំងអស់ មិនត្រូវព្យួរ ឬបន្ធូរបន្ថយ ទោះតាមរូបភាពណាក៏ដោយ នៅក្នុងតំបន់ឧស្សាហកម្មឡើយ ។
- ការិយាល័យអធិការកិច្ចនៃក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវៈនីតិសម្បទា ត្រូវបានបង្កើតឡើង នៅក្នុងតំបន់ឧស្សាហកមនីមួយៗ ដើម្បីធានាថាច្បាប់ការងារត្រូវបានគេប្រតិបត្តិយ៉ាងត្រឹមត្រូវ ។
- រដ្ឋាភិបាលជាតិ គួរតែគ្រប់គ្រងនិងត្រួតពិនិត្យអោយបានពេញលេញ លើប្រតិបត្តិការនៃតំបន់ឧស្សាហកម្ម ជាជាងទុកសមត្ថកិច្ចនេះអោយសាខានៅមូលដ្ឋាន។
- កម្មករ/និយោជិតដែលកំពុងបំរើការងារនៅក្នុងតំបន់ឧស្សាហកម្មគប្បីទទួលបានពត៌មានពីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវៈនីតិសម្បទា ដើម្បីពង្រឹងសិទ្ធិអំណាចរបស់ពួកគេ និងដើម្បីធានាឱ្យ ពួកគេទទួលបាននូវការពារខ្លួនទល់នឹងនិយោជកដែលពោរពេញទៅដោយការគាបសង្កត់ ។
- ទោសទណ្ឌដ៏ធ្ងន់ធ្ងរនឹងត្រូវដាក់ទៅលើនិយោជកដែលរារាំងឬជ្រៀតជ្រែកការអនុវត្តន៍សិទ្ធិរបស់កម្មករ/និយោជិត ក្នុងការបង្កើតសហជីព ការតវ៉ារួមគ្នា និងសកម្មភាពដែលពាក់ពន្ធ័ ដូចជាសិទ្ធិធ្វើកូដកម្មជាដើម ។
- រដ្ឋាភិបាលជាតិ គួរតែសាងសង់ផ្ទះ/សយនដ្ឋាន ដែលមានអនាម័យគ្រប់គ្រាន់ និងលក្ខខណ្ឌរស់នៅគាប់ប្រសើរ ជុំវិញតំបន់ឧស្សាហកម្ម សំរាប់កម្មករ/និយោជិត ដែលមានប្រភពចេញពីខេត្តឆ្ងាយៗ ។
- រដ្ឋាភិបាលជាតិ ត្រូវសាងសង់មន្ទីរពេទ្យ ឬមជ្ឈមណ្ឌលសុខាភិបាលនៅក្នុងតំបន់ឧស្សាហកម្ម ។
- រដ្ឋាភិបាលជាតិបង្កើតបណ្តាញសន្តិសុខសង្គមមួយសំរាប់កម្មករ/និយោជិតក្នុងតំបន់ឧស្សាហកម្មទាំងអស់។

ចំពោះពត៌មានបន្ថែមទាក់ទិននឹងបញ្ហានានាដែលលើកនៅក្នុងអត្ថបទនេះ, សូមមេត្តាទាក់ទង លោក ញ៉ែក សារិន នាយកប្រតិបត្តិនៃអង្គការ STAR កម្ពុជា លេខទូរសព្ទ័ (៨៥៥) ២៣ ២១១ ៦១២ , (៨៥៥) ១១ ៧២៥ ៨៧៣ និង អ៊ីម៉េល: star@forum.org.kh; sarin@orum.org.kh ; starldp@forum.org.kh

កំណែទំរង់ដីធ្លី

(i) សេចក្តីផ្តើម

អស់រយៈពេលជាងពីរឆ្នាំមកហើយ បន្ទាប់ពីច្បាប់ភូមិបាលបានចូលជាធរមាន កាលពីថ្ងៃទី ៣០ សីហា ឆ្នាំ ២០០១ ។ ក្នុងរយៈពេលនេះ រាជរដ្ឋាភិបាល ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានផ្តោតយកចិត្តទុកដាក់លើការរៀបចំរចនាសម្ព័ន្ធស្ថាប័ន ការពង្រឹងសមត្ថភាពដល់បុគ្គលិកជំនាញ ការរៀបចំគោលនយោបាយលិខិតបទដ្ឋានគតិយុត្តិនានា និងការចាប់ផ្តើមអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដែលនេះចាត់ទុកថាជាផ្នែកមួយក្នុងការអនុវត្តន៍នីច្បាប់ភូមិបាល ក្រោមជំនួយប្រាក់កម្ចីពីធនាគារពិភពលោក និងជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលអាល្លឺម៉ង់ និងរដ្ឋាភិបាលនៃប្រទេសហ្វាំងឡង់ ។

ក្នុងពេលមួយឆ្នាំចុងក្រោយ រដ្ឋាភិបាល បានបំពេញនូវភារកិច្ចរបស់ខ្លួនយ៉ាងសំខាន់មួយ គឺការអនុម័តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច និងក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃគោលនយោបាយដីធ្លី ដូចដែលបានសន្យាក្នុងកិច្ចប្រជុំប្រទេសផ្តល់ជំនួយឆ្នាំ ២០០២ ។ ក្រុមសង្គមស៊ីវិល អង្គការជាតិ អង្គការអន្តរជាតិ ជាពិសេសគ្រួសារគ្មានដីធ្លីមានការរីករាយយ៉ាងខ្លាំង និងស្វាគមន្ទូវសមិទ្ធិផលនេះ ទោះដំណើរការនៃការពិគ្រោះយោបល់ពុំសូវសកម្មក៏ដោយ ។

ទន្ទឹមនឹងនេះនៅមានលិខិតបទដ្ឋានគតិយុត្តិចាំបាច់ ដែលជាអាទិភាពមួយចំនួនទៀត ដើម្បីអនុវត្តច្បាប់ភូមិបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងគោលបំណងលើកស្ទួយកំរិតជីវភាព និងការពារកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋក្រីក្រ ដូចជាអនុក្រឹត្យស្តីពី ការកាត់បន្ថយសម្បទានសេដ្ឋកិច្ច ការគ្រប់គ្រងទ្រព្យរដ្ឋ និងច្បាប់ស្តីការដកហូតកម្មសិទ្ធិស្របច្បាប់ ។

បញ្ហានៅមានជាបន្តទាក់ទងនឹងដីដែលមានទីតាំងនៅជិត ងាយស្រួលបង្កបង្កើនផលសំរាប់ពលរដ្ឋគ្មានដី។ ដីនេះត្រូវបានរក្សាទុកដោយអ្នកមិនធ្វើផលិតកម្ម គឺរក្សាទុកសំរាប់លក់តំលើងថ្លៃ ឯអ្នកដែលត្រូវការដីដើម្បីផលិតភោគផលចិញ្ចឹមក្រពះបែរជាគ្មានដីសំរាប់បង្កបង្កើនផលទៅវិញ។ បាតុភាពរំលោភយកដីធ្លីពីសំណាក់អ្នកមានអំណាចទៅលើប្រជាពលរដ្ឋនៅតែមាន ដោយនៅមិនទាន់បានដោះស្រាយ។ នៅមានកិច្ចការជាបន្ទាន់ជាច្រើនទៀត ដែលតម្រូវឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ ។ រដ្ឋាភិបាលហាក់ដូចជានៅស្ទាក់ស្ទើរខាងឆន្ទៈនយោបាយ ប្រឈមមុខទៅក្នុងចំណាត់ការទាំងនេះ ទោះបីមានច្បាប់ខ្លះហើយក៏ដោយ ។

(ii) បញ្ហាគន្លឹះ

រដ្ឋបាលដីធ្លី: ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានចាប់ផ្តើមនៅក្នុងបណ្តាលខេត្តមួយចំនួន ដោយគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ក្នុងគោលបំណងដើម្បីលើកស្ទួយក៏រិតជីវភាពប្រជាជន ដោយផ្តល់នូវសុវត្ថិភាព ក្នុងការកាន់កាប់ដីធ្លី តាមរយៈការចេញប័ណ្ណកម្មសិទ្ធិក្នុងលក្ខណៈជាប្រព័ន្ធ ដែលមានអំណាចខាងផ្លូវច្បាប់ ។ ប្រសិនបើដំណើរការនៃការចុះបញ្ជីនេះពុំបានបើកទូលំទូលាយ និងមិនបង្កលក្ខណៈងាយស្រួលដល់ប្រជាជនទេ នេះនឹងរឹតតែធ្វើឱ្យក៏រិតជីវភាពរបស់ពួកគាត់ជួបប្រទះនូវការលំបាកថែមទៀត ដោយទីបំផុតពួកគាត់នឹងក្លាយជាអ្នកគ្មានដីធ្លី ដែលផ្ទុយទៅនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងផ្ទុយនឹងគោលនយោបាយបែងចែកដីធ្លីដែលរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ ។ ប្រជាជនកម្ពុជាភាគច្រើនជាអ្នកមិនចេះអក្សរ ពិបាកស្វែងយល់អំពីដំណើរការ និងនីតិវិធីនៃការចុះបញ្ជីដីធ្លី ហើយជាពិសេសគឺសិទ្ធិនានាដែលគាត់មានលើអចលនវត្ថុនោះ ។ កន្លងមក នៅមានការឆក់ល្វែងតាមតំបន់ខ្លះ ដែលជាហេតុបណ្តាលឱ្យជនឱកាសនិយម ឆ្លៀតទាញយកផលចំណេញ ពីកម្មវិធីចុះបញ្ជីដីធ្លី ជាលក្ខណៈជាប្រព័ន្ធនេះ។ ពេលនោះហើយ ដែលម្ចាស់ដីក្លាយជាអ្នកគ្មានដី តែអ្នកមានអំណាចមានដីយ៉ាងច្រើន ហើយកាន់តែមានដីស្របច្បាប់បន្ថែមទៀត (អនុក្រឹត្យនេះបានទុករយៈពេលមួយខែ នៃការបិតផ្សាយជាសាធារណៈ អំពីប្លង់សុរិយោដី និង បញ្ជីឈ្មោះម្ចាស់ដី ប្រសិនបើអ្នកកាន់កាប់ដីណាមួយមិនបានទាមទារ ឬប្តឹងតវ៉ាក្នុងរយៈពេលនេះទេ គាត់នឹងលែងបានដីរបស់គាត់ជារៀងរហូត)។

វិវាទដីធ្លី: ជម្លោះដីធ្លីនៅតែជាបញ្ហាក្តៅគគុក ដែលតែងតែកើតឡើងរវាងប្រជាជនច្រើនគ្រួសារ ជាមួយអ្នកមានទឹកប្រាក់ ឬជាមួយអ្នកមានអំណាចទៅលើដីភោគៈ ។ ភាគីអ្នកមានទឹកប្រាក់ ឬ អំណាច ភាគច្រើនជាអ្នកដែលមានឯកសារផ្លូវច្បាប់ជាអំណះអំណាង ។ ពេលបណ្តឹងដល់ដៃតុលាការ គេសង្កេតឃើញថា ប្រជាពលរដ្ឋក្រីក្រ ដែលគ្មានឯកសារ ភាគច្រើនជាអ្នកដែលត្រូវចាញ់ក្តី ។ បញ្ហានេះគឺជាឧបសគ្គរាំងដល់ការអភិវឌ្ឍន៍ និងស្ថេរភាពផ្លូវចិត្តរបស់ប្រជាជនក្រីក្រជាពិសេស ស្ត្រីដែលជាមេគ្រួសារ ។ ក្នុងការឆ្លើយតបទៅនឹងបញ្ហាដ៏លំបាកនេះ រដ្ឋាភិបាលបានបង្កើតគណៈកម្មការដោះស្រាយវិវាទដីធ្លី នៅថ្ងៃទី ១០ មិថុនា ១៩៩៩ ក្នុងគោលបំណង ដើម្បីដោះស្រាយរាល់វិវាទដីធ្លីដែលបានកើតឡើងជាជាងការបណ្តោយឱ្យមានរឿងក្តីប្តឹងតវ៉ាទៅតុលាការផ្ទាល់ ។ ប៉ុន្តែយន្តការដោះស្រាយវិវាទ ឆ្នាំ ១៩៩៩ នោះ គ្មានប្រសិទ្ធភាពឡើយ ដោយហេតុថា គេពិបាកនឹងប៉ះពាល់ដល់ភាគីម្ខាងដែលជាអ្នកមានអំណាច។ ច្បាប់ភូមិបាល ឆ្នាំ ២០០១ បានបង្កើតយន្តការថ្មីមួយទៀត ហៅថាគណៈកម្មការសុរិយោដី (អនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី ៣១ ឧសភា ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈកម្មការសុរិយោដី) មកជំនួសយន្តការចាស់ ។ ប្រជាជនរងគ្រោះ

មានចិត្តត្រេកអរចំពោះច្បាប់ភូមិបាល ឆ្នាំ ២០០១ ជាពិសេស គណៈកម្មការសុរិយោដីនេះតែម្តង ដោយក្តីសង្ឃឹមថា វិវាទដីធ្លីរបស់ខ្លួននឹងត្រូវបានដោះស្រាយដោយយុត្តិធម៌ជាក់ជាពុំខាន ។ក្រោមជំនួយបច្ចេកទេសពីម្ចាស់ជំនួយគណៈកម្មការសុរិយោដីដែលទើបតែចាប់ផ្តើមដំណើរការរបស់ខ្លួន បែរជាបកស្រាយថាគណៈកម្មការនេះ ដោះស្រាយតែវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជី (មុនច្បាប់ភូមិបាល ២០០១) ឯវិវាទដែលបានចុះបញ្ជីត្រូវបញ្ជូនទៅតុលាការ ។ ការបកស្រាយនេះហាក់ដូចជាផ្ទុយទៅនឹងស្មារតីនៃច្បាប់ដែលបានកំណត់ឱ្យ គណៈកម្មការសុរិយោដី "ត្រូវធ្វើសេចក្តីសំរេចលើបដិវាទកម្មចំពោះវិវាទរវាងភោគីចំពោះអចលនវត្ថុមួយ" (មាត្រា៤៧ នៃច្បាប់ ភូមិបាល ២០០១)។ ការបង្កើតគណៈកម្មការសុរិយោដីនេះ គឺដើម្បីដោះស្រាយវិវាទ ជាជាងការបណ្តោយឱ្យប្តឹងទៅតុលាការដោយផ្ទាល់តែម្តង ។ ប្រសិនបើការបកស្រាយនេះមិនបានធ្វើការផ្លាស់ប្តូរទេ ការបង្កើតគណៈកម្មការសុរិយោដីនេះ ពិតជាមិនអាចដោះស្រាយវិវាទដីធ្លីធំៗដែលបាន និងកំពុងកើតឡើងបានឡើយ ព្រោះករណីវិវាទភាគច្រើនភាគីម្ខាងដែលមានអំណាចសុទ្ធតែមានឯកសារជាសំអាង ឯក្រុមគ្រួសារក្រីក្រវិញគ្មានឯកសារអ្វីបញ្ជាក់ឡើយ ដោយពួកគាត់យល់ថាដីធ្លី ដែលគាត់កំពុងរស់នៅគឺជាដីកម្មសិទ្ធិរបស់ពួកគាត់ ។

<u>ការបែងចែកដីធ្លី:</u> ពុំទាន់មានកិច្ចការជាក់លាក់ណាមួយ នៃគំរោងការបែងចែកដីធ្លីបានអនុវត្តជាក់ស្តែងនៅឡើយទេ ប៉ុន្តែយើងសូមស្វាគមចំពោះការអនុម័ត អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច និងក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃគោលនយោបាយដីធ្លី ។ របាយការណ៍ពី CDRI ខែ ធ្នូ ឆ្នាំ ២០០២ បង្ហាញថា អ្នកគ្មានដីកសិកម្មបានកើនដល់ ២០ ភាគរយ ហើយ ២៥ ភាគរយទៀតមានដីតិចជាង ០,៥ ហិកតា ជាសរុប អ្នកគ្មានដីធ្លី និងអ្នកដែលជិតក្លាយជាអ្នកគ្មានដីធ្លីមានចំនួន ៤៥ ភាគរយ ទន្ទឹមនឹងនោះ ១០ ភាគរយ មានដី ៤០ ភាគរយ នៃផ្ទៃដីទាំងមូល ។ តម្រូវការដីធ្លីចេះតែកើនឡើងជារៀងរាល់ឆ្នាំ ឯការផ្តត់ផ្គង់ដីធ្លីត្រូវបានលើកយកមកពិភាក្សា នឹងនៅតែលើក្រដាស ប៉ុន្តែចំណាត់ការជាក់ស្តែង ពុំទាន់បានកើតឡើងនៅឡើយទេ ។ ថ្វីត្បិតតែច្បាប់ភូមិបាល ២០០១ បានហាមការចាប់ដីធ្លី ប៉ុន្តែយើងនៅតែសង្កេតឃើញ មានការចាប់ដីជាហូរហែរពីសំណាក់អ្នកមានលទ្ធភាព ។ ជាទូទៅ ដីមានជីជាតិ និងមានសក្តានុពលផ្នែកកសិកម្ម ហើយដែលអាចឱ្យអ្នកគ្មានដីធ្លីបង្កើនផលបាន ភាគច្រើនសុទ្ធតែជារបស់អ្នកមានអំណាចទុកទំនេរចោល។ សម្បទានដីសេដ្ឋកិច្ច ដែលមិនបានធ្វើអាជីវកម្ម-មាត្រា ៦២ នៃច្បាប់ ២០០១ និង ដីទំនេរដែលមិនបានប្រើប្រាស់ ដីទំនេរដែលមិនបានបង់ពន្ធក្រោយថ្ងៃទី ៣០ កញ្ញា ២០០០ ត្រូវបានចាត់ទុកជាដីដែលគ្មានម្ចាស់ (សេចក្តីជូនដំណឹង លេខ ០១០ សជណ.សហវ.៣ដ ចុះថ្ងៃទី ២ មិថុនា ២០០០ ស្តីពី វិធានការចំពោះការគ្រប់គ្រង និងប្រមូលពន្ធលើដីមិនបានប្រើប្រាស់) គឺជាផ្នែកនៃដីទំនេរធំមួយសំរាប់កម្មវិធីសម្បទានសង្គមកិច្ច ។

(iii) អនុសាសន៍

សំរាប់រដ្ឋាភិបាល

- ឆន្ទៈនយោបាយពិតប្រាកដ គឺជាកត្តាសំខាន់បំផុតមិនអាចខ្វះបាន ដើម្បីដោះស្រាយបញ្ហានានាខាងលើ
- ក្នុងរយៈពេលនៃការបិតផ្សាយនូវឯកសារនៃការវិនិច្ឆ័យ សូមឱ្យមានការបណ្តុះបណ្តាល ឬការពន្យល់ឱ្យបានច្បាស់លាស់ និងការជួយសំរួលផ្សេងៗទៀតរបស់គណៈកម្មការរដ្ឋបាល ដើម្បីធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋដែលនៅក្នុងតំបន់ត្រូវចុះបញ្ជីតាមលក្ខណៈជាប្រព័ន្ធ អាចការពារ ឬទាមទារកម្មសិទ្ធិរបស់ពួកគេ និងជៀសផុតពីការទាញយកចំណេញណាមួយ ពីសំណាក់ជនឱកាសនិយមតាមមធ្យោបាយណាមួយ
- វិវាទដីធ្លីសព្វថ្ងៃ កើតឡើងក្នុងរវាងឆ្នាំ ១៩៨៩ ដល់ ២០០១ ដែលភាគីម្ខាងភាគច្រើនជាអ្នកមានអំណាច ឬអ្នកមានទឹកប្រាក់ ។ ដើម្បីដោះស្រាយវិបត្តិនេះ លុះត្រាវិវាទនេះស្ថិតក្រោមសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីទោះភាគីណាមួយមានប័ណ្ណកម្មសិទ្ធិដីធ្លី ឬគ្មានក៏ដោយ (មាត្រា ៤៧ នៃច្បាប់ភូមិបាល ២០០១ បានកំណត់ឱ្យគណៈកម្មការសុរិយោដី មានអំណាយដោះស្រាយវិវាទរវាងភោគីចំពោះអចលនវត្ថុមួយ)។
- គួរចាត់វិធានការជាបន្ទាន់ ក្នុងការប្រមូលដីទំនេរមិនបានប្រើប្រាស់ និងដីសម្បទានសេដ្ឋកិច្ចដែលមិនបានធ្វើអាជីវកម្មដើម្បីអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចឱ្យមានប្រសិទ្ធភាព ។
- គំរោងសាកល្បងនានាស្តីពីសម្បទានសង្គមកិច្ចលើដីទំនេរដែលមិនមែនជាដីព្រៃត្រូវតែចាប់ផ្តើមឱ្យបានឆាប់។

អ្នកផ្តល់ជំនួយ

- ជំហរច្បាស់លាស់របស់ម្ចាស់ជំនួយ និងទីប្រឹក្សាបច្ចេកទេសមួយចំនួន ក្នុងរឿងបច្ចេកគួរត្រូវបានពង្រឹងបន្ថែមទៀតដើម្បីឱ្យបានជាការរួមចំណែកយ៉ាងពិតប្រាកដនៃការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

អង្គការក្រៅរដ្ឋាភិបាល

- អង្គការក្រៅរដ្ឋាភិបាលនានា ជាពិសេសអង្គការអភិវឌ្ឍន៍គួរចូលរួមអនុវត្តគោលនយោបាយស្តីពីការបែងចែកដីធ្លីដោយផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងអនុក្រឹត្យស្តីពីសម្បទានសង្គមកិច្ច អោយបានសកម្មក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ចំពោះពតិមានបន្ថែមទាក់ទិននឹងបញ្ហានានាដែលលើកនៅក្នុងអត្ថបទនេះសូមមេត្តាទាក់ទង Oxfam GB
លេខទូរសព្ទ័ (៨៥៥) ២៣ ៧២០ ០៣៦ និង អ៊ីម៉ែល: svannsin@oxfam.org.kh

ការរុះរើតាំងទីលំនៅសារជាថ្មី

(i) សេចក្តីផ្តើម

អភិវឌ្ឍន៍លើច្រើនវិស័យបាននិងកំពុងអនុវត្ត ពិសេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ជារូបវ័ន្ត ដោយផ្នែកលើមូលនិធិរបស់រដ្ឋាភិបាលកម្ពុជាផ្ទាល់ និងផ្នែកលើឥណទានពីធនាគារអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគី ទីភ្នាក់ងារជំនួយ និងមូលនិធិឯកជនដទៃទៀតជាច្រើន។ ទន្ទឹមនឹងអត្ថប្រយោជន៍ជាច្រើនដែលគំរោងអភិវឌ្ឍន៍ទាំងនេះ បាននាំមកដល់សាធារណៈជនទូទៅ វាក៏ផ្តល់ផលប៉ះពាល់អវិជ្ជមានជាច្រើនផងដែរ ដូចជា គំរោងខ្លះតំរូវឱ្យប្រជាជនជាច្រើនគ្រួសារផ្លាស់ទីលំនៅជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។

យោងតាមការស្រាវជ្រាវដ៏ធំមួយបានបង្ហាញឱ្យឃើញថា មានប្រជាជនប្រមាណ ៣.១៩៨ គ្រួសារ រងផលប៉ះពាល់ដោយសារការតបណ្តាញអគ្គិសនី ពីព្រំដែនវៀតណាម-ខេត្តតាកែវ។ ហើយក៏មានចំនួនប្រជាជនជាច្រើនពាន់គ្រួសារទៀតដែលរងផលប៉ះពាល់ដោយសារគំរោងស្តារឡើងវិញ នូវផ្លូវជាតិលេខ ១ ផ្លូវជាតិលេខ ២ ផ្លូវជាតិលេខ ៤ ផ្លូវជាតិលេខ ៥ ផ្លូវជាតិលេខ ៦ ផ្លូវជាតិលេខ ៧ ផ្លូវជាតិលេខ ៥៦ ផ្លូវជាតិលេខ ៦៨ និងការជួសជុលផ្លូវថ្នល់ ជាច្រើនទៀតនៅក្នុងទីក្រុង ព្រមទាំងគំរោងអភិវឌ្ឍន៍ដទៃទៀតដែលពាក់ព័ន្ធនឹងការរុះរើតាំងទីលំនៅសារជាថ្មីរបស់ប្រជាជន ដូចជាគំរោងស្តារប្រឡាយទឹកកខ្វក់ គំរោងទំនប់ការពារទឹកជំនន់ គំរោងប្រឡាយទឹកស្រោចស្រោពជាដើម។

យោងតាមអង្កេតរបស់អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការបំរើផលប្រយោជន៍សហគមន៍ក្រីក្រក្នុងទីក្រុង បានរកឃើញថា មានផ្ទះប្រជាពលរដ្ឋក្រីក្រចំនួន ៦២.២៤៩ ខ្នង នៅក្នុងលំនៅដ្ឋានចំនួន ៥៦៩ កន្លែងក្នុងទីក្រុង និងជាយក្រុងទីក្រុងភ្នំពេញ។ ភាគច្រើននៃពលរដ្ឋក្រីក្រនៅទីក្រុង ត្រូវបានបង្ខំអោយរុះរើលំនៅដ្ឋានចេញ ដោយសារគំរោងការអភិវឌ្ឍន៍ និងវិនិយោគនានា ហើយអ្នកដែលប្រឈមនឹងគ្រោះថ្នាក់ជាងគេ គឺអ្នកដែលរស់នៅលើដីសាធារណៈ។

ក្នុងរយៈកាលប៉ុន្មានឆ្នាំកន្លងមកនេះ ការបណ្តេញចេញ និងការរុះរើតាំងទីលំនៅសារជាថ្មី បានកើនឡើងយ៉ាងខ្លាំងក្នុងកំរិតមួយដែលបានជំរុញអោយប្រជាជនជាច្រើន ធ្លាក់ទៅក្នុងខ្នោះឃ្នាងនៃភាពក្រីក្រកាន់តែខ្លាំង ដោយសារការមិនបានទទួលសំណងទូទាត់ និងការទូទាត់សំណងមិនស្មើនឹងតំលៃនៃការបាត់បង់ដីធ្លីលំនៅដ្ឋានរបស់ពួកគាត់ ។ ម្យ៉ាងវិញទៀត ពួកគាត់ត្រូវចំណាយថវិកាអស់ជាច្រើន សំរាប់ការតាំងទីលំនៅសារឡើងវិញ ព្រមទាំងចំណាយចាំបាច់ផ្សេងៗទៀតដូចជា ការដឹកជញ្ជូន ការធ្វើដំណើរ និងការចំណាយសំរាប់សេវាកម្មសាធារណៈផ្សេងៗទៅកាន់ ទីតាំងថ្មី។

(ii) បញ្ហាជាគន្លឹះ

គំរោងអភិវឌ្ឍន៍នានាដែលតំរូវឱ្យមានការផ្លាស់ប្តូរទីលំនៅនោះ ត្រូវបានអនុវត្តមិនស្របតាមគោលការណ៍ និងមិនស្របតាមនីតិវិធីច្បាប់ច្បាស់លាស់ទេ ជាហេតុបណ្តាលឱ្យប្រជាជនដែលទទួលរងផលប៉ះពាល់ទាំងនោះ តែងតែត្រូវបានអាជ្ញាធរមូលដ្ឋាន បង្ខំឱ្យចាកចេញពីកន្លែងរបស់ខ្លួន ដោយគ្មានសំណង ឬផ្តល់ជំនួយសមស្រប ។

ជនរងគ្រោះទាំងនោះមិនត្រឹមតែត្រូវបានបង្ខំឱ្យចាកចេញពីលំនៅដ្ឋានរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវប្រឈមមុខនឹងការបាត់បង់ដ៏ធ្ងន់ធ្ងរជាបន្តបន្ទាប់ដូចជា:

- មិនបានទទួលសិទ្ធិតាំងទីលំនៅសារជាថ្មី
- ការខាតបង់ពេលវេលាដើម្បីរៀបចំស្ថានភាពរស់នៅជាថ្មីដែលបង្កើតឱ្យមានភាពក្រីក្រក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម ហើយជាពិសេសធ្វើឱ្យពលរដ្ឋក្រីក្រ កាន់តែក្រីក្រកាន់តែរងគ្រោះខ្លាំងឡើងបន្ថែមទៀត ។
- ការបាត់បង់មុខរបរ និងប្រាក់ចំណូលប្រចាំថ្ងៃ
- ប៉ះពាល់ដល់ការសិក្សារបស់កុមារ
- ប៉ះពាល់ដល់ទំនាក់ទំនងក្នុងសង្គម

កង្វះច្បាប់បានចោទជាបញ្ហាយ៉ាងធ្ងន់ធ្ងរ ដល់ការផ្លាស់ប្តូរទីលំនៅ ពោលគឺគោលនយោបាយនៃការរុះរើតាំងលំនៅសារជាថ្មី និងច្បាប់សំរាប់ការពារដល់ប្រជាជនដែលរងការប៉ះពាល់ដោយគំរោងអភិវឌ្ឍន៍ ដូចជា អនុក្រឹត្យស្តីពី "ការរុះរើតាំងទីលំនៅថ្មី " ។ ដូចគ្នានេះដែរ ការអនុវត្តន៍ច្បាប់ជាធរមាន ដូចជាច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល សន្ធិសញ្ញាសិទ្ធិសេដ្ឋកិច្ច-សង្គម ECOSOC ជាដើមនោះ មិនទាន់បានអនុវត្តត្រឹមត្រូវនៅឡើយទេ ។

(iii) អនុសាសន៍

អនុសាសន៍ទាក់ទងនឹងបញ្ហាការរុះរើតាំងទីលំនៅសារជាថ្មីក្នុងប្រទេសកម្ពុជា មានដូចខាងក្រោមនេះ:

- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែពន្លឿនការអនុម័ត "គោលនយោបាយថ្នាក់ជាតិ ស្តីពីការរុះរើតាំងទីលំនៅសារជាថ្មី " ដោយអនុម័តគោលនយោបាយនេះជាអនុក្រឹត្យ ហើយចេញជាលិខិតបទដ្ឋានច្បាប់បន្តបន្ទាប់ទៀតសំរាប់អនុវត្តលើគ្រប់គំរោងទាំងអស់ ព្រមជាមួយនឹងការពង្រឹងការអនុវត្តន៍ច្បាប់ដែលមានស្រាប់ ដើម្បីឱ្យមានតម្លាភាពដល់សំណងទូទាត់ និងគាំពារដល់ប្រជាជនដែលទទួលរងការប៉ះពាល់ ។

- រាជរដ្ឋាភិបាលគួរតែរៀបចំ និងអនុវត្តផែនការអំពីការប្រើប្រាស់ដីធ្លី និងការផ្លាស់ប្តូរទីលំនៅ។ ចំពោះប្រទេសកម្ពុជា ផែនការនេះគួរតែមានបញ្ចូលនូវចំនួនប្រជាជនជាក់ស្តែង ដែលទទួលរងការប៉ះពាល់ និងទំហំនៃការខាតបង់ ដោយយោងទៅលើគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ដូចជាការទូទាត់សំណងលើទ្រព្យសម្បត្តិ ការរុះរើទៅកាន់កន្លែងថ្មី ការស្តារទៅរកសភាពដើមវិញ ការចិញ្ចឹមជីវិតនិងការពារបរិស្ថាន ការទទួលខុសត្រូវលើការផ្តល់ពេលវេលារង់ចាំសំរាប់ទទួលបានដីថ្មី និងវិធានការនានាទាក់ទងនឹងការតាំងទីលំនៅសារជាថ្មី និងយន្តការពិគ្រោះយោបល់សមស្រប ចំពោះភាពមិនពេញចិត្តទាំងឡាយរបស់ប្រជាជនដែលទទួលរងការប៉ះពាល់ ។
- ត្រូវធ្វើការផ្សព្វផ្សាយពត៌មានពីគំរោងការអភិវឌ្ឍន៍នានា ទាក់ទងនឹងការរុះរើតាំងទីលំនៅសារជាថ្មីដល់ប្រជាជនរងផលប៉ះពាល់ និងអ្នកឯទៀតដែលមានការពាក់ព័ន្ធ ហើយប្រជាជនដែលរងផលប៉ះពាល់ទាំងនោះ គួរតែត្រូវបានផ្តល់ឱ្យនូវសិទ្ធិក្នុងការពិគ្រោះយោបល់ទៅលើគំរោងអភិវឌ្ឍន៍ និងជំរើសនានាទាក់ទងនឹងសំណងទូទាត់ និងការរុះរើតាំងទីលំនៅសារជាថ្មីរបស់ពួកគេ ។
- សាធារណជន និង ពលរដ្ឋរងគ្រោះ គប្បីបានទទួលសេចក្តីណែនាំជូនដំណឹងទាំងអស់ពីអង្គភាពអនុវត្តគំរោង ស្តីពីការចូលរួមរបស់សាធារណៈជន ចាប់តាំងពីការកសាងផែនការគំរោង រហូតដល់បញ្ចប់នៃគំរោង ។ រាល់នីតិវិធីទាំងអស់គប្បីបោះផ្សាយ ហើយពលរដ្ឋរងគ្រោះគប្បីបានទទួលពត៌មានអំពីកម្មវិធីសំណង ។
- រដ្ឋាភិបាលគួររៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈ *ជាមុន* ដើម្បីគាំទ្រតំរូវការជាមូលដ្ឋានរបស់ប្រជាជន ដូចជា ទឹក ភ្លើង ផ្លូវ សាលារៀន ទីផ្សារ និងមណ្ឌលសុខភាព ហើយក៏គួរតែ តាមដានសភាពប្រែប្រួលទាក់ទងជីវភាពរស់នៅ និងសុខុមាលភាពប្រជាពលរដ្ឋទាំងនោះ ។
- ដើម្បីកាត់បន្ថយនូវភាពក្រីក្រ និងការចំណាយលើការរៀបចំទាំងនេះ រដ្ឋាភិបាលគួរជៀសវាងការ រុះរើលំនៅដ្ឋានតាមដែលអាចធ្វើទៅបាន ។
- គួរតែបង្កើតកម្មវិធីផ្សេងៗ នៅតំបន់ដែលតាំងទីលំនៅសារជាថ្មី ដូចការបង្កើតមុខរបរ បណ្តុះបណ្តាលវិជ្ជាជីវៈ កសិកម្មខ្នាតតូច និងឥណទានខ្នាតតូច ដើម្បីបង្កើតប្រាក់ចំណូល ។
- ត្រូវបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសំរបសំរួលការធ្វើផែនការ និងការអនុវត្តន៍គំរោងតាំងទីលំនៅនានា ។ គ្រប់ស្ថាប័នទាំងនោះ ត្រូវសកម្មចូលរួម និងសំរបសំរួលគ្នា ដោយហេតុថា គណៈកម្មការនេះជាតួអង្គសំខាន់ក្នុងការអនុវត្តន៍គំរោង ។

- នៅក្នុងការអភិវឌ្ឍន៍ធនធានមនុស្សក្នុងរយៈពេលខ្លី រយៈមធ្យម ឬរយៈវែង ជាការចាំបាច់ណាស់ ដែលមន្ត្រីទាំងឡាយបានចូលរួម ដើម្បីបង្កើនសមត្ថភាពក្នុងផ្នែករុះរើតាំងទីលំនៅសារជាថ្មី។
- ប្រទេសផ្តល់ជំនួយ គួរតែសង្កត់ធ្ងន់ទៅលើតម្លាភាពនៃការអនុវត្តន៍ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលទៅលើបញ្ហារុះរើតាំងលំនៅ។ ម្ចាស់ជំនួយគួរតែមានតួនាទីសំខាន់ ជាអ្នកត្រួតពិនិត្យតាមដានខាងក្រៅ ទៅលើសកម្មភាពនានានៃគំរោងការងាររុះរើតាំងទីលំនៅ។

ចំពោះពតិមានបន្ថែមទាក់ទិននឹងបញ្ហានានាដែលលើកនៅក្នុងអត្ថបទនេះសូមមេត្តាទាក់ទងគណៈកម្មការប្រព្រឹត្តកម្មរុះរើតាំងទីលំនៅថ្មី C/O NGO Forum លេខទូរស័ព្ទ (៨៥៥) ២៣ ៩៨៦ ២៦៩ និង អ៊ីម៉ែល: leakhana@ngoforum.org.kh.

នីតិរដ្ឋ

(i) សេចក្តីផ្តើមៈ

ប្រជាជនកម្ពុជាបានអនុវត្តលទ្ធិប្រជាធិបតេយ្យ និង ករណីយកិច្ចជាពលរដ្ឋ ដោយបានបោះឆ្នោតជ្រើសរើសសភាជាតិកាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ កន្លងទៅនេះ ។ អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការផ្នែកបោះឆ្នោត និងផ្នែកសិទ្ធិមនុស្ស បានគាំទ្រដំណើរការបោះឆ្នោតនេះ តាមរយៈការផ្តល់ការអប់រំដល់ប្រជាពលរដ្ឋ និងការត្រួតពិនិត្យបោះឆ្នោត។ ថ្វីត្បិតតែមានការព្រួយបារម្ភ អំពីការបំភិតបំភ័យ និងភាពមិនប្រក្រតីក៏ដោយ ក៏អង្គការភាគច្រើនសន្និដ្ឋានថា ការអនុវត្តន៍បច្ចេកទេសនៃការបោះឆ្នោតមានភាពប្រសើរឡើងជាងការបោះឆ្នោតកាលពីពេលមុន ៗ ។

(ii) បញ្ហាជាគន្លឹះ

អង្គការក្រៅរដ្ឋាភិបាលសូមរំលឹកដល់អ្នកនយោបាយ អំពីភារកិច្ចរបស់ខ្លួនចំពោះប្រជាពលរដ្ឋ ដោយគោរពតាមការសន្យាដែលខ្លួនបានធ្វើក្នុងអំឡុងពេលបោះឆ្នោត និង ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីចំណុចសំខាន់ៗទាំងនេះ ជាលក្ខ័ណ្ឌសំរាប់បង្កើតរដ្ឋាភិបាលថ្មី ។

ជាពិសេស អង្គការក្រៅរដ្ឋាភិបាលសូមលើកឡើង ពីបញ្ហាសំខាន់ៗមួយចំនួន ដែលចាំបាច់ត្រូវចាត់ វិធានការណ៍ ដើម្បីកម្ពុជាអាចដោះស្រាយបាននូវបញ្ហាភាពក្រីក្រ និងអំពើពុករលួយ និង បង្កើតប្រព័ន្ធមួយរឹងមាំ ដែលធានាដល់ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។

<u>ការកែទំរង់ស្ថាប័ន</u>

ស្ថាប័នសំខាន់ៗ ដែលមានស្រាប់នាពេលបច្ចុប្បន្ន គួរតែត្រូវកែទំរង់អោយបានស៊ីជំរៅ រួមមាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មការស៊ុរិយោដី និង គណៈកម្មការសវនកម្ម ។ មុខតំណែងរបស់គេនៅក្នុងប្រព័ន្ធនេះទាំងមូល ចាំបាច់ត្រូវចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដើម្បីធានាថាពួកគេត្រូវបានទទួលការការពារ និងផ្តល់ជូននូវអានុភាពច្បាប់ និងស្ថេរភាព ។ ជាគោលការណ៍ គេត្រូវតែមានភាពឯករាជ្យ និងមិនប្រកាន់គណៈបក្សនយោបាយ ដោយគិតទាំងប្រភពនិងសមាជិកភាព ដែលចាំបាច់ត្រូវបង្កើត គណៈកម្មាធិការជ្រើសរើស ដើម្បីតែងតាំងសមាជិកនៃស្ថាប័នទាំងនេះ ។ គេត្រូវតែបំពេញតួនាទីប្រកបដោយសមត្ថភាព និងគួរអោយជឿទុកចិត្តបាន ដោយត្រូវពង្រឹងធនធានមនុស្សប្រកបដោយគុណភាព បុគ្គលិកមានជំនាញ និងមានធនធានហិរញ្ញវត្ថុ

គ្រប់គ្រាន់ ។ ស្ថាប័នទាំងនេះ ចាំបាច់ត្រូវត្រួតពិនិត្យដោយយន្តការផ្សេងៗ ដែលបង្កើតឡើងនៅក្នុងរដ្ឋសភា និងព្រឹទ្ធសភា តាមវិធីមួយដែលមានលក្ខណៈដូចគ្នានឹង គណៈកម្មការទាំង ៩ របស់រដ្ឋសភា និងព្រឹទ្ធសភា ។

ស្ថាប័ន និង ច្បាប់ដែលមិនទាន់មាន

គណៈកម្មការនានា គួរតែត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ហើយគួរតែត្រូវបានបង្កើតអោយបានឆាប់តាមដែលអាចធ្វើទៅបាន។ គណៈកម្មការទាំងនេះ យ៉ាងហោចណាស់ក៏ត្រូវរួមបញ្ចូលនូវ គណៈកម្មការប្រឆាំងអំពើពុករលួយ និង គណៈកម្មការសិទ្ធិមនុស្សជាតិ ដែលមានលក្ខណៈដូចគ្នានឹងគណៈកម្មការដទៃទៀត ហើយគួរមានឯករាជ្យភាព មិនប្រកាន់គណៈបក្សនយោបាយ មានសមត្ថភាព និងគួរអោយជឿទុកចិត្តបាន ។

រាជរដ្ឋាភិបាលថ្មី នឹងដោះស្រាយអំពីតំរូវការសំរាប់បង្កើតច្បាប់ថ្មីៗ ដើម្បីធានាថា ប្រព័ន្ធច្បាប់នោះ អាចដោះស្រាយបញ្ហាធ្ងន់ធ្ងរដែលកំពុងកើតមាន។ ច្បាប់ថ្មីៗទាំងនេះ ចាំបាច់ត្រូវបញ្ចូលច្បាប់អាទិភាពនានា រួមមាន ក្រមព្រហ្មទណ្ឌថ្មី ក្រមរដ្ឋប្បវេណី ច្បាប់នីតិវិធីព្រហ្មទណ្ឌ ។ រដ្ឋាភិបាលក៏ចាំបាច់ត្រូវបង្កើតច្បាប់ ដើម្បីកំណត់ស្ថាប័នសំខាន់ៗផងដែរ ដូចជាលក្ខន្តិកៈចៅក្រម ដែលយ៉ាងហោចណាស់អាចធានាបានថា គ្រប់ចៅក្រមទាំងអស់មិនពាក់ព័ន្ធនឹងនយោបាយ និង លក្ខន្តិកៈព្រះរាជអាជ្ញា លក្ខន្តិកៈកងកំលាំងប្រដាប់អាវុធ និងលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខន្តិកៈកងកំលាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិល គួរតែធ្វើវិសោធនកម្ម ដើម្បីកំណត់ថា កងកំលាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិលគ្មានការពាក់ព័ន្ធនឹងនយោបាយ ។ ច្បាប់នគរបាល ក៏ត្រូវធានាថា នគរបាលមិនជាប់ពាក់ព័ន្ធនឹងនយោបាយ។

ច្បាប់ទាំងឡាយ ចាំបាច់ត្រូវអនុម័ត ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរជាក់លាក់មួយចំនួន ដែលបន្តញាំញីសង្គមកម្ពុជា រួមមានច្បាប់ប្រឆាំងអំពើពុករលួយ ច្បាប់ប្រឆាំងការជួយដូរមនុស្ស និង ច្បាប់ប្រឆាំង អំពើហឹង្សាក្នុងគ្រួសារ។ ដើម្បីធានាអោយស្ថានភាពនយោបាយ កាន់តែមានតម្លាភាពជាងមុន ចាំបាច់ត្រូវបង្កើតច្បាប់ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និងច្បាប់ស្តីពីការប្រកាសទ្រព្យសម្បត្តិ ដែលគួរធានាថា គ្រប់រដ្ឋមន្ត្រីទាំងអស់ប្រកាសពីទ្រព្យសម្បត្តិរបស់ខ្លួន មុនពេលចូលកាន់តំណែង ។

ជាចុងក្រោយ ច្បាប់ស្តីពីសមាជជាតិ ចាំបាច់ត្រូវបង្កើតអោយបានឆាប់ ដើម្បីបំពេញការសន្យាដែលចែង នៅក្នុងជំពូក XII នៃរដ្ឋធម្មនុញ្ញ។ តាមរយៈការបង្កលក្ខណៈអោយ" ប្រជាពលរដ្ឋបានទទួលពតិមានដោយផ្ទាល់លើបញ្ហាផ្សេងៗស្តីពីផលប្រយោជន៍ជាតិ និងដើម្បីលើឡើងនូវបញ្ហា និងសំណើផ្សេងៗចំពោះសមត្ថកិច្ចរដ្ឋ ដើម្បីស្នើសុំអោយដោះស្រាយ"

សមាជជាតិមួយនឹងគាំទ្រនូវការពង្រឹងនយោបាយនៅគ្រប់ថ្នាក់របស់សង្គម និងកែលំអការចូលរួមនៅក្នុងជីវិតនយោបាយរបស់ប្រទេស ។

ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ

បើតាមបទពិសោធន៍នៃការបោះឆ្នោតឆ្នាំ២០០៣ ហាក់ដូចជាមានលក្ខណៈសមរម្យក្នុងការពិចារណា ទៅលើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលត្រូវការសំលេងភាគច្រើនធម្មតា ដើម្បីបង្កើតរដ្ឋាភិបាល ។ ភាពជាប់គាំងនយោបាយបច្ចុប្បន្ន ដែលស្រដៀងគ្នាទៅនឹងបទពិសោធន៍នៅក្នុងការបោះឆ្នោត ឆ្នាំ ១៩៩៨ នៅតែបន្តជះឥទ្ធិពលអស្ថេរភាពដល់ប្រទេសកម្ពុជា ។ ប្រសិនបើគ្មានរដ្ឋាភិបាលស្របច្បាប់ និងគ្មានសភាថ្មីមកជំនួសទេនោះ អាជ្ញាធរហាក់ដូចពិបាកនឹងចាត់វិធានការណាមួយប្រកបដោយប្រសិទ្ធភាពណាស់ ។ ជាមួយគ្នានេះដែរ រយៈពេលនៃការបំពេញការងារជានាយករដ្ឋមន្ត្រី គួរតែកំណត់មកនៅត្រឹម ២ អាណត្តិ ។

រដ្ឋធម្មនុញ្ញ គួរតែត្រូវបានធ្វើវិសោធនកម្មផងដែរ ដើម្បីធានាថា ប្រសិនបើរដ្ឋាភិបាលចំរុះមួយត្រូវបានបង្កើតឡើង ហើយគណបក្សនយោបាយមួយលាលែងចេញពីរដ្ឋាភិបាលចំរុះ នៅពេលនោះរដ្ឋាភិបាលត្រូវរលាយ ។

ជាចុងក្រោយ វិសោធនកម្មគួរតែត្រូវបានធ្វើទៅលើមាត្រា ៩៨ នៃរដ្ឋធម្មនុញ្ញ ដោយចែងឱ្យបានច្បាស់ថា សមាជិកសភាចំនួន ៣០រូប មានសិទ្ធិកោះហៅរដ្ឋមន្ត្រី ឬ នាយករដ្ឋមន្ត្រី អោយទៅបំភ្លឺជាសាធារណៈ ចំពោះបញ្ហាណាមួយ ។ ប្រសិនបើរដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី មិនព្រមទៅឆ្លើយបំភ្លឺតាមការកោះហៅរបស់សភាទេនោះ មានន័យថារដ្ឋមន្ត្រី ឬ នាយករដ្ឋមន្ត្រី បានទទួលយកកំហុសរបស់ខ្លួន ហើយកំហុសនេះត្រូវផ្សព្វផ្សាយជាសាធារណៈ ។

ក្រុមសីលធម៌

ប្រសិនបើក្រុមសីលធម៌មានប្រសិទ្ធភាព ជាការចាំបាច់ត្រូវបង្កើតយន្តការមួយនៅសភា និងព្រឹទ្ធសភា ដែលតាមរយៈនេះ សមាជិករាជរដ្ឋាភិបាល សភា និងព្រឹទ្ធសភា អាចត្រូវបានដាក់ទណ្ឌកម្ម ប្រសិនបើពួកគេរំលោភក្រុមសីលធម៌នេះ ។

(iii) អនុសាសន៍ ៖

សង្គមស៊ីវិលមានសុទិដ្ឋិនិយមថាគណបក្សជាប់ឆ្នោតទាំងបីនឹងទទួលយកអនុសាសន៍ខាងក្រោមដើម្បីជាប្រយោជន៍ដល់ប្រទេសជាតិទាំងមូលៈ

- ធ្វើការកែទំរង់ស្ថាប័នដែលមានស្រាប់ ដូចជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ និងគណៈកម្មការសវនកម្ម ដើម្បីធានាអោយស្ថាប័ន ទាំងនេះមានភាពឯករាជ្យ

តម្លាភាព មានសមត្ថភាព ព្រមទាំងពង្រឹងមុខតំណែងស្របច្បាប់របស់ស្ថាប័នទាំងនេះនៅក្នុងរដ្ឋធម្មនុញ្ញ និង បង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ។

- បង្កើតគណៈកម្មការនានា ដូចជាគណៈកម្មការប្រឆាំងអំពើពុករលួយ និងគណៈកម្មការជាតិស្តីពីសិទ្ធិមនុស្ស ដែលមានលក្ខណៈឯករាជ្យ មិនចូលគណបក្សនយោបាយ មានសមត្ថភាព និងគួរអោយជឿទុកចិត្តបាន។
- បង្កើត និងគាំទ្រការឆ្លងនិងអនុម័តនូវច្បាប់ថ្មី តាមរយៈរដ្ឋសភាជាតិ និងព្រឹទ្ធសភា រួមមានក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ច្បាប់ប្រឆាំងអំពើពុករលួយ ច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ និង ច្បាប់ប្រឆាំងការជួញដូរមនុស្ស ។
- បង្កើតច្បាប់ផ្សេងៗ ដើម្បីធានាថាស្ថាប័នសំខាន់ៗ ដូចជាស្ថាប័នតុលាការគ្មានការពាក់ព័ន្ធ នឹងគណបក្សនយោបាយ ។
- បង្កើតច្បាប់ថ្មីៗ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និងការប្រកាសទ្រព្យសម្បត្តិដែលធានាថា គ្រប់រដ្ឋមន្ត្រីត្រូវតែប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនមុនចូលកាន់តំណែង ។
- ធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញដើម្បីគាំទ្រ និងពង្រឹងដំណើរការនៃការបង្កើតរដ្ឋាភិបាល ដែលមានការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យ រួមមានការអនុញ្ញាតអោយមានការបោះឆ្នោតដោយសំលេងភាគច្រើនធម្មតានៅក្នុងការបោះឆ្នោតជាតិ ដើម្បីអាចឱ្យរដ្ឋាភិបាលមួយត្រូវបានបង្កើតឡើង និងកំណត់រយៈពេលកាន់តំណែងជានាយករដ្ឋមន្ត្រីត្រឹមតែ ២ អណត្តិ ។
- បង្កើតយន្តការមួយនៅរដ្ឋសភា និង ព្រឹទ្ធសភា ដើម្បីដាក់ទណ្ឌកម្មទៅលើសមាជិករដ្ឋាភិបាល សភាជាតិ និង ព្រឹទ្ធសភា ក្នុងករណីដែលពួកគេរំលោភលើក្រមសីលធម៌ ។

ចំពោះពត៌មានបន្ថែម សូមទំនាក់ទំនង :

- បណ្ឌិត Kek Galabru, ប្រធាន CHRAC និងជាប្រធាន LICADHO
- Tel: 012 802 506
- លោក ធន់ សារ៉ាយ ប្រធាន ADHOC , Tel: 016 880 509
- លោក សុក សំអឿន ប្រធានអនុកម្មការនីតិកម្ម និងនាយកប្រតិបត្តិ CDP Tel: 012 901 199

អាវុធធុនតូច និង អសន្តិសុខ

(i) សេចក្តីផ្តើម

តាំងពីមានការបញ្ចប់នូវភាពប្រទូស្តរាយរវាងភាគីច្បាំងគ្នាទាំងអស់នៅក្នុងឆ្នាំ ១៩៩៨ មក ប្រទេសកម្ពុជាបានប្រឈមមុខនឹងបញ្ហាពិបាកក្នុងការដោះស្រាយបញ្ហាអាវុធធុនតូចជាច្រើន ដែលមានបន្សល់នៅក្នុងសង្គម។ ចាប់តាំងពីឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានថ្លែងយ៉ាងសកម្មអំពីការរាលដាលនូវអាវុធធុនតូច ដែលបង្ករអោយមានអស្ថិរភាព។ ផ្នែកនេះមិនស្ថិតនៅក្រោមកម្មវិធីយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រឡើយ[៣៤]។ សកម្មភាពអស់ទាំងនេះ ត្រូវបានចាត់ជាផ្នែកធំ៧ដូចខាងក្រោមនេះ:

- ការអនុម័តអនុក្រឹត្យ ៣៨ នៅក្នុងឆ្នាំ ១៩៩៨ ដោយដាក់អោយនៅក្រៅច្បាប់ចំពោះការកាន់កាប់អាវុធដោយជនស៊ីវិល ហើយនឹងមានការប្រមូលអាវុធដ៏ច្រើនសម្បើមនៅក្នុងទីក្រុងភ្នំពេញ
- ការដកអាវុធពីកងជីវពលនៅតាមមូលដ្ឋានដែលបានបង្កើតឡើងក្នុងទិសដៅផ្តល់សន្តិសុខតាមភូមិ-ឃុំ ក្នុងកំឡុងពេលនៃសង្គ្រាម ដែលធ្វើឡើងដោយកងកំលាំងនគរបាល និងយោធា
- សំណើមួយនៅក្នុងឆ្នាំ ១៩៩៩ ដែលបញ្ជូនទៅអោយសហគមន៍អន្តរជាតិ ដើម្បីសុំអោយមានការជួយ ក្នុងការទប់ស្កាត់អាវុធធុនតូច និងអាវុធធុនស្រាល
- បង្កើតអោយមានគណៈកម្មការជាតិកែទំរង់ការគ្រប់គ្រងអាវុធជាតិផ្ទុះនៅកម្ពុជា ក្នុងឆ្នាំ ១៩៩៩
- ការប្រមូលអាវុធប្រមាណជាង ១២០.០០០ ដើម ពីជនស៊ីវិល គិតមកត្រឹមខែមិថុនា ឆ្នាំ ២០០៣
- ធ្វើការកំទេចអាវុធដែលខុសច្បាប់ និង អាវុធដែលលើសចំនួននៅក្នុងកងកំលាំងយោធាប្រមាណជាង ១១២.០០០ ដើម ក្នុងពិធីជាសាធារណៈ ដោយការដុតបំផ្លាញ និងការកិនកំទេច នៅចន្លោះពី ឆ្នាំ១៩៩៩ និង ២០០៣
- ធ្វើសេចក្តីព្រាងច្បាប់ថ្មីស្តីពីអាវុធ និង គ្រឿងផ្ទុះ
- អនុវត្តកម្មវិធីចុះបញ្ជីអាវុធ និងទុកដាក់អាវុធអោយមានសុវត្ថិភាពនៅក្នុងកំលាំង នគរបាល និង យោធា
- អនុវត្តនូវសកម្មភាពផ្សព្វផ្សាយអោយបានទូលំទូលាយ ក្នុងកិច្ចសហប្រតិបត្តិការជាមួយម្ចាស់ជំនួយអន្តរជាតិ និងសង្គមស៊ីវិល

[34] យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

- ដំណើរឆ្ពោះទៅរកការចុះហត្ថលេខាលើសិទ្ធិសញ្ញាហាមប្រាមការជួញដូរអាវុធ

មកទល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាមានការរីកចំរើនគួរអោយកត់សំគាល់ក្នុងយុទ្ធនាការរបស់ខ្លួន ក្នុងការប្រមូល និងបំផ្លាញចោលនូវអាវុធធុនតូច និងសព្វាវុធធុនស្រាល ដែលលើសចំនួន និងខុសច្បាប់ ជាពិសេសសហគមន៏នានាទូទាំងផ្ទៃប្រទេសបានយល់ដឹងពីបញ្ហាអាវុធ ហើយចាប់ផ្តើមយល់ឃើញថា បញ្ហាដែលពាក់ព័ន្ធទៅនឹងអាវុធ និងអំពើហឹង្សា ត្រូវថ្លែងអោយគេដឹងទាំងនៅថ្នាក់មូលដ្ឋានក៏ដូចជានៅថ្នាក់ជាតិ។

ទោះជាយ៉ាងនេះក្តី ការសាយភាយ និងការដែលអាចរកអាវុធធុនតូចមកប្រើប្រាស់បាននោះ នៅតែបន្តជះឥទ្ធិពលជាអវិជ្ជមានដល់សង្គមកម្ពុជា ទាក់ទងនឹងការប្រើប្រាស់វប្បធម៌ហឹង្សា និង និរទណ្ឌភាព។ អសន្តិសុខដែលនៅតែមានជាបន្តនោះ គឺជាឧបសគ្គមួយដល់និរន្តរភាពនៃការអភិវឌ្ឍន៍ ការកាត់បន្ថយភាពក្រីក្រដែលមាន រយៈពេលវែង និងមានឧបសគ្គចំពោះការវិនិយោគទុនបរទេស។ វឌ្ឍនភាពមានលក្ខណៈជាវិជ្ជមានជាខ្លាំង ប៉ុន្តែសកម្មភាពបន្តត្រូវតែរក្សាអោយបាន ដើម្បីធានាអោយជោគជ័យរបស់កម្ពុជានៅគង់វង្សជានិច្ច។

(ii) បញ្ហាគន្លឹះ

<u>ច្បាប់ថ្មី ស្តីពីអាវុធៈ</u> អនុក្រឹត្យលេខ ៣៨ គ្មានលក្ខណៈទូលំទូលាយអោយបានគ្រប់គ្រាន់នោះទេ ដែលបណ្តាលអោយមានសមត្ថកិច្ចមិនគ្រប់គ្រាន់ក្នុងការដាក់ទណ្ឌកម្មទៅលើបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងអាវុធ។ សេចក្តីព្រាងច្បាប់នេះគឺជាដំណោះស្រាយមួយ ប៉ុន្តែត្រូវបន្តរង់ចាំការផ្តល់សច្ចាប័នពីសភាជាតិ។

<u>ការអនុវត្តន៍ច្បាប់អោយមានសមធម៌ៈ</u> ទម្លាប់នៃការមិនដាក់ទោសទៅលើបុគ្គល គ្រួសារ ព្រមទាំងសមាជិករបស់ពួកគេមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរដ្ឋាភិបាលបន្តជ្រួតជ្រាបដល់សង្គម ជាមួយនឹងលទ្ធផលដែលថាបទឧក្រិដ្ឋ ពាក់ព័ន្ធនឹងអាវុធដែលប្រព្រឹត្តឡើងដោយក្រុមនេះ ជារឿយៗមិនត្រូវបានដាក់ទណ្ឌកម្មឡើយ។ លទ្ធផលដ៏សំខាន់មួយនៃនិរទណ្ឌភាពធ្វើអោយមានការខ្វះទំនុកចិត្តក្នុងចំណោមប្រជាពលរដ្ឋធម្មតា លើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាអាវុធធុនតូច និងអំពើហឹង្សា ព្រមទាំងប្រព័ន្ធតុលាការ។

<u>តួនាទីរបស់គណៈកម្មការជាតិកំណែទំរង់ និងការគ្រប់គ្រងអាវុធ និងជាតិផ្ទុះ</u>

គណៈកម្មការជាតិកំណែទំរង់ និងការគ្រប់គ្រងអាវុធនិងជាតិផ្ទុះនៅតែគ្មានសកម្មភាព ដោយសារការខ្វះខាតធនធាន និងខ្វះអាណត្តិការងារ ។

<u>ការគ្រប់គ្រងអាវុធដែលប្រើប្រាស់ប្រចាំថ្ងៃ និងអាវុធខុសច្បាប់ដែលប្រមូលបាន:</u> ការខ្វះខាតនូវឃ្លាំងសំរាប់ទុកដាក់អាវុធអោយមានសុវត្ថិភាព និងការគ្រប់គ្រងមិនបានល្អចំពោះអាវុធ ដែលប្រើការប្រចាំថ្ងៃ ព្រមទាំងអាវុធខុសច្បាប់ដែលបានប្រមូលនោះ បន្តទាមទារអោយអាជ្ញាធរមានសមត្ថភាព ដើម្បីទប់ស្កាត់កុំអោយមានការលេចចេញនូវអាវុធពីឃ្លាំងផ្ទុកអាវុធផ្លូវការ ។ ការអោយខ្ចីដោយគ្មានច្បាប់អនុញ្ញាត ការលក់ ការលួចអាវុធនៅតែជាកង្វល់មួយ ។ កង្វល់ដែលចេះតែកើនឡើងនោះ គឺវត្តមាននៃគ្រឿងផ្ទុះដ៏ច្រើន ដែលប្រមូលពីប្រជាពលរដ្ឋ ហើយត្រូវបានរក្សាទុកនៅក្នុងប៉ុស្តិ៍នគរបាលដែលមិនធានាសុវត្ថិភាព ។

<u>សមត្ថភាពរបស់ភ្នាក់ងារប្រតិបត្តិច្បាប់:</u> កង្វះខាតនូវសំភារៈទំនាក់ទំនង មធ្យោបាយដឹកជញ្ជូន ជំនាញវិជ្ជាជីវៈ (ដូចជាជំនាញខាងតុលាការ) ការយល់ដឹងតួនាទីក្នុងនាមជាមន្ត្រីរាជការមុខងារសាធារណៈ ហើយនិងប្រាក់ខែមិនគ្រប់គ្រាន់បានបន្តធ្វើ អោយកងកំលាំងនគរបាលមានការបាក់ទឹកចិត្តក្នុងការបំពេញតួនាទីរបស់ខ្លួនអោយបានគ្រប់គ្រាន់ ។ បញ្ហានេះរឹតតែធ្ងន់បន្ថែមទៀតដោយសារអំពើពុករលួយ ហើយប្រព័ន្ធតុលាការខ្សោយ ដែលបំរើអោយផលប្រយោជន៍អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋប៉ុណ្ណោះ ។ នគរបាលនៅតាមជនបទគ្មានសិទ្ធិអំណាចដើម្បីតតាំង ប្រឆាំងនឹងក្រុមអ្នកមានអំណាចដែលធ្វើអ្វីៗដោយគ្មានទោសពៃរ៍ ។ ហើយក៏មានការខ្វះខាតផងដែរ នូវទំនាក់ទំនងរវាងនគរបាល និងស្ថាប័នស៊ីវិល ។

<u>សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់លើបញ្ហាសន្តិសុខ:</u> ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានជ្រើសតាំងឡើង ជាលើកដំបូងនៅក្នុងខែកុម្ភៈ ឆ្នាំ២០០២ ប៉ុន្តែទោះជាយ៉ាងនេះក្តី មកទល់ពេលនេះ ពួកគេគ្មានគោលការណ៍ណែនាំ អោយបានជាក់លាក់ស្តីពីសកម្មភាពដែលពាក់ព័ន្ធនឹងសន្តិសុខនៅតាមមូលដ្ឋាន ហើយក៏គ្មានទំនាក់ទំនងជាផ្លូវការណាមួយ ជាមួយនគរបាលថ្នាក់ឃុំនិងស្រុកដែរ ។ បញ្ហានេះវានាំអោយមានការខ្វះខាតនូវការចូលរួមពីសហគមន៍ លើបញ្ហាសន្តិសុខតាមមូលដ្ឋាន ការយល់ច្រឡំជាទូទៅ និងការមិនទុកចិត្តលើកងកំលាំងនគរបាល ។

ការយល់ដឹងពីលក្ខណៈសំខាន់ផ្នែកសន្តិសុខ ដោយអង្គការអន្តរជាតិ: អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិជាច្រើនគ្មានការពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខនៅក្នុងកម្មវិធីរបស់ខ្លួន ដែលជាការគំរាមកំហែងដល់និរន្តរភាពនៃការរួមវិភាគទានលើដំណើរការអភិវឌ្ឍន៍។

ការរំសាយកងទ័ព និងការដកអាវុធ: ការខ្វះខាតនូវផ្នែកដកហូតអាវុធ ហើយនិងការពន្យារពេលទៅលើដំណើរការរំសាយកងទ័ពមានឥទ្ធិពលជាអវិជ្ជមាន ទៅលើកិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយចំនួនអាវុធដែលមាននៅក្នុងដៃបុគ្គលទាំងឡាយ ដែលជាប់ពាក់ព័ន្ធជាមួយយោធា ពីអតីតកាល ឬ បច្ចុប្បន្នកាល។

ការហូរចូលនូវអាវុធធុនតូច(អាវុធខ្លី)ជាច្រើន ជាពិសេសនៅតាមតំបន់ទីក្រុង: ជោគជ័យដ៏ចំបងមួយរបស់អនុក្រឹត្យ ៣៨ ហើយនិងការផ្សព្វផ្សាយជាបន្តបន្ទាប់មកនោះ គឺ ការថយចុះនូវអាវុធបែបយោធា (ឧ. អាកា ៤៧) ដែលមាននៅក្នុងដៃជនស៊ីវិល។ ចំនួនអាវុធដែលកើនឡើង អាវុធដែលអាចរកបាន និងការប្រើប្រាស់អាវុធដែលស្រួលលាក់ទុក (ឧ. កា ៥៤ និង កា ៥៩) ជាពិសេសនៅ តាមទីក្រុងនោះ គឺជាបញ្ហានៃកង្វល់មួយដ៏ធ្ងន់ធ្ងរ ហើយប្រភពនៃការផ្គត់អាវុធបែបនេះក៏ជាកង្វល់ផងដែរ។

(iii) អនុសាសន៍

ច្បាប់អាវុធ

- ក្រុមអ្នកពិគ្រោះយោបល់ រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ គួរតែបំផុសអោយសភាជាតិផ្តល់សច្ចាប័នលើសេចក្តីព្រាងច្បាប់ថ្មី ស្តីពីអាវុធ អោយបានឆាប់តាមដែលអាចធ្វើទៅបាន។
- ក្នុងពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាគួរតែមានការប្តេជ្ញាចិត្តអោយបានខ្លាំងក្លា ក្នុងការពង្រឹងបទបញ្ជាទាំងឡាយដែលពាក់ព័ន្ធនឹងអាវុធដែលមានស្រាប់ ហើយធ្វើការសំដៅរៀបចំបញ្ចប់អនុក្រឹត្យ ដើម្បីអនុវត្ត ទាក់ទងទៅនឹងការនាំចូល នាំចេញ ការដឹកជញ្ជូន ការគ្រប់គ្រង ។ល។ និង ។ល។ ចំពោះច្បាប់ថ្មីនេះ។

ការពង្រឹងច្បាប់អោយមានសមធម៌

រាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើនូវរាល់កិច្ចប្រឹងប្រែងទាំងអស់ តាមដែលអាចធ្វើទៅបាន ដើម្បីធានាអោយមានភាពស្មើគ្នាចំពោះមុខច្បាប់ ចំពោះអ្នកដែលពាក់ព័ន្ធទៅនឹងបទល្មើសដែលមានទាក់ទងនឹងអាវុធ។ ការពង្រឹងច្បាប់អោយបានតឹងរឹង នឹងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើបញ្ហាសន្តិសុខនៅតាមមូលដ្ឋាន និងការយល់ដឹងនៅថ្នាក់ជាតិ។

តួនាទីរបស់គណៈកម្មការជាតិកែទំរង់និងការគ្រប់គ្រងអាវុធ និងជាតិផ្ទុះ

- រាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើការដើម្បីពង្រឹងតួនាទីរបស់គណៈកម្មការជាតិកែទំរង់ការគ្រប់គ្រងអាវុធ និងជាតិផ្ទុះ ជាពិសេស ទាក់ទងទៅនឹងការឆ្លើយតបអោយបានឆាប់រហ័សទៅនឹងបញ្ហាដែលកំពុងកើតមាន ហើយនិងវិធីសាស្ត្រដែលមានការចូលរួមពេញទំហឹងជាមួយទីភ្នាក់ងារទាំងឡាយដែលពាក់ព័ន្ធនឹងការប្រមូលអាវុធ ព្រមទាំងសកម្មភាពកសាង សន្តិភាព។
- រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មការជាតិកែទំរង់ ការគ្រប់គ្រងអាវុធជាតិផ្ទុះ នៅកម្ពុជាគួរបង្កើតនូវកិច្ចប្រឹងប្រែងរួមគ្នាមួយក្នុងការយករំសេវផ្ទុះចេញពីប៉ុស្តិ៍នគរបាល នៅតាមជនបទ។

ការគ្រប់គ្រងអាវុធដែលប្រើប្រាស់ប្រចាំថ្ងៃ និងអាវុធខុសច្បាប់ដែលប្រមូលបាន

- រាជរដ្ឋាភិបាលកម្ពុជាគួរតែបន្តអនុវត្តកម្មវិធីចុះបញ្ជីអាវុធ និង ទុកដាក់អាវុធអោយមានសុវត្ថិភាពទូទាំងផ្ទៃប្រទេស ចំពោះអាវុធដែលប្រើប្រាស់ប្រចាំថ្ងៃទាំងអស់ដែលនៅក្រោមការគ្រប់គ្រងរបស់កងកំលាំងនគរបាល និងយោធា។ អាវុធខុសច្បាប់ទាំងអស់ដែលប្រមូលបានពីជនស៊ីវិល ត្រូវកត់ត្រាទុកមុនពេលយកទៅបំផ្លាញចោលជាសាធារណៈ។

សមត្ថភាពរបស់ភ្នាក់ងារប្រតិបត្តិច្បាប់

- រាជរដ្ឋាភិបាលកម្ពុជាគួរតែស្វែងរកជំនួយបន្តទៅទៀតដើម្បីបង្កើនសមត្ថភាពដល់ភ្នាក់ងារប្រតិបត្តិច្បាប់ (កងកំលាំងនគរបាល) ជាពិសេសនៅក្នុងតំបន់ជនបទ។ គួរសង្កត់ធ្ងន់ជាពិសេសទៅលើសំភារៈសំរាប់បណ្តុះបណ្តាល ទំនាក់ទំនងសហគមន៍ ហើយនិងការចូលរួម ព្រមទាំងក្រមសីលធម៌ប្រកបវិជ្ជាជីវៈសំរាប់មន្ត្រីនគរបាលថ្នាក់ឃុំ និងស្រុក។

សមត្ថភាពក្រុមប្រឹក្សាឃុំ-សង្កាត់លើបញ្ហាសន្តិសុខ

- រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើតគោលការណ៍អោយបានជាក់លាក់នៅក្នុងគំរោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ-សង្កាត់ ចំពោះសកម្មភាពដែលទាក់ទងទៅនឹងសន្តិសុខ។ គួរតែមានការសង្កត់ធ្ងន់ទៅលើការបង្កើតទម្រង់ការស្តីពីទំនាក់ទំនង រវាងក្រុមប្រឹក្សាឃុំ-សង្កាត់ និងនគរបាលឃុំ — ស្រុក ក្នុងទស្សនៈបន្តសកម្មភាពផ្សព្វផ្សាយ និងប្រមូលអាវុធ។
- អង្គការអន្តរជាតិគួរតែធ្វើការប្តេជ្ញាចិត្តជាផ្លូវការមួយ ដើម្បីធ្វើការក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងតំបន់ទិសដៅរបស់ពួកគេលើបញ្ហាសន្តិសុខ។ គោលការណ៍សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់គួរតែបង្កើត វិធីសាស្ត្រផ្តល់សន្តិសុខ ដែលមានការចូលរួមពីសហគមន៍អោយបានពេញទំហឹង តាមដែលអាចធ្វើទៅបាន។
- រាជរដ្ឋាភិបាលកម្ពុជា គួរតែធ្វើការប្តេជ្ញាចិត្តអោយបានពេញទំហឹងដើម្បីធានាសន្តិសុខសំរាប់ពលរដ្ឋគ្រប់រូប ជាពិសេសសំរាប់អ្នកដែលរស់នៅតំបន់ដាច់ស្រយាល។ អាវុធធុនតូច មីន សន្តិសុខផ្លូវកាយ គឺជាបញ្ហាសុខភាពសាធារណៈមួយដ៏សំខាន់សំរាប់ប្រទេសកម្ពុជា ហើយបញ្ហាទាំងនេះត្រូវការដោះស្រាយដូចដែលបានគូស បញ្ជាក់នៅឯកំរិតមូលដ្ឋានដែលមានការគាំទ្រជាប់លាប់ពីអាជ្ញាធរថ្នាក់កណ្តាល។

ការយល់ដឹងពីលក្ខណៈសំខាន់ ផ្នែកសន្តិសុខ ដោយអង្គការអន្តរជាតិ

- រាជរដ្ឋាភិបាលកម្ពុជាគួរតែដាក់សម្ពាធទៅលើអង្គការអន្តរជាតិអោយបញ្ចូលបញ្ហាសន្តិសុខនៅក្នុងការធ្វើគំរោងមេ នៃកម្មវិធីអភិវឌ្ឍន៍ ។
- អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ និងអង្គការអន្តរជាតិគួរតែមានការ ប្តេជ្ញាចិត្តចូលរួមអោយបានពេញទំហឹងក្នុងសកម្មភាពសំរបសំរួលផ្នែកសន្តិសុខនៅក្នុងកម្មវិធីតំបន់គោលដៅ ដោយរាប់បញ្ចូលទាំងការផ្លាស់ប្តូរពតិមានការចូលរួមប្រជុំពីបញ្ហាសន្តិសុខនៅតាមសហគមន៍ ។ល។

ការរំសាយកងទ័ព និងការដកអាវុធ

- រាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក គួរតែធ្វើការក្នុងកិច្ចសហប្រតិបត្តិការអោយបានជិតស្និទ្ធ ដើម្បីចាប់ផ្តើមជាថ្មីនូវដំណើរការរំសាយកងទ័ព នៅក្នុងគំរូមួយដែលមានតម្លាភាព ដោយមានការសង្កត់ធ្ងន់ទៅលើការធានាអោយមានការបញ្ចូលទៅក្នុងសង្គមជាតិវិញនូវកងទ័ព និង ការគ្រប់គ្រងអាវុធ អោយបានជោគជ័យ។

ការហូរចូលនូវអាវុធខ្លីជាច្រើន ជាពិសេសនៅតាមតំបន់ទីក្រុង

រាជរដ្ឋាភិបាលកម្ពុជាគួរតែបញ្ចេញសកម្មភាពអោយបានខ្លាំងក្លាតាមដែលអាចធ្វើទៅបាន ដើម្បីពង្រឹងច្បាប់លើបញ្ហាអាវុធខ្លីនេះនៅក្នុងតំបន់ទីក្រុង ហើយទទូចអោយកងកំលាំងនគរបាល និងកងកំលាំងសន្តិសុខធ្វើការដើម្បីទប់ស្កាត់ការជួញដូរ និងការនាំអាវុធចូល ។

ចំពោះពត៌មានបន្ថែមទាក់ទិននឹងបញ្ហានានាដែលលើកនៅក្នុងអត្ថបទនេះសូមមេត្តាទាក់ទង ក្រុមការងារកាត់បន្ថយអាវុធ ទូរស័ព្ទលេខ (៨៥៥)២៣ ២២២ ៤៦២ Email: WGWR@online.com.kh

វិស័យទេសចរណ៍

(i) សេចក្តីផ្តើម

ប្រទេសកម្ពុជាបានក្លាយជាគោលដៅទេសចរណ៍យ៉ាងឆាប់រហ័ស សំរាប់ភ្ញៀវទេសចរបរទេស ដោយមានចំនួនកើនឡើងពី ៤៦៣ ពាន់នាក់ នៅឆ្នាំ ២០០១ ទៅ ៧៩០ ពាន់នាក់ នៅឆ្នាំ ២០០២។ មិនតែប៉ុណ្ណោះកម្ពុជាក៏មានឈ្មោះល្បីល្បាញ ថាជាគោលដៅថ្មីមួយសំរាប់អ្នករួមភេទជាមួយកុមារ និងភ្ញៀវទេសចរផ្លូវភេទ ដែលកំពុងឆ្លៀតឱកាសពីកំសោយនៃយន្តការអនុវត្តន៍ច្បាប់របស់កម្ពុជា[៣៥]។ បើទោះបីរាជរដ្ឋាភិបាលកម្ពុជា មានផែនការរយៈពេល ៥ ឆ្នាំ ដើម្បីប្រយុទ្ធប្រឆាំងទល់នឹងអាជីវកម្មផ្លូវភេទលើកុមារក៏ដោយ ក៏រាជរដ្ឋាភិបាលបានស្នើសុំការគាំទ្រ តាមរយៈជំនួយអន្តរជាតិ ដើម្បីជួយបំពេញកិច្ចការនេះអោយបានសំរេច[៣៦]។ ភារកិច្ចនេះកាន់តែមានភាពស្មុគ្រស្មាញទៅទៀត ដោយសារការផ្សព្វផ្សាយពត៌មាន និងរូបភាពជាអន្តរជាតិ អំពីលទ្ធភាពដែលអាចរកកុមារបាននៅកម្ពុជា។ ពេស្យាចារកុមារថតរូបម្នាក់ឯង ឬជាមួយបុរសដែលវ័យចំណាស់ជាង បង្ហាញមុខនៅលើសារពត៌មានកាសែត និងទូរទស្សន៍អន្តរជាតិ។ នៅតាមទំព័រអ៊ីនធឺរណែតមានផ្តល់ពត៌មានពិស្តារថាតើត្រូវធ្វើដំណើរទៅកន្លែងណា ត្រូវចំណាយលុយប៉ុន្មាន និងភ័ស្តុតាងពីអតិថិជនមុនៗ។ ក្នុងករណីមួយចំនួន គេបានយកកុមារមកថតវីដេអូ និងរូបភាពអាសអាភាសផ្សេងៗ[៣៧]។ ពត៌មានទាំងនេះកាន់តែទាក់ទាញបុរសច្រើនថែមទៀត អោយធ្វើដំណើរមកកម្ពុជា ក្នុងគោលបំណងស្វែងរកកុមារដើម្បីរួមភេទ។ អ្នកដែលទទួលអត្ថប្រយោជន៍ពីការផ្គត់ផ្គង់ នឹងបំពេញតំរូវការក្នុងស្រុក។ គេក៏សង្កេតឃើញមានតំរូវការកុមារ ពីអ្នកទេសចរក្នុងស្រុកដែរ។ បច្ចុប្បន្ននេះ អង្គការទស្សនៈពិភពលោក (World Vision) កំពុងសហការក្នុងភាពជាដៃគូ ជាមួយក្រសួងមហាផ្ទៃ Unicef និងអង្គការអន្តរជាតិផ្សេងៗទៀត ដើម្បីពង្រឹងការប្រើប្រាស់យន្តការច្បាប់ជាធរមាន មកផ្តន្ទាទោសជនល្មើស និងការពារកុមារ[៣៨]។ បញ្ហាប្រឈមចំពោះអ្នកប្រឆាំងនឹងការធ្វើពាណិជ្ជកម្មកេងប្រវ័ញ្ច ផ្លូវភេទលើកុមារ (CSEC) គឺធ្វើឱ្យមានឥទ្ធិពលដល់ភាគីពាក់ព័ន្ធផ្សេងៗ នៅក្នុងវិស័យទេសចរណ៍ ហើយនិងសហគមន៍ ដើម្បីជំរុញសក្តានុពលរបស់ពួកគេឆ្លើយតបនឹងបញ្ហានេះ ជាគុណប្រយោជន៍ដល់កុមារកម្ពុជាគ្រប់

---

[35] Bertil Lintner, ទំនាក់ទំនងយ៉ាងមានគ្រោះថ្នាក់ ទស្សនាវដ្តី The Far Eastern Economic Review, ខែ មីនា ឆ្នាំ ២០០៣ .

[36] ផែនការ ៥ឆ្នាំ ដើម្បីប្រយុទ្ធប្រឆាំងនឹងអាជីវកម្មផ្លូវភេទលើកុមារ, ក្រុមប្រឹក្សាកុមារជាតិ ឆ្នាំ ១៩៩៩ ។

[37] Children’s Work Adult play, បញ្ហាទេសចរណ៍ផ្លូវភេទលើកុមារនៅកម្ពុជា, World Vision, ក្រសួងទេសចរណ៍ ឆ្នាំ ២០០០

[38] គំរោងអនុវត្តច្បាប់ប្រឆាំងនឹងអាជីវកម្មផ្លូវភេទលើកុមារ ត្រូវបានយល់ឃើញជាអន្តរជាតិថា ជាគំរូនៃកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាព រវាង NGO និង រដ្ឋាភិបាល។ ទំរង់នេះត្រូវបានលើកឡើងនៅក្នុងវេទិកាតំបន់ និងអន្តរជាតិ ដើម្បីដោះស្រាយ CSEC ។

រូប ។ ការងារនេះ រួមមានរាយការណ៍ពីបទឧក្រិដ្ឋប្រឆាំងទល់កុមារ និងធានាអោយអ្នកទាំងឡាយណា ដែលបំពេញការងារក្នុងវិស័យទេសចរណ៍ អាចស្គាល់ដឹង និងដោះស្រាយចំពោះសកម្មភាពអាជីវកម្ម ។

ទេសចរណ៍គឺជាវិស័យសំខាន់មួយ នៃវិស័យសេដ្ឋកិច្ចសំខាន់ៗដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ ដើម្បីលើកកំពស់ការអភិវឌ្ឍន៍ប្រទេសនៅពេលអនាគត ។ ចំនួនភ្ញៀវទេសចរបានកើនឡើងយ៉ាងច្រើន នៅក្នុងប៉ុន្មានឆ្នាំថ្មីៗ នេះ ហើយក៏កើតមានសេវាកម្មទេសចរណ៍ជាច្រើនក្នុងវិស័យឯកជនដែរ ។ នៅឆ្នាំ ២០០២ អង្គការទស្សនៈពិភពលោក សហការជាមួយក្រសួងទេសចរណ៍ និងក្រុមប្រឹក្សាជាតិកម្ពុជាសំរាប់កុមារ បានស្រាវជ្រាវពីបញ្ហាទេសចរផ្លូវភេទលើកុមារ និងបានស្នើឡើងនូវសកម្មភាពជាច្រើន ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាដែលកំពុងកើនឡើងនេះ[៣៩] ។ រដ្ឋាភិបាលអង់គ្លេសបានគាំទ្រអោយមានការបង្កើតគំរោងមួយ ដែលមានរយៈពេល ២ ឆ្នាំ ដើម្បីសហការជាមួយក្រសួងទេសចរណ៍ក្នុងការកសាងសមត្ថភាព ។ គំរោងនេះបានទទួលជោគជ័យ ក្នុងការប្រមូលផ្តុំចំលើយឆ្លើយតបរបស់រដ្ឋាភិបាលជុំវិញបញ្ហាអាជីវកម្មផ្លូវភេទបែប ។ ជាលទ្ធផលនៃរយៈពេល ២ ឆ្នាំដំបូង គឺការបង្កើតឡើងនូវឧបករណ៍ផ្សេងៗសំរាប់ផ្សព្វផ្សាយពត៌មាន ដើម្បីបង្កើនការយល់ដឹងពីកង្វល់នៃការការពារកុមារ នៅក្នុងវិស័យទេសចរណ៍ ពោលគឺកុមារនិងសហគមន៍ ដែលពឹងពាក់ទេសចរណ៍ ធ្វើជាសកម្មភាពសេដ្ឋកិច្ចដ៏ចំបងរបស់ខ្លួន ។ កម្មវិធីបណ្តុះបណ្តាលផ្លូវការមួយត្រូវបានយកមកអនុវត្តនៅក្នុងសិក្ខាសាលាជាច្រើន ដែលសរុបមានមន្ត្រីទេសចរណ៍ជាង ៧០០ នាក់ ។ ការបង្កើតឡើងនូវប្រព័ន្ធនៃការតាមដានត្រួតពិនិត្យសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ មានរចនាសម្ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត ។ ដៃគូអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក បានជួយគាំទ្រ ដល់ការចូលរួមរបស់កុមារ ក្នុងការតស៊ូមតិ ដើម្បីអោយមានការផ្លាស់ប្តូរ នៅក្នុងតំបន់បីដែលជាគោលដៅទេសចរណ៍ ។ សិក្ខាសាលានៅថ្នាក់សហគមន៍ បានលើកកំពស់ការយល់ដឹងពីបញ្ហានេះ និងយន្តការរាយការណ៍ក្នុងចំណោម អ្នកដឹកនាំកុមារនៅថ្នាក់មូលដ្ឋាន ។ យន្តការនេះ នាំអោយមានកំណើនសកម្មរបស់ប៉ូលីស និងការកាត់ទោសជនល្មើស នៅក្នុងតំបន់គោលដៅទេសចរណ៍ទាំងបី ។ ជនល្មើសខ្លះ ត្រូវបានចាប់ខ្លួនព្រមទាំងមានរូបភាពអាសអាភាសយ៉ាងច្រើន[៤០] ។ ទន្ទឹមការចាប់បានបរិមាណដ៏ច្រើន យ៉ាងនេះក៏ដោយ ក៏បញ្ហានៅតែបន្តកើតមានជាមួយភ្ញៀវទេសចរជាច្រើន មានការផ្លាស់ប្តូរពត៌មាន និងរូបថតតាមអ៊ីនធឺណែត និងការបង្ក្រាបនៅក្នុងប្រទេសជាច្រើន ដូចជាប្រទេសថៃ ស្តីអំពីជនល្មើសផ្លូវភេទលើកុមារ ។

[39] Ibid

[40] ករណីបុរសជនជាតិបារាំងម្នាក់ឈ្មោះ Guynot នៅក្រុងព្រះសីហនុ ឆ្នាំ ២០០០, ត្រូវបានចុះនៅក្នុងទំព័រកាសែត Phnom Penh Post ថ្ងៃទី ៨ មិថុនា ២០០១ ។

ការរីកចំរើន

ការរីកចំរើនក្នុងឆ្នាំ ២០០២-២០០៣ នៅក្នុងវិស័យនេះ រួមមានច្បាប់ទេសចរណ៍ (ព្រះរាជក្រឹត្យលេខ ០១៩៦/១៥) ដែលត្រូវបានកំណត់អោយអនុវត្តតាមអនុក្រឹត្យលេខ ២៦ (ឧសភា ២០០០) ស្តីពីរៀបចំតួនាទី និងភារកិច្ច នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានអាស៊ាន នៅក្នុងក្រសួងទេសចរណ៍។

- គណៈកម្មការទេសចរណ៍ដើម្បីការពារសុវត្ថិភាពកុមារចំនួន ៩ ត្រូវបានបង្កើតឡើង នៅក្នុងមន្ទីរទេសចរណ៍ ថ្នាក់ខេត្ត-ក្រុង: ភ្នំពេញ សៀមរាប ក្រចេះ ព្រៃវែង កំពង់ចាម ឧត្តរមានជ័យ ស្វាយរៀង ក្រុងព្រះសីហនុ និងបន្ទាយមានជ័យ ។
- គណៈកម្មការទេសចរណ៍ដើម្បីការពារសុវត្ថិភាពកុមារ របស់ក្រសួងទេសចរណ៍ បានបញ្ចប់វគ្គបណ្តុះ បណ្តាលចំនួន ៧ វគ្គ សំរាប់មន្ត្រីទេសចរណ៍ មគ្គុទេសក៍ ក្រុមហ៊ុនទេសចរណ៍ឯកជន កុមារ និងអប់រំគ្រូបង្រៀន និងអាជ្ញាធរមូលដ្ឋាន ក្នុងសហគមន៍ទេសចរណ៍។ រហូតមកដល់ពេលនេះ មានកម្មសិក្សាការីចំនួន ៣៥០នាក់ ហើយ (ស្រី:២០០ នាក់ និង ប្រុស :១៥០នាក់) ។
- វគ្គបណ្តុះបណ្តាល ៩វគ្គ សំរាប់កុមារ។ មានកុមារចំនួន ៥៦០ នាក់ (ប្រុស:២១០នាក់ និង ស្រី:៣៥០នាក់) ការងារកុមារ (ប្រុស:៣នាក់ និង ស្រី:១០នាក់)។ មានចំនួនសរុបទាំងអស់ ៥៧៣ នាក់ (ប្រុស:២១៣ និង ស្រី: ៣៦០)។ មានលោកគ្រូ ពលរដ្ឋក្រីក្រូចំនួន ៤៨ នាក់ (ពលរដ្ឋក្រីក្រូ: ៣៣ និង លោកគ្រូ:១៥) និង តំណាងមកពីអាជ្ញាធរមូលដ្ឋានចំនួន ៥៥ នាក់ (ប្រុសទាំង ៥៥) ពីបណ្តាសហគមន៍ ទេសចរណ៍ ។
- មានស្ទីកឃើរ ១០.០០០ ផ្ទាំងតូចៗជាបីភាសា ដែលផ្តល់ដំណឹងអំពីទេសចរណ៍ផ្លូវភេទ ត្រូវបានបោះពុម្ព

(ii) បញ្ហាគន្លឹះ

នៅឆ្នាំ ២០០២ គេបានប៉ាន់ប្រមាណថា ចំណូលរូបិយប័ណ្ណបរទេសពីវិស័យទេសចរណ៍ មានចំនួន ៥៧៦ លាន ដុល្លារអាមេរិក ដែលបានផ្តល់ឱកាសការងារដល់មនុស្សជាង ១០០.០០០ នាក់។ ការព្យាករណ៍កំណើនក្នុងវិស័យ ទេសចរណ៍ចំនួន ៣០% បានទស្សន៍ទាយថា នៅឆ្នាំ ២០១០ ចំណូលដោយផ្ទាល់ពីវិស័យទេសចរណ៍ នឹងមានចំនួន ១.៥២៩ លានដុល្លារ។ គេបានប៉ាន់ស្មានថា ការវិនិយោគជាមូលធនលើហេដ្ឋារចនាសម្ព័ន្ធ ពីឆ្នាំ ១៩៩៨-២០០០ មានចំនួនជាង ៣៦២ លានដុល្លារ។ ការវិនិយោគរបស់រាជរដ្ឋាភិបាល លើការបណ្តុះបណ្តាល ការតាមដាន ត្រួតពិនិត្យ និងធានា

ស្តង់ដារសុវត្ថិភាពសំរាប់កុមារ កំពុងអនុវត្ត នឹងតំរូវអោយរាជរដ្ឋាភិបាលកម្ពុជាកំណត់អាទិភាព។ ការខកខានមិនបានធ្វើសកម្មភាព កម្ពុជានឹងត្រូវបានមើលឃើញថា ជាគោលដៅនៃក្តីប្រាថ្នារបស់ជនល្មើសផ្លូវភេទលើកុមារ និងធ្វើអោយមានភាពមន្ទិលសង្ស័យ ទៅលើសេចក្តីថ្លែងការណ៍របស់ឥស្សរៈជននយោបាយជាន់ខ្ពស់ទាំងឡាយ ដែលថា ទេសចរណ៍ផ្លូវភេទលើកុមារ គ្មានទីកន្លែងណាមួយបានលើកទឹកចិត្តនៅកម្ពុជាឡើយ ហើយនិងនៅឆ្ងាយពីទេសចរណ៍វប្បធម៌ និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព។

ជំពូកទី ៣ នៃច្បាប់ទេសចរណ៍ កំណត់ពិស្តារពីប្រភេទមុខជំនួញអ្វីខ្លះ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ ទាំងនេះពោលគឺបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌអាជ្ញាប័ណ្ណសំរាប់ភ្នាក់ងារទេសចរណ៍ និងការអនុវត្តន៍នី។ មាត្រាទី ១៤.៥ ចែងថា ប្រសិនបើអធិការកិច្ចរបស់មន្ត្រីក្រសួងទេសចរណ៍ រកឃើញថាមានការរំលោភលើច្បាប់ព្រហ្មទណ្ឌ ដូចជាពេស្យាកម្មលើកុមារ ពួកគេត្រូវរាយការណ៍ទៅប៉ូលីសជាបន្ទាន់។ មាត្រាទី ១៥ ចែងថា ការលុបចោល ការព្យួរ អាជ្ញាប័ណ្ណ និងការបិទមុខជំនួញ គឺជាសកម្មភាពដែលក្រសួងអាចធ្វើបាន។ បើទោះបីជារាជរដ្ឋាភិបាលសមនឹងទទួលការកោតសរសើរចំពោះក្របខ័ណ្ឌអនុវត្តនេះក៏ដោយ ក៏ទាមទារអោយមានការងារបន្ថែមទៀត ក្នុងការអនុវត្តន៍នីច្បាប់នេះដែរ ។

នាង សុខា ត្រូវបានលក់អោយទៅបរទេសម្នាក់ កាលនាងអាយុបាន ១៣ ឆ្នាំ ដើម្បីជួយគ្រួសារនាងឱ្យមានប្រាក់បង់ថ្លៃព្យាបាលជំងឺ។ ចាប់ពីពេលនោះមក នាងនៅរកស៊ីជាស្រីពេស្យាក្នុងតំបន់ទេសចរណ៍ អស់រយៈពេល ២ ឆ្នាំ រហូតដល់នាងធ្លាក់ខ្លួនឈឺ ហើយក៏គ្មានភ្ញៀវណាត្រូវការនាងទៀតដែរ។ នាងត្រូវបានគេបោះបង់ចោលអោយរស់នៅតាមចិញ្ចើមថ្នល់។ អង្គការទស្សនៈពិភពលោក បានធ្វើការជាមួយនាងអស់រយៈពេលជាង ១ ឆ្នាំ ក្នុងពេលដែលនាងមានមេរោគហ៊ីវ។ នាងបានស្លាប់នៅអាយុ ១៦ ឆ្នាំ ក្នុងទំងន់មិនដល់ ២០ គីឡូផង ។

(iii) អនុសាសន៍

អនុសាសន៍សំរាប់រាជរដ្ឋាភិបាល :

- ក្រសួងទេសចរណ៍ សហការជាមួយគំរោងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ របស់អង្គការទស្សនៈពិភពលោក ECPAT (Child wise Australia) ដើម្បីលើកកំពស់សមត្ថភាពរបស់អ្នកតាមដានត្រួតពិនិត្យ ក្នុងការបំពេញភារកិច្ចរបស់គេប្រកបដោយប្រសិទ្ធិភាព ។

- ត្រូវអោយមានឆន្ទៈនយោបាយ ដើម្បីធានាអោយបទប្បញ្ញត្តិថ្មីៗ ការពារកុមារ និងអាចអនុវត្តទៅបាន។ ដើម្បីសំរេចបាននូវចំណុចនេះ ដំណើរការក្របខ័ណ្ឌការងារផែនការវិកិល ចាំបាច់ត្រូវកំណត់គោលដៅសំរាប់អ្នកតាមដានត្រួតពិនិត្យ ។
- យោងតាមផលប្រយោជន៍សេដ្ឋកិច្ចដែលបានមកពីឧស្សាហកម្មទេសចរណ៍ យើងសូមស្នើថា សមាមាត្រនៃចំណូលទទួលបានពីទេសចរណ៍ ចាំបាច់ត្រូវវិនិយោគឡើងវិញ ទៅក្នុងការបណ្តុះបណ្តាល និងធានាបទដ្ឋានការពារកុមារដែលបានឯកភាពគ្នា ត្រូវបានអនុវត្តដោយវិស័យទេសចរណ៍។ ដំណើរការនេះទាមទារអោយមានការដឹកនាំជាក់ស្តែងកាន់ច្រើនថែមទៀត ពីក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ ដើម្បីធានាថា គឺរដ្ឋាភិបាល មិនមែនតែអង្គការក្រៅរដ្ឋាភិបាលទេ តំណាងអោយកុមារលើបញ្ហាទាំងនេះ។ ទង្វើនេះ អាចមានជាទំរង់ការនៃការផ្តល់ថវិកាកំណត់គោលដៅ និងកិច្ចព្រមព្រៀងជាមួយទីភ្នាក់ងារគន្លឹះ នៅក្នុងវិស័យឯកជន ដើម្បីអោយឧស្សាហកម្មនេះ និងបុគ្គលគ្រប់រូបមានការទទួលខុសត្រូវ ។
- ត្រូវផ្តល់ធនធានអោយគណៈកម្មការសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ថ្នាក់ខេត្ត ដើម្បីបំពេញមុខងារតួនាទីរបស់ខ្លួន ។
- តាមដានត្រួតពិនិត្យ និងអនុវត្តលក្ខខណ្ឌសំរាប់ការផ្តល់អាជ្ញាប័ណ្ណមុខជំនួញទេសចរណ៍ ដើម្បីការពារកុមារអោយរួចផុតពីការប្រើប្រាស់ក្នុងពេស្យាកម្ម ។
- ធ្វើការសន្យាផ្តល់ហិរញ្ញវត្ថុ ដើម្បីការពារកុមារ ស្របទៅនឹងការយល់ព្រមរបស់ខ្លួន ចំពោះក្រមទេសចរណ៍អាស៊ាន ។
- ក្រសួងទេសចរណ៍ ត្រូវបង្កើតក្រុមតាមដានត្រួតពិនិត្យ ស្តីអំពីការអនុវត្តន៍ក្រមឧស្សាហកម្ម នៅតាមវិស័យជំនួញទេសចរណ៍ឯកជន ។
- អនុម័ត និង ពង្រឹងច្បាប់ជាតិ ប្រឆាំងទល់នឹងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ រួមមានយុត្តាធិការច្បាប់ក្រៅប្រទេស និងបទប្បញ្ញត្តិទាំងឡាយ ដែលអនុញ្ញាតអោយធ្វើការកាត់ទោសជនជាតិខ្លួនបានពីបទល្មើសផ្លូវភេទលើកុមារ ដែលបានប្រព្រឹត្តនៅក្រៅប្រទេស និងធានាអោយមានការអនុវត្តន៍ន៍ច្បាប់ទាំងនេះយ៉ាងតឹងតែង។
- ចុះកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីសំរួលដល់ការធ្វើបត្យាប័ន ការជួយគ្នាទៅវិញទៅមក ឬកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ នៅក្នុងការស្រាវជ្រាវនៃការកាត់ទោសបុគ្គលទាំងឡាយណា ដែលពាក់ព័ន្ធនឹងការជួញដូរ និងអាជីវកម្មផ្លូវភេទលើកុមារ ។

- តែងតាំងក្រុមទំនាក់ទំនង នៅក្នុងរដ្ឋបាលទេសចរណ៍ជាតិ ដែលនឹងធ្វើសហការជាមួយ នាយកដ្ឋានរដ្ឋាភិបាលពាក់ព័ន្ធ និងគណៈកម្មការជាតិ ដើម្បីបង្កាការពារការធ្វើអាជីវកម្មផ្លូវភេទ លើកុមារ និងអនុវត្តវិធានការជាក់ស្តែងនានា ដើម្បីជួយការពារកុមារ ដូចជាបង្កើតខ្សែទូរស័ព្ទទំនាក់ទំនងផ្ទាល់ និងទំនាក់ទំនងភ្លាមៗ។
- រៀបចំយុទ្ធនាការជាតិលើកកំពស់ការយល់ដឹងទូទៅ ប្រឆាំងនឹងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ ដោយសហការ និងសហប្រត្តិការជាមួយឧស្សាហកម្មទេសចរណ៍ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងទ្រទ្រង់យុទ្ធនាការទាំងនេះ ដោយផ្តល់នូវកម្មវិធីបណ្តុះបណ្តាល ដល់មន្ត្រីទេសចរណ៍ និង
- បញ្ចូលបទប្បញ្ញត្តិស្តីពីការការពារការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ ទៅក្នុងផែនការមេស្តីពីទេសចរណ៍ជាតិ ។

អនុសាសន៍សំរាប់ប្រទេសម្ចាស់ជំនួយ :

- លៃយ៉ាងណាអោយមូលនិធិសំរាប់ទ្រទ្រង់ដល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដូចជាអាកាសយានដ្ឋាន ត្រូវមានបទប្បញ្ញត្តិផងដែរសំរាប់ប្រឆាំងទល់នឹងផលវិបាកអវិជ្ជមានមកលើសង្គម ដែលអាចប៉ះពាល់ដល់កុមារ ដូចជាភ្ញៀវទេសចរផ្លូវភេទជាដើម។
- ប្រគល់ជូនរាជរដ្ឋាភិបាលទទួលខុសត្រូវ ចំពោះការគ្រប់គ្រងវិស័យទេសចរណ៍របស់ខ្លួននៅកម្ពុជា ក្នុងផលប្រយោជន៍នៃការគោរពតាមកិច្ចសន្យាការពារកុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលដៅសហស្សវត្សរ៍ពិភពលោក។
- ប្រគល់ជូនរាជរដ្ឋាភិបាលទទួលខុសត្រូវ ចំពោះការគ្រប់គ្រងចំណូលសារពើពន្ធរបស់ខ្លួន ដែលបានមកពីទេសចរណ៍យកទៅវិនិយោគសារឡើងវិញ ដើម្បីកែលំអគុណភាព។ សារៈសំខាន់ចំបងនោះ គឺកាត់បន្ថយឱកាស មិនអោយកុមារទទួលគ្រោះថ្នាក់ ពីសកម្មភាពដែលពាក់ព័ន្ធនឹងទេសចរណ៍។ កុមារពុំមែនជាទំនិញសំរាប់ទិញដូរឡើយ ហើយកង្វះខាតការឆ្លើយតបពីរាជរដ្ឋាភិបាល ឬប្រទេសម្ចាស់ជំនួយ ចំពោះស្ថានភាពដែលកុមារត្រូវបានគេលក់ដូរនោះ គឺជាការធ្វេសប្រហែសមួយ ។
- លៃយ៉ាងណាអោយមានការតាមដានត្រួតពិនិត្យ លើផលវិបាកសង្គមជាអវិជ្ជមាន នៃកម្មវិធីហេដ្ឋារចនាសម្ព័ន្ធ ឬកម្មវិធីកែតំរូវរចនាសម្ព័ន្ធ ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងផ្តល់មូលនិធិ។
- ធានាគាំទ្រអង្គការក្រៅរដ្ឋាភិបាល ឬក្រុមអង្គការសង្គមស៊ីវិលស្រាវជ្រាវ និងតាមដានត្រួតពិនិត្យ លើបញ្ហាដែលកំពុងកើតឡើង។

អនុសាសន៍សំរាប់អង្គការក្រៅរដ្ឋាភិបាល :

- អង្គការក្រៅរដ្ឋាភិបាលដែលកំពុងផ្តល់ជំរើសក្នុងការបណ្តុះបណ្តាល សំរាប់ប្រជាជនកម្ពុជាដែលចូលទៅក្នុងទីផ្សារការងារទេសចរណ៍ ត្រូវបញ្ចូលសមាសភាគសុវត្ថិភាពកុមារ ឬសំភារៈបណ្តុះបណ្តាលអោយ មានការយល់ដឹងពីកុមារក្នុងវិស័យទេសចរណ៍។ ពួកគេត្រូវតែគាំទ្រគំនិតផ្តល់សុវត្ថិភាពដល់កុមារ នៅពេលដែលពួកគេបណ្តុះបណ្តាលអ្នកដទៃ ។
- អង្គការក្រៅរដ្ឋាភិបាលដែលបំរើការងារ សំដៅលើកកំពស់ការការពារកុមារ ត្រូវប្រើប្រាស់ខ្សែទូរស័ព្ទ របស់ប៉ូលីសដែលបំរើការ ២៤ ម៉ោង (ទូរស័ព្ទ ០២៣ ៧២០ ៥៥៥) ដើម្បីរាយការណ៍នូវរាល់ករណីណាមួយ ដែលពួកគេសង្ស័យថា មានភ្ញៀវទេសចរ ឬទីកន្លែងទេសចរណ៍ណាមួយ កំពុងរំលោភផ្លូវភេទលើកុមារ ។

ចំពោះពត៌មានបន្ថែមពាក់ព័ន្ធបញ្ហាលើកឡើងក្នុងរបាយការណ៍នេះ សូមទំនាក់ទំនងជាមួយ: Laurence Gray, World Vision ទូរស័ព្ទលេខ : ៨៥៥ (០)២៣ ២១៦០៥២ Email: laurence_gray@wvi.org

នយោបាយពាណិជ្ជកម្ម

(i) សេចក្តីផ្តើម

ផ្នែកមួយនៃយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ (NPRS) គឺការអភិវឌ្ឍន៍ពាណិជ្ជកម្ម ដែលស្របនឹង " យុទ្ធសាស្ត្រពាណិជ្ជកម្មដើម្បីកាត់បន្ថយភាពក្រីក្រ " របស់ក្រសួងពាណិជ្ជកម្ម។ ឱកាសនៃការពិភាក្សាជាច្រើនស្តីអំពីនយោបាយនេះ ក៏ត្រូវបានធ្វើឡើងរវាងសមាជិកជាច្រើន របស់ក្រសួងពាណិជ្ជកម្ម ទាំងតាមរយៈដំណើរការនៃការរៀបចំ NPRS និងរួមទាំងក្រៅដំណើរការនេះ ក៏ប៉ុន្តែក៏មិនទាន់មានការពិភាក្សាជាសាធារណៈអោយបានពេញ លេញនៅឡើយទេ ។

ការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) របស់កម្ពុជា ត្រូវបានប្រកាសឡើងនៅ កង់គួននាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីពាណិជ្ជកម្ម កាលពីខែ កញ្ញា កន្លងទៅនេះ។ ការចូលជាសមាជិកយ៉ាងលឿននេះ គឺជាគោលការណ៍ជាសារវ័ន្តរបស់ក្រសួងពាណិជ្ជកម្ម ប៉ុន្តែយើងមិនទាន់អាចដឹងច្បាស់ថា សមាជិកភាពនៅក្នុង WTO នេះ នឹងអាចកាត់បន្ថយភាពក្រីក្របានដែរឬយ៉ាងណា។ ឯកឧត្តម ចមប្រសិទ្ធ បានមានប្រសាសន៍អំពីសន្និសញ្ញាចូល ជាសមាជិកនោះថា

> *"នេះគឺជាកញ្ចប់នៃសម្បទាននិងកាតព្វកិច្ចមួយដែលមានលក្ខណៈដាច់ឆ្ងាយពីអ្វីដែលស្មើនឹងកំរិតនៃការអភិវឌ្ឍន៍របស់ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ដូចជាប្រទេសកម្ពុជា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវទទួលយកនូវឧបសគ្គ ទាំងនេះព្រោះយើងមើលឃើញពីផលប្រយោជន៍យ៉ាងច្រើននៃការចូលរួមនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក "*

យើងនៅតែមិនទាន់ដឹងច្បាស់ថា តើផលប្រយោជន៍ទាំងនោះគឺជាអ្វីនៅឡើយ។ ជាការពិតណាស់ថា មិនទាន់មានការវិភាគពីផលប៉ះពាល់ផ្នែកសង្គម និងភាពក្រីក្រមុននិងក្រោយ.... ដើម្បីទស្សន៍ទាយទុកអោយបានប្រសើរ ទាំងផលវិបាកជាវិជ្ជមាន និងផលវិបាកអវិជ្ជមាននៃយុទ្ធសាស្ត្រពាណិជ្ជកម្ម ព្រមទាំងធានាអោយផលប្រយោជន៍ទាំងអស់តំរង់ទិសចំពោះពលរដ្ឋក្រីក្រីក្របំផុត " ដូចមានសន្យានៅក្នុង NPRS ។

(ii) បញ្ហាគន្លឹះ

តំរូវការនៃការពិភាក្សានិងវិភាគនយោបាយ

ទោះបីជាមានការប្តេជ្ញាចិត្តថា " នឹងធ្វើការវិភាគពីផលប៉ះពាល់ផ្នែកសង្គម និងភាពក្រីក្រមុននិងក្រោយ " ទៅលើយុទ្ធសាស្រ្តនេះក៏ដោយ វាជាការដែលគួរអោយសោកស្តាយ ដែលសន្ធិសញ្ញាចូលជាសមាជិក WTO ត្រូវបានចរចាដោយគ្មានការវិភាគបែបនេះឡើយ។ NPRS ទទួលស្គាល់ថា មានផលប៉ះពាល់ទាំងផ្នែកអវិជ្ជមាន និងវិជ្ជមានផងដែរ នៅក្នុងសំណើយុទ្ធសាស្រ្តពាណិជ្ជកម្មនោះ។ សេចក្តីព្រាងឯកសារទស្សនទាននរបស់ធនាគារពិភពលោក សំរាប់ការត្រួតពិនិត្យនយោបាយអភិវឌ្ឍរបស់ខ្លួន ស្តីពី " ប្រភពនៃកំណើន និងការកាត់បន្ថយភាពក្រីក្រ " ក៏បានចង្អុលបង្ហាញថា " គេសង្ឃឹមថាប្រទេសកម្ពុជានឹងក្លាយជាសមាជិក WTO នៅក្នុងឆ្នាំនេះ ដែលនឹងនាំមកទាំងឧបសគ្គ និងឱកាសផងដែរ " ។

ទោះបីជាយ៉ាងណាក៏ដោយ ចំណុចអវិជ្ជមាននិងវិជ្ជមានទាំងនេះ មិនទាន់ត្រូវបានវិភាគឬពិភាក្សានៅឡើយ ហើយសន្ធិសញ្ញាស្តីពីការចូលជាភាគី WTO នឹងត្រូវដាក់ស្នើទៅសភាជាតិ ដែលនឹងត្រូវផ្តល់សច្ចាប័នតាមមូលដ្ឋាននៃ ការ " ទទួលយក ឬលុបចោល " ។ ជាការពិតណាស់ថា នឹងមានសំពាធយ៉ាងខ្លាំង ដើម្បីអោយសភាជាតិផ្តល់សច្ចាប័ន ប៉ុន្តែនៅក្នុងសន្ធិសញ្ញានេះ មានចំណុចជាច្រើនដែលត្រូវពិភាក្សាដេញដោល ស្របទៅតាមការប្តេជ្ញាចិត្តអំពីការអភិវឌ្ឍន៍ពាណិជ្ជកម្ម នៅក្នុង NPRS ។

ជាឧទាហរណ៍ NPRS ចែងថា " ត្រូវគិតគូរពិចារណាពីវិធានការនានា ដើម្បីកាត់បន្ថយអតិថរណា (ការឡើងចុះតំលៃ) ឬដើម្បីការពារផលិតករក្រីក្រ(ឬអ្នកប្រើប្រាស់ក្រីក្រ) អោយចៀសផុតពីផលប៉ះពាល់នៃការឡើងចុះតំលៃនេះ។ ឧទាហរណ៍ការកាត់បន្ថយពន្ធគយជាដំណាក់ៗដោយប្រុងប្រយ័ត្នការឧបត្ថម្ភកធន និងវិធានការបំពេញបន្ថែមផ្សេងៗទៀត "។ ផ្ទុយទៅវិញ ប្រទេសកម្ពុជាត្រូវតែឯកភាពនៅក្នុងសន្ធិសញ្ញាចូលជាភាគី WTO របស់ខ្លួនជាមុនថា ខ្លួននឹងលុបបំបាត់ការឧបត្ថម្ភកធន ដើម្បីនាំចេញផលិតផលកសិកម្មក្នុងកំរិត 0%[៤១] ។ ដោយហេតុថា ប្រទេសកម្ពុជាមិនដែលធ្វើការឧបត្ថម្ភកធនសំរាប់ផលិតផលកសិកម្មពីមុនមក។ អ្នកចរចារបស់ប្រទេសកម្ពុជានៅឯ WTO មិនបានយល់ព្រមចំពោះបទប្បញ្ញត្តិនេះទេ ដោយអះអាងថា តាមកិច្ចព្រមព្រៀងស្តីពីកសិកម្ម បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច (LDC) មិនបានតំរូវអោយបំពេញកាតព្វកិច្ចណាមួយ ចំពោះការឧបត្ថម្ភធនក្នុងការនាំចេញឡើយ។ តែទោះបីជាយ៉ាងនេះក៏ដោយ បន្ទាប់ពីមានសំពាធឥតឈប់ឈរមក ប្រទេសកម្ពុជាក៏បានយល់ព្រមតាមសំណើ។ ចំពោះអត្រាពន្ធគយ ក្នុងកំឡុងពេលចរចាចូលសមាជិកភាព WTO កម្ពុជាត្រូវបង្ខំចិត្តកាត់បន្ថយសំណើរបស់ខ្លួនពីដំបូង ក្នុងអត្រាពន្ធគយមធ្យមពី ២៥%

[41] WT/ACC/SPEC/KHM/4/Rev.1, 19 June 2003

មកនៅត្រឹមក៏រិត ២២.១៣% ដែលជាអត្រាទាបបំផុតសំរាប់ប្រទេស LDC ។ ចំណែកឯពន្ធគយដែលមានអត្រាខ្ពស់វិញ ប្រទេសកម្ពុជា ដែលជាប្រទេសមួយមានប្រជាជន ៨០% ជាកសិករនោះ ត្រូវបានស្នើអោយផ្តល់ជូនចំពោះវិស័យកសិកម្មដ៏សំខាន់របស់ខ្លួន ដោយមានការការពារតិចតួចបំផុត បើប្រៀបធៀបទៅនឹងសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប និងប្រទេសកាណាដា ។ NPRS ក៏បានលើកឡើងពី " ការសិក្សាវិនិច្ឆ័យពីការប្រកួតប្រជែងពាណិជ្ជកម្ម របស់ប្រទេសកម្ពុជា " ដែលត្រូវបានធ្វើឡើងដោយមាន " ជំនួយពីប្រទេសផ្តល់ជំនួយនៃក្រុម " ក្របខ័ណ្ឌសមាហរណកម្ម" (IMF ITC UNCTAD UNDP WB និង WTO)។ ការសិក្សានេះផ្តោតលើ " ការវិវត្តន៍នៃនយោបាយពាណិជ្ជកម្ម ...និងការជ្រើសរើសការសិក្សាតាមវិស័យ...."។ ម៉ាទ្រីសស្តីពីតំរូវការជំនួយបច្ចេកទេស សំរាប់តំរង់ទិសពាណិជ្ជកម្ម ចំពោះពលរដ្ឋក្រីក្រ ត្រូវបានកសាងឡើង និងបានកំណត់ពីគោលនយោបាយ កម្មវិធី និងគំនិតផ្តួចផ្តើមក្នុងការកសាងសមត្ថភាពជាច្រើន និងតំរូវការធនធានសំរាប់បំពេញចំណុចទាំងនេះ "។ បើទោះបីជាការសិក្សានេះ លើកឡើងនូវទិសដៅតាមផ្នែកមួយចំនួន ដែលមានសារៈសំខាន់ជាសក្តានុពល សំរាប់ប្រទេសកម្ពុជាក៏ដោយ ក៏យើងមិនជឿជាក់ទាំងស្រុងចំពោះកិច្ចខិតខំប្រឹងប្រែងណាមួយ ដើម្បីភ្ជាប់ទំនាក់ ទំនងរវាងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការកាត់បន្ថយភាពក្រីក្រនោះឡើយ។ ទោះជាតាមរូបភាពណាក៏ដោយ ក៏យើងមិនអាចនិយាយបានថា " ការវិភាគពីផលប៉ះពាល់ផ្នែកសង្គម និងភាពក្រីក្រមុននិងក្រោយ " មានភាព គួរអោយជឿជាក់បានឡើយ។

កញ្ញា ស្រី ទូច មានអាយុ ២៣ ឆ្នាំ មានស្រុកកំណើតនៅខេត្តព្រៃវែង។ នាងបានមករស់នៅភ្នំពេញ ហើយកំពុងធ្វើការនៅក្នុងរោងចក្រកាត់ដេរមួយ អស់រយៈពេល ៣ ឆ្នាំហើយ។ នាងមិនចូលចិត្តការងារនេះ ឬជីវភាពរស់នៅរបស់នាងទេ ហើយនាងតែងតែមានជំងឺជារឿយៗ និងនឹកអាល័យដល់ស្រុកកំណើត។ ប៉ុន្តែ នាងនៅតែបន្ត ធ្វើការ និងរកប្រាក់ផ្ញើទៅគ្រួសារនាងនៅឯស្រុក។

នាងចាប់ផ្តើមធ្វើការនៅក្នុងរោងចក្រ ព្រោះឪពុកម្តាយនាងមានការលំបាកក្នុងរកប្រាក់ចិញ្ចឹមគ្រួសារ។ នាងនៅ ចាំឪពុកនាងប្រាប់ថា " កាលពីមុន នៅពេលដែលឯងនៅតូច ពុកម៉ែអាចធ្វើស្រូវបានគ្រប់គ្រាន់ទុកហូប ហើយ លក់ស្រូវដែលនៅសល់ខ្លះទៅថៅកែស្រូវ ប៉ុន្តែនៅពេលនេះ ការធ្វើស្រែត្រូវចំណាយប្រាក់ច្រើនខ្លាំងពេក "។ កញ្ញា ស្រី ទូច ប្រាប់ថា នាងគ្រាន់តែអាចចាំបានថាគ្មានស្រូវគ្រប់គ្រាន់ប៉ុណ្ណោះ ហើយពេលខ្លះដោយសារតែ គ្រួសាររបស់នាងត្រូវយកស្រូវមួយភាគ អោយទៅថៅកែលក់ជីដាក់ស្រែ ដើម្បីសងចំពោះជីដែលបានខ្ចី។ នាងបន្ថែមថា នៅពេលខ្លះ

គ្រួសារនាងត្រូវលក់ស្រូវយ៉ាងច្រើន ទើបគ្មានស្រូវហូបគ្រប់គ្រាន់ ព្រោះថា " បងប្រុសខ្ញុំឈឺ ហើយត្រូវយកគាត់ទៅមន្ទីរពេទ្យ "។ នៅពេលមួយទៀតនោះ គឺបណ្តាលមកពីគ្រួសារនាងមិនបានទទួលផលទាល់តែសោះ ដោយសារភាពរាំងស្ងួតអូសបន្លាយវែងពេក។ នាងនៅចាំថា " បើទោះជាគ្រួសារនាងបានខ្ចីប្រាក់គេ ដើម្បីចំណាយលើការបូមទឹកក៏មិន ដែលបានគ្រប់គ្រាន់ដែរ ហើយភាពរាំងស្ងួត បានធ្វើអោយស្រូវងាប់អស់នៅក្នុងរដូវនោះ ហើយយើងក៏ខ្វះស្រូវ និងរស់នៅដោយក្តីអស់សង្ឃឹមគ្រប់ពេលវេលា។

" ដូច្នេះហើយ នៅពេលដែលខ្ញុំឮថា មាននារីម្នាក់មកភ្នំពេញដើម្បីធ្វើការនៅក្នុងរោងចក្រនោះ ខ្ញុំនិងម្តាយខ្ញុំបានទៅសាកសួរពត៌មាន តើត្រូវធ្វើដូចម្តេចដើម្បីអោយលុយគេខ្លះដើម្បីបានការងារធ្វើ នៅក្នុងរោងចក្រ។ ចំពោះបញ្ហានេះ គ្រួសារខ្ញុំបានខ្ចីប្រាក់គេយ៉ាងច្រើន ...ប្រហែលជា ១០០ ដុល្លារអាមេរិក។ គឺក្រោយពេលនេះហើយ ទើបខ្ញុំបានត្រៀមខ្លួន និងយល់ថា ខ្ញុំត្រូវធ្វើការដើម្បីជួយពួកគាត់អោយរួចផុតពីក្តីអស់សង្ឃឹមនេះ "។

" នៅពេលនេះ គ្រួសារខ្ញុំអាចរស់បានតែដោយសារប្រាក់ដែលខ្ញុំផ្ញើជូនគាត់តែប៉ុណ្ណោះ។ ខ្ញុំមានការលំបាកយ៉ាងខ្លាំងដែលខ្ញុំត្រូវហូបត្រីម្តងគត់ ក្នុងមួយសប្តាហ៍។ ខ្ញុំឈឺព្រោះខ្ញុំហូបអាហារមិនល្អ និងធ្វើការធ្ងន់ ព្រោះថា ប្រសិនបើយើងមិនបានដេរខោអាវអោយបានមួយសំរាប់ទេ យើងមិនបានប្រាក់ទេ ព្រោះថាគេគិតប្រាក់ ឱ្យលើតែចំនួនសំរាប់ដែលយើងបានដេរ "។

កញ្ញា ស្រី ទូច ប្រាប់ថា នៅពេលណាដែលគ្រួសារនាងមានស្រូវខ្លះលក់ ស្រូវនោះមានតំលៃទាបយ៉ាខ្លាំង ព្រោះស្រូវមកពីប្រទេសវៀតណាម ឬប្រទេសថៃ បានធ្វើអោយតំលៃស្រូវកម្ពុជាចុះថោក។ ប៉ុន្តែ ជីមកពីប្រទេសហ្វីលីពីន ឬអាមេរិក មានតំលៃខ្ពស់យ៉ាងខ្លាំង ហើយប្រភេទពូជស្រូវថ្មីៗ ពឹងផ្អែកលើការប្រើជីយ៉ាងខ្លាំង។

នាងក៏បាននិយាយថា នាងនៅតែប្រឹងប្រែងរកប្រាក់ ព្រោះនាងដឹងថា ចំពោះស្រី ទូច ធ្វើការក្នុងរោងចក្រមិនមែនជាការងាយស្រួលឡើយ ហើយនាងមិនអាចធ្វើការក្នុងរោងចក្ររហូតទេ។ " នៅពេលណាដែលខ្ញុំឈឺខ្លាំង ខ្ញុំមិនហ៊ានទៅជួបគ្រូពេទ្យទេ ព្រោះខ្ញុំគ្មានប្រាក់នៅសល់ដើម្បីចំណាយទេ។ ខ្ញុំមិនដែលទៅចូលរួមពិធីអាពាហ៍ពិពាហ៍ ឬលំហែកាយទេ ព្រោះថានេះជាការចំណាយលុយឥតប្រយោជន៍ នៅពេលដែលឪពុកម្តាយរបស់ខ្ញុំត្រូវការប្រាក់ពីខ្ញុំ។ ខ្ញុំមានការភ័យខ្លាចបាត់បង់ការងារយ៉ាងខ្លាំង។ មនុស្សជាច្រើននិយាយថា រោងចក្រទាំងអស់នឹងបិទទ្វារក្នុងពេលឆាប់ៗនេះ ហើយប្រសិនបើបិទមែននោះ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេ ព្រោះឪពុកម្តាយខ្ញុំ នឹងស្លាប់បើខ្ញុំមិនអាចជួយផ្គត់ផ្គង់ពួកគាត់ទេ។ ស្រីៗជាច្រើនក៏ភ័យខ្លាចបាត់បង់ការងារដែរ។ ការភ័យខ្លាចនេះបណ្តាលមកពីក្តីបារម្ភណ៍ដូចគ្នា គឺគ្រួសាររបស់គេ នឹងរស់នៅដោយក្តីអស់សង្ឃឹម បើគ្មានប្រាក់ផ្ញើទៅអោយទេ "។

តំរូវការដោះស្រាយចំណាយខ្ពស់ ក្នុងការធ្វើជំនួញនៅកម្ពុជា

រាជរដ្ឋាភិបាលគួរទទួលបាននូវការសារទរ ចំពោះការប្តេជ្ញាចិត្តច្បាស់លាស់របស់ខ្លួន នៅក្នុង NPRS ដើម្បីដោះស្រាយឧបសគ្គនានាចំពោះពាណិជ្ជកម្ម ដែលបណ្តាលមកពីអំពើពុករលួយ។ ផ្នែកមួយដែលស្តីពីការអភិវឌ្ឍន៍ពាណិជ្ជកម្ម លើកឡើងថា " ការិយាធិបតេយ្យ និងអំពើពុករលួយបន្តកើតមាន " ក្នុងវិស័យកម្មន្តសាលក្នុងស្រុក ហើយថា " ចំណាយក្នុងការដឹកជញ្ជូនក្នុងស្រុកមានតំលៃខ្ពស់ ដោយហេតុថាហេដ្ឋារចនាសម្ព័ន្ធមានគុណភាពទាប និងការទារយកប្រាក់ក្រៅផ្លូវការ ចំពោះការប្រើប្រាស់ផ្លូវ (មានរហូតដល់ ១៧% នៃចំណាយដឹកជញ្ជូនសរុប) "។ ផ្នែកនេះក៏លើកឡើងអំពី " ភាពកំសោយនៅក្នុងប្រព័ន្ធច្បាប់តុលាការ និងរដ្ឋបាល" ផងដែរ។ យើងមើលឃើញយ៉ាងច្បាស់នៅក្នុងឯកសារ ថា ឧបសគ្គទាំងនេះត្រូវបានលើកយកមកដោះស្រាយ ហើយយើងក៏មានការពេញចិត្តដែរ ដោយឃើញថាធនាគារពិភពលោកបានសង្កត់ធ្ងន់ទៅលើការដោះស្រាយបញ្ហាទាំងនេះនៅក្នុងឯកសារត្រួតពិនិត្យ នយោបាយអភិវឌ្ឍន៍របស់ខ្លួន ដែលបានលើកឡើងខាងលើ។

(iii) អនុសាសន៍

អនុសាសន៍សំរាប់រាជរដ្ឋាភិបាល :

- ផ្តល់ឱកាសអោយមានការពិភាក្សាដេញដោលគ្នាជាសាធារណៈ អំពីជំរើសផ្សេងៗនៃនយោបាយពាណិជ្ជកម្ម។
- ធានាអោយមានការពិភាក្សាអោយបានពេញលេញ អំពីសទ្ធិសញ្ញាចូលជាភាគី WTO នៅសភាជាតិ។
- ធានាថារោងចក្រផលិតសំល្បៀកបំពាក់ទាំងអស់ ដែលកំពុងវិនិយោគលើកំលាំងពលកម្មរបស់ខ្លួន តាមរយៈការផ្តល់ឱកាសក្នុងការបណ្តុះបណ្តាល។
- បន្តលុបបំបាត់អំពើពុករលួយជាជំហានៗ ដោយហេតុថាវាជាឧបសគ្គមួយនៃការធ្វើជំនួញនៅកម្ពុជា ។
- សូមស្នើយ៉ាងទទូចអោយប្រើប្រាស់ថវិកាមួយផ្នែកធំ នៃថវិកាជំនួយ ក្នុងការផ្តល់ឱកាសអោយស្ត្រី និងបុរសក្រីក្រជាជាងផ្តល់អោយ " អ្នកជំនួយបច្ចេកទេស " បរទេសដែលមានតំលៃខ្ពស់។

អនុសាសន៍សំរាប់ប្រទេសផ្តល់ជំនួយ :

- ធានាអោយ " ជំនួយបច្ចេកទេស " អំពីនយោបាយពាណិជ្ជកម្ម រួមបញ្ចូលនូវការវិភាគច្បាស់លាស់ អំពីអ្វីដែលទំនងជាផលប៉ះពាល់លើភាពក្រីក្រ និងស្នើឡើងនូវជំរើសនយោបាយផ្សេងៗ ជាជាង ផែនការយុទ្ធសាស្ត្រនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។
- វិនិយោគលើធនធានមនុស្សកម្ពុជា ពោលគឺមានតែស្ត្រីនិងបុរសក្រីក្រខ្លួនគេផ្ទាល់ទេ ដែលជាអ្នករំដោះខ្លួនគេអោយរួចផុតពីភាពក្រីក្រ ដូចជាការទទួលបាននូវចំណេះវិជ្ជា និងការបណ្តុះបណ្តាលសមស្រប ។

អនុសាសន៍សំរាប់អង្គការក្រៅរដ្ឋាភិបាល :

- ដូចអនុសាសន៍ទីពីរខាងលើសំរាប់ប្រទេសផ្តល់ជំនួយ
- ធានាអោយបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលយល់ដឹងពីទំនាក់ទំនងរវាងជំរើសនៃនយោបាយម៉ាក្រូសេដ្ឋកិច្ច និងលទ្ធផលនៃនយោបាយទាំងនោះ នៅថ្នាក់មូលដ្ឋាន។
- ជួយសំរួលដល់ផលិតករក្រីក្រ ដើម្បីអោយគេអាចបង្កើត និងប្រើប្រាស់ឱកាសថែមទៀត ដើម្បីអោយទីផ្សារឆ្លើយតបទៅតាមគោលបំណងរបស់គេ ។

ចំពោះពត៌មានបន្ថែមពាក់ព័ន្ធបញ្ហាលើកឡើងក្នុងរបាយការណ៍នេះ សូមទំនាក់ទំនងជាមួយ: Mike Bird ឬ Khorn Dinravy នៅ Oxfam GB (ទូរស័ព្ទលេខ : ០២៣ ៧២០០៣៦ Email: mbird@oxfam.org.kh) ឬ Rosanna Barbero ឬ Sam Vuthy នៅ Womyns Agenda for Change (ទូរស័ព្ទលេខ : ០២៣ ៧២២៣១៤ Email: rosanna@oxfam.org.kh)